# ព្រះចេតិយតម្កល់សារីរិកធាតុ នៅប្រទេសកម្ពុជា



រៀបរៀងដោយ ខ្ញុំព្រះករុណាអាត្មាភាព

ភិក្ខុ ភទ្ទបណ្ឌិតោ ផូ សុភ័ក្ត្រ

ព.ស. ២៥៦៧ - គ.ស. ២០២៤

# សំវេជនីយដ្ឋានទាំងប្រាំកន្លែង




**លុម្ពិនី**
(កន្លែងព្រះអង្គទ្រង់ប្រសូត)




**ចេតិយពុទ្ធគយា**
(កន្លែងព្រះអង្គទ្រង់ត្រាស់ដឹង)




**ធម្មេក្ខស្តូប**
(កន្លែងព្រះអង្គទ្រង់សម្តែងធម្មចក្ក)




**មហាបរិនិព្វានស្តូប**
(កន្លែងព្រះអង្គទ្រង់បរិនិព្វាន)



**មកុដពន្ធនចេតិយ**
(កន្លែងបូជាព្រះសរីរៈរបស់ព្រះពុទ្ធ)

# សេចក្ដីជូនដំណឹង

*ខ្ញុំព្រះករុណាអាត្មាភាព សូមទូលពិតថា បើព្រះករុណាលោកម្ចាស់ និងពុទ្ធបរិស័ទដែលមានព្រះចេតិយតម្កល់ព្រះសារីរិកធាតុ ដែលមិនទាន់ឃើញមានក្នុងសៀវភៅនេះ ប្រាថ្នាចង់ដាក់ចូលដើម្បីទុកជាប្រវត្តិសាស្ត្រដល់កូនចៅជំនាន់ក្រោយ សូមទំនាក់ទំនងញោមវត្ត ខ្ញុំព្រះករុណា និងដាក់ប្រគេន ជូនៗ សៀវភៅនេះ មិនទាន់បានបោះពុម្ពនៅឡើយ ព្រោះខ្វះខាតនូវតម្លៃ, ប្រសិនបើញាតិញោមជាពុទ្ធស័ទមានសទ្ធាជ្រះថ្លាចង់ចូលរួមក្នុងការជួយបោះពុម្ពសៀវភៅនេះ សូមទំនាក់ទំនងតាមរយៈ ញោមវត្ត(វេយ្យាវច្ចក)*

*ឧបាសិកា* ***ហម ឌី*** 011 566 446

*ឧបាសិកា* ***ហាវ សុគន្ធ*** 096 206 7422

*ខ្ញុំករុណាអាត្មាភាព* 096 449 8243 (Telegram: Pho Sopheak)

*សូមសាធុជនប្រុសស្រីទាំងឡាយ មេត្តាចូលរួមតាមសទ្ធាជ្រះថ្លារៀងៗខ្លួន ៕*

*សូមអរព្រះគុណ និអរគុណ*

# ព្រះចេតិយ តម្កល់ព្រះសារីរិកធាតុ
# នៅប្រទេសកម្ពុជា



**ព្រះគោតមចេតិយ វត្តមហាវ័នគិរីរម្យចាស់**
**រៀបរៀងដោយៈ**

*ភិក្ខុ ភទ្ទបណ្ឌិតោ ផូ សុភ័ក្ត្រ*

*ព.ស. ២៥៦៧ _ គ.ស. ២០២៤*

# គន្ថានិទ្ទេស

- ឈ្មោះសៀវភៅ : ព្រះចេតិយតម្កល់ព្រះសារីរិកធាតុ នៅប្រទេសកម្ពុជា
- អ្នករៀបរៀង : ភិក្ខុ ភទ្ទបណ្ឌិតោ ផូ សុភ័ក្រ្ត
- ទីកន្លែងរៀបរៀង : វត្តមហាវ័ន "គីរីរម្យចាស់"
- អ្នកជួយពិនិត្យផ្ទៀងផ្ទាត់ : លោកម្ចាស់គ្រូ ទីឃរតោ វី សាលឿត និង លោកគ្រូ នាគ ទី, កន្ដេ ពឹល សីហា ភិក្ខុ ផាត សុផាវ, ភិក្ខុ ប៉ែត បញ្ញា

***ធម្មទានរូបត្ថម្ភកដន: ភិក្ខុ សាមណេរ និងពុទ្ធបរិសទ្ទទូទៅ***

## អ្នកជួយខ្វលខ្វាយក្នុងការទារធម្មទាន

- ឧបាសិកា: ហម ឌី
- ឧបាសិកា: ហាវ សាវុធ
- ឧបាសិកា: ហាវ សុគន្ធ
- លោក: ជឿន ចាន់ណា

- កាលបរិច្ឆេតបោះពុម្ព: ថ្ងៃទី... ខែ... ឆ្នាំ២០២៤
- បោះពុម្ពលើកទី ១ : ចំនួន ១០០០ក្បាល សម្រាប់ជាធម្មទាន
- ខ្នាតសៀវភៅ : A5 (14.85cm x 21cm)

# អារម្ភកថា

*ជាបឋមខ្ញុំព្រះករុណា សូមធ្វើសេចក្តីរាប់អានចំពោះករុណាលោកម្ចាស់ និងញាតិញោមប្រុសស្រីទាំងឡាយ, សៀវភៅ "**ព្រះចេតិយតម្កល់ព្រះសារីរិកធាតុនៅប្រទេសកម្ពុជា**" ដែលលោកអ្នកកំពុងអាននេះ ជាវណ្ណកម្មថ្មីមួយដែលខ្ញុំព្រះករុណារៀបរៀងឡើង ដើម្បីជាក្បួនច្បាប់សម្រាប់សិក្សាអំពីប្រវត្តិសាស្ត្រ ដែលជាប្រយោជន៍ដល់អ្នកសិក្សាទូទៅ។*

*អ្នកសិក្សាច្បាស់ជាដឹងហើយថា ប្រទេសខ្មែរយើង ជាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាមួយ ដែលមានអាយុកាលយូរលុងមកហើយ, ក្នុងសម័យបុរាណនោះ ព្រះពុទ្ធសាសនាមានការរីកចម្រើនណាស់ ។*

*ឯការសាងសង់ស្ថាបត្យកម្មវិញ ព្រះរាជាជំនាន់មុនទ្រង់កសាងប្រាង្គប្រាសាទដោយច្រើនដើម្បីតម្កល់រូបអាទិទេពក៏មាន សម័យខ្លះទៀតក៏ ព្រះរាជាកាន់ព្រះពុទ្ធសាសនា បានប្តូររូបអាទិទេព ដាក់ព្រះពុទ្ធរូបវិញក៏មាន។*

*រីឯព្រះចេតិយវិញមិនសូវឃើញមានទេ លុះសម័យក្រោយមកទៀត ទើបព្រះរាជាទ្រង់កែទម្រង់ប្រាសាទទាំងនោះឱ្យទៅជាចេតិយ និងកសាងព្រះកោដិបញ្ចុះព្រះសារីរិកធាតុក្នុងទីនោះ។*

*នាកាលសម័យបច្ចុប្បន្ននេះ អ្នកកាន់ព្រះពុទ្ធសាសនាប្រមាណ ៩៥ភាគរយ ដែលមានវត្តអារាមប្រមាណជាង ៥,០០០វត្ត ព្រះសង្ឃប្រមាណជា ៧០.០០០ អង្គ។*

*ក្នុងនោះផងដែរ វត្តដែលមានការកសាងព្រះចេតិយតម្កល់ព្រះបរម-សារីរិកធាតុនៅតាមខេត្តនានា មានកម្រិតនៅឡើយ ពីព្រោះប្រទេស*

យើងទើបតែអភិវឌ្ឍ។

ខ្ញុំព្រះករុណា សូមខន្តីអភ័យទោសរាល់កំហុសទាំងឡាយដោយចេតនាក្តី និងអចេតនាក្តី។

ដោយអំណាចនៃបុណ្យកុសលទាំងឡាយដែលខ្ញុំករុណាបំពេញហើយ មានការកសាងសៀវភៅមួយនេះជាដើម សូមបុណ្យកុសលទាំងនោះ ជាឧបនិស្ស័យធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន និងទីបំផុតនៃទុក្ខ សូមបានសម្រេចនូវព្រះអរហន្តទ្រង់ព្រះនាមថាព្រះមាល័យទេវថេរ ក្នុងខាងមុខនោះហោង៕

ថ្ងៃច័ន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

១១.០៩.២០២៣

ភិក្ខុកទ្ទបណ្ឌិតោ ផូ សុភ័ក្ត្រ សមណៈសិស្ស

វត្ត**មហាវ័ន**"គិរីរម្យចាស់"

# មាតិកា ទំព័រ

អារម្ភកាថា .................................................... 1

មាតិកា .................................................... 3

គាថាសម្រាប់នមស្ការព្រះធាតុចេតិយ និងពាក្យចេតិយ ....................14

១. មហាចេតិយឧណ្ណាលោម ភ្នំពេញ ....................22

២. ព្រះចេតិយនៅលើភ្នំសន្ទុក កំពង់ធំ ....................24

៣. ព្រះចេតិយ ប្រាសាទនគរបាជ័យ ....................26

៤. ព្រះចេតិយ វត្តព្រះធាតុ ត្បូងឃ្មុំ ....................28

៥. ព្រះពុទ្ធប្រាង្គ វត្តប្រាង្គឧដុង្គ កំពង់ស្ពឺ ....................30

៦. ព្រះចេតិយ វត្តព្រះធាតុ ភ្នំពេញ ....................32

៧.ព្រះចេតិយ វត្តព្រះពុទ្ធឃោសាចារ្យ រាជធានីភ្នំពេញ ....................34

៨. ព្រះចេតិយ វត្តបទុមវតីរាជវរារាម ....................36

៩. ព្រះចូឡាមណីចេតិយ វត្តគិរីរតន ភ្នំយ៉ាត ....................38

១០. ព្រះវិហារ ដូចប្រាសាទ វត្តសន្តិវ៉ែន ....................40

១១. ព្រះចេតិយ វត្តមហានន្ទិយារាម ....................42

១២. ព្រះសក្យមុនីចេតិយ រាជធានីភ្នំពេញ ....................44

១៣. ប្រាសាទ ឬចេតិយ កសាងពីដីឥដ្ឋ ....................46

១៤. ព្រះសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ....................48

១៥. ព្រះគោតមចេតិយ វត្តមហាវ័ន "គិរីរម្យចាស់" ........................................50

១៦. ព្រះសក្យមុនីចេតិយ វត្តធុតង្គ "ចំការដូង" ............................................52

១៧. ព្រះចេតិយមហាឧទ្ទេសកចេតិយ វត្តសុវណ្ណគីរីរតនៈ "ភ្នំប្រុស" ..............54

១៨. ព្រះត្រៃរតនចេតិយ វត្តនិគ្រោធវ័ន "គល់ទទឹង" ......................................56

១៩. ព្រះសក្យមុនីចេតិយ វត្តព្រៃកស្ដី ..........................................................58

២០. ព្រះបរមចេតិយ វត្តសិរីឧត្ដម "ស្រះជុំអណ្ដូងក្ដី" .....................................60

២១. ព្រះមហាគន្ធកុដិ ខេត្តបាត់ដំបង .........................................................62

២២. ព្រះគន្ធកុដិ វត្តអាស្រមព្រះគន្ធកុដិ.........................................................64

២៣. ព្រះមុនិរាជចេតិយ វត្តរស្មីសោភណារាម "សន្ទុង"..................................66

២៤. ព្រះពុទ្ធចេតិយ វត្តចំបក់មានជ័យ .........................................................68

២៥. ព្រះបរមចេតិយ វត្តវេឡុវ័ន "ព្រៃឫស្សី" ..................................................70

២៦. ព្រះគន្ធកុដិ វត្តដំណាក់.........................................................................72

២៧. ព្រះសុគន្ធកុដិ វត្តរស្មីសាមគ្គី រតនារាម....................................................74

២៨. ព្រះបទុមចេតិយ វត្តមណីរតនារាម .......................................................76

២៩. ព្រះគន្ធកុដិ  វត្តសុវណ្ណបទុម "ចំបក់មាស" .............................................78

៣០. ព្រះសក្យមុនីចេតិយ វត្តបទុមសាគរ ......................................................80

៣១. ព្រះមហាចូឡាមណីចេតិយ ឧទ្យានជាតិ "គិរីរម្យ" .................................82

៣២. ព្រះសុវណ្ណចេតិយ វត្តស្រះមុជ្ជលិន្ទ "កោះត្រើង" ..................................84

៣៣. បទុមធម្មចក្កពោធិព្រឹក្សព្រះចេតិយ "ព្រៃសារញាណ" ..........................86

៣៤. ព្រះគោតមចេតិយ (ព្រះគន្ធកុដិ) វត្តអង្គពណ្ណរាយណ៍ ..........................88

៣៥. ព្រះចេតិយ ភូមិក្រាំងស្វាយ ..........................90

៣៦. ព្រះបរមរតនចេតិយ វត្តហ្លួងស៊ីសុវត្ថិរតនារាម ..........................92

៣៧. ព្រះពុទ្ធង្គចេតិយ វត្តបទុម ..........................94

៣៨. ព្រះគន្ធកុដិ ឬព្រះចេតិយ វត្តនន្ទសាលវ័ន "ទួលប្រាសាទ" ..........................96

៣៩. មហាប្រាសាទព្រះគន្ធកុដិ វត្តវេឡុវ័ន ..........................98

៤០. ព្រះពុទ្ធមុនីចេតិយ វត្តមជ្ឈិមវ័ន ..........................100

៤១. ព្រះគន្ធកុដិ វត្តនិគ្រោធារាម "ធាំធា" ..........................102

៤២. ព្រះសក្យមុនីចេតិយ វត្តពោធិរាម្មា ..........................104

៤៣. ព្រះចេតិយ វត្តធម្មសាមគ្គីពង្រ ..........................106

៤៤. ព្រះចេតិយ វត្តព្រហ្មមានជ័យ ..........................108

៤៥. ព្រះចេតិយ វត្តច័ន្ទស៊ីសាមគ្គីរតនារាម ..........................110

៤៦. ព្រះគន្ធកុដិ វត្តវិសុទ្ធិមគ្គ ..........................112

៤៧. ព្រះគន្ធកុដិ វត្តភ្នំអណ្ដើក ..........................114

៤៨. ព្រះមហាមុនីចេតិយ អម្ពវ័ន វត្តព្រៃស្វាយ ..........................116

៤៩. មកុដពន្ធនចេតិយ វត្តគិរីបរវង្សមានជ័យ ..........................118

៥០. សម្ពហៈចេតិយ ឯកឧត្តម ម៉ុង ឬទ្ធី ..........................120

៥១. ព្រះបរមកេសធាតុចេតិយ "ពុទ្ធមណ្ឌលវិបស្សនា"...............................122

៥២.សង្ឃិត្ថរចេតិយ ថូបារាមចេតិយ និងចេតិយពុទ្ធគយា នៅវត្តប្រាសាទស្រះកណ្តាលខ្ពស់.........................................................................................124

៥៣.បូជនីយដ្ឋានសង្ឃិត្ថរចេតិយ ឬស្វេដាហ្គូន ............................................126

៥៤.ព្រះមហាចេតិយពុទ្ធគយា ព្រះមហាពោធិព្រឹក្ស ..................................128

៥៥.ព្រះចេតិយ វត្តប្រាសាទឥន្ទ្រា "វត្តគោកប៉ាទ្រី"......................................130

៥៦. ព្រះគន្ធកុដិ វត្តសាលវង្សិយារាម "វត្តស្រះវង្សី "...................................132

៥៧.ព្រះចេតិយនេះ កំពុងកសាងនៅ ភូមិព្រៃស្នៀត ..................................134

៥៨.ព្រះចេតិយ វត្តបភាវត្យារាម "គគរ .....................................................136

៥៩. ព្រះមហាមុនីចេតិយ វត្តព្រះនាង .......................................................138

៦០.ពុទ្ធគយាចេតិយ វត្តទឹកវិល...............................................................140

៦១. ព្រះចេតិយ វត្តកែវកេសរមុនី "វត្តបន្ទេច" ..........................................142

៦២. ព្រះចេតិយ វត្តជេតពន "វត្តត្រី"..........................................................144

៦៣. ព្រះចេតិយ វត្តភ្នំសន្ទូច ......................................................................146

៦៤. ព្រះគន្ធកុដិ វត្តគិរីបញ្ចបុប្ផារាម "វត្តបាណន់"........................................148

៦៥. ព្រះចេតិយ វិទ្យាល័យសម្តេចឪ ..........................................................150

៦៦. ព្រះបរមចេតិយ វត្តមុនីរតនា "អន្លង់ថ្ងាន់"............................................152

៦៧. ព្រះចេតិយ វត្តភ្នំទទា ........................................................................154

៦៨. ព្រះចេតិយ វត្តព្រះវិហារធំ ........................................................ 156

៦៩. ព្រះគន្ធកុដិ វត្តគោសិង្គសាលវ័ន "វត្តព្រៃគោ" ........................................ 158

៧០. ព្រះសក្យមុនីចេតិយ វត្តពោធិ៍សាល "វត្តអំពិល" .................................. 160

៧១. ព្រះចូឡាមុនីចេតិយ វត្តវាល ........................................................ 162

៧២. ព្រះចេតិយ វត្តប្រាំបីឆោម ........................................................ 164

៧៣.ព្រះចេតិយវត្តឧត្តមសាគរ "ហៅវត្តព្រៃកក្របៅ" ...................................... 166

I- បកិណ្ណកៈរឿងអំពីព្រះចេតិយផ្សេងៗ .................................................. 168

១.ព្រះអង្គទ្រង់បញ្ញត្តវត្ត អាវាសិកភិក្ខុ ................................................... 168

២.ការទទួលព្រះកោដ្ឋមាសមិនគួរ ........................................................ 169

៣.ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយ គួរប៉ះវត្ថុអនាមាសបាន ................................ 170

៤.ភិក្ខុដែលនាំដំណឹង ដែលសមគួរ របស់ពួកគ្រហស្ថបាន .................................. 171

៥.ពេលដែលគួរឱ្យផ្លែឈើជាដើម ដល់គ្រហស្ថ .............................................. 172

៦.ការបដិបត្តិក្នុងពុទ្ធបូជា (ការថ្វាយដល់សង្ឃពីរចំណែក) ................................ 173

៧.សម្មុទ្ទចក្កវត្តិចេតិយកថា (ពោលអំពីរឿងព្រះចេតិយ) .................................. 175

៨.សម្មជ្ជនានិសំសកថា (រឿងព្រះបុស្សទេវថេរ បោសសម្អាតទីលានព្រះចេតិយ មាររមករំខាន) ........................................................................ 180

៩.រឿងព្រះទត្តភិក្ខុកំលោះ បោសសម្អាតទីលានព្រះចេតិយ បានសម្រេចមគ្គផល ...................................................................... 184

១០.រឿងតិស្សភិក្ខុនៅក្នុងជម្ពូលោកវិហារ .................................................. 185

១១.រឿងព្រះមហាថេរៈ ២ រូប បានសម្រេចឈានសមាបត្តិ ..........................186

១២.រឿងភិក្ខុធ្វើវត្តបដិបត្តិចំពោះព្រះចេតិយ និងព្រះពោធិព្រឹក្ស ទេវតាបូជាផ្កាទិព្វ ..........................................................................................................187

១៣.រឿងព្រះអភយត្ថេររូបស្អាត ..................................................................188

១៤.ការសាងចេតិយ........................................................................................191

១៥.ទោសនៃការមិនទៅព្រះចេតិយ.............................................................194

១៦.បុគ្គលអ្នកទំលាយចេតិយ មានទោសស្មើអនន្តរិយកម្ម..........................195

១៧.បូជនីយដ្ឋានដែលមានក្នុងទេវលោក នឹងព្រហ្មលោក...........................197

១៨.វិនិច្ឆ័យការលួចទ្រព្យដែលជាបូជនីយវត្ថុ (ចេតិយអវហរណវិនិច្ឆ័យ)......198

១៩.ទោសនៃការលួចពុទ្ធបូជា ធម្មបូជា នឹងសង្ឃបូជាជាដើម ......................201

២០.កាលបានទាន់សាសនាព្រះសិអាមេត្រីសម្ពុទ្ធ និងមិនទាន់ .....................201

២១.រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល...................................203

២២.រឿងបុព្វកម្មរបស់ព្រះអង្គ (ផលនៃការកសាងព្រះចេតិយព្រះបច្ចេកពុទ្ធជាដើម).....................................................................................................208

២៣.រឿងនាងសេសវតី...................................................................................224

២៤.រឿងនាគទេវបុត្រ....................................................................................228

២៥.រឿងអាយលម្ពាយចាប់ពស់....................................................................230

២៦.រឿងនាងកាញ្ចនទេវី ...............................................................................231

២៧.រឿងឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ ....................................................234

២៨.រឿងគហបតិប្រេត ............................................................................237

២៩.រឿងព្រះបាទអជាតសត្រូវសម្លាប់បិតា នឹងទោសនៃការពាក់ស្បែកជើងឡើងព្រះចេតិយ (សង្ខេប) ..........................................................................239

៣០.រឿងអភ័យចោរ..................................................................................241

II- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៥៥ ខ្លះៗ .................................244

១.គុត្តិលវិមាន(ផលនៃការប្រស់ព្រំគ្រឿងក្រអូបទៅលើព្រះស្តូបព្រះពុទ្ធកស្សប). ....244

២.វិសាលក្ខិវិមាន(ផលនៃការបូជាព្រះស្តូប) ...................................................244

៣.បិតវិមាន(ផលនៃការបូជាផ្កានទោងព្រៃ ចំពោះព្រះស្តូប)........................246

៤.ចូឡរថវិមាន(ផលនៃការបូជាព្រះសរីរធាតុព្រះពុទ្ធជាម្ចាស់) .....................248

៥.អនេកវណ្ណវិមានផលនៃការថ្វាយបង្គំព្រះចេតិយកែវ)................................249

៦.សុនិក្ខិត្តវិមាន(ផលនៃការរៀបចំផ្កាកម្រងតម្កល់ព្រះស្តូប) ........................250

III- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧២ ខ្លះៗ ...............................252

១.មហាកស្សបត្ថេរាបទាន (ផលនៃការកសាងវិមាន) ...................................252

២.បិលិន្ទវច្ឆត្ថេរាបទាន (ផលនៃការបូជាព្រះស្តូបព្រះសុមេធៈសម្ពុទ្ធ) ............255

៣.ឧបវាណត្ថេរាទាន (ផលនៃការថ្វាយទង់ ចំពោះព្រះស្តូបព្រះទុមុត្តរៈសម្ពុទ្ធ) ..........................................................................................................256

៤.ធូបទាយកត្ថេរាបទាន (ផលនៃការបូជាធូប ក្នុងព្រះកុដិព្រះសិទ្ធត្ថៈសម្ពុទ្ធ) ..........................................................................................................262

៥.មហាកច្ចាយនត្ថេរាបទាន (ផលនៃការធ្វើចេតិយ និងការលាបទឹកមាសជាដើម).....262
៦.អាយាគទាយកត្ថេរាបទាន (ផលនៃការថ្វាយបង្គំព្រះស្តូប និងការធ្វើពេងសម្នាក់).....265
៧.កប្បរុក្ខិយត្ថេរាបទាន (ផលនៃការដាំដើមកប្បព្រឹក្ស និងព្យួរនូវសំពត់ដ៏វិចិត្រ).....266
៨.សុភទ្ទត្ថេរាបទាន (ផលនៃការបូជាទង់ដ៏វិចិត្រចំពោះព្រះស្តូប ).....267
៩.ចន្ទត្ថេរាបទាន (ផលនៃការធ្វើរចេតិយ ស្រោបដោយផ្កាម្ទិះ).....268
១០.នាគសមាលត្ថេរាបទាន (ផលនៃការបូជាផ្កាដែលរើសតាមផ្លូវធំ).....270
១១.សុធាបិណ្ឌិយត្ថេរាបទាន (ផលនៃការជួសជុលចេតិយព្រះសិទ្ធត្ថៈសម្ពុទ្ធ).....271
១២.គន្ធមាលិយត្ថេរាបទាន (ផលនៃការកសាងព្រះស្តូប ប្រកបដោយគ្រឿងក្រអូប).....272
IV- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៣ ខ្លះៗ.....273
១.បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន (ផលនៃការធ្វើព្រះស្តូប បញ្ចុះព្រះសារីរិធាតុ).....273
២.ញាណសញ្ញកត្ថេរាបទាន (ផលនៃការឃើញផ្នូកខ្សាច់).....274
៣.អធិចត្តិយត្ថេរាបទាន (ផលនៃការធ្វើឆត្ររួតដាក់ត្រង់ព្រះស្តូប).....275
៤.ថម្ភារោបកត្ថេរាបទាន (ផលនៃការធ្វើដងទង់ ត្រង់ព្រះចេតិយ).....276
៥.វេទិការកត្ថេរាបទាន (ផលនៃការសាងខឿនព្រះចេតិយ).....277

៦.សបរារិយត្ថេរាបទាន (ផលនៃការកសាខឿនខ្ទឹមចន្ទន៍ ថ្វាយធូប និងគ្រឿងក្រអូបដល់ព្រះស្តូប) ....................................................................278
៧.ឧម្មាបុប្ផិយត្ថេរាបទាន (ផលនៃការយកផ្កាទៅដោតលើព្រះស្តូប).............278
៨.បញ្ចង្គុលិយត្ថេរាបទាន (ផលនៃការបូជាផ្កាកម្រងក្នុងព្រះគន្ធកុដិ)...........279
៩.ខណ្ឌផុល្លិយត្ថេរាបទាន (ផលនៃការសម្អាត និងជួសជុលព្រះស្តូប)..........280
១០.ជគតិការកត្ថេរាបទាន (ផលនៃការជម្រះផែនដីត្រង់កន្ទែងព្រះស្តូប).......281
១១.កុដិធូបកត្ថេរាបទាន (ផលនៃការបង្ហុយផ្សែងអប់ក្នុងកុដិព្រះសិទ្ធត្ថៈសម្ពុទ្ធ) .....281
១២.ធាតុបូជកត្ថេរាបទាន (ផលនៃការបូជាព្រះធាតុព្រះសិទ្ធត្ថៈសម្ពុទ្ធ) .........282
V- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៤ ខ្លះៗ................................285
១.អាសនត្ថវិកត្ថេរាបទាន (ផលនៃការអញ្ជលីសរសើរព្រះសិខីសម្ពុទ្ធ)...........285
២.បុន្នាគបុប្ផិយត្ថេរាបទាន (ផលនៃការយកផ្កាបុន្នាគ ធ្វើជាព្រះស្តូបលើផ្នូកខ្សាច់)..286
៣.បកង្គុរត្ថេរាបទាន (ផលនៃការសម្អាតព្រះស្តូបក្នុងព្រៃ) ...........................287
VI- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៥ ខ្លះៗ................................290
១.សោណ្ណកឹកណិយត្ថេរាបទាន (ផលនៃការធ្វើព្រះស្តូប លើផ្នូកខ្សាច់).........290
២.ធាតុបូជកត្ថេរាបទាន (ផលនៃការបូជា ព្រះធាតុព្រះសិទ្ធត្ថៈសម្ពុទ្ធ)...........292
៣.បុឡិនថូបិយត្ថេរាបទាន (ផលនៃការ ធ្វើបុឡិនចេតិយ) ...........................293
៤.ពោធិសម្មជ្ជកត្ថេរាបទាន (ផលនៃការរើសស្លឹកពោធិដែលជ្រុះ ចេញពីលានចេតិយ).............................................................................................296

៥.លកុណ្ឌកភទ្ទិយត្ថេរាបទាន (ផលនៃការធ្វើព្រះស្តូបកម្ពស់ ៧យោជន៍ដោយកែវ ៧ប្រការ)......299

VII- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៦-៧៧ ខ្លះៗ......302

១.មេខលទាយិកាថេរិយាវាបទាន (ផលនៃការធ្វើព្រះស្តូប និងថ្វាយខ្សែក្រវាត់ចំពោះព្រះសិទ្ធត្ថៈសម្ពុទ្ធ)......302

២.មណ្ឌបទាយិកាថេរិយាបទាន (ផលនៃការធ្វើមណ្ឌប និងថ្វាយព្រះស្តូបដល់ព្រះកោនាគមនៈសម្ពុទ្ធ)......303

៣.ប្រវត្តិព្រះពុទ្ធទាំងប្រាំព្រះអង្គក្នុងភទ្ទកប្បនេះ (ដោយសង្ខេប)......304

VIII. ថ្ងៃបុណ្យសំខាន់ក្នុងព្រះពុទ្ធសាសនា......309

IX. មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធជាម្ចាស់......311

X. រូបមង្គល ១០៨ ក្នុងស្នាមព្រះពុទ្ធបាទ......316

XI. ព្រះសទ្ធម្មជោតិក ធម្មាចរិយពោលសរសើរគម្ពីរផ្សេង ៗ......321

XII. បត្តិទានគាថា យាទេវតា......323

XIII. អនុមោទវគ្គាយាចនគាថា (អាកាសដ្ឋា...)......325

XIV. អវសានកថា......327

XV. កំណាព្យ វត្តគិរីរម្យចាស់ និងកំណាព្យ ឱគិរីរម្យដំរំចិត្ត......329

XVI. នាមលោកអ្នកសប្បុរសចូលរួមបោះពុម្ពសៀវភៅ......332

# នមស្ការបូជនីយវត្ថុជាទីគោរព



*បុគ្គលដែលមានសទ្ធាជ្រះថ្លា ធ្វើការបោសសម្អាត ព្រះពោធិព្រឹក្ស ទីលានព្រះចេតិយ ឈ្មោះថាធ្វើសេចក្តីគោរព ចំពោះព្រះសាស្តា ។*

# គាថាសម្រាប់នមស្សការព្រះធាតុចេតិយ និងពាក្យថាចេតិយ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

## នមស្ការបូជនីយវត្ថុជាទីគោរព

| | |
|---|---|
| វន្ទាមិ ចេតិយំ សព្វំ | សព្វដ្ឋានេសុ បតិដ្ឋិតំ |
| សារីរិកធាតុមហាពោធឹ | ពុទ្ធរូបំ សកលំ សទា ។ |
| *ខ្ញុំសូមថ្វាយបង្គំ* | *ចំពោះព្រះបរមចេតិយ* |
| *ព្រមទាំងព្រះសារី-* | *រិកធាតុនៃព្រះពុទ្ធ ។* |
| *និងមហាពោធិព្រឹក្ស* | *ដែលគួរនឹកដោយលំអុត* |
| *លំឱនចិត្តបរិសុទ្ធ* | *លើកកម្បង់អញ្ជលី ។* |
| *និងព្រះពុទ្ធរូប* | *តំណាងអង្គព្រះមុនី* |
| *ដែលឋិតនៅគ្រប់ទី* | *ឋាននានានោះទាំងអស់ ។* |
| *(ដោយតេជៈនៃគុណ* | *ព្រះមានបុណ្យប្រសើរខ្ពស់* |
| *ដែលតែងតែរំលស់* | *រំដោះទុក្ខភ័យអន្តរាយ ។* |
| *សូមឱ្យខ្ញុំបានសុខ* | *ឃ្លាតចាកទុក្ខផងទាំងឡាយ* |
| *សត្រូវទោះជិតឆ្ងាយ* | *សូមឱ្យក្លាយមកជាមិត្ត ។* |
| *សូមទាន់ព្រះអរិ-* | *យមេត្រេយ្យថ្លៃវិសិដ្ឋ* |
| *សូមបានឃើញធម៌ពិត* | *សមដូចចិត្តប្រាថ្នាហោង)។* |

*(ពាក្យកាព្យសម្រាយ តែងដោយសម្ដេចព្រះសង្ឃរាជ ជួន-ណាត)*

មហាគោតមសម្ពុទ្ធោ　　កុសិនារាយ និព្វុតោ
ធាតុវិត្ថារកំ កត្វា　　តេសុ តេសុ វិសេសតោ ។

*ព្រះគោតមបរមសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយ នៅក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុ ក្នុងទីទាំងឡាយនោះ ៗ ដោយផ្សេង ៗ គ្នា ។*

ឧណ្ហីសំ ចតស្សោ ទាឋា　　អក្ខកា ទ្វេ ច សត្តមា
អសម្ភិន្នា វតា សត្ត　　សេសា ភិន្នា វ ជាតយោ ។

*ព្រះសារីរិកធាតុទាំងនោះ ដែលមិនបែកចេញមានប្រាំពីរអង្គគឺ ព្រះឧណ្ហីសធាតុ[១] ១ ព្រះទាឋាធាតុ[២] បួន, ព្រះអក្ខកធាតុ[៣] ពីរ ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះសុទ្ធតែបែកចេញជាបំណែកតូចៗ ។*

មហន្តា បញ្ចនាឡី ច　　មជ្ឈិមា ច ឆ នាឡិយោ
ខុទ្ទកា បញ្ចនាឡី ច　　សម្ភិន្នា តិវិធា មតា ។

*ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថាមាន៣ យ៉ាងគឺ ព្រះធាតុខ្នាតធំវាល់បានចំនួន ៥ នាឡិ, ព្រះធាតុខ្នាតកណ្តាលវាល់បានចំនួន ៦ នាឡិ , ព្រះធាតុខ្នាតតូចវាល់បានចំនួន ៥ នាឡិ[៤] ។*

មហន្តា ភិន្នមុគ្គា ច　　មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា　　ឯវំ ធាតុប្បមាណិកា ។

*ព្រះបរមធាតុទាំងឡាយមានប្រមាណយ៉ាងនេះគឺ ព្រះធាតុខ្នាតធំមានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាលមាន*

---

*(១) ឆ្អឹងថ្ងាស ។*
*(២) ព្រះចង្កូម ។*
*(៣) ឆ្អឹងដងកាំបិត ។*
*(៤) ព្រះធាតុរួមទាំងអស់ ១៦ នាឡិ ។*

*ទំហំប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូចមានទំហំប៉ុនគ្រាប់ស្ពៃ ។*

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា[១]
ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ ។

*ព្រះបរមធាតុទាំងឡាយ មានពណ៌ផ្សេងគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្ដាល មានពណ៌ដូចកែវផ្លេក ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាពកុល[២] ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ ។*

ឯកោ ចូឡោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ ។

*ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងវេសាលី ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងកបិលព័ស្តុ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងអលកប្បក: ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងរាមគ្រាម ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងវេដ្ឋទីបក: ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងបាវេយ្យក:ក្នុងមល្លរដ្ឋជនបទ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងកុសិនារា (រួមជា ៨ កន្លែង) ។*

---

(១) *បាលីខ្លះថា មុត្តិកប្បភា មានពណ៌ដូចកែវមុក្តា ។* (២)*ពណ៌សស្រគាំ ។*

ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

*ព្រះស្តូបទាំង ៨ នោះ ជាព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុប្រតិស្ឋាននៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះបរម-ធាតុទាំងឡាយក្នុងព្រះស្តូបទាំង ៨ នោះ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។*

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ ។

*ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងស្ថានត្រៃត្រឹង្ស ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងពិភពនាគ ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងដែនគន្ធារៈ ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងសីហឡទ្វីប ។*

ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

*ព្រះទាឋាធាតុទាំងឡាយនេះ របស់ព្រះបរមសាស្តាប្រតិស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។*

ឧទ្ធំ ទក្ខិណទាឋា ច តាវត្តឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

"ព្រះទាឋាធាតុស្តាំខាងលើ ប្រតិស្ឋាននៅក្នុងស្ថានត្រៃត្រឹង្ស
ព្រះទាឋាធាតុស្តាំខាងក្រោម ប្រតិស្ឋាននៅក្នុងសីហឡទ្វីប
ព្រះទាឋាធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារៈ
ព្រះទាឋាធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា ។

ព្រហ្មលោកេ ទុស្សធាតុ វាមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ ។

ព្រះទស្សធាតុ[១] នឹងព្រះអក្ខកធាតុខាងឆ្វេងប្រតិស្ឋាននៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នាតែងបូជានូវព្រះស្តូបកម្ពស់ ១២ យោជន៍ (ដែលបញ្ចុះនៅព្រះធាតុទាំងនោះ) ។

តាវត្តឹសម្ហិ ទេវានំ ចុឡាមណិម្හិ កេសកំ
សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងបូជា នូវព្រះកេសធាតុ ដែលប្រតិស្ឋាននៅក្នុងចូឡាមណីចេតិយ របស់ទេវតាទាំងឡាយក្នុងស្ថានត្រៃត្រឹង្សខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា ។

---

(១) ព្រះទុស្សធាតុ គឺ ព្រះព័ស្ត្រដែលព្រះអង្គផ្លាស់ចេញហើយ ទ្រង់សំពត់កាសាវៈដែលឃដិការមហាព្រហ្មយកមកថ្វាយ រួចទ្រង់ប្រទានព្រះព័ស្ត្រនោះទៅឃដិការមហាព្រហ្មៗ បានទទួលយកទៅប្រតិស្ឋានឯព្រហ្មលោក ។

ចត្តាឡីស សមាទន្តា កេសា លោមា នខាបិ ច
ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

*ព្រះទន្តធាតុទាំងឡាយ ៤០ គាត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះលោមធាតុទាំងឡាយផង ព្រះនខាធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅនូវព្រះធាតុមួយអង្គៗ កាន់ចក្រវាឡដទៃ និងដទៃ គឺព្រះធាតុមួយអង្គៗ ក្នុងចក្រវាឡមួយៗ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា ។*

អដ្ឋារស ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្សា ចេតិយោ ច ការាបិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

*នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រមួយព្រះអង្គព្រះនាម**ធម្មាសោក** ក្នុងកាលនោះព្រះអង្គបានកសាងព្រះចេតិយចំនួន ៨៤០០០ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធាតុទាំងឡាយក្នុងព្រះចេតិយទាំងនោះ ដែលទេវតានិងមនុស្សទាំងឡាយតែងធ្វើសក្ការបូជា ។ (ប្រស្នាពុទ្ធប្រវត្តិពិស្តារ ទំព័រ១៧៨-១៨៤)*

## ព្រះគាថា

ជិព្ហេ លោកជាថម្ភិ សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ

ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តជន្តូនេ បបិតា ហោន្តិ ចាលិតំ។

*កាលព្រះសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយ ដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។*

*(សៀវភៅប្រជុំភាណវារ ទំព័រ ៤២១-៤២២)*

🕯 **ពាក្យចេតិយ** (ន.) *ទីដែលគេគោរពបូជា គឺទីណាមួយទោះមានដើមឈើធំជាប្រធាន ជាទីសម្គាល់ក្តី, មានថ្មធំៗជាទីចំណាំក្តី ។ល ។ ដែលអ្នកផងគេសន្មត គេជឿថាជាទីសក្តិសិទ្ធិ គេតែងតែធ្វើសក្ការៈគោរពបូជាហៅថា ចេតិយ ទាំងអស់ ។ តែក្នុងប្រទេសខ្មែរសព្វថ្ងៃនេះ សំដៅ ចំពោះតែគារវវត្ថុដែលគេយកឥដ្ឋជាដើម សម្រាប់តម្កល់ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ជាដើមនោះ ទើបហៅថា ចេតិយ ឬ ចៃដីក៏មាន, ហៅ ក្លាយជាចាយដី ក៏មាន* (Sepulchralmonument) ។

*ចេតិយដែលទាក់ទងនឹងព្រះពុទ្ធសាសនាមាន ៤ ប្រភេទគឺ ៖*

***១.ធាតុចេតិយ*** *ចេតិយដែលបញ្ចុះធាតុ ។ តាមសេចក្តីក្នុងគម្ពីរព្រះពុទ្ធសាសនា សំដៅចំពោះតែចេតិយដែលបញ្ចុះព្រះសារី-រិកធាតុព្រះសព្វញ្ញុពុទ្ធ ឬដែលបញ្ចុះធាតុព្រះអរហន្ត, មានន័យ ផ្សេងទៀតថាទោះបីចេតិយដែលបញ្ចុះព្រះពុទ្ធរូបបែកបាក់ ក៏ហៅថា ធាតុចេតិយដែរ ។*

***២.បរិភោគចេតិយ*** *ចេតិយ គឺវត្ថុ ឬស្ថានទីដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ធ្លាប់ប្រើប្រាស់ទាក់ទង ជាមួយនឹងរបស់របរវត្ថុ បានដល់ សំវេជនីយដ្ឋានទាំង ៤ កន្លែង, តុម្ពស្តូប, និងអង្គារស្តូប រហូតដល់បាត្រ, ចីវរ, គ្រែ, តាំង, កុដិ, វិហារដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រើប្រាស់ ។*

***៣.ធម្មចេតិយ*** *ចេតិយដែលតម្កល់ព្រះធម៌, ពាក្យបង្ហាត់បង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ (ទូដាក់គម្ពីរព្រះត្រៃបិដកជាដើម ក៏ហៅថា ធម្មចេតិយដែរ) ។*

***៤.ឧទ្ទេសិកចេតិយ*** *ចេតិយដែលសាងឡើងដើម្បីជាគ្រឿងដាស់តឿន ចិត្ត ឱ្យរឭក ដល់ព្រះសម្មាសម្ពុទ្ធ បានដល់ព្រះពុទ្ធរូប ។*

*(សទ្ទានុក្រមព្រះពុទ្ធសាសនា)*

**ពាក្យ គន្ធកុដិ** (ន.) *កុដិដែលមានក្លិនក្រអូប, កុដិដែលគេដាំផ្កាក្រអូបនៅក្បែរ, ទីប្រថាប់របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។*

**ពាក្យ សុគន្ធកុដិ** (ន.) *កុដិមានក្លិនក្រអូប (ឈ្មោះកុដិដែលជាលំនៅរបស់ព្រះសម្មាសម្ពុទ្ធ មានផ្កាក្រអូបដែលគេដាក់បូជា ឬផ្កាឈើជិតខាងផ្សាយក្លិនក្រអូបជានិច្ច) ។*

**ពាក្យ ប្រាង្គ** *នាមសព្ទ( សំ. < ប + អង្គ ) ស្តូប ឬ ប្រាសាទដែលមាន កំពូលខ្ពស់ ស្ថិតនៅលើទីលានច្រើនថ្នាក់ឬមួយ ថ្នាក់ពីរថ្នាក់, ច្រើនតែមានរាងប្រឡោតាំងពី ក្រោមរហូតដល់កកំពូល ។*

**ពាក្យ មកុដពន្ធនចេតិយ** *ន. ស្ថាទីថ្វាយព្រះភ្លើង ព្រះសរីរៈរបស់ព្រះសម្មាសម្ពុទ្ធ គឺនៅផ្លូវទិសខាងកើតនៃក្រុងកុសិនារា ។*

*(វចនានុក្រមខ្មែរ នឹងសទ្ទានុក្រមព្រះពុទ្ធសាសនា)*

## ១. មហាចេតិយឧណ្ណាលោម ភ្នំពេញ

*វត្តឧណ្ណាលោម គឺជាវត្តមួយក្នុងចំណោមវត្តប្រចាំទិសធំៗទាំង ៤ នៃព្រះបរមរាជវាំង និងជាទីស្នាក់ការគង់នៅរបស់ព្រះសង្ឃរាជគណៈមហានិកាយ ។ វត្តនេះមានព្រះចេតិយបុរាណមួយ នៅខាងក្រោយ (ខាងលិច) ព្រះវិហារមានចេតិយមួយ ដែលមានសណ្ឋានទ្រង់ទ្រាយខុសប្លែកពីចេតិយផងនានា ក្នុងព្រះរាជណាចក្រកម្ពុជា ដែលមានឈ្មោះថា មហាចេតិយ ឧណ្ណាលោម ។*

*តាមឯកសារប្រវត្តិនៃវត្តឧណ្ណាលោមបានឱ្យយើងដឹងថា : សម្តេចព្រះសង្ឃរាជព្រះនាម ទៀង (សុវណ្ណកេសរ) បានមានសង្ឃដីកាថា : ទាំងព្រះពុទ្ធរូបថ្មអង្គធំ ដែលតាំងតម្កល់ក្នុងរូងខាងក្រោម ទាំង មហាចេតិយឧណ្ណាលោមនេះ គឺបានសាងសង់តាំងពីសម័យកាល ដែល ព្រះពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយ ចូលមកក្នុងប្រទេសកម្ពុជាជាលើក ដំបូងបង្អស់ ។ យោងតាមបទសម្ភាសន៍មួយ ដែលគេបានធ្វើជាមួយ សម្តេចព្រះសង្ឃរាជ ព្រះសុមេធាធិបតី **ទេព វង្ស** បានមានសង្ឃដីកាឱ្យដឹងថា : ប្រាសាទនេះ ប្រហែលជាកសាង ឡើងដោយខ្សែស្រឡាយ នៃរាជវង្សស្តេចនគរភ្នំ ស.វ. ទី៥-៦ ឬ ទី៧ ជានិមិត្តរូបនៅក្នុងជ្រោយ សុវណ្ណភូមិនេះ ។*

*រីឯការបញ្ចុះព្រះឧណ្ណាលោម នៃ**ព្រះអស្សជិតត្ថេរ**[១] ដែលមានដើមកំណើតនៅ**បង់ហ្កាល** ប្រទេសឥណ្ឌានោះ គេពុំបានដឹងប្រាកដថាក្នុងសម័យកាលណាមួយ ឬ ព្រះមហាក្សត្រអង្គណាមួយនោះឡើយ ។*

(១). *មតិរបស់អាចារ្យពួកខ្លះថា ជារោមប្រជុំចិញ្ចើមរបស់ព្រះសម្មាសម្ពុទ្ធពុទ្ធ ។*

លុះសម័យក្រោយមកទៀត ទើបសម្តេចព្រះសង្ឃរាជ ព្រមទាំងពុទ្ធបរិស័ទ បានកសាងចេតិយ ៥ ព័ទ្ធជុំវិញ ភ្ជាប់ទៅនឹងមហា ចេតិយនេះ ព្រមទាំងបានឱ្យគេធ្វើឆត្ររួតដាក់ពីកំពូល នៃមហាចេតិយ នេះទៀតផង ។ *(មគ្គុទេសក៍ទេសចរ)*



## ២. ព្រះចេតិយនៅលើភ្នំសន្ទុក កំពង់ធំ

*ព្រះធម្មរាជា ឡើងសោយរាជ្យសម្បត្តិ ក្នុងឆ្នាំ ច សំរឹទ្ធិស័ក ព.ស .២០២២ - គ.ស.១៤៧៨ - ម.ស.១៤០០ - ច.ស.៨៤០ ក្នុងជន្មាយុ ២៦ឆ្នាំ ព្រះអគ្គមហេសីព្រះភគវតី សេរីទេពវី នារីចក្រពត្តិ ។ ព្រះអង្គ ទ្រង់គង់នូវ ក្រុងចតុម្មុខ* ***ភ្នំដូនពេញ***, *ក្នុងរាជ្យព្រះបាទសម្តេច****ព្រះស្រីធម្មរាជា*** *ព្រះ អង្គបង្ក្រាបរាជសង្គ្រាមនូវសឹកសត្រូវរាបទាបហើយ ស្តេច ទ្រង់ទំនុក បម្រុង****ព្រះពុទ្ធសាសនា*** *បានរុងរឿងថ្កើងថ្កាន ជាស្តេចប្រកាន់* ***ទសពិធ រាជធម៌*** *។*

*ព្រះអង្គមានបុត្រាមួយអង្គព្រះនាម* ***ព្រះស្រីសុគន្ធបទ*** *ទ្រង់បាន រៀនព្រះត្រៃបិដក ចាំចប់គ្មានទើសទាល់ ។ ព្រះរាជាទ្រង់សព្វព្រះទ័យ ធ្វើព្រះរាជកុសល និមន្តព្រះសង្ឃទេសនា បរិច្ចាគព្រះរាជទ្រព្យ ។ ទ្រង់ សម្តែងព្រះធម្មចក្ក ប្រទានជាសណ្តាប់ ដល់សេវកាមាត្យ ទាំងឡាយ រាល់ ថ្ងៃឧបោសថសីល ពុំដែលដាច់ ។ ស្តេចតាំងព្រះរាជហឫទ័យ ប្រាថ្នាជា* ***ពុទ្ធភូមិ****ទៅអនាគត។*

*ព្រះរាជាទ្រង់ប្រជុំសម្តេចព្រះសុគន្ធាធិបតី ជារាជាគណៈ មុខមន្ត្រី ករីជាតិមកជួបជុំហើយ ទ្រង់ប្រាថ្នាកសាងព្រះចេតិយ តម្កល់ព្រះសារី- រិកធាតុ ដើម្បីឱ្យសាសនាគង់វង់គ្រប់៥០០០ ព្រះវស្សា ។*

*ព្រះចេតិយធំនោះទ្រង់កសាងនៅភូមិខ្វាវ ខេត្តអាសន្ទុក* (ភ្នំសន្ទុក) *ព្រះអង្គតម្កល់ព្រះបរមសារីរិកធាតុ រៀបថ្មជាទីបរិមណ្ឌល ។ ទ្រង់ឱ្យធ្វើ ប្រាសាទទង់ដែងតម្កល់លើមន្ទីរ ក្នុងប្រាសាទនោះ មានស្តូប ដល់បីជាន់ ស្តូបជាន់ក្រៅរចនាពី****ប្រាក់*** *ស្តូបជាន់បន្ទាប់ធ្វើពី****ទង់ហ្វា*** *ស្តូប ជាន់ក្នុង*

របនាពីមាស ប្រដាប់ដោយត្បូង ព្រះចេតិយនេះកសាង ២ឆ្នាំ- ថ្វាយ ។ ព្រះរាជាទ្រង់បូជាគ្រឿងមានតម្លៃជាច្រើនក្នុងចេតិយនេះ រីឯ ព្រះសារីរិកធាតុអារាធនាមកពី**ព្រះមហានគរវត្ត** មកធ្វើបុណ្យឆ្លង នៅថ្ងៃ ១១កើត ខែអាសាធ ឆ្នាំពោង អដ្ឋស័ក ព.ស.២០៤០ គ.ស.១៤៩៦ ម.ស.១៤១៨ - ច.ស.៨៥៨ ។ *(ឯកសារ មហាបុរសខ្មែរ ទំព័រ ៧០-៧៤)*



ព្រះចេតិយតូចនេះ ជាចេតិយរបស់ព្រះធម្មរាជា រីឯព្រះចេតិយធំបញ្ចុះព្រះសារីរិកធាតុនោះ ឯកសារថា នៅជិតចេតិយព្រះធម្មរាជានេះឯង។

## ៣. ព្រះចេតិយ ប្រាសាទនគរបាជ័យ

*ប្រាសាទនគរបាជ័យ ជាប្រាសាទបុរាណមួយដែលបានសាងសង់ឡើងនៅចុងសតវត្សទី ១២ ព្រះបាទកម្រង់តេងអញស្រីជ័យវរ្ម័ទេវទី ៧ (ព្រះបាទជ័យវរ្ម័នទី ៧) ដើម្បីឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន... ។*

*លុះកន្លងទៅបានប្រមាណកន្លះសហស្សវត្សរ៍ក្រោយមក ក្នុងថ្ងៃចន្ទ ១៤រោច ខែអាសាឍ ឆ្នាំខាល មហាសករាជ ១៤៨៨ ត្រូវនឹងថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៦៦ ខ្ទង់វេលាម៉ោង ៨ព្រឹក សម្តេច**ឧកញ៉ាយស ស្រី សៅគន្ធបទ** អតីតព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះស្រីសុគន្ធបទ បានកសាងជាសូរេច នូវព្រះចេតិយដែលកម្ពាយកំពូលព្រះប្រាង្គចាស់ ដើម្បីតម្កល់ព្រះមហាសារីរិកធាតុ ហើយក៏បានប្រតិស្ឋានព្រះពុទ្ធរូបសន្ធប់មុខទ្វារទាំងបីទិសនៃព្រះប្រាង្គប្រធានផង ហើយទើបចាត់កសាងមហាវិហារនិងគោលសីមា រក្សាជាសក្ការៈ នៅត្រង់ពីខាងមុខនៃទិស ខាងកើត ។*

*ដោយសារព្រះវិហារកសាងអំពីឈើក៏ចេះតែពុកផុយ ក៏ត្រូវកសាងជាច្រើនលើកច្រើនសា រហូតមកទល់នឹងព្រះវិហារបុរាណ ដែលយើងបានឃើញសព្វថ្ងៃនេះ ។ ព្រះវិហារបុរាណនេះ គឺជាស្ថាបត្យកម្មនៃទសវត្សរ៍ឆ្នាំ ១៩៣០ ដែលនៅសេសសល់គំនូរនៅតាមហប់ខ្យល់ និង ពិដាន ក៏ត្រូវបានគេគូរពីលើឱ្យថ្មីនាសម័យនេះបន្ថែមទៀត ។ វត្ត**នគរបាជ័យ (បន្ទាយព្រៃនគរ)** នេះត្រូវបានជាប់ឈ្មោះក្នុងបញ្ជីស្នើរសុំទៅកាន់អង្គការ* UNESCO *ដើម្បីដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកតាំងតែពីឆ្នាំ ១៩៩២, កម្រងសរសេរជាប្រវត្តិត្រួសៗនៃ វត្ត**នគរបាជ័យ** ដោយ **សី លីហៀង** តាមរយៈឯកសារយោង៖ សៀវភៅ "សិលាចារឹកនៃ*

ប្រទេសកម្ពុជាសម័យកណ្តាល"  ត្រង់ សិលាចារឹកនៅប្រាសាទនគរបាជ័យ និង (Something by Evan) ។

សព្វថ្ងៃព្រះចេតិយនេះ នៅ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។



## ៤. ព្រះចេតិយ វត្តព្រះធាតុ ត្បូងឃ្មុំ[១]

*ក្នុងរាជ**ព្រះបាទធម្មាសោករាជ** ស្តេចបានចាត់ឱ្យ សម្តេចចៅ**ពញា អរជូន ព្រះអង្គកែម** ទ្រង់បានមកគ្រង់ស្រុកត្បូងឃ្មុំ ។*

*សម័យថ្ងៃមួយនោះ បណ្តាអ្នកស្រុកទាំងប៉ុន្មាន ក្រឡេកទៅឃើញព្រះអរហន្តហោះផ្សានលើអាកាស ធ្លាក់មកលិចទៅក្នុងដីបាត់ បែករស្មីជា ៧ពណ៌ ក៏នាំគ្នាធោឡោជីកដីនោះទៅ ទើបជ្រាបដល់សម្តេចចៅ**ពញាអរជូនអង្គកែម** ព្រះអង្គក៏ទ្រង់សាទរ បេញមកឃោសនាអស់ក្រុម-ការ ឱ្យជួយជីកដីនោះទៅ ឃើញព្រះបរមសារីរិកធាតុ ហើយក៏ធោឡោធ្វើសក្ការបូជា ធ្វើព្រះអារាម ធ្វើព្រះវិហារ សីមា ព្រះចេតិយសុទ្ធសឹង តែពីថ្មល្អថ្លៃថ្លា បញ្ចុះព្រះបរមសារីរិកធាតុ រួចតាំងនាមចៅអធិការវត្ត នោះជា សម្តេច**ព្រះសិរីធម្មធាតុ** តាំងនាមវត្តនោះហៅ **វត្តព្រះធាតុ** បាន ជាជាប់ហៅវត្ត **ព្រះស្រីព្រះធាតុ** រៀងមក ។*

*ព្រះអង្គធ្វើបុណ្យឆ្លង ៣ខែ និមន្តព្រះសង្ឃទេសនា តាំងពី ៥០ ជាតិ មកដល់ទសជាតក ហើយសម្តេចចៅពញាអរជូនអង្គកែម សព្វព្រះទ័យនឹងរឿងព្រះមហោសថណាស់ ទ្រង់ត្រាស់ឱ្យជីកជាអុងម៉ុង១ តែ អុងម៉ុងនោះតូច, ទ្រង់សព្វព្រះទ័យឱ្យជីកមួយទៀត ទំហំទទឹង ១៤ហត្ថ កម្ពស់ ១៥ហត្ថ ជម្រៅទទឹងចម្ងាយវែងឆ្ងាយទៅដល់មាត់សមុទ្រ ដែលនៅស្រុកយួន ជាតំណាងអុងម៉ុង ព្រះមហោសថ បានជាអ្នកស្រុកហៅ **អុងម៉ុង ព្រះមហោសថ**រៀងមក ៕*

*(ឯកសារ មហាបុរសខ្មែរ ទំព័រ ២០៣-២០៤)*

---

[១] *វត្តនេះ សព្វថ្ងៃមានឈ្មោះថា វត្តព្រះធាតុបាស្រី, ខេត្តត្បូងឃ្មុំ*

ព្រះវិហារនេះ កសាងពីលើចេតិយបុរាណ នៅកំឡុងឆ្នាំ១៩៣០, រីឯព្រះមណ្ឌបកសាងនៅឆ្នាំ១៩៥៣ ។









## ៥. ព្រះពុទ្ធប្រាង្គ វត្តប្រាង្គឧដុង្គ កំពង់ស្ពឺ

*ព្រះពុទ្ធប្រាង្គ ឬព្រះប្រាង្គនេះ ស្ថិតនៅភូមិចម្ការហ្លួង ឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ, វត្តប្រាង្គក៏ជាវត្តបុរាណមួយក្នុងព្រះរាជា- ណាចក្រកម្ពុជាយើងផងដែរ ,នៅក្នុងវត្តយើងឃើញមានព្រះប្រាង្គ ដែលស្ថិតនៅទិសខាងជើងនៃព្រះវិហារ ដែលកសាងនាសម័យបុរាណ ។*

*សម្ដេចព្រះមហាសង្ឃរាជព្រះនាម **ទៀង** ទ្រង់បានជួសជុល ព្រះប្រាង្គឡើងជាថ្មី ដោយទ្រង់នឹកដល់ព្រះរាជបណ្ដាំនៃព្រះបាទ សម្ដេចព្រះហរិរ័ក្សរាមា (**ព្រះអង្គឌួង**), នៅខាងដើមនៃរជ្ជកាលព្រះបាទ សម្ដេច **ព្រះស៊ីសុវត្ថិ**ក្នុង ព.ស.២៤៤៨ គ.ស.១៩០៥, បានហើយសម្រេចនៅ ព.ស.២៤៥១ គ.ស.១៩០៨ ។ ក្នុងឆ្នាំនោះសម្ដេចព្រះមហាសង្ឃ រាជទ្រង់បានប្រារព្ធហ្នឹងដង្ហែព្រះសារីរិធាតុ ពីក្រុងភ្នំពេញ ដោយក្បួន នាវាតាមផ្លូវទឹកទៅកាន់**វត្តប្រាង្គ** ហើយបានតម្កល់ព្រះសារីរិកធាតុក្នុង ធម្មសាលាវត្តប្រាង្គ, និងបានធ្វើពិធីបុណ្យសម្ពោធព្រះប្រាង្គ ៣ថ្ងៃ ទើបដង្ហែព្រះបរមសារីរិកធាតុ ទៅតម្កល់លើព្រះប្រាង្គនៅថ្ងៃព្រហស្បតិ៍ ១២រោច ខែអស្សុជ ឆ្នាំវក សំរិទ្ធិស័ក ព.ស.២៤៥១ គ.ស.១៩០៨ ពេលរសៀល ក្រោមព្រះរាជាអធិបតីភាព នៃព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេច**ព្រះស៊ីសុវត្ថិ** ។*

*លុះដល់សម័យក្រោយមកទៀត ត្រូវបានព្រះចៅអធិការវត្ត ព្រះគ្រូ **អគ្គវង្សោ ឆាយ កន** បានដឹកនាំពុទ្ធបរិស័ទជួសជុលឡើងជាថ្មី រួចស្រេចបាច់ និងធ្វើពិធីបុណ្យសម្ពោធឆ្លង និងដង្ហែព្រះសារីរិកធាតុនា ថ្ងៃសៅរ៍-អាទិត្យ-ចន្ទ ៤-៥-៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

ត្រូវនឹងថ្ងៃទី២៥-២៦-២៧ ខែមីនា ឆ្នាំ២០២៣ មានពុទ្ធបរិស័ទគ្រប់ខេត្តក្រុង បានមកចូលរួមបុណ្យនោះយ៉ាងច្រើន កុះករ ។ ព្រះសារីរិកធាតុអាពនាមកពីខេត្តសៀមរាប បានតម្កល់ខាង លើព្រះពុទ្ធប្រាង្គ ដើម្បីប្រយោជន៍ដល់សាធុសប្បុរស និងទេវតាទាំង- ឡាយ ៕

*(ប្រវត្តិនៃវត្តប្រាង្គ រៀបរៀងដោយព្រះពោធិវង្ស ហួត តាត)*



## ៦. ព្រះចេតិយ វត្តព្រះធាតុ ភ្នំពេញ

*វត្តព្រះធាតុស្ថិតនៅ ភូមិព្រះធាតុ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ បើយើងចេញដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ ២ ហួសរង្វង់មូលក្បូរស្រូវប្រមាណ ១គីឡូម៉ែត្រជាង យើងឃើញខ្លោងទ្វារ វត្តនៅខាងស្តាំដៃ បត់ចូលក្នុងជិត៥០០ម៉ែត្រ ទើបដល់វត្តព្រះធាតុ ។*

*ក្នុងវត្តអារាមមានសំណង់ធំតូចជាច្រើន, នៅទិសខាងត្បូងនៃព្រះវិហារថ្មី យើងដើរទៅប្រមាណ ២០០ម៉ែត្រ យើងនឹងឃើញព្រះវិហារមួយទៀត គឺជាព្រះវិហារដែលគេធ្វើពីលើទីតាំងប្រាសាទបុរាណមួយកន្លែងដែលខូចខាត ហើយគេបានកសាងចេតិយមួយទៀតត្រង់កណ្តាលប្រាសាទក្នុងព្រះវិហារនោះដែរ។*

*រីឯចេតិយនេះ គេតម្កល់ព្រះអដ្ឋិធាតុស្តេច ឬព្រះសារីរិកធាតុក៏ពុំច្បាស់ទេ មិនដឹងនឹងកសាងឆ្នាំណា សម័យណាដែរ រីឯប្រជាជនខ្មែរយើងអ្នកខ្លះថាតម្កល់ព្រះសារីរិកធាតុ អ្នកខ្លះទៀតថាធាតុស្តេច, បើតាមមតិរបស់ខ្ញុំព្រះករុណាប្រហែល ជាតម្កល់ព្រះសារីរិកធាតុដោយច្រើនព្រោះវត្តនេះយកឈ្មោះតាមទីតាំងនោះ ប្រហែលគ្នានិងវត្តព្រះធាតុខេត្តត្បូងឃ្មុំដែរ ។*

*បើញាតិញោមបានទៅវត្តនេះកុំភ្លេចទៅថ្វាយបង្គំ និងបូជាគ្រឿងសក្ការៈផ្សេងៗ ចំពោះព្រះចេតិយនេះផង ៕*



## ៧.ព្រះចេតិយ វត្តព្រះពុទ្ធឃោសាចារ្យ រាជធានីភ្នំពេញ

*ព្រះសារីរិកធាតុដែលបញ្ចុះក្នុងចេតិយនេះ ដង្ហែមកពី**កោះស្រី-លង្កា** ដោយព្រះពុទ្ធ ឃោសៈនៅ ច.ស.១, ព.ស.១១៨៣, ម.ស.៥៦១, គ.ស.៦៣៩ **ឥន្ទបត្ត បូរី (នគរវត្ត)** ។*

*នៅខាងមុខព្រះវិហារវត្តព្រះពុទ្ធឃោសាចារ្យ ហៅ **វត្តចិនដំដែក** ខាងត្បូង ខណ្ឌដូនពេញ ក្រុងភ្នំពេញ មានចេតិយ បុរាណមួយ គេថត នៅឆ្នាំ ១៨៩៥ និងបច្ចុប្បន្ន (ឆ្នាំ២០២០) ចេតិយនេះមាន អាយុកាលជិត ២០០ឆ្នាំ ត្រូវបានសាងសង់មុនសម័យបារាំងទៅទៀត ព្រោះខាងក្រោម ចេតិយនេះសព្វថ្ងៃមានចារឹកជាអក្សរសៀម ច.ស.១២០១... (ត្រូវនឹង ព .ស.២៣៨២ គ.ស.១៨៣៩) ដែលគ្រានោះប្រទេសកម្ពុជាស្ថិតក្នុងឥទ្ធិ ពល**សៀម-វៀតណាម** ។*

*ព្រះមហាក្សត្រសៀមព្រះនាម **ណាំងក្លៅ** ឬ **រាមាទី៣** (១៨២៤-១៨៥១) បានចាត់ឱ្យមន្ត្រីឈ្មោះ **ចៅយុនបឱន** មកកម្ពុជា ហើយចៅយុន នេះឯងដែលជាអ្នកស្ថាបនាឡើងវិញ នូវអារាមសាសនានេះឡើង ក្រោយ ដែលត្រូវបានខូចខាតដោយការទន្ទ្រានឈ្លានពានរបស់ **វៀត-ណាម** ៕*

*(Facebook Amazing Cambodia)*


NOW
WWW.FACEBOOK.COM/AMAZINGCAMBO
THEN

## ៨. ព្រះចេតិយ វត្តបទុមវតីរាជវរារាម

វត្តខ្ពបតាយ៉ង ឬវត្តបទុមវតីរាជវរារាម កសាងឡើងក្នុងឆ្នាំ ១៤៤២ ដោយព្រះចៅ **ពញាយ៉ាត** (អ្នកកសាងទីក្រុងភ្នំពេញលើកទី១) បន្ទាប់ពីការបោះបង់ក្រុងអង្គរក្នុង ឆ្នាំ ១៤៣២ ។ វត្តបទុមវតី ក៏ជាវត្តមួយក្នុងចំណោមវត្តប្រចាំទិសធំៗ ទាំង៤ នៃព្រះបរមរាជវាំង, ដែលនៅទិសខាងត្បូងបរមរាជវាំងប្រមាណ ៣០៩ម៉ែត្រ ។

ក្នុងវត្តបទុមវតី យើងឃើញមានចេតិយចាស់ ថ្មី តូចធំជាច្រើននៅក្នុងបរិវេណវត្ត ក្នុងនោះមានចេតិយបុរាណមួយធំជាងគេនេះ មានសេចក្តីថា សម្តេចព្រះសុគន្ធាធិបតី **ប៉ាន** ទ្រង់កំពុងប្រារព្ធ ឱ្យសាងព្រះចេតិយធំមួយ ស្រាប់តែទ្រង់ប្រឈួនចុកសៀតព្រះឧទរសោយទិវង្គតទៅ នៅថ្ងៃសៅរ៍ ៤រោច ខែផល្គុន ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៤៣៦ ច.ស. ១២៥៥ គ.ស. ១៨៩៣ ក្នុងរវាងព្រះជន្ម ៦៨ វស្សា ។

ឯព្រះចេតិយធំនោះ បានសម្តេចព្រះមង្គលទេពាចារ្យ **អៀម** ជាសិស្សផ្ទាល់ ដែលបានឡើងឋានន្តរស័ក្តិជាសម្តេចព្រះសង្ឃនាយក ទី២ គ្រប់គ្រងវត្តបទុមវតីបានឃោសនាធ្វើការនោះហើយស្រេច បានធ្វើពិធីបុណ្យសម្ពោធឆ្លង បញ្ចុះព្រះបរមសារីរិកធាតុ ព្រះអរហន្តធាតុនៅថ្នាក់ខាងលើ និងព្រះធាតុសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី **ប៉ាន** បញ្ចុះនៅថ្នាក់ខាងក្រោម នៅថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំរកា ឯកស័ក ព.ស. ២៤៥២ ច.ស ១២៧១ ត្រូវនឹងថ្ងៃទី៨ ខែឧសភា គ.ស ១៩០៩ ។ ព្រះសារីរិកធាតុ ១អង្គ អរហន្តធាតុ ១អង្គ និងកូនពោធិព្រឹក្ស ១ ដើម ដែលអាពធនាមកពីប្រទេសលង្កា សម្តេចប៉ាន បានឱ្យដាំនៅខាងមុខវត្ត នៅ

ថ្ងៃអង្គារ៍ ១០រោច ខែផល្គុន ឆ្នាំកុរ នពស័ក ច.ស. ១២៤៩ ព.ស. ២៤៣០ គ.ស.១៨៨៧ ។

ចេតិយនេះមានសណ្ឋានជាបួនជ្រុង មានកម្ពស់ ៣៣ ម៉ែត្រ មានចេតិយតូច ៗ ជាបរិវារអម គ្រប់ជ្រុងទាំង ៤ នីមួយៗ កម្ពស់ ៦ ម៉ែត្រ មានប្រាង្គគ្រប់ទាំងបួនជ្រុងរំលិចក្បាច់រចនាយ៉ាងប្រណីត (គេហៅចេតិយប្រាំបីទិស) ។ (សៀវភៅព្រះវិនយវណ្ណនា)








## ៩. ព្រះចូឡាមណីចេតិយ វត្តគិរីរតន ភ្នំយ៉ាត

*អង្គចូឡាមណីចេតិយដ៏ធំ ឬហៅថាចេតិយភ្នំយ៉ាត មានបាតប្រវែង ១៦ ម៉ែត្រ គុណនឹងកម្ពស់ ២៧ ម៉ែត្រ កសាងឡើងនៅសតវត្សរ៍ទី ១៩ ក្នុងឆ្នាំ ១៩២៥ ដោយជនជាតិ ភូមា(កូឡា) ក្នុងគោលបំណងដើម្បីតម្កល់ព្រះសារីរិកធាតុរបស់* ***ព្រះសមណគោតម*** *។ ចេតិយនេះមានអាយុកាលជិត ១០០ឆ្នាំមកហើយ ត្រូវបានជួសជុលនៅថ្ងៃទី២១ តុលា ២០១០ ដោយជនជាតិ****ភូមា*** *(កូឡា) សហការជាមួយអាជ្ញាធរខេត្តប៉ៃលិន។*

*ចេតិយភ្នំយ៉ាត ត្រូវអាជ្ញាធរខេត្តរៀបចំសំណុំឯកសារបញ្ជូនទៅថ្នាក់លើ ដើម្បីឱ្យស្នើសុំដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក ។ ព្រះសង្ឃនាម* ***ផៃ ចាន់សេរីវ័ត្ន*** *ព្រះជន្ម៥១វស្សា គង់នៅក្នុងវត្ត* ***គិរីរតនៈ*** *ហៅវត្តភ្នំយ៉ាត មានថេរដីកាឱ្យដឹងថា អង្គចូឡាមណីចេតិយ ហៅចេតិយភ្នំយ៉ាត ជាកន្លែងគោរពបូជា សាងសង់នៅលើភ្នំយ៉ាត តែដោយមានសភាពទ្រុឌទ្រោមពុកផុយក៏មានការ គាំទ្រឧបត្ថម្ភប្រាក់ និងបច្ចេក-ទេសជួសជុលឡើងវិញដោយសប្បុរសជនសហភាពមីយ៉ាន់ម៉ា តាំងពីថ្ងៃទី ២១ តុលា ២០១០ រហូតរួចរាល់មានគុណភាពរឹងមាំល្អ ដើម្បី អភិ- រក្សទុកជាកេរដំណែលប្រវត្តិសាស្ត្រវប្បធម៌ឱ្យបានគង់វង្សជាប្រយោជន៍សម្រាប់អ្នកជំនាន់ ក្រោយៗទៀត ៕*

*(កោះសន្តិភាព)*











## ១០. ព្រះវិហារ ដូចប្រាសាទ វត្តសន្តិវ័ន

*នៅវត្តសន្តិវ័ន មានព្រះវិហារឧបោសថមួយ ប្លែកពីព្រះវិហារដទៃ ក្នុងព្រះរាជាណាចក្រកម្ពុជាយើង ព្រោះមានរាងដូចជាប្រាសាទបុរាណ មានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ដែលដឹកនាំកសាងដោយសម្តេចព្រះ **វនរ័ត្ន ប៉ុណ្យ សម្ភាជន៍ ធម្មាភាមោ** នៅ ព.ស.២៤៩៩ គ.ស .១៩៥៦ ។*

*ព្រះវិហារនេះមានទំហំបណ្តោយ ៨ម៉ែត្រ និងទទឹង ៨ម៉ែត្រជាង មានពីរជាន់ ជាន់ក្រោមជាកន្លែងធ្វើឧបោសថកម្មរបស់ភិក្ខុសង្ឃ និងជាន់ខាងលើជាទីសក្ការកម្កល់ព្រះសារីរិកធាតុ ។ ក្នុងថ្ងៃបុណ្យវិសាខ-បូជា មាឃបូជា មានញាតិញោមប្រុសស្រីនាំគ្នាមកគោរពបូជានៅទីនេះយ៉ាងច្រើនកុះករ ។ ដែលស្ថិតនៅភូមិអូរដំបង ឃុំអូរដំបង ២ ស្រុកសង្កែ ខេត្តបាត់ដំបង ។*

*(Facebook វត្តសន្តិវ័ន-ខេត្តបាត់ដំបង)*



## ១១. ព្រះចេតិយ វត្តមហានន្ទិយារាម

*ប្រិយមិត្តជាទីរាប់អាន ខ្ញុំព្រះករុណានឹងណែនាំលោកអ្នកឱ្យស្គាល់ព្រះចេតិយមានក្បាច់រចនាយ៉ាងស្អាតមួយ ដែលស្ថិតនៅវត្ត* ***មហានន្ទិយារាម "ខ្សាច់ប្រឆេះក្រោម"*** *ភូមិក្សាច់ប្រឆេះក្រោម ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ។*

*ព្រះចេតិយដែលមានក្បាច់រចនាបែបបុរាណមួយនេះ កសាងក្នុងកំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ សម្រាប់តម្កល់ព្រះសារីរិកធាតុ ។*

*ករុណាលោកម្ចាស់ ញាតិញោមនិមន្ត និងអញ្ជើញទៅកុំភ្លេចទៅថ្វាយបង្គំព្រះចេតិយមួយនេះផង សូមអនុមោទនា ៕*







## ១២. ព្រះសក្យមុនីចេតិយ រាជធានីភ្នំពេញ

*ព្រះចេតិយដ៏ស្រស់ស្អាតមួយ មានទីតាំងស្ថិតនៅមុខស្ថានីយ រថភ្លើងរាជធានីភ្នំពេញ បច្ចុប្បន្នមានអាយុកាលចំណាស់ណាស់ហើយ បើគិតចាប់តាំងពីពេលសាងសង់ដំបូងក្នុងឆ្នាំ ១៩៥០ គឺបច្ចុប្បន្នមាន អាយុរហូតដល់ ៧៣ឆ្នាំ។*

*ពិធីបុណ្យឆ្លងចេតិយគឺធ្វើឡើងក្នុងឆ្នាំ ១៩៥៧ គឺធ្វើឡើងជាមួយគ្នានឹងធ្វើពិធីបុណ្យអស្ចារ្យមួយដែលមិនទាន់មានប្រទេសកាន់ពុទ្ធសាសនាធ្វើនោះគឺបុណ្យ**ពុទ្ធសតវត្សរ៍** ២៥០០ ឬបុណ្យពាក់កណ្ដាលសាសនា។ ពិធីបុណ្យកាលណោះ ប្រារព្ធធ្វើនៅក្រុងភ្នំពេញគឺប្រារព្ធឡើងនៅបរិវេណព្រះសក្យមុនីចេតិយនេះ ក្នុងពេលជាមួយគ្នានេះគឺដើម្បីបញ្ចុះព្រះបរមសារីរិកធាតុព្រះបរមគ្រូ។*

*ព្រះសក្យមុនីចេតិយត្រូវបានផ្ដួចផ្ដើមសាងឡើង ដោយសម្ដេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** ក្រោមព្រះរាជឧបត្ថម្ភនៃព្រះចៅផែនដីខ្មែរព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សុរាម្រឹត** និងសម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះឧបយុវរាជ ដែលព្រះអង្គសុទ្ធជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភតាំងពីដើមរៀងមក។*

*លុះសម័យក្រោយ **សម្ដេច នរោត្តម សីហនុ** បានកសាងព្រះសក្យមុនីចេតិយធំថ្មីមួយទៀត នៅលើភ្នំព្រះរាជទ្រព្យនៅឆ្នាំ១៩៩៦-២០០២, ពិធីដង្ហែព្រះសារីរិកធាតុយកទៅ តម្កល់នៅលើភ្នំព្រះរាជទ្រព្យ ប្រព្រឹត្តទៅនៅថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ មិគសិរ ឆ្នាំ មមីចត្វាស័ក ព.ស.២៥៤៦ ត្រូវនិងទី ២៩ ខែ ធ្នូ ឆ្នាំ ២០០២ ៕* *(tnaot.com)*



## ១៣. ប្រាសាទ ឬចេតិយ កសាងពីដីឥដ្ឋ រាជធានីភ្នំពេញ

*ប្រិយមិត្តជាទីរាប់អាន នៅភូមិព្រែកជំ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានផ្លូវចូលតាមវត្តចាន់រង្សី ហៅវត្តទួល, មានប្រាសាទរូបបីតភណ្ឌជាតិ[(១)] ឬចេតិយមានកំពូលប្រាំជារូបព្រហ្មមុខបួន ដែលកសាងពីដីឥដ្ឋ ក្នុងឆ្នាំ ១៩៩៤ បានកសាងរួចប្រហែល ៥ ឆ្នាំ ដោយឧបាសក **រស់ តាំងលី** ជាម្ចាស់ប្រាសាទដីឥដ្ឋនេះ, គាត់ស្លាប់នៅឆ្នាំ ២០១៨។*

*នៅខាងក្នុងចេតិយនេះ ក៏មានតម្កល់រូបព្រះពុទ្ធរូបអង្គធំតូចជាច្រើន, តាមជញ្ជាំងក៏មានរូបចម្លាក់ព្រះពុទ្ធផងដែរ ។*

*បើញាតិញោមណាបានទៅទស្សនាកន្លែងនេះ កុំភ្លេចទៅថ្វាយបង្គំចេតិយនេះផង ព្រោះថាជាឧទ្ទេសិកចេតិយ គួរដល់ការបូជារបស់ពុទ្ធបរិស័ទទាំងឡាយ៕*

*(Facebook Bo Phaktra)*

---

(១). *ប្រាសាទរូបបិតៈភណ្ឌជាតិ គឺឈ្មោះអ្នកភូមិស្រុកហៅប៉ុណ្ណោះ*





## ១៤. ព្រះសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ

*ព្រះសក្យមុនីចេតិយ ជាទីសក្ការៈដ៏ធំមួយរបស់ពុទ្ធបរិស័ទកម្ពុជាយើង, ដែលស្ថិតនៅរមណីយដ្ឋាន ភ្នំឧដុង្គ គឺជារមណីយដ្ឋានទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ នៅក្នុង ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ។*

*ព្រះសក្យមុនីចេតិយ មានទីតាំងនៅលើភ្នំព្រះរាជទ្រព្យ បានចាប់កសាងនៅថ្ងៃ ព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ព.ស.២៥៤០ ត្រូវនឹងថ្ងៃទី ០៨ ខែសីហា ឆ្នាំ ១៩៩៦ (ជាថ្ងៃបញ្ចុះបឋមសិលា) ពិធីនេះ ស្ថិតក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះរាជអគ្គមហេសី* ***មុនីនាថ សីហនុ*** *។*

*ព្រះចេតិយបានកសាងរួចស្រេចជាស្ថាពរ នៅថ្ងៃ ព្រហស្បតិ៍ ០៦ រោច ខែស្រាពណ៍ ព.ស.២៥៤៦ ត្រូវនឹងថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០២ ។*

*ពិធីដង្ហែព្រះសារីរិកធាតុ ដែលចេញដំណើរពី ព្រះសក្យមុនីចេតិយភ្នំពេញទៅកាន់ភ្នំព្រះរាជទ្រព្យ ប្រារព្ធធ្វើឡើង នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០២ ។*

*ព្រះចេតិយនេះ មានក្បូរក្បាច់រចនាប័ទ្មដ៏ស្អាតគួរជាទីជ្រះថ្លា នៅតាមហោជាងទាំង៤ នៃចេតិយមានរូបចម្លាក់ពុទ្ធប្រវត្តិ ព្រះអង្គទ្រង់ប្រសូតជាដើម, នៅខាងក្នុងចេតិយជាន់ក្រោម មានតម្កល់ព្រះពុទ្ធ បដិមារជំតូចជាច្រើន ដែលយើងអាចចូលទៅថ្វាយបង្គំបាន, រីឯជាន់លើ បង្អស់មានបុស្បុកមួយតម្កល់ព្រះបរមសារីរិកធាតុក្នុងទីនោះ ។*

*(សៀវភៅ មគ្គុទេសក៍ទេសចរ)*



## ១៥. ព្រះគោតមចេតិយ វត្តមហាវ័ន គិរីរម្យចាស់

*ព្រះគោតមចេតិយ វត្តមហាវ័ន គិរីរម្យចាស់ ស្ថិតនៅឧទ្យានជាតិ គិរីរម្យ ភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ, ជាប់នឹងរមណីយដ្ឋានទឹកឈូទី៣ ដែលជាតំបន់ទេសចរដ៏ស្រស់ត្រកាលមួយក្នុងព្រះរាជាចក្រកម្ពុជាយើង។*

*ព្រះចេតិយនេះ កសាងនៅ ព.ស.២៥៤៤ គ.ស.២០០០ អ្នកផ្ដើមកសាងដោយលោកគ្រូ* ***មេត្តាបាលោ ទឹម សឿត*** *ព្រះគ្រូចៅ អធិការវត្ត និគ្រោធវ័ន គល់ទទឹង ព្រះភិក្ខុឥន្ទ្រីយ* ***សំវរោ សុទ្ធរ៍សាមៀន*** *ព្រះគ្រូចៅអធិការវត្ត* ***គិរីរម្យចាស់*** *ឧបាសិកា* ***អ៊ុំ សារុន*** *ឧបាសក* ***គា*** *ភិក្ខុ* ***សំសាន*** *ឧបាសក* ***ហ៊ុន សាន*** *ឧបាសិកា* ***សុខ ណារី*** *គណៈកម្មការវត្ត, អ្នកជួយឧបត្ថម្ភកសាងដោយ លោកគ្រូ អគ្គបណ្ឌិត* ***ប៊ុត សាវង្ស*** *សិស្សានុសិស្ស សិក្សា ព្រះធម៌ លោកគ្រូ អគ្គបណ្ឌិត* ***ប៊ុត សាវង្ស*** *និងពុទ្ធបរិស័ទគ្រប់ទិសទីក្នុងប្រទេស ក្រៅប្រទេស ។*

*លុះមកដល់សព្វថ្ងៃនេះលោកម្ចាស់គ្រូ* ***ទីឃរតោ វី សាលឿត*** *ព្រះចៅអធិការវត្តគិរីរម្យចាស់ មានការជួសជុលចេតិយ និងលាប ពណ៌សាជាថ្មី និងមានការអភិវឌ្ឍក្នុងវត្តឱ្យរីកចម្រើនគួរជាទីជ្រះថ្លា របស់ពុទ្ធបរិស័ទ ។*

*ព្រះចេតិយនេះមានបណ្ដោយ ៩.១៩.ម. ទទឹង ៩.១៩.ម. នឹងកម្ពស់ ៤០ម៉ែត្រ នៅខាងក្នុងព្រះចេតិយមានបួនជាន់ ។ ជាន់ខាងក្រោមតម្កល់ព្រះពុទ្ធរូបអង្គធំផ្ចាញ់មារ ធ្វើពីថ្មភ្នំ នៅតាមជញ្ជាំងមានចម្លាក់ពុទ្ធប្រវត្តិ ព្រះអង្គទ្រង់ប្រសូត ព្រះអង្គទ្រង់ត្រាស់ដឹង ព្រះអង្គ-ទ្រង់សម្ដែង*

*ធម្មចក្ក និងព្រះអង្គទ្រង់ចូលបរិនិព្វាន, ជាន់ទី២ តម្កល់ ព្រះពុទ្ធរូបធំតូចជាច្រើនអង្គ និងគ្រឿងសក្ការៈផ្សេងៗ, ជាន់ទី៣ ទំនេរ និងជាន់ទី ៤ តម្កល់បល្ល័ង្កទ្រព្រះកោដ្ឋថ្មកែវ ព្រះបរមសារីរិកធាតុ ។ នៅតាមជញ្ជាំងនៃទិសទាំង៤ ក៏មានរូបចម្លាក់ពុទ្ធប្រវត្តិ ព្រះអង្គទ្រង់ ត្រាស់ដឹងជាដើម និងមានក្បាច់ចម្លាក់យ៉ាងស្អាត គួរជាទីជ្រះថ្លា ៕*

*(Facebook Samein Sun)*



## ១៦. ព្រះសក្យមុនីចេតិយវត្តធុតង្គ ចំការដូង

*ខ្ញុំព្រះករុណា សូមណែនាំលោកអ្នកសប្បុរសប្រុសស្រីឱ្យស្គាល់ ព្រះចេតិយមួយក្នុងវត្តធុតង្គ ចំការដូង តម្កល់ព្រះសារីរិកធាតុ ដែលអារាធនាមកពីប្រទេសថៃ ដោយអ្នកគ្រូ* ***ម៉េង សុចិន*** *ត្រូវជាគ្រូរបស់ លោកគ្រូអគ្គ* ***ប៊ុត សាវង្ស*** *។*

*ចេតិយកសាងដោយព្រះគ្រូចៅអធិការព្រះនាម* ***ហោ គីមសាន*** *ឧបាសក* ***ខួន យ៉ា*** *កម្មការវត្ត និងពុទ្ធបរិស័ទគ្រប់ទិសទី ក្នុងពុទ្ធសករាជ ២៥៤៤ គ្រិស្តសករាជ ២០០០ដែលជាវត្តមួយទ្រទ្រង់ធម៌វិន័យ នាសម័យ មុន។*

*ព្រះចេតិយនេះនៅជៀងខាងត្បូងនៃព្រះវិហារ ដែលស្ថិតនៅ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានី ភ្នំពេញ បើព្រះករុណា លោកម្ចាស់, ញាតិញោម បាននិមន្ត និងអញ្ជើញមកវត្តកុំភ្លេចនៅ ថ្វាយបង្គំចេតិយនេះផង ៕*

*(Facebook: Samein Sun)*









## ១៧. ព្រះចេតិយមហាឧទ្ទេសកចេតិយ វត្តសុវណ្ណគីរីរតនៈ ភ្នំប្រុស

*ព្រះមហាឧទ្ទេសកចេតិយភ្នំប្រុស ស្ថិតនៅលើភ្នំប្រុសខាងក្រោយព្រះវិហារធំ ។ តាមអក្សរដែលចារឹកនៅលើ ព្រះមហាចេតិយនេះបានបញ្ជាក់ថា ៖ ព្រះមហាឧទ្ទេសកចេតិយ ត្រូវបានកសាងឡើងវិញដោយឯកឧត្តម* ***មុត ខៀវ*** *និងលោកជំទាវ* ***អឿន សារ៉ន*** *នៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំរោង ទោស័ក ពុទ្ធសករាជ ២៥៤៤ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០១ ដើម្បីឧទ្ទិសបំពោះអង្គព្រះសម្មាសម្ពុទ្ធ ព្រះបរមគ្រូនៃយើង និងព្រះពុទ្ធសាសនា ។ ប្រវត្តិព្រះមហាឧទ្ទេសកចេតិយត្រូវបាន កសាងឡើងដោយព្រះតេជគុណព្រះនាម* ***កែវ សួរ្យ*** *ព្រះគ្រូចៅអធិការ ទី១ វត្ត****សុវណ្ណ គិរីរតនៈ*** *ភ្នំប្រុស នៅថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំមមី សំរឹទ្ធិស័ក ពុទ្ធសករាជ ២៤៦២ ត្រូវនឹងថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩១៨ ដើម្បីឧទ្ទិសចំពោះ អង្គព្រះសម្មាសម្ពុទ្ធ ព្រះបរមគ្រូនៃយើង និង ព្រះពុទ្ធ សាសនា ។ ព្រះមហាឧទ្ទេសកចេតិយនេះត្រូវបានបំផ្លាញចោលទាំង ស្រុងនៅថ្ងៃអង្គារ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ នព្វស័ក ព.ស. ២៥២១ ត្រូវនឹងថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៧ វេលាម៉ោង ១៤រសៀល ដោយបនប្រល័យពូជសាសន៍នៃ របបកម្ពុជាប្រជាធិបតេយ្យ ៕*











## ១៨. ព្រះត្រៃរតនចេតិយ វត្តនិគ្រោធវ័ន "គល់ទទឹង"

ព្រះត្រៃរតនចេតិយ កសាងនិងសម្ពោធឱ្យប្រើប្រាស់នៅពុទ្ធសក-រាជ ២៥៤៨ គ្រិស្តសករាជ២០០៤ ។ អ្នកឧកញ៉ាមហាឧបាសិកា **ញឹក ប៊ុនថា** ដង្ហែព្រះសារីរិកធាតុពីប្រទេស**ឥណ្ឌា**ប្រគេន ព្រះគ្រូធម្មាចារ្យ មេត្តាបាលោ **ទឹម សឿត** ដើម្បីតម្កល់ក្នុងព្រះត្រៃរតនចេតិយ នាពេលសម្ពោធ ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០០៤។

ព្រះចេតិយនេះ កសាងឡើងពីឥដ្ឋនិង ស៊ីម៉ងត៍ មានបីជាន់គឺៈ ជាន់ទី១ តម្កល់ព្រះពុទ្ធរូបកសាងពីថ្មកែវ ជាន់ទី២ មិនតម្កល់អ្វីទេ និង ជាន់ទី៣ តម្កល់ព្រះកោដ្ឋព្រះបរមសារីរិកធាតុក្នុងបុស្បុក ។ ព្រះចេតិយនេះ កសាងដើម្បីឧទ្ទិសថ្វាយដល់គុណព្រះរតនត្រៃ មានព្រះពុទ្ធជាប្រធាន។

បូជនីយដ្ឋានមួយនេះ ក៏ជាកន្លែងប្រារព្ធកម្មពិធីបុណ្យដូចជា បុណ្យវិសាខបូជា មាឃបូជា និងថ្ងៃសីលជាដើម, ដែលមានពុទ្ធបរិស័ទចូលរួម ធ្វើបទនមស្ការគុណព្រះរតនត្រៃ ដង្ហែគ្រឿងសក្ការបូជាជុំវិញព្រះចេតិយ បូជាប្រទីប និងធ្វើសមាធិជាដើម ។

លុះមកដល់សព្វថ្ងៃនេះ ព្រះគ្រូ មង្គលធម្មកិច្ច សុវណ្ណជោតោ **ភួង សុវណ្ណ** ជាព្រះចៅអធិការវត្ត លោកគ្រូសូត្រស្តាំព្រះនាម **តុន គីមសាយ** លោកគ្រូសូត្រឆ្វេងព្រះនាម **គួ សុភាព** មានការដឹកនាំបន្ត ។ ក្នុងវត្តក៏មានសាលាធម្មវិន័យ ដែលសមណៈសិស្សចូលសិក្សា ចំនួន២០០អង្គ ជាង និងមានការអភិវឌ្ឍន៍ក្នុងវត្ត រួមមានសួនច្បារ កុដិជាដើម ។ វត្តនិគ្រោធវ័ន **គល់ទទឹង** ស្ថិតនៅភូមិ កោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជ

ជាទីភ្នំពេញ៕

(សៀវភៅប្រវត្តិ វត្តនិគ្រោធវ័ន ហៅគល់ទទឹង)













## ១៩. ព្រះសក្យមុនីចេតិយ វត្តព្រែកស្ដី

*វត្តព្រែកស្ដី ជាវត្តមួយដែលមានព្រះសង្ឃសិក្សារៀនសូត្រព្រះធម៌ព្រះវិន័យ ។ ក្នុងវត្តនេះក៏មានព្រះសក្យមុនីចេតិយតម្កល់ព្រះសារីរិក-ធាតុ មួយយ៉ាងស្អាតគួរជាទីជ្រះថ្លារបស់ពុទ្ធបរិស័ទទាំងឡាយផងដែរ។*

*ក្នុងថ្ងៃបុណ្យវិសាខបូជា មាឃបូជាជាដើម មានប្រារព្ធពិធីនៅខាងមុខព្រះ ចេតិយនេះ ដែលមានព្រះសង្ឃនិងពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។ ព្រះសក្យមុនីចេតិយនេះស្ថិតនៅ វត្តព្រែកស្ដី សង្កាត់ព្រែកស្ដីក្រុង សំពៅពូន ខេត្តកណ្ដាល។*







## ២០. ព្រះបរមចេតិយ វត្តសិរីឧត្តមស្រះជុំអណ្តូងក្តី

*ញាតិញោមពុទ្ធបរិស័ទជាទីរាប់អាន ខ្ញុំករុណាណែនាំឱ្យស្គាល់ចេតិយមួយ ដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា (រូបក្នុងប្លង់នេះ), ដែលសព្វថ្ងៃនេះកំពុងកសាងបានប្រហែល ៦០ភាគរយហើយ ។ ព្រះចេតិយនេះដឹកនាំកសាងដោយព្រះគ្រូ* ***សុវណ្ណជោតិញាណ ហ៊ុត គឹមហ៊ាន*** *ព្រះចៅអធិការវត្ត ព្រះសង្ឃ និងគណកម្មការវត្ត ព្រះចេតិយមានទំហំបណ្តោយ ១៨ គុណានឹងទទឹង ១៨ម៉ែត្រ និងកម្ពស់ ២៨.៩០ ម៉ែត្រ ព្រះបរមចេតិយ វត្តសិរីឧត្តមស្រះជុំ ស្ថិតនៅភូមិសាមគ្គី ឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។*

*ខ្ញុំព្រះករុណាសង្ឃឹមថាបរិស័ទដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រៃ និងជួយកសាងព្រះចេតិយមួយនេះឱ្យបានឆាប់រួចរាល់នៅថ្ងៃខាងមុខ ដើម្បីប្រយោជន៍ដល់មនុស្ស និងទេវតាឡាយ ៕*

*សូមអនុមោទនាបុណ្យ !*









# ២១. ព្រះមហាគន្ធកុដិ ខេត្តបាត់ដំបង

*សាធុសប្បុរសប្រុសស្រីទាំងឡាយ នៅខេត្តបាត់ដំបង មានព្រះមហាគន្ធកុដិយ៉ាងធំមួយ មានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, ព្រះមហាគន្ធកុដិនេះផ្ដួចផ្ដើមដោយលោកគ្រូអគ្គបណ្ឌិត* ***ប៊ុត សាវង្ស*** *នឹងកូនសិស្សសិក្សាព្រះធម៌ទាំងក្នុងប្រទេស នឹងក្រៅប្រទេស, ធ្វើពិធីបុណ្យសម្ពោធឆ្លងនៅថ្ងៃសៅរ៍ ១១កើត ដល់ថ្ងៃព្រហស្បតិ៍ ១រោច ខែផល្គុន ឆ្នាំមមី ឆស័ក ព.ស.២៥៥៨ ត្រូវនឹងថ្ងៃទី ២៨ ខែកុម្ភៈ ដល់ថ្ងៃទី ៥ ខែមីនា ឆ្នាំ២០១៥ ដែលមានពុទ្ធបរិស័ទចូលរួមពិធីបុណ្យនេះយ៉ាងច្រើនកុះករ។*

*ព្រះមហាគន្ធកុដិនេះមានពីរជាន់ ជាន់ខាងក្រោមជាកន្លែងសិក្សារៀនសូត្រព្រះធម៌ព្រះវិន័យ ក៏ជាកន្លែងប្រារព្ធពិធីផ្សេងៗ ដូចជា បុណ្យវិសាខបូជាជាដើម នឹងជាន់ខាងលើជាទីសក្ការៈបូជា ដែលមានបុស្បុកតម្កល់ព្រះពុទ្ធរូបទ្រង់ដោះប្រស្នាព្រះឥន្ទ្រ រូបព្រះពុទ្ធទ្រង់ផ្ទុំ នឹងនៅខាងលើបុស្បុកនេះតម្កល់ព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់ដែលអារាធនាមកពីប្រទេស**សិរីលង្កា**, យ៉ាងស្អាតគួរជាជ្រះថ្លារបស់មនុស្សទេវតាទាំងឡាយ ។*







## ២២. ព្រះគន្ធកុដិ វត្តអាស្រមព្រះគន្ធកុដិ

*នៅខេត្តបាត់ដំបង មានវត្តមួយឈ្មោះថា វត្តអាស្រមព្រះគន្ធកុដិ ក្នុងវត្តនេះមានកូនភ្នំសុមនកូដសិប្បនិម្មិតមួយ នៅខាងលើភ្នំនោះមានព្រះគន្ធកុដិ ខាងក្នុងកុដិនេះ មានតម្កល់ព្រះពុទ្ធបដិមាធ្វើពីស្ពាន់ព្រះអង្គទ្រង់ផ្ចាញ់មារ នៅខាងស្ដាំព្រះពុទ្ធបដិមា មានព្រះកោដិយ៉ាងស្អាតតម្កល់នូវព្រះសារីរិកធាតុ និងខាងឆ្វេងតម្កល់ព្រះពុទ្ធបាទយ៉ាងស្អាតគួរជាទីជ្រះថ្លា ។*

*នៅថ្ងៃសីល ថ្ងៃបុណ្យវិសាខបូជា មាឃបូជាជាដើម, មានការដង្ហែព្រះសារីរិកធាតុពីព្រះគន្ធកុដិ ទៅគង់ក្នុងទីលានព្រះពោធិព្រឹក្ស មានការបូជាផ្កា ប្រទីបជាដើម ដែលមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។*

*ព្រះគន្ធកុដិនេះដឹកនាំកសាងដោយលោកគ្រូអគ្គ* ***ប៊ុត សាវង្ស*** *ឧបាសក* ***នាក់ ម៉ៅ*** *,ឧបាសក* ***សំ ឆាយ****, ឧបាសក* ***ឡាំ ធឿន****, ឧបាសក* ***សុខ ហ៊ិត****, ឧបាសក* ***កុយ សាម៉ន*** *និងកូនសិក្សលោកគ្រូ* ***ប៊ុត សាវង្ស*** *ទាំងក្នុងប្រទេស និងក្រៅប្រទេស, នាថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ទោស័ក ព.ស.២៥៤៤ ត្រូវនឹងថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០០ ។*

*រីឯនៅក្នុងវត្តនេះក៏មាន ព្រះវិហារយ៉ាងស្រស់ស្អាត, កុដិព្រះសង្ឃស្នាក់នៅគង់សិក្សារៀនសូត្រព្រះធម៌ព្រះវិន័យគួរជាទីជ្រះថ្លា,* ***សមូហចេតិយ*** *សម្រាប់តម្កល់អដ្ឋិធាតុពុទ្ធបរិស័ទពីទីជិតឆ្ងាយ ។ បរិស្ថានក្នុងអារាមនេះគួរជាទីមនោរម្យនៃជនទាំងឡាយ ដែលស្ថិតនៅភូមិរំចេក៣ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។*

*(Facebook ភិក្ខុមេត្តជនោ មឿន សឺន)*



## ២៣. ព្រះមុនិរាជចេតិយ វត្តរស្មីសោភណារាម សន្លុង

បើញាតិញោមពុទ្ធបរិស័ទ ចេញដំណើរពីភ្នំពេញទៅតាមផ្លូវជាតិលេខ២ ហួសរង្វង់មូលក្បូរស្រូវទៅប្រមាណ ៣គីឡូម៉ែត្រ យើងនឹងឃើញខ្លោងទ្វារវត្តសន្លុងនៅខាងឆ្វេងដៃ, ក្នុងវត្តយើងនិងឃើញព្រះមុនិ-រាជចេតិយដ៏ស្រស់ស្អាតគួរជាទីជ្រះថ្លា ដែលកសាងដើម្បីឧទ្ទិសដល់គុណព្រះពុទ្ធជាម្ចាស់ ជាធាតុចេតិយ ។ ដែលស្ថិតនៅភូមិស្រុកធំ ឃុំដើងកើបស្រុកក-ណ្តាលស្ទឹង ខេត្តកណ្តាល។

ព្រះចេតិយនេះដឹកនាំកសាងដោយព្រះចៅអធិការព្រះនាម **ពុទ្ធវីរោ យូ ជួប** ដែលមានព្រះគ្រូធម្មសេនានុរក្ស **អ៊ុំ គឹមអាន** ជាអ្នកកាន់ការកសាងដោយផ្ទាល់ និងព្រះសង្ឃ គណកម្មការវត្ត កសាងនៅថ្ងៃសៅរ៍ ៦រោច ខែចេត្រ ឆ្នាំមមែ បញ្ចស័ក ព.ស.២៥៤៧ គ.ស.២០០៤។

ព្រះចេតិយមានការជួសជុលនិងលាបពណ៌ថ្នាំ និងធ្វើពិធីបុណ្យដង្ហែព្រះបរមសារីរិកធាតុ វេរសុវណ្ណកោដ្ឋនិងឆ្លងចេតិយជាលើកទី២ ដែលប្រារព្ធនៅថ្ងៃសុក្រ សៅរ៍ អាទិត្យ ៩.១០.១១ កើត ខែ ស្រាពណ៍ ឆ្នាំថោះ ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៥.៥៦.២៧ ខែសីហា ឆ្នាំ ២០២៣, ក្នុងបុណ្យនោះ យើងឃើញមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ គ្រប់ទិសទី ៕

*(Facebook: Oum Kimann)*









## ២៤. ព្រះពុទ្ធចេតិយ វត្តចំបក់មានជ័យ

*វត្តចំបក់មានជ័យ ស្ថិតនៅភូមិស្វាយឧត្តម ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល ក្នុងវត្តនេះមានព្រះពុទ្ធចេតិយមួយ យ៉ាងស្អាតគួរជាទីជ្រះថ្លា ដែលមានកម្ពស់ ៣៥ម៉ែត្រ ព្រះចេតិយនេះកសាងរួចរាល់ជាស្ថាពរនៅថ្ងៃចន្ទ ១១កើត ខែពិសាខ ឆ្នាំរកា សប្តស័ក ព.ស.២៥៤៨ គ.ស.២០០៥, រីឯព្រះសារីរិកធាតុដែលតម្កល់ក្នុងព្រះ-ចេតិយនេះ អារាធនាមកពីប្រទេសថៃ។*

*ព្រះចេតិយនេះ ដឹកនាំកសាងដោយព្រះគ្រូចៅអធិការ ព្រះនាម* ***ដុល ឌឿន*** *ព្រះសង្ឃ លោកអាចារ្យគណកម្មការ ព្រមទាំងពុទ្ធបរិស័ទគ្រប់ទិសទី។*

*លុះសម័យក្រោយមកទៀត ព្រះគ្រូចៅអធិការថ្មី ព្រះនាម* ***វិរិយប្បិយោ សួន ផន*** *បានដឹកនាំពុទ្ធបរិស័ទ្ធជួសជុលព្រះចេតិយនេះ ផងដែរ។*

*ក្នុងថ្ងៃបុណ្យធំៗដូចជាវិសាខបូជាជាដើម មានពុទ្ធបរិស័ទចូលរួមក្នុងកម្មពិធីនោះយ៉ាងច្រើនកុះករផងដែរ ។*

*(Facebook សុខវិថី លីហួរ)*



## ២៥. ព្រះបរមចេតិយ វត្តវេឡុវ័ន ព្រៃឬស្សី

*ប្រិយមិត្តជាទីរាប់អាន ខ្ញុំព្រះករុណា នឹងណែនាំលោកអ្នកឱ្យស្គាល់ព្រះបរមចេតិយមួយនៅវត្ត**វេឡុវ័ន** (**ព្រៃឬស្សី** ) ដែលមានរាងជាប្រាំបីជ្រុង ជាជាន់ៗ ជាថ្នាក់ៗ ដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, នៅខាងក្នុងព្រះចេតិយតម្កល់នូវព្រះពុទ្ធបដិមា ៤ព្រះអង្គ និងព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ, ជាន់ខាងលើទី២ តម្កល់នូវព្រះពុទ្ធបដិមាច្រើនព្រះអង្គ, នៅលើជាន់ទី៣ តម្កល់ព្រះបរម សារីរិកធាតុ របស់ព្រះសម្មាសម្ពុទ្ធដែលយាងមកពី**ប្រទេសស្រីលង្កា**, នៅតាមហោជាងទាំង៤ នៃព្រះបរមចេតិយ មានក្បាច់រចនាយ៉ាងស្អាត គួរជាទីជ្រះថ្លា។*

*ព្រះបរមចេតិយនេះ ដឹកនាំកសាងដោយព្រះគ្រូធម្មាចារ្យ សោក-ណត្ថោ **សោម សុភាព** ព្រះគ្រូចៅអធិការវត្តវេឡុវ័ន( ព្រៃឬស្សី ) ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ព្រមទាំងគណកម្មការ ពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ។ ព្រះបរមចេតិយបានកសាង នៅថ្ងៃ ៥កើត ខែជេស្ឋ ឆ្នាំរកា ព.ស.២៥៤៨, ដែលមានទំហំទទឹង ១៤ ម៉ែត្រ ទំហំបណ្តោយ ១៤ ម៉ែត្រនិង កម្ពស់ ៣៥ម៉ែត្រ, បានកសាងរួចរាល់ស្រេច និងបានធ្វើពិធីបុណ្យសម្ពោធឆ្លងថ្ងៃ ១៥ កើត ខែផល្គុន ឆ្នាំកុរ នព្វស័ក ព.ស. ២៥៥១ ។*

*រីឯព្រះសារីរិកធាតុ តម្កល់ក្នុងព្រះបរមចេតិយ អារាធនាមកពីប្រទេស**ស្រីលង្កា** ដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ**ប៊ុតសាវង្ស** ក៏ជាបូជនីយដ្ឋានសម្រាប់ពុទ្ធបរិស័ទគោរពបូជាពីគ្រប់ទិសទី នៅក្នុងថ្ងៃ*

បុណ្យមាឃបូជា វិសាខបូជាជាដើម មានញាតិញោមចូលរួម យ៉ាងច្រើនកុះករ ។ ដែលស្ថិតនៅបច្ចុប្បន្ននេះ ភូមិព្រៃមាសទី ២ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ ៕

*(facebook Sudhamma VongSarann)*



## ២៦. ព្រះគន្ធកុដិ វត្តដំណាក់

*សាធុសប្បុរសប្រុសស្រីទាំងឡាយ នៅខេត្តសៀមរាប មានព្រះគន្ធកុដិមួយក្នុងវត្តដំណាក់ ដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ។*

*ព្រះគន្ធកុដិនេះ កសាងក្នុង ព.ស.២៥៥១ គ.ស.២០០៧ ដែលមានកម្ពស់ ១៦ ម៉ែត្របីជាន់ នៅខាងក្នុងតម្កល់ព្រះពុទ្ធបដិមាប្រាក់ ចីវរមាស ព្រះនេត្រពេជ្រ ព្រមទាំងតម្កល់នូវ ព្រះសុវណ្ណវជិរកោដ្ឋបរមសរីរក- ធាតុ ព្រះបដិមាចង្កូមកែវ និងគម្ពីរព្រះត្រៃបិដក កសាងដោយ លោកគ្រូ ធម្មាចារ្យ **កែវ វិមុត្តិ** ព្រមទាំងព្រះសង្ឃ លោកអាចារ្យ គណកម្មការ និងពុទ្ធបរិស័ទទាំងអស់ ។*

*បើព្រះករុណាលោកម្ចាស់ និងញាតិញោមណាបានទៅខេត្តសៀមរាប កុំភ្លេចឆ្លៀងចូលបានថ្វាយបង្គំព្រះគន្ធកុដិនេះ ដោយសេចក្តីជ្រះថ្លាទៅហោង ៕*





ព្រះគន្ធកុដិ ក្នុងវត្តដំណាក់នាខេត្តសៀមរាប កសាងក្នុង ព.ស.២៥៥១ មានកម្ពស់ ១៦ ម៉ែត្រ តម្កល់ព្រះពុទ្ធបដិមាប្រាក់ ចីវរមាស ព្រះនេត្រពេជ្រ ព្រមទាំងតម្កល់នូវ ព្រះសុវណ្ណវជិរកោដ្ឋបរមសារីរិកធាតុ ព្រះបដិមាចង្កូមកែវ និង គម្ពីរព្រះត្រៃបិដក កសាងដោយលោកគ្រូ ធម្មាចារ្យ **កែត ទិមុត្ត** ព្រមទាំងព្រះសង្ឃ លោកអាចារ្យ គណកម្មការ និង ពុទ្ធបរិស័ទទាំងអស់។





## ២៧. ព្រះសុគន្ធកុដិ វត្តរស្មីសាមគ្គី រតនារាម

*ខ្ញុំព្រះករុណា នឹងណែនាំអ្នកលោកអ្នកអានឱ្យស្គាល់ព្រះសុគន្ធ-កុដិមួយ ដែលមានរចនាប័ទ្មយ៉ាងស្អាតគួរជាទីជ្រះថ្លា, ព្រះសុគន្ធកុដិនេះ មានសសរមួយឡើងទៅលើទ្រព្រះសុគន្ធកុដិ ដែលមានជណ្ដើរកាច់ឡើងទៅលើ, ដែលកសាងដោយ ឧបាសកហោជាន និងឧបាសិកា* ***ឈួន ស្រ៊ា*** *នៅពុទ្ធសករាជ ២៥៥២ និង គ្រិស្តសករាជ ២០០៨ ។*

*លុះមកដល់សម័យ ព្រះគ្រូរស្មីសិរីវឌ្ឍនមុនី* ***ជឹម ច័ន្ទមុនី*** *លោកបានកែព្រះសុគន្ធកុដិកនេះកន្លែងខ្លះ ដូចជាស៊ុមទ្វារ ស៊ុមបង្អួច លាបថ្នាំព្រះសុគន្ធកុដិ និងនៅខាងក្នុងព្រះគន្ធកុដិមានរូបចម្លាក់ព្រះពុទ្ធ ប្រវត្តិព្រះអង្គទ្រង់ប្រសូត ត្រាស់ដឹង បរិនិព្វាន និងកន្លែងពុទ្ធាសនៈ ដែលតម្កល់ព្រះសារីរិកធាតុ ព្រះអរហន្តធាតុសាវ័ក ដែលអារាធនា មកពី* ***វត្តភ្នំតូច*** *ខេត្តបន្ទាយមានជ័យ។*

*សព្វថ្ងៃព្រះសុគន្ធកុដិ វត្តរស្មីសាមគ្គីរតនារាម ស្ថិតនៅសង្កាត់ជ្រោយតាកែវ ក្រុងសំពៅពូន ខេត្តកណ្ដាល ក៏មានសាលាធម្មវិន័យកំពុងកសាងផងដែរ ៕*

*(Facebook ព្រះភិក្ខុ ករវីជម្មោ)*











## **២៨. ព្រះបទុមចេតិយ វត្តមណីរតនារាម**

*ព្រះបទុមចេតិយ វត្តមណីរតនារាម ជាស្ថាបត្យកម្មសំណង់ថ្មីមួយ ដែលមានក្បាច់រចនាដូចផ្កាឈូកទ្រព្រះចេតិយយ៉ាងស្រស់ស្អាតគួរជាទីជ្រះថ្លា នៅតាមហោជាងទាំង៤ នៃព្រះចេតិយនេះ មានរូបចម្លាក់ពុទ្ធប្រវត្តិ ព្រះអង្គទ្រង់ប្រសូតជាដើម, នៅខាងក្នុងចេតិយ មានព្រះពុទ្ធបដិមាទ្រង់ឈរ ៤ ព្រះអង្គបែរព្រះភ័ក្ត្រទៅទិសទាំងបួន , ជាន់ទី២ ជាន់ទី៣ ទំនេរនិងជាន់ទី ៤ បង្អស់តម្កល់ព្រះសារីរិកធាតុ ដែលអាពធនាមកពីប្រទេស**ឥណ្ឌា លង្កា ភូមា** ជាដើម។*

*ព្រះចេតិយនេះ ដឹកនាំកសាងដោយលោកគ្រូ **សាន សុជា** ព្រះសង្ឃ និងគណកម្មការវត្ត នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៩ &ព.ស.២៥៥២ ដែលមានទំហំមាត់ផ្កាឈូកជុំវិញចេតិយ ១៨ ម៉ែត្រ និងកម្ពស់ ៥១ ម៉ែត្រ សព្វថ្ងៃនេះបទុមចេតិយកំពុងកសាងបានសម្រេចប្រមាណជាង ៩៥ % ហើយ និងធ្វើពិធីបុណ្យសម្ពោធឆ្លងនៅខែ ៣ ឆ្នាំ ២០២៤ ។ ដែលស្ថិតនៅភូមិថ្នល់បំបែក ស្ថិតក្នុងសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។*

*បើយើងចេញដំណើរពីភ្នំពេញទៅក្រុងពោធិ៍សាត់ យើងនឹងឃើញព្រះចេតិយនោះពីចម្ងាយ នៅខាងឆ្វេងដៃយើង គួរជាទីជ្រះថ្លា ៕*










ព្រះបទុមចេតិយ

## ២៩. ព្រះគន្ធកុដិ វត្តសុវណ្ណបទុម "ចំបក់មាស"

*វត្តសុវណ្ណបទុម ចំបក់មាស ជាវត្តបុរាណមួយក្នុងព្រះរាជាណាចក្រកម្ពុជា, ក៏ជាសម្នាក់ព្រះសង្ឃសិក្សារៀនសូត្រទ្រទ្រង់ព្រះធម៌ព្រះវិន័យផងដែរ, ដែលស្ថិតនៅ ភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។ នៅក្នុងវត្តអារាមយើងឃើញមានការអភិវឌ្ឍជាច្រើន មានសាលារៀន បូជនីយដ្ឋានផ្សេងៗ មានព្រះគន្ធកុដិជាដើម។*

*ព្រះគន្ធកុដិផ្ដើមកសាងដោយព្រះគ្រូចៅអធិការ សុវណ្ណជោតោ* ***អ៊ុប សុខុន*** *ភិក្ខុ សាមណេរព្រមទាំង គណកម្មការវត្ត នាថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំឆ្លូវ ព.ស.២៥៥៣ និងបានកសាងរួចស្រេចជាស្ថាពរនៅថ្ងៃសៅរ៍ ១៤រោច ខែមិគសិរ ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥ / ២៤.១២.២០១១ ។*

*ព្រះគន្ធកុដិមានបណ្ដោយ ១២ម៉ែត្រ ទទឹង ១២ម៉ែត្រ នឹងកម្ពស់ ១៨ ម៉ែត្រ មានខឿនបីជាន់ ខាងក្នុងមានបន្ទប់ទុកវត្ថុផ្សេងៗ និងគំនូរពុទ្ធប្រវត្តិបែបបុរាណជាដើម, នៅជាន់ខាងលើជាគន្ធកុដិសម្រាប់តម្កល់ព្រះសារីរិកធាតុ ព្រះពុទ្ធបដិមា និងស្នាមព្រះពុទ្ធបាទមួយគូ ផងដែរ រីឯដំបូលខាងលើ ជាចេតិយកំពូលប្រាំ។ នៅខាងមុខព្រះគន្ធកុដិមានព្រះមហាពោធិព្រឹក្ស ព្រះពុទ្ធកសាងពីស្ពាន់ទ្រង់ប្រោសសត្វ ខាងក្រោយព្រះគន្ធកុដិមានព្រះពុទ្ធបរិនិព្វានកសាងពីស្ពាន់ ខាងក្រោយទៀតមានព្រះពុទ្ធបដិមាកសាងពីថ្មភ្នំយ៉ាងធំ ប្រហែលគ្នានិងពុទ្ធមណ្ឌលវិបស្សនាធុរៈនៅអង្គរស្សផងដែរ ៕*

*(Facebook: បញ្ញា លង្ការោ)*


vivo V19
Perfect Shot
2022.02.17 08:11





## ៣០. ព្រះសក្យមុនីចេតិយ វត្តបទុមសាគរ

*សាធុសប្បុរសប្រុសស្រីទាំងឡាយ នៅក្រុងតាខ្មៅមានវត្តមួយនៅកណ្ដាលបឹង ឈ្មោះថាវត្តបទុមសាគរ ជាវត្តមួយខាងទ្រទ្រង់សមថ និងវិបស្សនា ដែលមានអ្នកមកសិក្សាបដិបត្តិក្នុងវត្តនេះយ៉ាងច្រើនកុះករ។*

*នៅក្នុងវត្ត មានអាគារដ៏ធំមួយឈ្មោះថា សាលាសមថវិបស្សនាកម្មដ្ឋានអន្តរជាតិកម្ពុជា ដែលដឹកនាំកសាងដោយព្រះអង្គគ្រូវិបស្សនាចារ្យ កុសលត្ថេរ **ស៊ើន សុកោសល** ជាព្រះចៅអធិការវត្ត ព្រះសង្ឃ លោកអាចារ្យ គណកម្មការវត្ត និងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស។*

*សាលានេះកសាងនៅថ្ងៃទី០៧ ខែ៧ ឆ្នាំ២០១៤ សាលាវិបស្សនាឬព្រះសក្យមុនីចេតិយ មួយនេះ ជាសាលារៀនផង ជាព្រះវិហារផង មានទំហំ ៤៤ × ៤៣ ម៉ែត្រ មានបួនជាន់ ជាន់ក្រោមជាកន្លែងប្រារព្ធកម្មពិធីបុណ្យផ្សេងៗ ជាន់ទីពីរជាកន្លែងបដិបត្តិ ជាន់ទីបីជាកន្លែងបដិបត្តិ និងជាន់ទីបួនជាព្រះវិហារ ក៏ជាកន្លែងតម្កល់ព្រះសក្យមុនីចេតិយមួយយ៉ាងស្អាត ដែលកសាងពី**ការស៊ីលីកូដ** មានពណ៌ដូចត្រួយចេក មានកម្ពស់បួនម៉ែត្រជាងកសាងនៅឆ្នាំ២០២០ សព្វថ្ងៃនេះកំពុងតែកសាងបាន ៩០ ភាគរយ និងសាលាក៏កំពុងកសាងផងដែរ។*

*សូមសាធុសប្បុរសទាំងឡាយមានសទ្ធាចូលរួមកសាងសាលានេះ និងព្រះចេតិយនេះឱ្យបានឆាប់រួចរាល់ទៅហោង៕*









## ៣១. ព្រះមហាចូឡាមណីចេតិយ ឧទ្យានជាតិសគិរីរម្យ

*មជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា ត្រូវបានសាងសង់ឡើង នៅលើផ្ទៃដី ១២៦ ហិតា ស្ថិតនៅក្នុង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ គម្រោងបុង់នេះ មានរាងសណ្ឋានជាស្លឹកពោធិ៍ ហើយនៅក្នុងបរិវេណ ទាំងក្រៅ និងក្នុងនឹងសាងសង់ទិដ្ឋភាពចម្រុះពាក់ព័ន្ធព្រះពុទ្ធសាសនា ។*

*នៅចំកណ្តាលសាងសង់ព្រះមហាចូឡាមណីចេតិយ ព្រះពុទ្ធ សមណគោតម ដ៏ធំបំផុតមានទទឹង ៨០ ម៉ែត្រ និងកម្ពស់រហូតដល់ទៅ ៩២,៧០ម៉ែត្រ សម្រាប់តម្កល់ព្រះបរមសារីរិកធាតុព្រះពុទ្ធជាម្ចាស់ដែល បានអារាធនាពី**ប្រទេសឥណ្ឌា** ។*

*ព្រះមហាចេតិយនេះ មានកម្ពស់ ១១ជាន់ ដែលក្នុងនោះមាន សាលសន្និសីទ សាលប្រជុំ សាលពិព័រណ៍ បណ្ណាល័យ រដ្ឋបាល និង កន្លែងជាច្រើនទៀត ។ មានមហាប្រាសាទចំនួន១២ បែងចែកជាពីរ ជួរ ព័ទ្ធជុំវិញ ។*

*ជួរទី១ ប្រាសាទតម្កល់គម្ពីរ ក្បួនច្បាប់សាសនា និងផ្ទាំងថ្មចារ គម្ពីរ ព្រះត្រៃបិដកទាំង ១១០ ភាគជាដើម។*

*សរសេរមតិ…តាមការសិក្សា គម្រោងនេះ អាចនឹងចំណាយថវិកា ប្រមាណជាង ១០លានដុល្លារអាមេរិក ហើយត្រូវប្រើពេលប្រហែលពី ៥ ទៅ៧ឆ្នាំ ទើបរួចរាល់ ។ ដែលនាំកសាង ដោយឧបាសិកា ធម្មបណ្ឌិត **ញឹក ប៊ុនថា** និងពុទ្ធបរិស័ទពីទីជិតទីឆ្ងាយ, សព្វថ្ងៃនេះកំពុងកសាង ព្រះ ចេតិយ និងស្រះទឹកជាដើម សូមពុទ្ធបរិស័ទចូលរួមកសាងតាម កម្លាំង សទ្ធាជ្រះថ្លារៀងៗខ្លួន ៕ (Facebook Khmer Architectural)*











## ៣២. ព្រះសុវណ្ណចេតិយ វត្តស្រះមុជ្ជលិន្ទ "កោះត្រើង"

*ព្រះសុវណ្ណចេតិយនេះ ដឹកនាំកសាងដោយព្រះគ្រូចៅអធិការវត្ត ព្រះនាម* **អ៊ួន ប្រាក់** *និងលោកអាចារ្យគណកម្មការវត្ត ព្រមទាំងពុទ្ធបរិស័ទជិតឆ្ងាយ, នៅថ្ងៃព្រហស្បតិ៍ ទី៩ ខែឧសភា ឆ្នាំ២០១៣, ដែលមានទំហំបណ្ដោយ ៣០ម៉ែត្រ ទទឹង ៣០ម៉ែត្រ និងកម្ពស់ ២៨ម៉ែត្រ ។*

*ព្រះសុវណ្ណចេតិយ មានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លារបស់សាធុសប្បុរសទាំងឡាយ, នៅខាងក្នុងព្រះចេតិយមានតម្កល់ព្រះពុទ្ធបដិមា និងព្រះសារីរិកធាតុដែលអារាធនាមកពីប្រទេស***សិរីលង្កា** *ដោយលោកម្ចាស់* **ធុំ សាវឿន** *គង់នៅវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង ។*

*ព្រះចេតិយនេះ បានធ្វើពិធីបុណ្យសម្ពោធឆ្លងនៅឆ្នាំ២០១៥ នៅថ្ងៃបុណ្យនោះផងដែរ មានញាតិញោមពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។ ក្នុងថ្ងៃបុណ្យមាឃបូជា វិសាខបូជា ថ្ងៃសីលជាដើម ព្រះករុណាលោកម្ចាស់ ពុទ្ធបរិស័ទបានប្រារព្ធពិធីគោរពបូជាគុណព្រះរតនៈត្រៃនៅខាងមុខព្រះចេតិយនេះ យ៉ាងច្រើនគួរជាទីជ្រះថ្លា ។*

*វត្តស្រះមុជ្ជលិន្ទ (កោះត្រើង)ស្ថិតនៅ ភូមិត្រើង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល ។*

*(Facebook ភិក្ខុ នួន សាវ៉េត)*





## ៣៣. បទុមធម្មចក្កពោធិព្រឹក្សព្រះចេតិយ (ព្រៃសារញ្ញាណា)

*លោកអ្នកអានជាទីមេត្រី ខ្ញុំនឹងណែនាំលោកអ្នកឱ្យស្គាល់ព្រៃអប់រំចិត្តសារញ្ញាណសីលវតី ដែលជាទីកន្លែងស្ងប់ស្ងាត់ឆ្ងាយពីភូមិស្រុក ជិតជើងភ្នំ ពោពេញទៅដោយព្រៃឈើ និងដើមព្រិចដុះជុំវិញទីកន្លែងនោះ ។ អ្នកដែលស្គាល់ទីនោះមិនសូវមានទេ មានតែអ្នកបដិបត្តិសមថៈវិបស្សនាប៉ុណ្ណោះទេ ទើបស្គាល់កន្លែងមួយនេះ។*

*ព្រៃនេះ ជាទីកន្លែងសិក្សាបដិបត្តិសមថវិបស្សនាមួយកន្លែង ដែលស្ថិតនៅភូមិប្រសិទ្ធ ឃុំអូរបាក់រទេះ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ ដែលសីលវតីសិក្សាព្រះធម៌ព្រះវិន័យជាច្រើនរូបផងដែរ, ឯវីព្រះសង្ឃវិញជួនមាន ជួនអត់ ។*

*នៅទីកន្លែងនោះក៏មាន បទុមធម្មចក្កពោធិព្រឹក្សព្រះចេតិយ ដឹកនាំកសាងដោយអ្នកគ្រូសីលវតី* ***ហៀង ស៊ីនាង*** *ព្រមទាំងពុទ្ធបរិស័ទគ្រប់ទិសទី នៅ ព.ស. ២៥៥៧ - គ.ស.២០១៣ ដែលមានរូបរាងមូលបិទ ក្បាច់សន្ទឹកពោធិ៍ ទំហំចេតិយប្រហែល១៤ម៉ែត្រ និងកម្ពស់ ១០ម៉ែត្រ ជាង ដំបូលចេតិយមានរាងជាប្រាំបីជ្រុង ស្អាតគួរជាទីចាប់អារម្មណ៍ ដែលនៅខាងក្នុងចេតិយជាន់ខាងលើតម្កល់ព្រះអរហន្តធាតុ ដែលអាពធនាមកពី* ***ឥណ្ឌា*** *ដោយបងប្អូនអ្នកគ្រូផ្ទាល់ ។*

*ទីកន្លែងនេះខ្ញុំករុណាធ្លាប់បានទៅពីរដង កាលនៅជាគ្រហស្ថម្តង និងបានបួសប្រហែល ២ឆ្នាំ បានទៅម្តងទៀត លុះមកដល់ឥឡូវមិនដែលបានទៅទេ ប៉ុន្តែបានជិះឡានកាត់ផ្លូវល្បឿនលឿនទៅកំពង់សោមឃើញទីនោះផងដែរ ។*






កច្ចាយនទូ បត្តម្ភក

## ៣៤. ព្រះគោតមចេតិយ (ព្រះគន្ធកុដិ) វត្តអង្គពណ្ណារាយណ៍

*ព្រះគោតមចេតិយ វត្តអង្គពណ្ណារាយណ៍ ស្ថិតនៅភូមិប្រជុំអង្គ ឃុំដើមកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលដឹកនាំផ្ដើមកសាងដោយព្រះគ្រូចៅអធិការវត្ត សិរីរតនញាណ ខេមកាមោ **ខាន់ ខេត** ភិក្ខុសាមណេរ ព្រមទាំងគណកម្មការវត្តនៅ ព.ស.២៥៥៧ - គ.ស.២០១៤។*

*ព្រះចេតិយបានកសាងរួចស្រេច និងធ្វើពិធីបុណ្យសម្ពោធឆ្លង និងដង្ហែព្រះសារីរិធាតុពីវត្តនិគ្រោធវ័នគង់ទទឹង ដោយលោកម្ចាស់គ្រូ **ភួង សុវណ្ណ** និងគ្រូសូត្រឆ្វេង នៅ ព.ស.២៥៦២ - គ.ស.២០១៩ ដែលមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ, ក្នុងថ្ងៃបុណ្យ វិសាខបូជា មាឃបូជាជាដើម មានការប្រារព្ធកម្មពិធីនៅមុខចេតិយនេះ មានការបូជាគ្រឿងសក្ការៈផ្សេងៗផងដែរ ។*

*ព្រះគោតមចេតិយ មានទំហំ ៤ម៉ែត្រ ៤ជ្រុង និងកម្ពស់ចេតិយ ២១ម៉ែត្រ មានខឿនបីជាន់, ខាងក្នុងព្រះចេតិយមានបុស្បុកតម្កល់ព្រះសារីរិកធាតុ អរហន្តធាតុ ព្រះពុទ្ធបដិមាតូចកសាងពីស្ពាន់ធំតូច និងតាមជញ្ជាំងមានតម្កល់ព្រះពុទ្ធអង្គស្ពាន់ ចំនួន ១០៨អង្គ គួរជាទីជ្រះថ្លា ៕*

*(Facebook: វត្តអង្គពណ្ណារាយណ៍)*



## ៣៥. ព្រះចេតិយ ភូមិក្រាំងស្វាយ

*ព្រះចេតិយនៅអាស្រមនទីសមីបារាមមួយកន្លែង ស្ថិតនៅភូមិក្រាំងស្វាយ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅខាងចុងភូមិ មានទីទួលមួយជិតមាត់ស្ទឹង ដែលជាទីស្ងប់ស្ងាត់របស់អ្នកបដិបត្តិសមថ វិបស្សនា ក៏ជាកន្លែងសិក្សាព្រះធម៌របស់ពុទ្ធបរិស័ទផងដែរ។*

*ព្រះចេតិយនៅក្នុងអាស្រមនេះដឹកនាំកសាងដោយ**ឧបាសិកា ឌឹម សុខន*** (*ហៅយាយឥត*) *និងពុទ្ធបរិស័ទពីទីជិតពីទីឆ្ងាយ, កសាងនៅឆ្នាំ ២០១២ ដែលមានបណ្ដោយ ៤ម៉ែត្រ ទទឹង ៤ម៉ែត្រ និងកំពស់ ១២ម៉ែត្រ ព្រះចេតិយបានធ្វើរួចរាល់ហើយ និងធ្វើពិធីបុណ្យឆ្លងនៅឆ្នាំ២០១២ ខាងក្នុងព្រះចេតិយតម្កល់ ព្រះសារីរិកធាតុ និងអរហន្តធាតុ អារាធនាមកពី**ប្រទេសសិរីលង្កា** ដោយលោកគ្រូ **ឃិន ចន្ទ** ។*

*ព្រះចេតិយនេះ កាលខ្ញុំករុណាមិនបួស ក៏បានមកជួយធ្វើចេតិយនេះខ្លះដែរ ពីព្រោះភូមិក្រាំងស្វាយ និងភូមិអូរអណ្ដូងជិតគ្នា ខណ្ឌដោយស្ទឹងម្ខាងម្នាក់ បើយើងឈរពីមាត់ស្ទឹងអូរអណ្ដូងមើលទៅទិសខាងលិច ធៀងខាងជើងយើងនឹងឃើញព្រះចេតិយ និងភូមិនោះមិនខាន ។*

*(ឧបាសិកា ឥត)*



## ៣៦. ព្រះបរមរតនចេតិយ វត្តហ្លួងស៊ីសុវត្ថិរតនារាម

*អ្នកអានជាទីមេត្រី ខ្ញុំព្រះករុណាអាត្មា នឹងណែនាំលោកអ្នកឱ្យស្គាល់ចេតិយមួយនៅខេត្តបន្ទាយមានជ័យ ដែលមានក្បាច់រចនាយ៉ាងស្អាត គួរជាទីជ្រះថ្លា គឺព្រះបរមរតនចេតិយ ដែលគេកសាងដើម្បីតម្កល់ព្រះបរមសារីរិកធាតុ ស្ថិតនៅវត្តហ្លួងស៊ីសុវត្ថិរតនារាម ជាវត្តបុរាណមួយ ក្នុងឃុំឫស្សីក្រោង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។*

*ព្រះចេតិយនេះដឹកនាំកសាងដោយព្រះអង្គគ្រូ ឋិតិញ្ញាណោ* ***ស៊ិញ សៀប*** *ជាព្រះចៅអធិការវត្ត និងភិក្ខុ សាមណេរ គណកម្មការវត្ត នៅព.ស.២៥៥៨ គ.ស.២០១៥ ចេតិយមានបណ្តោយ ១២ម៉ែត្រ ទទឹង ១០ម៉ែត្រ និងកម្ពស់ ២០ម៉ែត្រ និងបានកសាងរួចស្រេចជាស្ថាពរ នៅ ព.ស.២៥៦៣ គ.ស.២០២០ ។*

*ព្រះចេតិយនេះមានបួនជាន់ ជាន់ទីមួយតម្កល់អដ្ឋិធាតុពុទ្ធបរិស័ទ ជាន់ទីពីរតម្កល់ព្រះពុទ្ធរូប ជាន់ទីបីតម្កល់ព្រះបរមសារីរិកធាតុ ដែលអារាធនាមកពី* ***ប្រទេសឥណ្ឌា*** *មកគង់ក្នុងវត្តជាង២០ឆ្នាំហើយ និងជាន់លើបង្អស់មិនមានតម្កល់អ្វីទេ។ ក្នុងថ្ងៃបុណ្យមាឃបូជា វិសាខបូជា ជាដើម យើងឃើញមានពុទ្ធបរិស័ទចូលរួមក្នុងកម្មពិធីបុណ្យនេះ យ៉ាង-ច្រើនកុះករនៅទីនេះផងដែរ ៕*

*(Facebook អគ្គ ជោតិកោ)*




វត្តហ្លួងស៊ីសុវត្ថិតេជារាម
ឃុំឫស្សីក្រោក ស្រុកមង្គលបូរី
ខេត្តបន្ទាយមានជ័យ




វត្តហ្លួងស៊ីសុវត្ថិតេជារាម
ឃុំឫស្សីក្រោក ស្រុកមង្គលបូរី
ខេត្តបន្ទាយមានជ័យ

## ៣៧. ព្រះពុទ្ធច្ចេតិយ វត្តបទុម

*ព្រះពុទ្ធច្ចេតិយចាប់ផ្ដើមកសាងនៅ ព.ស.២៥៦០ គ.ស. ២០១៦ ដោយព្រះចៅអធិការមុន, លុះមកដល់សម័យលោកម្ចាស់គ្រូសិរីបញ្ញោ តោ **ឡាវ សុវណ្ណសាត** បានដឹកនាំកសាងបង្ហើយ រួចរាល់ស្រេចបាច់នៅ ព.ស.២៥៦៣ /គ.ស.២០១៩ ។*

*រីឯការទាក់ទងហ្នឹងព្រះសារីរិកធាតុ ត្រូវបានអារាធនានិមន្តពី**វត្តរាជបូរណ៍** ប្រហែលជាឆ្នាំ ១៨៧០មក, នេះជាប្រវត្តិកាលជំនាន់ ចាស់ៗពីមុននិយាយតៗគ្នាមក ។*

*ព្រះពុទ្ធច្ចេតិយ វត្តបទុម ស្ថិតនៅភូមិបទុមខាងលិច ឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ, ក្នុងថ្ងៃបុណ្យមាឃបូជា វិសាខបូជា ជាដើម ព្រះសង្ឃបានប្រារព្ធកម្មពិធីបុណ្យនៅកន្លែងព្រះចេតិយនេះផងដែរ ដែលមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។*

***ក្នុងវត្តនេះក៏មានការកសាងព្រះវិហារថ្មីមួយ ដែលបានសម្រេចជាង ៩០ភាគរយហើយ ញាតិញោមមានសទ្ធាចូលរួមកសាងឱ្យបានរួចរាលទៅហង ៕***





## ៣៨. ព្រះគន្ធកុដិ ឬព្រះចេតិយ វត្តនន្ទសាលវ័ន “ទួលប្រាសាទ”

ព្រះគន្ធកុដិ ឬព្រះចេតិយនេះ ផ្តើមកសាងឡើងដោយព្រះគ្រូវិនយរក្ខិតោ **សុខ ព្រហ្ម** ជាព្រះគ្រូចៅអធិការវត្ត គ្រូសូត្រស្តាំ ភិក្ខុ **អ៊ឹម ឡឹម** និងលោកអាចារ្យគណកម្មការ ដែលស្ថិតនៅភូមិស្រីប្រសើរ ឃុំស្វា ស្រុកសំរោង ខេត្តតាកែវ ។ ព្រះគន្ធកុដិបានបញ្ចុះបឋមសីលា និងបុកគ្រឹះចំនួន ៨០ដើមជាង វេលាម៉ោង ៨.០០នាទីព្រឹក នាថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ។ ព្រះគន្ធកុដិមានកម្ពស់ ២០.ម ទំហំទទឹង ១៦.ម x បណ្តោយ ១៦.ម សម្រាប់តម្កល់ព្រះពុទ្ធរូប និងស្នាមព្រះបាទ, ជាន់កណ្តាល ទំហំ ១២.ម x ១២.ម សម្រាប់តម្កល់ព្រះពុទ្ធរូប ព្រះអង្គទ្រង់ផ្ទំ នឹងព្រះអង្គទ្រង់ដោះប្រស្នារ សក្កទេវរាជ នៅជាន់លើបង្អស់មានរាងមូលទំហំ ៤.ម ជាកន្លែងតម្កល់ព្រះបរមសារីរិកធាតុ និងអរហន្តធាតុ ។

ចំណែកព្រះបរមសារីរិកធាតុ បានអារាធនាយាងមកពី**ប្រទេសភូមា** ដោយភិក្ខុ **សុខ សឿន** លោកបានជូនដល់ឯកឧត្តម **ប្រូចឋ ប៊ុន ថុល** ឯកឧត្តមបានប្រគេនព្រះបរមសារីរិធាតុបី ព្រះអង្គខ្នាតកណ្តាល នោះដល់លោកម្ចាស់តា **សុខ ព្រហ្ម វត្តនន្ទសាលវ័ន** នៅថ្ងៃព្រហស្បតិ៍ ៣ រោច ខែចេត្រ ឆ្នាំច អដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ ២០០៧។

លុះសម័យក្រោយមកទៀត លោកម្ចាស់តាបានទទួលព្រះសារីរិកធាតុខ្នាតតូច និងអរហន្តធាតុ ពីកូនសិស្សភិក្ខុ **ង៉ែត សុភក្តិ** ដែលនាំមកពីប្រទេស**ភូមា** ដោយព្រះភិក្ខុ សុវណ្ណថេរោ **ឈុន ពេជ្រ** ដែលត្រូវជាមារបស់លោក, នៅ ថ្ងៃអង្គារ ១រោច ខែកត្តិក ឆ្នាំឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។

ព្រះគន្ធកុដិនេះកសាងនៅឆ្នាំ ២០១៦ គិតមកដល់ឆ្នាំ ២០២៣ នេះបាន៨ ឆ្នាំហើយ សម្រេចបានតែជាង ៧០% ប៉ុណ្ណោះ អាស្រ័យហេតុនេះ ញាតិញោមពុទ្ធបរិទ័សមានសទ្ធាជួយកសាងព្រះគន្ធកុដិនេះឱ្យបានឆាប់រួចរាល់ទៅហោង ៕ *(ថេរដីកា លោកម្ចាស់គ្រូ សុខ ព្រហ្ម ព្រះគ្រូចៅអធិការវត្តនន្ទសាលវ័ន ទទួលប្រាសាទ)*



## ៣៩. មហាប្រាសាទព្រះគន្ធកុដិ វត្តវេឡុវ័ន

*វត្តវេឡុវ័ន (កោះធំ) មានមហាប្រាសាទព្រះគន្ធកុដិដ៏ធំមួយដែល មានរាងជាប្រាសាទផង ជាគន្ធកុដិផង,មានបីជាន់ គឺជាន់ទី១ ជាបន្ទប់ សម្រាប់សិក្សាព្រះធម៌ ជាន់ទីពីរតម្កល់ព្រះសារីរិធាតុ អរហន្តធាតុ មាន ព្រះពុទ្ធបដិមាធំតូច នៅតាមជញ្ជាំងមានរូបចម្លាក់ពុទ្ធប្រវត្តិ និងជាន់ទីបី លើគេបង្អស់តម្កល់ព្រះសារីរិកធាតុ ដែលអាពធនាមកពី**ប្រទេសថៃ** និង **ប្រទេសសិរីលង្កា** និងរតនវត្ថុមានតម្លៃលផ្សេងៗ ដែលពុទ្ធបរិស័ទបូជា ដោយសេចក្តីជ្រះថ្លា។ ថ្ងៃបុណ្យ មាឃបូជា វិសាខបូជាជាដើម មានពុទ្ធ បរិស័ទចូលរួមច្រើនកុះករនៅទីនោះផងដែរ។*

*ព្រះមហាប្រាសាទគន្ធកុដិ កសាងក្នុងសម័យលោកម្ចាស់តា ព្រះ-នាម **ស្រ៊ាន ឡេង** នៅថ្ងៃពុធ ១២កើត ខែពិសាខ ឆ្នាំមមែ សប្តស័ក ព.ស .២៥៥៩ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ នឹងបានប្រារព្ធពិធីបុណ្យ ឆ្លងនៅថ្ងៃសៅរ៍ អាទិត្យ ចន្ទ ១៤.១៥កើត និង១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស.២៥៦១-២៥៦២ / គ.ស.២០១៨ ។ ដែលស្ថិតនៅ ស្រុក កោះធំ ខេត្តកណ្តាល ៕*









## ៤០. ព្រះពុទ្ធមុនីចេតិយ វត្តមជ្ឈិមវ័ន

ព្រះពុទ្ធមុនីចេតិយ ជាស្ថាបត្យកម្មសំណង់ថ្មីមួយដែលកសាងពីឥដ្ឋ និងស៊ីម៉ង់ត៍ ដែលមានរូបរាងចេតិយជាប្រាំបីជ្រុង មានបីជាន់ថ្នាក់ មានក្បាច់យ៉ាងស្រស់ស្អាត និងមានកម្ពស់ ១៥ ម៉ែត្រ រាងអដ្ឋកោណ មួយជ្រុងស្មើនឹង ១,៩តឹក ។ ខាងក្នុងព្រះចេតិយតម្កល់ព្រះសារីរិកធាតុ ដែលអារាធនាមកពីវត្តធម្មកាយ **ប្រទេសថៃ** និងព្រះពុទ្ធបដិមាសាងពីស្ពាន់ជាដើម ។

ចេតិយនេះដឹកនាំកសាងដោយព្រះគ្រូសង្គមមុនី **សឿង សុវណ្ណា** ចៅអធិការវត្ត ព្រះសង្ឃ ព្រមទាំងគណកម្មការ នៅថ្ងៃអង្គារ ១២កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ គ.ស. ២០១៨ ។ ព្រះពុទ្ធមុនីចេតិយ កសាងរួចស្រេចជាស្ថាពរ និងធ្វើពិធីបុណ្យសម្ពោធ ឆ្លង និងពុទ្ធាភិសេកព្រះអង្គស្ពាន់ នៅថ្ងៃសៅរ៍ អាទិត្យ ចន្ទ ១៣.១៤.១៥កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ៤.៥.៦ ខែមីនា ឆ្នាំ ២០២៣ ។ នៅពេលថ្ងៃបុណ្យធំៗ មាន មាឃបូជា ជាដើមមានពុទ្ធបរិស័ទចូលរួមច្រើន ក្នុងថ្ងៃបុណ្យផងដែរ ។ វត្តមជ្ឈិមវ័នជាវត្តបុរាណមួយ ស្ថិតនៅភូមិជ្រោយអំពិល សង្កាត់ ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ៕

(Facebook: វត្ត មជ្ឈិមវ័ន)









# ៤១. ព្រះគន្ធកុដិ វត្តនិគ្រោធារាម "ឆាំឆា"

*វត្តនិគ្រោធារាម ជាមួយវត្តក្នុងប្រទេសយើងខាងទ្រទ្រង់ធម៌វិន័យមួយ ដែលស្ថិតនៅភូមិឆាំឆា ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម ។*

*ក្នុងវត្តនេះមានព្រះគន្ធកុដិមួយយ៉ាងស្អាត ដែលមានកម្ពស់បីជាន់នៅខាងលើបង្អស់តម្កល់ព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង គួរជាទីជ្រះថ្លា ដែលដឹកនាំកសាងដោយព្រះសង្ឃ គណកម្មការ និងពុទ្ធបរិស័ទគ្រប់ទិសទី ៕*



## ៤២. ព្រះសក្យមុនីចេតិយ វត្តពោធិរាម្នា

*ព្រះចេតិយតម្កល់ព្រះសារីរិកធាតុ មួយនៅវត្តពោធិរាម្នា ដែលជាស្ថាបត្យកម្មថ្មីមួយកសាងពីឥដ្ឋ និងស៊ីម៉ង់ត៍ មានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, ដែលដឹកនាំកសាងដោយព្រះគ្រូ* ***ឥន្ទជោត្តោ ប៉ែន ជា*** *ព្រះសង្ឃ ព្រមទាំងគណកម្មការវត្ត និងពុទ្ធបរិស័ទពីទីជិត ទីឆ្ងាយ។*

*ព្រះចេតិយនេះសព្វថ្ងៃស្ថិតនៅភូមិប្រជាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ៕*







## ៤៣. ព្រះចេតិយ វត្តធម្មសាមគ្គី "ពង្រ"

*ខេត្តបន្ទាយមានជ័យមានវត្តមួយឈ្មោះថា វត្តធម្មសាមគ្គី ក្នុងវត្តនេះមានព្រះចេតិយតម្កល់ព្រះសារីរិកធាតុមួយ, មានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, ដែលដឹកនាំកសាងដោយព្រះគ្រូចៅអធិការវត្ត ព្រះសង្ឃ លោកអាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទគ្រប់ទិសទី ។*

*ក្នុងថ្ងៃបុណ្យធំៗ ដូចជាបុណ្យមាឃបូជាជាដើម ក៏មានការប្រារព្ធពិធីនៅទីលានព្រះចេតិយនេះ មានព្រះសង្ឃ និងញាតិញោមចូលរួមយ៉ាងច្រើនផងដែរ, ដែលស្ថិតនៅភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។*

(Facebook Oeurn Somen)









# ៤៤. ព្រះចេតិយ វត្តព្រហ្មមានជ័យ

*នៅខេត្តបន្ទាយមានជ័យ មានព្រះចេតិយមួយស្ថិតនៅក្នុងវត្ត* ***ព្រហ្មមានជ័យសុវណ្ណារាម*** *ចេតិយនេះមានក្បាច់រចនាគួរជាទីជ្រះថ្លារបស់សប្បុរសប្រុសស្រីទាំងឡាយ។*

*ព្រះចេតិយនេះដឹកនាំកសាងដោយព្រះតេជៈគុណ* ***ព្រហ្ម យេត*** *ជាព្រះចៅអធិការវត្ត ព្រះសង្ឃ គណៈកម្មការ និងពុទ្ធបរិស័ទពីទីជិតពីទីឆ្ងាយ, ដែលមានបណ្តោយ ២០ម៉ែត្រ ទទឹង ២០ម៉ែត្រ និងកម្ពស់ ៣០ម៉ែត្រ មានពីរជាន់ ជាន់ខាងក្រោម តម្កល់ព្រះពុទ្ធបដិមា ទ្រង់ បរិនិព្វាន ប្រវែង ១៥ម៉ែត្រ និងជាន់ខាងលើតម្កល់ព្រះសារីរិកធាតុ ព្រះពុទ្ធអង្គ ចេតិយនេះធ្វើពិធីបុណ្យសម្ពោធឆ្លងនៅ ខែមេសា ឆ្នាំ ២០១៧, រយៈពេលកសាងចេតិយនេះ ៣ឆ្នាំ ទើបហើយ ។*

*ក្នុងវត្តនេះក៏មានព្រះពុទ្ធបដិមាយ៉ាងធំគួរជាទីគោរពជ្រះថ្លារបស់ពុទ្ធបរិស័ទផងដែរ ស្ថិតនៅភូមិអន្លង់ស្វាយ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ៕*

*(Facebook វត្តវាំងមួង ឆ្នាំ១៩៩៨)*









## ៤៥. ព្រះចេតិយ វត្តច័ន្ទស៊ីសាមគ្គីរតនារាម

*សាធុសប្បុរសប្រុសស្រីទាំងឡាយ នៅខេត្តបន្ទាយមានជ័យមានវត្តមួយឈ្មោះថា* ***វត្តច័ន្ទស៊ីសាមគ្គីរតនារាម*** *ក្នុងវត្តនេះមានព្រះចេតិយក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, ដែលផ្តួចផ្តើមកសាងដោយព្រះគ្រូចៅអធិការវត្ត ព្រះសង្ឃ លោកអាចារ្យ គណៈកម្មការ នឹងពុទ្ធបរិស័ទគ្រប់ទិសទី ។*

*ក្នុងថ្ងៃបុណ្យធំៗ ដូចជាបុណ្យមាឃបូជាជាដើម ក៏មានការប្រារព្ធពិធីនៅទីលានព្រះចេតិយនេះ មានព្រះសង្ឃ និងញាតិញោមចូលរួមយ៉ាងច្រើនផងដែរ, ដែលស្ថិតនៅ ភូមិកូបកើត ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ៕*

*(Facebook វត្តច័ន្ទស៊ីសាមគ្គីរតនារាម)*




2023/05/04 18:40







## ៤៦. ព្រះគន្ធកុដិ វត្តវិសុទ្ធិមគ្គ

*វត្តវិសុទ្ធិមគ្គ ជាវត្តមួយក្នុងព្រៃដែលឆ្ងាយពីអ្នកភូមិ ក្នុងបរិវេណវត្តនេះសម្បូរទៅដោយដើមឈើធំតូចជាច្រើន និងកុដិព្រះសង្ឃជាច្រើនក្នុងព្រៃនោះ ដែលជាអ្នកសិក្សារៀនសូត្របដិបត្តិព្រះធម៌ព្រះវិន័យ។ ក្នុងវត្តមានសាលាលោកុត្តរៈធម៌ដ៏ធំកំពុងកសាង និងព្រះគន្ធកុដិពីរ ចាស់មួយ ថ្មីមួយ។*

*ព្រះគន្ធកុដិចាស់នេះផ្ដួចផ្ដើមកសាងដោយព្រះគ្រូសូត្រឆ្វេង ព្រះនាម **កែវ ដារារិទ្ធិ** និងពុទ្ធបរិស័ទគ្រប់ទិសទី នៅថ្ងៃទី១៣ ខែ ៧ ឆ្នាំ ២០១៣, ដែលមានបណ្ដោយ ៤ ម៉ែត្រកន្លះ ទទឹង៤ម៉ែត្រកន្លះ និងកម្ពស់ជាង ១០ម៉ែត្រ ។*

*រីឯព្រះគន្ធកុដិថ្មីវិញ ដឹកនាំកសាងដោយលោកម្ចាស់គ្រូ **ភួង សុវណ្ណ** ព្រះគ្រូចៅអធិការវត្តគល់ទទឹង លោកម្ចាស់គ្រូសាន សប្បាយ ព្រះសង្ឃនិងគណកម្មការវត្ត។ គន្ធកុដិនេះមានពីរជាន់ ជាន់ខាងក្រោមជាកន្លែងព្រះសង្ឃតម្កល់ឯសារ ក៏ជាកន្លែងធ្វើសៀវភៅធម៌ផងដែរ, នៅជាន់ទីពីរតម្កល់ព្រះសារីរិធាតុ និងវត្ថុមានតម្លៃផ្សេងៗដែលពុទ្ធបរិស័ទបូជា និងគួរជាទីជ្រះថ្លារបស់ពុទ្ធបរិស័ទគ្រប់ទិសទីផងដែរ។*

*ព្រះគន្ធកុដិវត្តវិសុទ្ធិមគ្គ ស្ថិតនៅភូមិបំពេញរាជ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប សូមអនុមោទនាបុណ្យ ៕*

*(Facebook: អ្នកត្រាច់ វង្គត់)*









## ៤៧. ព្រះគន្ធកុដិ វត្តភ្នំអណ្តើក

វត្តភ្នំអណ្តើក ជាវត្តមួយក្នុងព្រះរាជាណាចក្រកម្ពុជាយើង ដែលមានឈ្មោះល្បីល្បាញខាងព្រះសង្ឃសិក្សាទ្រទ្រង់ព្រះធម៌ព្រះវិន័យ ជាទីជ្រះថ្លារបស់ពុទ្ធបរិស័ទគ្រប់ទិសទី, ក្នុងវត្តមានបូជនីយដ្ឋានផ្សេងៗ មានព្រះអង្គទ្រង់ប្រសូត និងជាពិសេសនោះគឺព្រះគន្ធកុដិមួយកន្លែង ដែលនៅខាងក្រោយព្រះវិហារ ឆៀងខាងត្បូងជិតកុដិធម្មចេតិយ ។

ក្នុងព្រះគន្ធកុដិ មានតម្កល់ព្រះកោដ្ឋពណ៌មាសមានរាងដូចជាព្រះចេតិយ ដែលតម្កល់ព្រះសារីរិកធាតុ យ៉ាងស្អាតគួរជាទីជ្រះថ្លា និងមានព្រះពុទ្ធរូបធំតូចកសាងពីថ្មកែវស្លាន់ជាច្រើនក្នុងនោះផងដែរ ។ ក្នុងថ្ងៃសីល បុណ្យមាឃបូជា វិសាខបូជាជាដើម មានញាតិញោមពុទ្ធបរិស័ទចូលរួមក្នុងកម្មពិធីនោះយ៉ាងច្រើនកុះករ ។

វត្តភ្នំអណ្តើក ស្ថិតនៅភូមិក្រពើដើង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង, ក៏ជាកន្លែងបំពេញបុណ្យផង ក៏ជាកន្លែងរមណីយដ្ឋានញាតិញោមប្រុសស្រីផងដែរ ៕



## ៤៨. ព្រះមហាមុនីចេតិយ "វត្តព្រៃស្វាយ"

*នៅក្នុងវត្តអម្ពវ័ន ព្រៃស្វាយ មានព្រះចេតិយមួយឈ្មោះថា ព្រះមហាមុនីចេតិយ ដែលមានក្បាច់រចនាយ៉ាងស្អាត គួរជាទីជ្រះថ្លា, មានកម្ពស់ ១៩មែត្រ និងបណ្ដោយ ៧ម៉ែត្រ, នៅខាងក្នុង ព្រះចេតិយនេះមានបីជាន់គឺ ជាន់ទី១ តម្កល់ព្រះពុទ្ធមេត្តា ដែលចម្លង ពី**ប្រទេសឥណ្ឌា** គួរជាទីជ្រះថ្លា និងតម្កល់ព្រះសារីរិកធាតុ, ជាន់ទី២ តម្កល់ព្រះពុទ្ធបដិមារចនាប័ទ្មខ្មែរ និងជាន់ទី៣ ខាងលើបង្អស់តម្កល់ព្រះសារីរិក- ធាតុ និងព្រះពុទ្ធមេត្តា, នៅតាមហោជាងទាំង៤ នៃចេតិយមានរូបចម្លាក់ ព្រះពុទ្ធទ្រង់សមាធិ ។*

*ព្រះចេតិយនេះផ្ដួចផ្ដើមកសាងដោយឧបាសិកា **សេង ស៊ាងលីម** ព្រះគ្រូ មេត្តាបាលោ **ឡឹង សំបូរ** ព្រះគ្រូចៅអធិការវត្ត ភិក្ខុ សាមណេរ និងគណកម្មការវត្ត នៅក្នុងឆ្នាំ ២០១៦ ។*

*សព្វថ្ងៃនេះ ញាតិញោមពុទ្ធបរិស័ទមកគោរពបូជាគ្រឿងសក្ការៈគ្រប់មជ្ឈដ្ឋាននានា, រីឯថ្ងៃសីល និងថ្ងៃបុណ្យមាឃបូជា វិសាខបូជា មានពុទ្ធបរិស័ទចូលរួមជាច្រើនកុះករ ដែលស្ថិតនៅ ភូមិថ្កុកឈើទាល ឃុំ សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ៕*

*(Facebook: Lek SomBo)*


ព្រះមហាមុនីចេតិយ







## ៤៩. មកុដពន្ធនចេតិយ វត្តគិរីបរវង្សមានជ័យ

*មកុដពន្ធនចេតិយ វត្តគិរីបរវង្សមានជ័យ (ឈ្មោះភ្នំបរវង្ស) ស្ថិតនៅសង្កាត់ ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានកម្ពស់ជាង ១០០ម៉ែត្រ ប៉ុន្តែមានផ្លូវឡើងយានយន្តបាន ។ នៅលើកំពូលភ្នំនោះ មានសាងសង់សំណង់ព្រះចេតិយមួយដ៏ស្កឹមស្កៃ មានសសរ៤អមជុំវិញ ក្រៅពីនេះក្នុងទីវត្តនេះក៏មាន សំណង់ពុទ្ធសាសនា ជាច្រើនប្រកប ដោយសោភ័ណភាពគួរឱ្យចង់ទស្សនាផងដែរ ៕*


www.ilovecambodia.co.kr





## ៥០. សម្ធហៈចេតិយ ឯកឧត្តម ម៉ុង ឬទ្ធី

*ញាតិញោមប្រុសស្រីជាទីរាប់អាន នៅខេត្តកំពង់ស្ពឺមានរមណីយដ្ឋានមួយកន្លែង ដែលជាកន្លែងទេសចរណ៍ មានដូចជាសួនសត្វ ចម្ការផ្លែឈើ នឹងជាពិសេសនោះគឺ ចេតិយរួមមួយសម្រាប់តម្កល់ធាតុរបស់ញាតិញោមប្រុសស្រីណា ដែលមានទលិទ្ទភាព*[១] *ធ្វើចេតិយផ្ទាល់ខ្លួន។*

*សមូសហៈចេតិយនេះដឹកនាំកសាងដោយឯកឧត្តម* ***ម៉ុង ឫទ្ធី*** *និងលោកជំទាវ កសាងនៅថ្ងៃ ទី២៧ ខែឧសភា ឆ្នាំ ២០២១, គ្រោង នឹងបញ្ចប់ការងារ សាងសង់នេះ នៅក្នុងខែឧសភាឆ្នាំ២០២២ ឱ្យហើយរួចរាល់ជាស្ថាពរ ។*

*ព្រះចេតិយនេះ មានកម្ពស់ខ្ពស់ ជាងនីវ៉ូទឹក សមុទ្រ ១៣០ម៉ែត្របាតក្រោម សាងសង់ ជាអាង ស្តុកទឹកស្អាតបាន ចំនួន ២.៣០០ម៉ែត្រគុប ដែលមាន ទំហំ ២៨មx២៨ម កម្ពស់ ៣០ម៉ែត្រ ។ ដែលស្ថិតនៅលើកំពូលភ្នំ ដែលមានទីតាំងតំបន់ រមណីយដ្ឋាន អភិវឌ្ឍន៍ កសិកម្ម ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានទេសភាពស្រស់ស្អាតគួរជាទីជ្រះថ្លា៕*

*(Facebook ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី)*

---

(១). ***ទលិទ្ទភាព*** (*ទៈ-លិត-ទៈ-ភាព*)

***នាមសព្ទ*** (*បា. ទលិទ្ទភាវ*) *ភាពជាអ្នកក្រីក្រ, ការខ្វះខាតទ្រព្យសម្បត្តិ, សេចក្ដីទ័លក្រ ។*






www.khmer24.com









## ៥១. ព្រះបរមកេសធាតុចេតិយ "ពុទ្ធមណ្ឌលវិបស្សនា"

*ព្រះបរមកេសធាតុចេតិយនេះ ស្ថិតនៅក្នុងពុទ្ធមណ្ឌលវិបស្សនា-ធុរៈកម្មដ្ឋានអន្តរជាតិកម្ពុជា (ភ្នំអដ្ឋវស្ស) ភូមិភ្នំ ឃុំផ្សារដែក ស្រុក ពញាឮ ខេត្តកណ្ដាល ។ ព្រះចេតិយនេះដឹកនាំកសាងដោយព្រះ* ***គ្រូសាសនមុនី*** *មហាកម្មដ្ឋានាចរិយ* ***ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ*** *ព្រះចៅ អធិការវត្តព្រះសង្ឃ ព្រមទាំមហាឧបាសិកា* ***សុខ អ៊ឹម*** *នៅ ព.ស.២៥៦៦ គ.ស. ២០២២ ។*

*ចេតិយនេះ កសាងនៅកណ្ដាលស្រះទឹក មានប្រមាណ ១ហិតា ព្រះបរមកេសធាតុ ដែលមានរចនាប័ទ្មសម័យលង្វែក គួរជាទីជ្រះថ្លា ។ នៅខាងក្នុងព្រះចេតិយនេះ ក៏មានព្រះចេតិយថ្មកែវ ដែលតម្កល់ព្រះកេសធាតុបានអាពធនាមកពី* ***ប្រទេសសិរីលង្កា*** *នាថ្ងៃច័ន្ទ ១៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២៣ និងតាមជញ្ជាំងមានរូបចម្លាក់ពុទ្ធប្រវត្តិជាដើម ។*

*បើយើងឡើងភ្នំព្រះរាជទ្រព្យមើលទៅទិសខាងលិច នៃព្រះសក្យ-មុនីចេតិយ យើងនឹងឃើញព្រះចេតិយនោះគួរជាទីជ្រះថ្លាក្នុងបុណ្យ-កុសលមិនខាន ។ នៅក្នុងវត្តក៏មានព្រះសុគន្ធកុដិ មានពីរជាន់ នៅជាន់ក្រោមសម្រាប់ទទួលញាតិញោម និងជាន់ខាងលើតម្កល់ព្រះ សារីរិកធាតុ ព្រះអរហន្តធាតុ និងព្រះពុទ្ធបដិមាធំតូចគួរជាទីជ្រះថ្លាផង ដែរ ។ ជាពិសេសនោះគឺ មានការបង្រៀន* ***សមថៈវិបស្សនាកម្មដ្ឋាន*** *ដល់យោគាវចរចូលមកសិក្សា មានវគ្គសិក្សាតាមកម្មវិធីរបស់វត្ត ។*







## ៥២.សន្ថុត្តរចេតិយ ថូបារាមចេតិយ និងចេតិយពុទ្ធគយា នៅវត្ត ប្រាសាទស្រះកណ្តាលខ្ពស់

*សិង្ឃុតរចេតិយ ថូបារាមចេតិយ ចេតិយពុទ្ធគយានេះ ជាសំណង់ស្ថាបត្យកម្មថ្មីមួយក្នុងប្រទេសខ្មែរយើង ដែលចម្លងពី **ប្រទេសភូមា សិរីលង្កា និងឥណ្ឌា** ដែលជាចេតិយមានប្រវត្តិដ៏អស្ចារ្យក្នុងព្រះពុទ្ធសាសនាយើងនេះ។*

*ខ្ញុំព្រះករុណាសូមលើកប្រវត្តិសង្ខេប ពីចេតិយថូបារាម **ប្រទេសសិរីលង្កា**ជាដើម ឱ្យបានជ្រាបដូចតទៅ ៖*

***ព្រះមហិន្ទថេរ** និងគណៈ ៥រូបទៀត បាននិមន្តផ្សព្វផ្សាយព្រះពុទ្ធសាសនា ក្នុងកោះស្រីលង្កានេះធ្វើឱ្យព្រះរាជា និងពុទ្ធបរិស័ទ ជ្រះថ្លាយ៉ាងខ្លាំង ព្រមទាំងមានអ្នកបានសម្រេចលោកុត្តរធម៌ជាច្រើន សន្ទឹកសន្ធាប់ផងដែរ, ក្រោយមកព្រះថេរៈបានណែនាំឱ្យព្រះរាជា ព្រះ បាទ**ទេវានម្បិយតិស្ស** កសាងនូវព្រះចេតិយ ដើម្បីបញ្ចុះនូវព្រះ **អក្ខកធាតុ** (ឆ្អឹងដងកាំបិតខាងស្តាំ) ដែល**សុមនសាមណេរ**បានអាពធនាពី **ព្រះចូឡាមណីចេតិយ** នាឋានតាវត្តិង្សទេវលោក, លើកដំបូងព្រះធាតុ បានសម្តែងយមកបាដិហារ្យ ដ៏អស្ចារ្យតាមការអធិដ្ឋាន របស់ព្រះសម្មាសម្ពុទ្ធ បានឱ្យពួកជនជាតិ **កោះលង្កា**នោះបានឃើញ។*

*ក្នុង**ព្រះអដ្ឋកថា** បានបញ្ជាក់ថាព្រះពុទ្ធ**កក្កុសន្ធោ** បានបញ្ចុះនូវធម្មក្ក **ព្រះពុទ្ធកោនាគមនោ** បានបញ្ចុះនូវវត្ថពន្ធបង្កេះ **ព្រះពុទ្ធកស្សប** បានបញ្ចុះនូវឧទកសាដក ។*

*ចេតិយថូបារាមនេះ ជាព្រះចេតិយដែលមានមុនគេដំបូងបង្អស់*

ក្នុង***កោះតម្ពបណ្ណិទ្វីប*** ហើយក៏ជាកន្លែងដែលព្រះអង្គធ្លាប់បានគង់ចូលនិរោធសមាបត្តិ កាលដែលព្រះអង្គយាងមកកោះនេះជាលើកទី៣ សម័យក្រោយមកទៀត ព្រះចេតិយត្រូវបានបាក់បែកដោយសាការបៀតបៀនអំពីពួក ***ទមិឡ*** ក្នុង ព.ស ១៨៦២ ***ព្រះបាទអគ្គពោធិ*** បានកសាងឡើងវិញជាថ្មីម្តងទៀតទុកជាទីជ្រះថ្លារហូតមកដល់សព្វថ្ងៃនេះ៕



## ៥៣.ម្ជូជនីយដ្ឋានសង្គុត្តរចេតិយ ឬ ស្វេដាហ្គុន

ប្រជាជននៅប្រទេសភូមាសព្វថ្ងៃ កាន់ព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ គេបានកសាងនូវព្រះចេតិយជាច្រើន, ក្នុងនោះមានព្រះចេតិយមួយដែលល្បីល្បាញទូទាំងពិភពលោកឈ្មោះថា សង្គុត្តរចេតិយ បច្ចុប្បន្នក្លាយឈ្មោះ **ជាស្វេដាហ្គុន** មានន័យថាចេតិយ **ត្រៃរត្ន** ដែលមានកម្ពស់ ៩៩ម៉ែត្រ ដំបូលបិទមាសជាច្រើនតោនរំលេចដោយ ត្បូងពេជ្រជាច្រើនគ្រាប់ ។ លុះដល់សម័យក្រោយមក រដ្ឋាភិបាលនៃប្រទេសភូមាបានរៀបចំបិទមាសព្រះចេតិយនេះ រហូតដល់សព្វថ្ងៃ ។

នៅខាងក្នុងព្រះចេតិយ មានសំពៅរូបសត្វករវិកកសាងពីមាសប្រវែង ៦ហ្វីត[១]កន្ទុះ មានកំពូលប្រាំ នៅខាងក្នុងនោះតម្កល់វត្ថុរបស់ព្រះពុទ្ធបួនព្រះអង្គគឺ ១.ឈើច្រត់របស់**ព្រះពុទ្ធកក្កុសន្ធោ**, ២.ធម្មក្រករបស់**ព្រះពុទ្ធកោនាគមនោ**, ៣.សំពត់ស្រង់ទឹករបស់**ព្រះពុទ្ធកស្សបោ**,៤.**ព្រះកេសធាតុ** ៨ សរសៃ ដែល**តបុស្ស** និង**ភល្លិក**ឧបាសក បានទទួលពីព្រះហស្តផ្ទាល់នៃព្រះពុទ្ធជាម្ចាស់ ទើបតែត្រាស់ដឹងដំបូងនៅគយាសីសប្រទេសនា **រាជាយតនចេតិយ** នៅជិតមណ្ឌលពោធិព្រឹក្ស នឹងនៅថ្ងៃអនាគត តម្កល់ព្រះលោមា **ព្រះពុទ្ធសិអារមេត្រី**ផងដែរ៕

---

(១).ហ្វីត [ ft ] ហ្វីត គឺជាឯកតាប្រវែងនៅក្នុងប្រព័ន្ធទំនៀមទម្លាប់របស់អធិរាជ និងអាមេរិក។ ចាប់តាំងពីឆ្នាំ 1959 អង្គភាពទាំងពីរត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង អន្តរជាតិដែល 1 ហ្វីត ស្មើនឹង 0.3048 ម៉ែត្រ។ 6ហ្វីត=1.8288 ម៉ែត្រ



## ៥៤.ព្រះមហាចេតិយពុទ្ធគយា ព្រះមហាពោធិព្រឹក្ស

*ចេតិយពុទ្ធគយាជាកន្លែងព្រះពុទ្ធគ្រប់ព្រះអង្គត្រាស់ដឹង ព្រោះទីនេះជាផ្ចិតផែនដី ។ សម័យពុទ្ធកាលកន្លែងនេះ ក្នុងឧរុវេលាសេនានិគមនៃ**ដែនមគធៈ** បច្ចុប្បន្ននៅក្នុងស្រុកពុទ្ធគយា**រដ្ឋពិហារ ប្រទេសឥណ្ឌា*** មានចម្ងាយ *៥គីឡូម៉ែត្រពីអាកាសយានដ្ឋានគយា ១៤គីឡូម៉ែត្រពីក្រុងគយា ៩៦គីឡូម៉ែត្រពីរាជគ្រិះ ២៥០ម៉ែត្រពីក្រុងពារាណសី ទីនោះនៅខាងលិចស្ទឹងនេរញ្ជរា ប្រហែលជាមិនដល់ ៥០០ ម៉ែត្រ ។*

*ព្រះមហាចេតិយនេះ គឺជាទីសក្ការៈមួយក្នុងចំណោមទីសក្ការៈទាំងបួននៃសំវេជនីយដ្ឋាន, ដែលមានកម្ពស់ ៥៥ម៉ែត្រ ព្រះចេតិយនេះដំបូងត្រូវបានសាងសង់ឡើងដោយ**ព្រះបាទធម្មាសោក** ក្នុងសតវត្សទី៣ មុនគ.ស. វាជាមហាចេតិយពុទ្ធសាសនាដំបូងបំផុតមួយដែលសាងសង់ដោយឥដ្ឋទាំងស្រុងនៅក្នុង**ប្រទេសឥណ្ឌា*** ចាប់តាំងពីចុងសម័យGupta។

*ព្រះមហាចេតិយនេះ សាងសង់នៅខាងកើត ជាប់ហ្នឹងដើមពោធិព្រឹក្ស, ដើមពោធិសព្វថ្ងៃនេះជាដើមពោធិព្រឹក្សទី៤ ដាំដោយឧត្តម-សេនីយ៍ ជនជាតិអង់គ្លេសឈ្មោះ **ហ្សរីនិងខានហោម*** ព.ស.២៤២១, *ដើមពោធិព្រឹក្សបច្ចុប្បន្នមានអាយុ ១៤៦ឆ្នាំ គិតមកដល់ ព.ស.២៥៦៧។ សំវេជនីយដ្ឋានកន្លែងព្រះពុទ្ធត្រាស់ដឹងនេះ ពុទ្ធបរិស័ទមកគោរពបូជាទាំងថ្ងៃ ទាំងយប់ ដែលមកពីប្រទេសនានាទូទាំងពិភពលោក៕*

*វះករុណាលោកម្ចាស់ និងញាតិញោមបានអានប្រវត្តិព្រះចេតិយទាំងបីនេះរួចហើយ,ក៏មានសទ្ធាក្នុងគុណព្រះរតនៈត្រៃប្រាថ្នាចង់*

ទៅថ្វាយបង្គំព្រះចេតិយទាំងនោះផ្ទាល់ ,បើករុណាលោកម្ចាស់និងញាតិញោមគ្មានទលិទ្ធភាពទៅប្រទេសក្រៅទេ  ក៏អាចនិមន្តទៅថ្វាយបង្គំព្រះចេតិយនេះនៅក្នុងវត្តប្រាសាទស្រះកណ្ដាលខ្ពស់  ខេត្តបន្ទាយមានជ័យនោះក៏បានដែរ ៕ (ដាក់ជាអក្សរតូចក៏បានដែល)



## ៥៥.ព្រះចេតិយ វត្តប្រាសាទឥន្ទ្រា "វត្តគោកប៉ាទ្រី"

ព្រះចេតិយនៅទីអារាម វត្តប្រាសាទឥន្ទ្រា ហៅ**វត្តគោកប៉ាទ្រី** ខេត្តសៀមរាប ត្រូវបានគេដឹងឮថាជាទឹកដីដែលសម្បូរដោយប្រាង្គប្រាសាទរាប់រយប្រាសាទ ដែលបានទាក់ទាញភ្ញៀវទេសចរណ៍ ឱ្យមកទស្សនារាប់លាននាក់ជារៀងរាល់ឆ្នាំ។

ក្រៅពីប្រាង្គប្រាសាទ នៅខេត្តនេះក៏មានព្រះចេតិយមានកំពូលច្រើន គួរជាទីជ្រះថ្លារបស់ពុទ្ធបរិស័ទ្ធទាំងឡាយផងដែរ, ព្រះចេតិយនេះមានពីរជាន់ ជាន់ខាងក្រោមតម្កល់ធាតុរបស់ញាតិញោម នៅជាន់ខាងលើជាព្រះចេតិយតម្កល់ព្រះសារីរិកធាតុ និងចេតិយតូចៗព័ន្ធជុំវិញជាចេតិយពុទ្ធបរិស័ទ ។

វត្តប្រាសាទឥន្ទ្រា ស្ថិតនៅក្នុង ភូមិគ្រួស សង្កាត់ថ្វាយបង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ៕

(Facebook ដៀ ដួងពេជ្រ ភិក្ខុចន្ទជម្មោ)



## ៥៦.ព្រះគន្ធកុដិ វត្តសាលវង្សិយារាម "វត្តស្រះខ្សឿ"

*ព្រះគន្ធកុដិ លើភ្នំសុមនកូដ វត្តសាលវង្សិយារាម មានភ្នំ**សុមនកូដ** ចម្លងមួយកន្ទ្វេង ប្រតិស្ឋានស្នាមព្រះបាទ និងតម្កល់ ព្រះបរមសារីរិកធាតុ ដឹកនាំកសាងដោយ ព្រះគ្រូសច្ចមនោ **ប៉ែន សារុជ** ព្រះចៅអធិការវត្ត និងអាចារ្យគណកម្មការពុទ្ធបរិស័ទគ្រប់ទិសទីនៅ ព.ស. ២៥៦៣ គ.ស.២០១៩ ។*

*នៅលើភ្នំនេះមានព្រះគន្ធកុដិមួយយ៉ាងស្អាតគួរជាទីជ្រះថ្លា នៅខាងលើព្រះគន្ធកុដិមានព្រះពុទ្ធបដិមាទ្រង់ប្រទានពរ ជុំវិញភ្នំនេះក៏មានរូបព្រះពុទ្ធបដិមាថ្មទ្រង់ឈរប្រទានអភ័យជាដើមផងដែរ។ **វត្តសាលវង្សិ-យារាម** ស្ថិតនៅភូមិស្រះរាំង ឃុំស្រះរាំង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ៕*

*(សិលាចារឹកថ្មម៉ាប)*







## ៥៧.ព្រះចេតិយនេះ កំពុងកសាងនៅ ភូមិព្រៃស្មៀត

*លោកអ្នកអានជាទីមេត្រី ខ្ញុំករុណាណែនាំលោកអ្នកឱ្យស្គាល់ឧបាសកម្នាក់ ដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រៃមួយរូប គឺឧបាសិក* ***ហេង ថត*** *គាត់បានវេរដីស្រែឈូកគាត់ឱ្យជារបស់សង្ឃប្រមាណជាមួយហិតាជាង នៅថ្ងៃបុណ្យចម្រើនព្រះជន្មាយុម្តាយគាត់ នាថ្ងៃអាទិត្យ ១៥កើត ខែមាឃ ឆ្នាំខាល បត្វាស័ក ព.ស .២៥៦៦ / ០៦.០២.២០២៣ ,*

*រីឯដីនេះនឹងធ្វើព្រះចេតិយតម្កល់ព្រះសារីរិកធាតុ ដែលអាពធនាមកពី* ***ប្រទេសឥណ្ឌា*** *និង* ***ប្រទេសសិរីលង្កា*** *ដាំដើមពោធិព្រឹក្ស ដែលដឹកនាំកសាងដោយលោកម្ចាស់គ្រូ* ***ហេង សុភទ្ទ*** *និងឧបាសក* ***ហេង ថត*** *ត្រូវជាប្អូន ព្រមទាំងញាតិមិត្តព្រះធម៌ជិតឆ្ងាយ, នាខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ គ.ស.២០២៣ ខាងមុននេះ ដែលស្ថិតនៅ ភូមិព្រៃស្មៀត ឃុំព្រៃស្មៀត ស្រុកពារាំង ខេត្តព្រៃវែង ។*

*ព្រះចេតិយនេះមានទំហំជុំវិញ ១៥ ម៉ែត្រ កម្ពស់ ១៥ ឬ២០ម៉ែត្រ, សូមសាធុសប្បុរសប្រុសស្រីទាំងឡាយ មានសទ្ធាកសាងចេតិយមួយនេះឱ្យរួចរាល់ដើម្បីទុកជាសម្បត្តិក្នុងព្រះពុទ្ធសាសនាទៅហោង ៕*

*(Facebook ហេង ថត)*





# ៥៨.ព្រះចេតិយ វត្តបភាវត្យារាម គគរ

*នៅវត្តបភាវត្យារាម ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានសំណង់ចេតិយបុរាណមួយ ដែលមានរាងស្រដៀងនឹងព្រះប្រាង្គ ដែលកសាងលើកទី ១ ដោយព្រះចៅអធិការព្រះនាម* ***ឌុក ឌី*** *នៅឆ្នាំ ១៩៣៨ ។*

*ព្រះចេតិយនេះ គេមិនដឹងច្បាស់ថា តម្កល់ព្រះធាតុអ្វីឱ្យប្រាកដទេ មតិអ្នកខ្លះថាតម្កល់ធាតុព្រះរាជា អ្នកខ្លះថាតម្កល់ព្រះធាតុព្រះគ្រូចៅអធិការ និងអ្នកខ្លះទៀតថាតម្កល់ព្រះសារីរិកធាតុ ។*

*ព្រះចេតិយនេះ មានញោមម្នាក់ឈ្មោះថា* Hor Sokleap *គាត់បានហៅចេតិយនេះថា ដែលគាត់ជាអ្នកស្រុកនោះ, តាមន័យដែលពោលមកនេះ សបញ្ជាក់ឱ្យយើងដឹងបានថា ព្រះចេតិយ នេះតម្កល់ព្រះបរមសារីរិកធាតុដោយច្រើន ព្រោះចេតិយនេះមានរាងដូចនឹង* ***ព្រះប្រាង្គ*** *ផងដែរ ។*

*ព្រះបរមចេតិយនេះមានសភាពចាស់ទៅហើយ ក្នុងនាមខ្ញុំ ព្រះករុណាជាអ្នកកាន់ព្រះពុទ្ធសាសនាមួយរូប សូមមានមតិយោបល់ខ្លះទៅលោកគ្រូចៅអធិការ នឹងគ្រូសូត្រឆ្វេងស្តាំ ព្រមទាំងញាតិញោមពុទ្ធ-បរិស័ទចំណុះជើងវត្ត សូមមេត្តាជួយជួសជុលព្រះចេតិយមួយនេះឱ្យទៅជា* ***បូជនីយដ្ឋាន*** *ជាទីសក្ការៈបូជារបស់ពុទ្ធបរិស័ទគ្រប់ទិសទីទៅហោង៕*









## ៥៩. ព្រះមហាមុនីចេតិយ វត្តព្រះនាង

*វត្តព្រះនាង ជាវត្តបុរាណមួយដែលស្ថិតនៅ ភូមិកំពុងក្តី ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានព្រះមហាមុនីចេតិយមួយ មានក្បាច់ រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា, នៅតាមហោជាងទាំងបួន នៃច្រកចូល ព្រះចេតិយ យើងឃើញមានរូបចម្លាក់ពុទ្ធប្រវត្តិ ព្រះអង្គទ្រង់ប្រសូត ព្រះអង្គទ្រង់ត្រាស់ដឹង ព្រះអង្គសម្តែងធម្មចក្ក និងព្រះអង្គទ្រង់ចូល បរិនិព្វាន, ព្រះចេតិយនេះមានបួនជាន់ ជាន់ទីមួយ តម្កល់ព្រះពុទ្ធ- បដិមា, ជាន់ទីពីរ និងជាន់ទីបីមិនមានតម្កល់អ្វីទេ រីឯជាន់ទីបួន តម្កល់ព្រះបរមសារីរិកធាតុ ដែលអារាធនាមកពី**អាស្រមកោះរ៉ុង** ខេត្ត បាត់ដំបង ។*

*ព្រះចេតិយនេះកសាងក្នុងសម័យលោកម្ចាស់ **ឡុក ផុន** ព្រះសង្ឃគណកម្មការវត្ត និងពុទ្ធបរិស័ទគ្រប់ទិសទី, នៅ ព.ស.២៥៥៥, ដែល មានបណ្តោយ និងទទឹង ១៤ ម៉ែត្រ កម្ពស់ប្រហែល ២៣ ម៉ែត្រជាង ។*

*នៅថ្ងៃសីល និងថ្ងៃបុណ្យវិសាខបូជា មាឃបូជាក៏មានការបូជាគ្រឿងសក្ការៈផ្សេងៗ ហើយក៏អារាធនាព្រះសារីរិកធាតុមកតម្កល់នៅលើសាលាធម្មសភាដើម្បីប្រារព្ធកម្មពិធីផ្សេងៗដែលមានព្រះសង្ឃ និងពុទ្ធបរិស័ទចូលរួមច្រើនកុះករផងដែរ។*

*(Facebook: រ៉ាន់ វ៉ុន)*






# ៦០.ពុទ្ធគយាចេតិយ វត្តទឹកវិល

ពុទ្ធគយាចេតិយនេះ ផ្ដួចផ្ដើមកសាងដោយព្រះគ្រូចៅអធិការវត្ត ព្រះនាម ***សិរីគណញ្ញាណ*** ព្រះរាជាគណាថ្នាក់កិត្តិយសព្រះរាជាណាចក្រកម្ពុជា ***អ៊ឹម សុខសាន្ត*** ភិក្ខុ សាមណេរ និងគណកម្មការវត្ត នៅថ្ងៃសៅរ៍ ១៥កើត ខែពិសាខ ឯកស័កព.ស.២៥៦៣ ។

ព្រះចេតិយនេះមានទទឹង ១០ម៉ែត្រ បណ្ដោយ ១០ម៉ែត្រ និងកម្ពស់ ៣៣ម៉ែត្រ ,សព្វថ្ងៃនេះព្រះចេតិយកំពុងកសាងបាន ៨០ ភាគរយហើយ និងបង្ហើយនៅថ្ងៃខាងមុខ, ដែលតម្កល់ព្រះសារីរិកធាតុអារាធនាមកពី***ប្រទេសឥណ្ឌា*** ដោយព្រះគ្រូចៅអធិការវត្ត និងញាតិញោមពុទ្ធបរិស័ទ ។

ព្រះចេតិយនេះ មានរាងស្រដៀងទៅនឹងចេតិយពុទ្ធគយា ***ប្រទេសឥណ្ឌា*** ជាកន្លែងព្រះពុទ្ធទ្រង់ត្រាស់ដឹង, ដែលស្ថិតនៅភូមិ ស្វាយជួ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ។

ពុទ្ធបរិស័ទទាំងឡាយដែលប្រាថ្នានូវបុណ្យកុសលក៏សូមបញ្ចេញនូវសទ្ធារៀង ៗ ខ្លួនចុះ ព្រោះថាការកសាងព្រះចេតិយនេះមិនងាយ នឹងកើតមានទេ សូមអនុមោទនាបុណ្យ ៕

*(Facebook វត្តទឹកវិល Wat Toekvil )*








#LMZ

## ៦១.ព្រះចេតិយវត្តកែវកេសរ្យមុនី " វត្តបន្លេច "

*ព្រះចេតិយវត្តកែវកេសរ្យមុនី ស្ថិតនៅ ភូមិបន្ទេច ឃុំពាមមានជ័យ ស្រុកពាមរក៍ ខេត្ត ព្រៃវែង,*

*ព្រះចេតិយនេះកសាងដោយព្រះសង្ឃ គណៈកម្មការវត្ត នឹងពុទ្ធ បរិស័ទគ្រប់ទិសទី ដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រៃ។*

*រីឯព្រះសារីរិកធាតុវិញ អារាធនាពី**ប្រទេសសិរីលង្កា** យកមកតម្កល់ នៅ **វត្តចំបក់មានជ័យ**មួយរយៈ រួចហើយក៏អារាធនាព្រះសារីរិកធាតុចេញ ពីវត្តនេះ ទៅតម្កល់ក្នុងព្រះចេតិយវត្តកែវកេសរ្យមុនី ដែលកសាង រួចរាល់ហើយ។*

(facebook Sudhamma VongSarann)



## ៦២.ព្រះចេតិយ វត្តជេតពន "វត្តត្រី"

*ព្រះករុណាលោកម្ចាស់ និងពុទ្ធបរិស័ទទាំងឡាយ ក្នុង**វត្តជេតពន** ហៅ**វត្តត្រី**នេះ មានព្រះចេតិយព្រហ្មមុខបួនមួយដែលនៅជិតព្រះវិហារ កសាងនៅឆ្នាំ២០០២ ដែលដឹកនាំកសាងដោយគ្រូ **សុខ ជា** ដែលមានឧបាសិកា **សុខ អ៊ីម** ជាអ្នកឧបត្ថម្ភក និងព្រះពុទ្ធបរិស័ទគ្រប់ទិសទីផងដែល។ ព្រះចេតិយតម្កល់ព្រះសារីរិកធាតុនៅជាន់ខាងលើ ដែលបានមកពីព្រះសង្ឃជនជាតិកូមាទ្រទ្រង់ព្រះត្រៃបិដកប្រគេនលោកគ្រូ **សុខ ជា** នាវត្តធម្មកាយ ជាន់ទីពីរតម្កល់អដ្ឋិធាតុព្រះគ្រូចៅអធិការវត្តគ្រប់ជំនាន់ និងលោកតាធម្មាចារ្យ **រស់ ឈុន** ជាន់ខាងក្រោមតម្កល់ធាតុរបស់ សីលវន្ត សីលវតី សីល១០ ពុទ្ធបរិស័ទ សីល៨ សីល៥ ។*

*ក្នុងវត្តនេះក៏មានវគ្គបដិបត្តិធុតង្គ វិបស្សនាកម្មដ្ឋាន រយៈពេល៧ថ្ងៃក្នុងមួយឆ្នាំបើកវគ្គម្តង ដែលមានព្រះសង្ឃ និងពុទ្ធបរិស័ទចូលមកបដិបត្តិយ៉ាងច្រើនគួរជាទីជ្រះថ្លា, ក្រោមការគ្រប់គ្រងដឹកនាំបែងចែករបស់ព្រះសាសនមុនី មហាកម្មដ្ឋានាចរិយ **ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ** ប្រធានពុទ្ធមណ្ឌលនៃព្រះរាជាណាចក្រកម្ពុជា អមដោយព្រះអនុប្រធាន និងមន្ត្រីសង្ឃ អ្នកឧញ៉ាសុធម្មាធិបតីឯក**សុខ អ៊ីម**។ មជ្ឈមណ្ឌលវិបស្សនាធុ នេះស្ថិតនៅភូមិល្វាក្រោម ឃុំស្ដៅ ស្រុកងមាស ខេត្តកំពង់ចាម ។*

*(Facebook លោកគ្រូ ធម្មបាលឡេង សុខជា)*





## ៦៣.ព្រះចេតិយ វត្តភ្នំសន្ទូច

*នៅខេត្តកំពង់ធ្មំមានអារាមវត្តមួយកន្លែងឈ្មោះថា* ***វត្តពលិសបព្វតារាម*** *ដែលស្ថិតនៅលើភ្នំសន្ទូច ក្នុងវត្តនេះមានព្រះចេតិយស្អាតមួយតម្កល់ព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង, នៅក្នុងថ្ងៃបុណ្យធំៗ ដូចជាបុណ្យមាឃបូជា វិសាខ បូជាជាដើម មានព្រះសង្ឃ និងពុទ្ធបរិស័ទចូលរួមក្នុងបុណ្យនោះយ៉ាងច្រើនគួរជាទីជ្រះថ្លា។ ដែលស្ថិតនៅភូមិសន្ទូច ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ធ្មំ បើព្រះករុណាលោកម្ចាស់ និងញាតិញោមបានជិះកាត់ខេត្តនេះកុំភ្លេចឆៀងចូលផង៕*

*(Facebook ប៉ែន សដ្ឋា)*







## ៦៤.ព្រះគន្ធកុដិ វត្តគិរីបញ្ញាបុប្ផារាម "វត្តបាណន់"

*បូជនីយដ្ឋានប្រាសាទភ្នំបាណន់ខេត្តបាត់ដំបង ករុណាលោកម្ចាស់ និងពុទ្ធបរិស័ទធ្លាប់បានស្គាល់ហើយ នៅឡើយ ព្រះគន្ធកុដិវត្ត***បាណន់** *ដែលគេតម្កល់ព្រះសារីរិកធាតុ នៅខាងឆ្វេងដៃផ្លូវចូលប្រាសាទភ្នំបាណាន់,ព្រះគន្ធកុដិនេះមានបីជាន់ ជាន់ទីមួយទីពីរជាកុដិ និងជាន់ខាងលើជាព្រះចេតិយ យកគំរូតាមព្រះសក្យមុនីចេតិយ***ភ្នំអដ្ឋរស្ស** *ដែលដឹកនាំកសាងដោយព្រះសពព្រះគ្រូសង្ឃបញ្ញា* **ប៉ុន ញាណ** *ព្រះអនុគណស្រុកបាណន់ និងពុទ្ធបរិស័ទគ្រប់ទិសទី ដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ។*

*សព្វថ្ងៃនេះព្រះសារីរិកធាតុត្រូវបានអារាធនាចុះពីព្រះគន្ធកុដិតម្កល់ក្នុងសាលាធម្មសភា, ក្នុងថ្ងៃបុណ្យធំៗ ដូចជាបុណ្យវិសាខបូជា និងបុណ្យមាឃបូជាជាដើម ក៏មានការដង្ហែព្រះសារីរិកធាតុជុំវិញព្រះគន្ធកុដិ និងព្រះពោធិព្រឹក្ស បូជាគ្រឿងសក្ការៈមានទៀន ធូប ផ្កា ចំពោះគុណព្រះរតនត្រៃ ដែលមានព្រះសង្ឃ និងពុទ្ធបរិស័ទចូលរួមយ៉ាងកុះករផងដែល៕*

*(Facebook វត្តបាណាន់)*



## ៦៥.ព្រះបរមចេតិយ វិទ្យាសម្តេចឪ

*ក្នុងវិទ្យាល័យសម្តេចឪ មានព្រះបរមចេតិយមួយដែលបញ្ចុះព្រះសារីរិកធាតុ ព្រះចេតិយនេះមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ដែលស្ថិតនៅ ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង តាមបណ្តោយផ្លូវលេខ ៣ ទល់មុខវត្តកំផែង ។ ព្រះចេតិយនេះបើព្រះករុណាលោកម្ចាស់បានជិះកាត់ផ្លូវនេះ កុំភ្លេចចៀងចូលថ្វាយបង្គំបូជាគ្រឿងសក្ការៈផ្សេងៗផង៕*

*(Facebook រចនា រចនា)*



## ៦៦.ព្រះបរមចេតិយ វត្តមុនីរតនារាម "អន្លង់ថ្នាន់"

*ក្នុងវត្តមុនីរតនារាម មានព្រះបរមចេតិយមួយដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ដែលមានកម្ពស់បីជាន់ជាន់ខាងក្រោមនាថ្ងៃខាងមុខនិងតម្កល់ព្រះពុទ្ធបដិមា ជាន់ទីពីរតម្កល់ព្រះសារីរិកធាតុ និងជាន់ទីបីតម្កល់ព្រះពុទ្ធរូបទាំងបួនព្រះអង្គ, កសាងនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៧ ដែលដឹកនាំកសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទគ្រប់ទិសទី ។*

*ក្នុងថ្ងៃបុណ្យព្រះពុទ្ធសាសនាធំៗដូចបុណ្យមាឃបូជា វិសាខបូជាជាដើម មានពុទ្ធបរិស័ទគ្រប់ទិសទី មកចូលរួម ដង្ហែព្រះសារីរិកធាតុជុំវិញព្រះចេតិយ និងព្រះពោធិព្រឹក្សបូជាគ្រឿងសក្ការៈផ្សេងៗ ដោយចិត្តរីករាយក្នុងបុណ្យកុសលទាំងឡាយ។ ដែលស្ថិតនៅភូមិអន្លង់ថ្នាន់ ឃុំបត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ៕*

*(Facebook សាមណេរ សិទ្ធ)*






Wondershare
Filmora
Created with
Wondershare Filmora free plan

## ៦៧.ព្រះចេតិយ វត្តភ្នំទទា

*វត្ត**ភ្នំទទា** ជាវត្តមួយសំបូរទៅដោយបូជនីយដ្ឋានគោរពបូជាជាច្រើន, ក្នុងនោះក៏មានព្រះចេតិយមួយតម្កល់ព្រះសារីរិកធាតុ និងអរហន្តធាតុ ព្រះមហាមោគ្គល្លាន ដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា ។ ដែលដឹកនាំកសាងដោយព្រះគ្រូចៅអធិការព្រះនាម* **កយ តូច** *និងពុទ្ធបរិស័ទគ្រប់ទិសទីផងដែល។*

*នៅពេលបុណ្យពុទ្ធសាសនាធំ ៗ ដូចជាបុណ្យមាឃបូជា វិសាខបូជាជាដើម មានការប្រារព្ធពិធីនោះនៅខាងមុខព្រះចេតិយនេះដែលមានព្រះសង្ឃ និងពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករគួរជាទីជ្រះថ្លា។ វត្ត**ភ្នំទទា**ស្ថិតក្នុងឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ៕*

*(Facebook សច្ចំពេរ អមតៈវាចា)*









## ៦៨.ព្រះគន្ធកុដិ វត្តវិហារធំ

*វត្តព្រះវិហារធំដែលស្ថិតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ក្នុងវត្តនេះមានបូជនីយដ្ឋានជាច្រើនដែលកំពុងកសាងផងដែល ក្នុងនោះក៏មានព្រះគន្ធកុដិមួយយ៉ាងស្អាត ដែលមានក្បាច់រចនាគួជាទីជ្រះថ្លា ដែលតម្កល់ព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់នៃយើង។*

*ព្រះគន្ធកុដិនេះក្នុងថ្ងៃបុណ្យពុទ្ធសាសនាធំៗ ដូចជាបុណ្យមាឃបូជា វិសាខ បូជាជាដើម មានការដង្ហែជុំវិញព្រះគន្ធកុដិ បូជាគ្រឿងសក្ការៈផ្សេង ដែលមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។ ដែលស្ថិតនៅ ភូមិពោធិ៍ដំរី ឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង៕*

*(Facebook យុន ស្រីនីត)*





## ៦៩.ព្រះគន្ធកុដិ វត្តគោសិង្គសាលវ័ន "ហៅវត្តព្រៃគោ"

*ព្រះគន្ធកុដិ វត្តគោសិង្គសាលវ័ន* ***"ហៅវត្តព្រៃគោ"*** *ជាវត្តមួយដែលមានព្រះសង្ឃសិក្សាព្រះធម៌ព្រះវិន័យផងដែល, ក្នុងវត្តនេះក៏មានព្រះគន្ធកុដិមួយយ៉ាងស្អាតគួរជាទីជ្រះថ្លា ដែលកសាងនៅឆ្នាំ២០០៤ ដែលតម្កល់ព្រះបរមសារីរិកធាតុ អារាធនាមកពីប្រទេសសិរីលង្កា។*

*ក្នុងបុណ្យធំៗ ដូចជាបុណ្យបូជា វិសាខបូជា ជាដើមក៏មានការបូជាគ្រឿងសក្ការៈផ្សេងៗ ដែលមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករ ។ ដែលស្ថិតនៅភូមិ ព្រៃគោ ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល៕*

*(Facebook ហេង ហេង)*




វត្តគោសិទ្ធសាលវ័ន ហៅវត្តព្រៃគោ
ភូមិព្រៃគោ ឃុំលំហាច ស្រុកអង្គស្នួល









## ៧០.ព្រះសក្យមុនីចេតិយ វត្តពោធិ៍សាល "ហៅថាវត្តអំពិល"

*ព្រះសក្យមុនីចេតិយយ៉ាងស្រស់ស្អាតដែល នឹងប្រារព្ធពិធីសម្ពោធឆ្លង នាថ្ងៃសុក្រ សៅរ៍ អាទិត្យ ចន្ទ ៧-៨-៩-១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៦-១៧-១៨-១៩ ខែកម្ភៈ ឆ្នាំ ២០២៤ ដែលស្ថិតនៅវត្តពោធិ៍សាល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ។*

*ព្រះចេតិយនេះដឹកនាំកសាងដោយ ព្រះវិន័យ**សរណៈភទ្ទ** ព្រះរាជាគណៈថ្នាក់កិត្តិយស ព្រះគ្រូព្រះនាម **បាន សុភេទ** ព្រមទាំង លោកអាចារ្យ គណកម្មការ លោកគ្រូ អ្នកគ្រូ ពុទ្ធបរិស័ទគ្រប់ទិសទី ៕*

*(Facebook វត្តពោធិ៍សាល ហៅវត្តអំពិល)*







## ៧១.ព្រះចូឡាមណីចេតិយ វត្តវាល

*ព្រះករុណាលោកម្ចាស់ ញាតិញោមប្រុសស្រីទាំងឡាយនៅខេត្តពោធិ៍សាត់ មានវត្តមួយឈ្មោះថា**វត្តវាល** ក្នុងវត្តនេះមានបូជនីយដ្ឋានគួរដល់ការគោរពបូជា មានព្រះពុទ្ធបដិមាផ្ចាញ់មារដ៏ធំកម្ពស់ ២៩ម៉ែត្រ ព្រះភ្នែនប្រវែង ២១ម៉ែត្រ កសាងនៅឆ្នាំ២០០៩-២០១៣ , ត្រូវបានកែទម្រង់ព្រះពុទ្ធបដិមារនេះ នៅផ្នែកព្រះភ័ក្ត្រ និងដងខ្លួនជាដើម នៅឆ្នាំ ២០២៣-២០២៤ និងព្រះចូឡាមណីចេតិយ តម្កល់ព្រះបរមសារីរិកធាតុ , ដែលមានក្បាច់រចនាយ៉ាងស្រស់ស្អាតនៅខាងមុខព្រះអង្គធំ គួរជាទីជ្រះថ្លា ។*

*ព្រះពុទ្ធបដិមាផ្ចាញ់មារ និងព្រះចូឡាមណីចេតិយនេះត្រូវបានធ្វើពិធីបុណ្យពុទ្ធាភិសេកឆ្លងយ៉ាងឧឡារឹកនៅថ្ងៃសៅរ៍.អាទិត្យ ១៤-១៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចាស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃ ទី២៣-២៤ ខែមីនា ឆ្នាំ២០២៤, ដែលមានពុទ្ធបរិស័ទគ្រប់ទិសទីចូលរួមយ៉ាងច្រើនកុះករដែលស្ថិតនៅភូមិផ្សារលើ សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់៕*

*(អត្ថបទ ភិរុណ ពៅ)*











## ៧២.ព្រះចេតិយ វត្តប្រាំបីឆោម

*វត្តប្រាំបីឆោម ក្នុងវត្តនេះបូជនីយដ្ឋានគោរពបូជាដូចជាព្រះពុទ្ធទ្រង់ទទួលផ្ទឹតឃ្មុំពីស្វា និងដំរីថ្វាយទឹកជាដើម, ក្នុងនោះក៏មានព្រះចេតិយព្រហ្មមុខបួនកសាងពីថ្មភក់យ៉ាងស្អាត , ខាងលើសីស:ព្រហ្មនេះតម្កល់ព្រះវិសេសធាតុ (ព្រះបរមសារីរិកធាតុ) ព្រះពុទ្ធរូបថ្មក្រមួន ព្រះធរណីអាពធនាមកពីពុទ្ធដ្ឋាននានា និងរតនៈវត្ថុផ្សេងៗ ជាន់ខាងលើនេះតំណាងឱ្យព្រះពុទ្ធ, ជាន់បន្ទាប់ដែលមានរូបព្រហ្មមុខបួនតំណាងឱ្យព្រះធម៌ (ព្រហ្មវិហារធម៌ទាំងបួន) ជាន់ដែលមានរូបព្រះសង្ឃប្រាំបីទិស តំណាងឱ្យព្រះអរិយសង្ឃ ជាន់បន្ទាប់ទៀតតម្កល់អដ្ឋិធាតុលោកអ្នកមានគុណ មានមាតាបិតាជីដូនជីតាន ញាតិរបស់ក្រុមគ្រួសារលោកគ្រូ**ឡេងសុខ ជា** ។*

*ព្រះចេតិយនេះ ដឹកនាំកសាងលើកទីបី ដោយលោកគ្រូធម្មបាល**ឡេង សុខជា** និងញាតិមិត្តជិតឆ្ងាយ នៅថ្ងៃ ព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០២៣ ,និងធ្វើពិធីពុទ្ធាភិសេកឆ្លង នៅថ្ងៃ អង្គារ ៨កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៤ ,ញោមកសាងព្រះចេតិយនេះដើម្បីទុកជាទីសក្ការៈដល់មនុស្សទេវតាទាំងឡាយបូជា, វត្តប្រាំបីឆោម ស្ថិតនៅ ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល៕*

*(Facebook លោកគ្រូ ធម្មបាល ឡេងសុខជា)*











## ៧៣.ព្រះចេតិយវត្តឧត្តមសាគរ "ហៅវត្តព្រៃកក្របៅ"

*ព្រះចេតិយតម្កល់ព្រះសារីរិកធាតុដែលមានក្បាច់រចនាយ៉ាងស្អាតគួរជាទីជ្រះថ្លា នៅវត្តឧត្តមសាគរនេះ ដឹកនាំកសាងដោយលោកព្រះគ្រូចៅអធិការវត្ត ព្រះនាម **សូរ សុខា** និងគណកម្មការវត្ត ពុទ្ធបរិស័ទគ្រប់ទិសទី ។*

*ព្រះចេតិយនេះមានបណ្តោយ ២២ម៉ែត្រ ៤ជ្រុង នឹងកម្ពស់១៧ម៉ែត្រ មាន៣ជាន់ ជាន់ទី១តម្កល់ព្រះពុទ្ធរូប ជាន់ទី២តម្កល់ព្រះអរហន្តធាតុ និងជាន់ទី៣តម្កល់ព្រះបរមសារីរិកធាតុ ដែលដង្ហែមកពីវត្តគល់ទទឹង ។ ក្នុងថ្ងៃសីល បុណ្យមាឃបូជា វិសាខ បូជាជាដើម មានពុទ្ធបរិស័ទចូលរួមមកគោរពបូជានូវគ្រឿងសក្ការៈទាំងឡាយយ៉ាងច្រើនកុះករ, ដែលវត្តនេះស្ថិតនៅភូមិឧត្តម ឃុំព្រៃកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង ៕*

*(Facebook វត្តឧត្តមសាគរ ហៅវត្តព្រៃកក្របៅ)*







## I- **បកិណ្ណកៈរឿងអំពីព្រះចេតិយផ្សេងៗ**

## **១.ព្រះអង្គទ្រង់បញ្ញត្តវត្ត អាវាសិកភិក្ខុ**

***អាវាសិកេន ភិក្ខវេ ភិក្ខុនា អាគន្តុកំ ភិក្ខុំ វុឌ្ឍតរំ ទិស្វា អាសនំ បញ្ញាបេតព្វំ,*** *អាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុដែលចាស់ជាងខ្លួនហើយ ត្រូវក្រាលអាសនៈដល់អាគន្តុកភិក្ខុដែលចាស់ជាង ។*

***អដ្ឋកថា ៖ អាសនំ បញ្ញាបេតព្វន្តិ ឯវមាទិ សព្វំ វុឌ្ឍតរេ អាគតេ ចីវរកម្មំ វា នវកម្មំ វា ឋបេត្វាបិ កាតព្វំ ។ ចេតិយង្គណំ សម្មជ្ជន្តេន សម្មជ្ជនី និក្ខិបិត្វា តស្ស វត្តំ កាតុំ អារភិតព្វំ ។***

*កាលអាគន្តុកៈដែលចាស់ជាងមក គប្បីវៀរចីវរកម្ម ឬនវកម្មចេញ ធ្វើកិច្ចទាំងពួង មានជាដើមយ៉ាងនេះថា ត្រូវក្រាលអាសនៈ ដូច្នេះ កំពុងបោសលានចេតិយ គប្បីទុកដាក់អំបោស ផ្ដើមធ្វើវត្តដល់លោក ។*

***បណ្ឌិតោ ហិ អាគន្តុកោ "សម្មជ្ជាហិ តាវ ចេតិយង្គណ"ន្តិ វក្ខតិ ។*** *បើថាអាគន្តុកៈជាអ្នកឆ្លាត លោកពោលថា "ចូរបោសលានចេតិយជាមុនចុះអ្នកមានអាយុ" ។*

*ក្នុងអត្ថយោជនាថា:* ***បណ្ឌិតោតិអាទិនា សចេ ពាលោ សម្មជ្ជាហិ តាវ ចេតិយង្គណន្តិ ន វទតិ, សម្មជ្ជនី និក្ខិបិត្វា តស្ស វត្តមេវ កាតព្វន្តិ ទស្សេតិ ។***

*ដោយពាក្យថា ជាបណ្ឌិតជាដើម រមែងសម្ដែងថាបើភិក្ខុ អាគន្តុកៈជាអ្នកមិនឆ្លាត មិនពោលថា លោកចូរបោសលាន ព្រះចតិយ សិនចុះ ដូច្នេះក៏ត្រូវទុកដាក់អំបោសធ្វើវត្តដល់ភិក្ខុអាគន្តុកៈ នោះមុនពិត ។*

*(វិនយបឋមសិក្សា ភាគ២ វត្តក្ខន្ធកៈ១៤ និងមហាវត្ត៨២ ទំព័រ ២០-២១)*

## ២.ការទទួលព្រះកោដ្ឋមាសមិនគួរ
## (ព្រះអដ្ឋកថាចារ្យ)

*បានឮថា ឧត្តររាជឱរសឱ្យសាងព្រះចេតិយមាស បញ្ជូនទៅប្រគេន* ***ព្រះមហាបទុមត្ថេរៈ*** *។ ព្រះថេរៈហាមថា មិនគួរ ។ ផ្កាឈូកមាស និងផ្កាយមាសជាដើម មាននៅត្រង់ទីលានព្រះចេតិយ, សូម្បីវត្ថុទាំងនោះ ក៏ជា****អនាមាស*** *តែពួកភិក្ខុដែលនៅថែទាំព្រះចេតិយតាំងនៅក្នុងឋានជាអ្នក* ***ចោលរូបិយៈ*** *ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុទាំងនោះនឹងស្ទាបអង្អែលមើល ក៏គួរ ។ តែពាក្យនោះ លោកហាមទុកក្នុងកុរុន្ទី ។ លោកអនុញ្ញាតត្រឹមតែប៉ុណ្ណេះថានឹងនាំចេញនូវសំរាមលើព្រះចេតិយមាសគួរ ។*

## ដីកាចារ្យ

****សុវណ្ណចេតិយន្តិ ធាតុករណ្ឌកំ ។ បដិគ្គិបីតិ "ធាតុដ្ឋបនត្ថាយ គណ្ហថា" តិ អវត្វា "តុម្ហាកំ គណ្ហថា" តិ បេសិតត្តា បដិក្ខិបិ ។*** *ពាក្យថា ចេតិយមាស បានដល់ ព្រះកោដ្ឋ សម្រាប់បម្កល់ព្រះសារីរិកធាតុ ។ ពាក្យថា* ***ហាម*** *បានដល់****ការហាម*** *ព្រោះគេមិនបានពោលថា លោក ម្ចាស់ចូលទទួលទុក ដើម្បីប្រយោជន៍ដល់ការតម្កល់ទុក* ***ព្រះសារីរិកធាតុ*** *តែគេពោលថា ចូរទទួលទុកសម្រាប់លោកម្ចាស់ ។*

*( សារត្ថទីបនី ភាគ ២/៣៩០)*

****ថេរោ ន កប្បតីតិ "តុម្ហាកំ បេសិត"ន្តិ វុត្តតា ។ "ចេតិយស្ស បូជំ ករោថា"តិ វុត្តេ វដ្ដតិ កិរ ។*** *ពាក្យថា ព្រះថេរ ពោលថា មិនគួរ គឺមានសេចក្ដីថា ព្រោះភាវនៃព្រះកោដ្ឋមាស គឺគេបញ្ជូនទៅដើម្បីលោក ។ បានឮថា*

*កាលបើគេពោលថា សូមលោកម្ចាស់ធ្វើការបូជាព្រះចេតិយ ដូច្នេះ រមែងគួរ ។ ( ដីកាវជិរ:/ ២៣៨ )*

**** បដិក្ខិបីតិ សុវណ្ណមយធាតុករណ្ឌកស្ស, ពុទ្ធរូបាទិស្ស ច អត្តនោ សន្តកករណេ និស្សគ្គិយត្តា វុត្តំ*** *។ ពាក្យថា ហាម ដូច្នេះគឺលោកពោលហើយព្រោះភាវៈនៃព្រះកោដ្ឋតម្កល់ព្រះធាតុសម្រេចពីមាស ជាវត្ថុនិស្សគ្គិយផង ព្រោះព្រះពុទ្ធរូបជាដើម ដែលគេធ្វើឱ្យជារបស់នៃខ្លួនផង ។*

**** "រូបិយឆឌ្ឌកដ្ឋានេ" តិ វុត្តត្តា រូបិយឆឌ្ឌកស្ស ជាតរូបរជតំ អាមសិត្វា ឆឌ្ឌេតុំ វដ្ដតីតិ សទ្ធំ*** *។ ព្រោះភាវៈនៃពាក្យដែលលោកអាចារ្យពោលថា ក្នុងឋានៈជាអ្នកចោលរូបិយដូច្នេះ លោកសម្រេចថា ភិក្ខុ អ្នកចោលរូបិយគួរដើម្បីនឹងប៉ះពាល់នូវមាស និង ប្រាក់ហើយចោលបាន ។*

*( វិមតិវិនោទនី ភាគ ១ /៣៣៨ ) (វិកង្ខបត្តក្កក: ភាគ២. ទំព័រ ៤០-៤២ ។)*

## ៣.ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយ គួរប៉ះវត្ថុអនាមាសបាន

**** កចវ រមេវ ហរិតុំ វដ្ដតីតិ ចេតិយគោបកា វា ភិក្ខុ ហោន្តុ អញ្ញេ វា ហត្ថេនបិ បុញ្ឆិត្វា កចវរំ អបនេតុំ វដ្ដតិ មលម្បិមជ្ជិតុំ  វដ្ដតិយេវ*** *។ ពាក្យថា នាំចេញនូវសំរាមគួរ នេះមានសេចក្ដីថា ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយក្ដី ភិក្ខុដទៃក្ដី ចូរលើកទុកចុះ, សូម្បីយកដៃជូត (នូវផ្កាឈូកមាសនិងប្រអប់មាសជាដើម ក្នុងព្រះចតិយ) នាំយកសំរាមចេញគួរ ។ សូម្បីខាត់នូវ ស្នឹម (ច្រេះ) គួរ ពិត ។( សារត្ថទីបនី ភាគ ២ ‌| ៣៩០)*

**** កចវ រមេវ ហរិតុំ វដ្ដតីតិ គោបកា វា ហោន្តុ អញ្ញេ វា, ហត្ថេន បុញ្ឆិ***

***ត្វា កចវរំ អបនេតុំ វដ្ដតិ, មលម្បិ បមជ្ជិតុំ វដ្ដតិ ឯវាតិ វទន្តិ*** ។ *ពាក្យថា នាំចេញនូវសំរាមតែម្យ៉ាងគួរ ដូច្នេះ អាចារ្យទាំងឡាយពោលថា ភិក្ខុអ្នករក្សាក្តី ភិក្ខុដទៃក្តី ចូរលើកទុកចុះ, រមែងគួរដើម្បីយកដៃជូត (នូវផ្កាឈូកមាស និងប្រអប់មាសជាដើម ក្នុងព្រះចេតិយ) ហើយនាំយកសំរាមចេញបាន ។ សូម្បីខាត់នូវស្នាម (ច្រេះ) រមែងគួរពិត ។*

***តំ អដ្ឋកថាយ ន សមេតិ កេឡាយនសទិសត្តា*** ។ *ពាក្យរបស់អាចារ្យនោះមិនសមនឹងអដ្ឋកថាទេ ព្រោះប្រាកដដូចជាការស្ទាបអង្អែលមើលដែរ ៕*

*(វិមតិវិនោទនី ភាគ ១ /៣៣៨) (វិភង្គបត្ថម្ភក: ភាគ២ . ទំព័រ ៤២-៤៣)*

## ៤.ភិក្ខុដែលនាំដំណឹង ដែលសមគួរ របស់ពួកគ្រហស្ថបាន ព្រះអដ្ឋកថាចារ្យ

❖ *ភិក្ខុដែលនាំដំណឹង ដែលសមគួររបស់ពួកគ្រហស្ថបាននោះគឺ :*

***១- មម វចនេន ភគវតោ បាទេ វន្ទថ*** *សូមលោកម្ចាស់ថ្វាយបង្គំយុគលបាទរបស់ព្រះមានព្រះភាគ តាមពាក្យរបស់ខ្ញុំព្រះករុណាផង ។*

***២- ចេតិយំ បាដិមំ ពោធឹ សង្ឃត្ថេរំ វន្ទថ*** *សូមលោកម្ចាស់ ថ្វាយបង្គំព្រះចេតិយព្រះបដិមាព្រះពោធិព្រឹក្សព្រះសង្ឃត្ថេរផង ។*

***៣- ចេតិយេ គន្ធបូជំ ករោថ បុប្ផបូជំ ករោថ*** *សូមលោកម្ចាស់ធ្វើការបូជាដោយគ្រឿងក្រអូបបូជាដោយផ្កា ចំពោះព្រះចេតិយ ។*

***៤- ភិក្ខុ សន្និបាតេថ ទានំ ទស្សាម ធម្មំ សោស្សាម*** *សូមលោកម្ចាស់និមន្តឱ្យភិក្ខុទាំងឡាយប្រជុំគ្នា ពួកខ្ញុំករុណា នឹងថ្វាយទាន នឹងស្តាប់ធម៌ ។ (វិភង្គបត្ថម្ភក: ភាគ២ ទំព័រ ១៨៧)*

## ៥.ពេលដែលគួរឱ្យផ្លែឈើជាដើម ដល់គ្រហស្ថ
## (ព្រះអដ្ឋកថាចារ្យ)

*ភិក្ខុដែលសង្ឃសន្មតហើយ ឱ្យជាអ្នកចែកផ្កាឈើ គួរ ឱ្យចំណែកពាក់កណ្តាលដល់ពួកសាមណេរ ដែលមកដល់ក្នុងពេលកំពុងចែក ក្នុង* ***កុរុន្ទី****ពោលថា គួរឱ្យចំណែកពាក់កណ្តាល ដល់គ្រហស្ថដែលមកដល់ តែក្នុង****មហាបច្ចរី****ពោលថា គួរឱ្យបន្តិចបន្តួច (ចំណែកទី៤) បើភិក្ខុមិនបានទទួលសន្មតទេ* ***ត្រូវអបលោកឱ្យ*** *។ សាមណេរទាំងឡាយ មានសេចក្តីគោរពក្នុងអាចារ្យនិងឧបជ្ឈាយ៍ នាំផ្កាជាច្រើនមកហើយតម្កល់ទុកឱ្យជាគំនរ ព្រះថេរទាំងឡាយ ឱ្យដល់****សិទ្ធិវិហារិក****ជាដើម ឬឧបាសកឧបាសិកាទាំងឡាយដែលមកដល់អំពីព្រលឹមស្រាងៗដោយពាក្យថា* ***តុំ ឥទំ គណ្ហ, តុំ ឥទំ គណ្ហ*** *អ្នកចូរកាន់យកវត្ថុនេះ. អ្នកចូរកាន់យកវត្ថុនេះដូច្នេះ ។ មិនឈ្មោះជាការឱ្យផ្កាទេ ។ ពួកភិក្ខុកាន់យកទៅដោយគិតថា* ***ចេតិយំ បូជេស្សាម*** *យើងនឹងបូជាព្រះចេតិយក្តី កំពុងធ្វើការបូជាក្តី ឱ្យដល់មនុស្សទាំងឡាយ ដែលមកដល់លានព្រះចេតិយនោះៗ ដើម្បីជាប្រយោជន៍ដល់ការបូជាដល់ព្រះចេតិយសូម្បីការឱ្យនេះ មិនឈ្មោះថាជាការឱ្យទេ ។ សូម្បីពួកភិក្ខុឃើញពួកឧបាសកទាំងឡាយ កំពុងបូជាដោយ****ផ្កាពាំង****ជាដើម ហើយពោលថា ក្នុងវិហារមាន****ផ្កាកណ្ណិការ****ជាដើម ម្នាលឧបាសកទាំងឡាយ ពួកអ្នកចូលកាន់យកផ្កាទាំងនោះបូជាចុះ រមែងសមគួរ ។*

*តែក្នុង****មហាបច្ចរី*** *និង****កុរុន្ទី****លោកពោលថា ព្រះថេរៈទាំងឡាយរមែងមិនបានដើម្បីប្រើឱ្យពួកសាមណេរឱ្យ, បើពួកសាមណេរឱ្យផ្កាឈើទាំងនោះ ដល់ពួកអ្នកស្រុកទាំងនោះ ដោយខ្លួនឯងផ្ទុះឯង, ការឱ្យនោះ*

សមគួរ, តែព្រះថេរៈទាំងឡាយ គួរពោលពាក្យត្រឹមតែប៉ុណ្ណោះថា ពួកសាមណេរបេះផ្កាឈើទាំងនេះទុក ។

(វិភង្គបត្ថម្ភក: ភាគ២ ទំព័រ ១៩១-១៩២)

## ៦.ការបដិបត្តិក្នុងពុទ្ធបូជា (ការថ្វាយដល់សង្ឃពីរចំណែក)

មួយទៀត កាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់ចេតិយផង, ចេតិយបានចំណែកមួយផ្សេងទៀត, សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុសង្ឃផង ដល់លោកផង ដល់ចេតិយផង", ចេតិយប៉ុណ្ណោះ បានចំណែកមួយផ្សេងទៀត បុគ្គលមិនបាន ។ សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណាថ្វាយដល់ភិក្ខុទាំងឡាយផង ដល់លោកផង", បុគ្គលមិនបានចំណែកមួយផ្សេងទៀត ។ តែកាលគេពោលថា "ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុទាំងឡាយផង ដល់ចេតិយ ផង" ចេតិយ រមែងបានចំណែកមួយផ្សេងទៀត សូម្បីកាលគេពោលថា "ខ្ញុំព្រះករុណា ថ្វាយដល់ភិក្ខុទាំងឡាយផង ដល់លោកផង ដល់ចេតិយ ផង" ចេតិយប៉ុណ្ណោះ រមែងបានចំណែកមួយផ្សេងទៀត បុគ្គលមិន បាន ។ គប្បីលើក ភិក្ខុនីសង្ឃឱ្យជាដើមខ្លះ ប្រកបសេចក្តីយ៉ាងនេះ ដូចគ្នា ។

***សួរថា*** ក្នុងកាលមុន ទាយកទាំងឡាយថ្វាយទានដល់សង្ឃទាំងពីរផ្នែក មានព្រះពុទ្ធជាប្រធាន ព្រះមានព្រះភាគប្រថាប់អង្គុយត្រង់កណ្តាល ភិក្ខុអង្គុយខាងស្តាំ ភិក្ខុនីអង្គុយខាងឆ្វេង ព្រះមានព្រះភាគទ្រង់ជា***ព្រះសង្ឃត្ថេរ***នៃសង្ឃ ២ចំណែក គ្រានោះព្រះមានព្រះភាគ ទ្រង់សោយបច្ច័យដែលព្រះអង្គបាន ដោយព្រះអង្គឯងខ្លះ បង្គាប់ឱ្យ ប្រគេន

ដល់ភិក្ខុទាំងឡាយខ្វះ ។ ចំណែកក្នុងឥឡូវនេះ អ្នកឆ្លាតទាំងឡាយតាំង **ព្រះបដិមា** ឬព្រះចេតិយដែលតម្កល់**ព្រះធាតុ** ហើយថ្វាយទានដល់សង្ឃ ២ ចំណែកមានព្រះពុទ្ធជាប្រធាន តាំងបាត្រលើជើងទ្រខាងមុខនៃ**ព្រះបដិមា** ឬ **ព្រះចេតិយ**ហើយថ្វាយ**ទក្ខិណោទក** ពោលថា "សូមថ្វាយដល់**ព្រះពុទ្ធ**" ដូច្នេះហើយ ដាក់**ខាទនីយៈ ភោជនីយៈ**យ៉ាងណាជាទីមួយក្នុងបាត្រនោះ ឬនាំមកកាន់វត្តថ្វាយបិណ្ឌបាត និងវត្ថុមានកម្រងផ្កា និងគ្រឿងក្រអូប ជាដើមពោលថា "នេះថ្វាយព្រះចេតិយ" នឹងគប្បីបដិបត្តិយ៉ាងណា ក្នុង**ខាទនីយ** និង របស់គួរ**បរិភោគ**នោះ ?

**ឆ្លើយថា** វត្ថុមានកម្រផ្កា និងគ្រឿងក្រអូបជាដើម គួរតម្កល់ទុកទីព្រះចេតិយមុន, សំពត់គប្បីធ្វើជាទង់ផ្ទាំងសំពត់ ប្រេង គប្បីធ្វើអុជប្រទីប; ចំណែកបិណ្ឌបាតនិងភេសជ្ជៈមានទឹកឃ្មុំ និងទឹកអំពៅជាដើម គប្បីឱ្យដល់បព្វជិត ឬ គ្រហស្ថដែលជាអ្នករក្សា ព្រះចេតិយជាប្រចាំ កាលមិនមានអ្នករក្សាជាប្រចាំ សមគួរនឹងតាំងទុកដូច**ភត្ត**ដែលខ្លួនឯងនាំមក**ធ្វើវត្ត**ហើយឆាន់ ។ ក្នុងវេលាថ្ងៃជិតត្រង់ឆាន់ហើយ សឹម**ធ្វើវត្ត**ជាខាងក្រោយ ក៏គួរដូចគ្នា ។ ក៏កាលគេពោលថា "សូមលោក- ម្ចាស់ទាំងឡាយនាំវត្ថុនេះ ទៅធ្វើការបូជាព្រះចេតិយ ដូច្នេះបណ្ដាវត្ថុ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ឯណានីមួយ សូម្បីក្នុងទីឆ្ងាយ គួរនាំទៅបូជា សូម្បីកាលគេពោលថា "សូមលោកម្ចាស់នាំទៅដើម្បី ភិក្ខុសង្ឃ" គួរនាំទៅ ។ ក៏បើថា កាលភិក្ខុពោលថា "យើងនឹងត្រាច់បិណ្ឌបាត ឯអាសនៈ សាលាមានភិក្ខុ លោកទាំងឡាយនឹងនាំទៅ គេពោលថា "លោកដ៏ចម្រើន ខ្ញុំព្រះករុណាថ្វាយលោកម្ចាស់នុ៎ះឯង សមគួរឆាន់ ។ ក៏បើថា កាលភិក្ខុកំពុងនាំ

*ទៅ តាំងចិត្តថា នឹងថ្វាយ ភិក្ខុសង្ឃ" វេលាចូលកាន់តែជិត ក្នុងចន្លោះផ្លូវ នោះឯង សមគួរឱ្យដល់ខ្លួនហើយធាន់ចុះ ។*

*(សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបដិក មហាវគ្គ ភាគ៨ ទំព័រ ៤៧៦-៤៧៨)*

## ៧.សម្ពុទ្ធចក្កវត្តិចេតិយកថា (ពោលអំពីរឿងព្រះចេតិយ)

### *សម្ពុទ្ធចក្កវត្តិចេតិយកថា*

*លំដាប់តទៅនេះ **ព្រះនន្ទាចារ្យ** ទើបដោះស្រាយក្នុងបទមាតិកា គឺ **សម្ពុទ្ធចក្កវត្តិនំ ចេតិយានំ និទស្សនំ** បន្តទៅលោកពោលទុកក្នុង**អដ្ឋកថាគម្ពីរអង្គុត្តរនិកាយថា** ស្តេចចក្រពត្តិត្រាធិរាជដែលបានមកកើតក្នុងលោក នេះតែងតែប្រៀនប្រដៅសត្វទាំងឡាយ ឱ្យប្រព្រឹត្តកាយសុចរិត វចីសុចរិត មនោសុចរិត ញុំាំងសត្វលោកទាំងឡាយ ឱ្យសម្រេចនូវសម្បត្តិ ២ប្រការគឺ សម្បត្តិមនុស្សប្រការ១ សម្បត្តិទេវតាប្រការ១ ឱ្យសម្រេចបានតែពីរប្រការនេះប៉ុណ្ណោះ មិនអាចនឹង ឱ្យសម្បត្តិព្រះ- និព្វានបាន ដូចព្រះសម្មាសម្ពុទ្ធឡើយ ។ **ពុទ្ធានំ ឧប្បត្តិយា តិស្សោ សម្បត្តិយោ លភន្តិ** ព្រះសម្ពុទ្ធបើបានមកឧប្បត្តិត្រាស់ដឹងក្នុងលោកនេះ ហើយ ក៏តែងតែប្រោសដល់វេនេយ្យសត្វទាំងឡាយ ឱ្យបានសម្រេចនូវ សម្បត្តិទាំង៣ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ប្រសិនបើនឹងពោលដោយបុគ្គលអ្នកបដិបត្តិ នូវព្រះចេតិយនោះ បុគ្គលបដិបត្តិនូវព្រះចេតិយ ដែលបញ្ចុះព្រះធាតុ នៃស្តេចចក្រពត្តិនោះ បាននូវសម្បត្តិ២ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ ។ បុគ្គលបដិបត្តិនូវព្រះចេតិយនៃព្រះបរមនាថសាស្តាចារ្យនោះ បាននូវសម្បត្តិទាំង៣ គឺសម្បត្តិមនុស្ស១*

សម្បត្តិទេវតា១ សម្បត្តិ ព្រះនិព្វាន១ ។

បើពោលដោយចេតិយដ្ឋាននៃព្រះសាស្តានោះ ដីកាចារ្យលោកពោលទុកក្នុង សារត្ថទីបនីដីកា ព្រះវិន័យថា **តិវិធំ ហិ ពុទ្ធចេតិយំ** ពុទ្ធចេតិយនេះមាន ៣ ប្រការ គឺ**បរិភោគចេតិយ ១ ធាតុចេតិយ ១ ធម្មចេតិយ ១ ។**

**បរិភោគចេតិយ** បានដល់ព្រះចេតិយដែលបញ្ចុះបរិក្ខារ គឺសង្ឃាដិ ឧត្តរាសង្គៈ អន្តរវាសកៈ វត្តពន្ធចង្កេះ បាត្រជាដើមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

**ធាតុចេតិយ** បានដល់ ព្រះចេតិយដែលបញ្ចុះនូវព្រះបរមធាតុនៃព្រះសម្មាសម្ពុទ្ធ ។

**ធម្មចេតិយ** បានដល់ ចេតិយដែលពុទ្ធបរិស័ទតម្កល់ទុកនូវព្រះពុទ្ធវចនៈ មានបដិច្ចសមុប្បាទធម៌ជាដើម ។

ន័យមួយទៀត ចេតិយ៣ប្រការនេះ លោកចាត់ជា**ព្រះបរមសារីរិកធាតុចេតិយ ១ បរិភោគចេតិយ១ ឧទ្ទេសកចេតិយ ១ ។**

**ព្រះសារីរិកធាតុចេតិយ** នោះ បានដល់ ព្រះចេតិយដែលបញ្ចុះនូវព្រះបរមសារីរិកធាតុ ។

**បរិភោគចេតិយ** នោះ បានដល់ ព្រះចេតិយដែលបញ្ចុះគ្រឿងបរិក្ខារ មានបាត្រជាដើមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

**ឧទ្ទេសកចេតិយ** បានដល់ ព្រះចេតិយដែលបុគ្គលធ្វើឧទ្ទិសចំពោះព្រះពុទ្ធជាម្ចាស់ ហើយចាត់ចែងធ្វើ ដូចរូបព្រះពុទ្ធបដិមា ដែលបុគ្គលកសាងរាល់ថ្ងៃនេះ ក៏សង្គ្រោះចូលក្នុងឧទ្ទេសកចេតិយ ហេតុថា

បុគ្គលទាំងឡាយកសាងហើយ **ឧទ្ទិសថា** ជាអង្គព្រះសម្មាសម្ពុទ្ធ យល់អត្ថនោមត្យាធិប្បាយថា ព្រះចេតិយទាំងឡាយ ដែលបុគ្គលកសាងដោយឥដ្ឋក្តី កសាងដោយដីក្តី កសាងដោយដីខ្សាច់ក្តី ប៉ុន្តែក្នុងបណ្តាលដែលកសាងស្រេចហើយ រាប់ចូលក្នុងឧទ្ទេសកចេតិយទាំងអស់ ហេតុថាបុគ្គលទាំងឡាយរៀបចំធ្វើចំពោះតែព្រះពុទ្ធជាម្ចាស់ ជាទីគោរពបូជាឧទ្ទិសតបគុណព្រះពុទ្ធជាម្ចាស់ ទើបចាត់ចែងធ្វើព្រះចេតិយ ៣ គឺ **ព្រះសារីរិកធាតុចេតិយ ១ បរិភោគចេតិយ ១ ឧទ្ទេសកចេតិយ ១** ដូចពណ៌នាមកនេះ ដីកាចារ្យពោលសរសើរថា **សេដ្ឋតរំ យុជ្ជតិ** សមគួរក្រៃលែង ល្អក្រៃលែង និងបុគ្គលដែលបានថែរក្សាដ៏ល្អប្រពៃនូវព្រះចេតិយទាំងឡាយ ព្រះសម្ពុទ្ធជាម្ចាស់ត្រាស់សម្តែងថា ប្រកប ដោយប្រយោជន៍យ៉ាងច្រើន ។

សេចក្តីក្នុង **មហាបរិនិព្វានសូត្រ** នោះថា ព្រះពុទ្ធអង្គត្រាស់ទេសនាដល់ព្រះអានន្ទថា **យេ កេចិ អានន្ទ ចេតិយចារិកំ អាហិនទន្តា បសន្នចិត្តា កាលំ ករិស្សន្តិ** ម្នាលអានន្ទ បុគ្គលដែលមានកុសលចេតនាគិតថា យើងនឹងទៅនមស្ការព្រះចេតិយក្នុងព្រះវិហារឯណោះ កាលបើគិតដូច្នេះហើយ ក៏ចេញទៅដោយចិត្តសទ្ធាជ្រះថ្លា កាន់ទីនមស្ការព្រះចេតិយនោះ តែជាចៃដន្យក៏ស្លាប់ក្នុងរវាងផ្លូវ ទាំងដែលនៅមិនទាន់ដល់ព្រះចេតិយ នៅមិនទាន់បាននមស្ការព្រះចេតិយ បានតែចិត្តសទ្ធាជ្រះថ្លាប៉ុណ្ណោះ ក៏អាចបានសិរីសម្បត្តិក្នុង**មនុស្ស** និងសិរីសម្បត្តិក្នុង**ទេវតា** ខាងមុខអំពីចុតិចិត្ត ដោយអំណាចនៃសេចក្តីជ្រះថ្លា ក្នុងទី **នមស្ការព្រះចេតិយ** ព្រះពុទ្ធជាម្ចាស់ មានព្រះពុទ្ធដីកា ត្រាស់ដល់ ព្រះអានន្ទដូច្នេះ ។

ទើបមានពាក្យ **ព្រះអដ្ឋកថាចារ្យ** នៅក្នុង **មហាបរិនិព្វានសូត្រ** អធិប្បាយថា ប៉ុន្តែបុគ្គលដែលមានចិត្តជ្រះថ្លាវត្ថុមួយប៉ុណ្ណោះ នៅមិនទាន់ទៅដល់ព្រះចេតិយ នៅមិនទាន់នមស្ការព្រះចេតិយ ព្រះទសពលទ្រង់ត្រាស់សរសើរថា ប្រកបដោយផលច្រើន អាចនឹងឱ្យសម្រេច នូវសម្បត្តិក្នុង**មនុស្ស** និងសម្បត្តិក្នុង**ទេវលោក** ក៏ចាំបាច់ពោលទៅថ្វីដល់ផលនៃបុគ្គល ដែលបានទៅដល់ព្រះចេតិយហើយ បានក្រាបថ្វាយបង្គំបានបូជាព្រះចេតិយនោះ **ចេតិយង្គណ-សម្មជ្ជន្តា អាសនានិ ធោវន្តា ពោធិម្ហិ ឧទកំ អាសិញ្ចន្តា** បុគ្គលដែលមានចិត្តជ្រះថ្លាទៅដល់ព្រះចេតិយហើយ បានបោសសម្អាតនូវទីលានព្រះចេតិយ បានដងទឹក លាងជម្រះអាសនៈ ក្នុងទីលានព្រះចេតិយនោះក្តី ដងទឹកស្រោចព្រះសិរីរតនមហាពោធិព្រឹក្សនោះក្តី បុគ្គលដែលបានបដិបត្តិព្រះចេតិយ មានសភាពដូចនេះ អ្នកប្រាជ្ញទាំងឡាយកុំគប្បីពោលថា មានផលតិច ផលដែលបានបដិបត្តិព្រះចេតិយ បានទំនុកបម្រុ ងព្រះចេតិយនេះ ប្រសើរលើសលប់ក្រៃលែង អានិសង្សស្មើគ្នានឹងផលដែលបានបដិបត្តិអង្គព្រះសម្មាសម្ពុទ្ធ ។

សេចក្តីមួយក្នុង **អដ្ឋកថាព្រះវិន័យ** លោកពោលទុកថា **តីណិ ខោ ភគវតោ បទចេតិយានិ** ព្រះបាទចេតិយរបស់ព្រះមានព្រះភាគនៃយើងនេះប្រតិស្ឋាននៅក្នុងទីទាំង ៣ គឺ**លង្កាទ្វីប១ ជម្ពូទ្វីប១ ក្រុងយោនកៈ១** ។

**ព្រះបាទចេតិយ** ដែលប្រតិស្ឋានក្នុងលង្កាទ្វីបនោះ ព្រះសម្ពុទ្ធ ព្រះអង្គប្រតិស្ឋាននៅពេលណា ?

**ពោធិតោ អដ្ឋមេ វស្សេ** ឆ្លើយថា កាលព្រះមានព្រះភាគ ព្រះអង្គបានត្រាស់ដឹងកន្លងទៅបាន ៧ វស្សាហើយ ឈានចូលវស្សាទី ៨ **ស្តេច**

**មុនីអគ្គិកនាគរាជ** ដែលនៅក្នុងកល្យាណីប្រទេស មកអារាធនា ដើម្បីឱ្យព្រះអង្គយាងទៅទទួលចង្ហាន់ ព្រមដោយភិក្ខុសង្ឃទាំងឡាយ **បញ្ចហិ ភិក្ខុសតេហិ បរិវុតោ** ព្រះមានព្រះភាគ មានភិក្ខុសង្ឃ ៥០០ រូប ហែហមព្រះអង្គទៅកាន់លង្កាទ្វីប ព្រះអង្គទ្រង់គង់ក្នុងមណ្ឌបកែវ ដែលស្ដេចនាគតាក់តែង ក្នុងទីកល្យាណីចេតិយ **ភត្តកិច្ចំ កត្វា** ធ្វើនូវភត្តកិច្ចរួចស្រេចហើយ ក៏ទ្រង់ព្រះមហាករុណា សម្ដែងស្នាមព្រះបាទ ចេតិយទុកលើកំពូល**ភ្នំសុមនកូដ**ហើយព្រះអង្គ ក៏ចៀសចេញទៅ ។

ស្នាមព្រះបាទចេតិយ ដែលព្រះពុទ្ធជាម្ចាស់ប្រតិស្ឋានទុកក្នុងជម្ពូទ្វីប និងយោនកៈនោះ ព្រះអដ្ឋកថាចារ្យពោលទុកក្នុង **បុណ្ណោវាទសូត្រ អដ្ឋកថាមជ្ឈិមនិកាយ** ថា គ្រាមួយ **ព្រះបុណ្ណៈ**ដ៏មានអាយុអារាធនាព្រះពុទ្ធជាម្ចាស់ ដើម្បីឱ្យព្រះអង្គទៅទទួលមណ្ឌបឈើខ្លឹមចន្ទន៍ក្រហម ដែលពាណិជពីរនាក់បងប្អូនរួមគ្នានឹងពាណិជទាំងឡាយតាក់តែងនៅក្នុង**សុនាបរន្តជនបទ** ព្រះមានព្រះភាគ ព្រះអង្គទទួលនូវការអារាធនា នៃ**ព្រះបុណ្ណត្ថេរ** ហើយក៏ស្ដេចទ្រង់យាងទៅកាន់**សុនាបរន្តជនបទ** ព្រមដោយភិក្ខុ ៥០០ រូប កាលស្ដេចទៅដោយ**កុដាគារបុស្បុក** ៥០០ អណ្ដែតទៅតាមផ្លូវអាកាស ទៅប្រោសដល់ពួកពាណិជក្នុង**សុនាបរន្តជនបទ**ស្រេចហើយ ក៏ព្រះអង្គយាងទៅកាន់កំពង់ឈ្មោះ**សុបារកបដ្ដន**ទៅប្រោស **ស្ដេចនិម្មទានាគរាជ** ក្នុងស្ថានទីនោះ **សាវត្ថី បច្ឆា គច្ឆន្តោ** កាលព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រឡប់មកកាន់សាវត្ថី គ្រានោះ **ស្ដេចនិម្មទានាគរាជ** ទើបក្រាបបង្គំទូលសូមព្រះចេតិយដ្ឋាន នឹងបានជាទីគោរពសក្ការបូជា **បទចេតិយំ ទេសេសិ** ព្រះសាស្ដា ទ្រង់មហាករុណា បាន

*ប្រតិស្ឋានព្រះបាទចេតិយ ទុកនៅទៀបឆ្នេរនៃ* ***ស្ទឹងនម្មទា*** *ស្នាមព្រះបាទចេតិយនោះ ពេលដែល ទឹករលកបក់មកដល់ មើលមិនឃើញ កាលរលកថយចុះទៅវិញ ទើប មើលឃើញច្បាស់ បានជាទីសក្ការ គោរពបូជាសព្វសត្វទាំងឡាយ* ***តតោ សច្ចពន្ធបព្វតំ បិត្វា*** *ព្រះលោកនាថព្រះអង្គបាន ប្រតិស្ឋានស្នាមព្រះបាទទុកទៀបឆ្នេរនៃស្ទឹងឈ្មោះ* ***នម្មទា*** *នោះហើយក៏ចៀសចេញចាក ទីនោះ ព្រះអង្គមកកាន់* ***ភ្នំសច្ចពន្ធបព៌ត*** *ក៏មានព្រះពុទ្ធដីកាត្រាស់ ប្រាប់ដល់****ព្រះសច្ចពន្ធត្ថេរ****ឱ្យនៅប្រោសឧបដ្ឋាកនៅក្នុងទីនោះ* ***ព្រះសច្ចពន្ធ*** *ទទួលព្រះពុទ្ធដីការហើយ ក្រាបបង្គំទូលសូមនូវព្រះចេតិយ ដ្ឋាន និងបានជាទីគោរពបូជា* ***បទចេតិយំ ទស្សេសិ*** *ព្រះមានព្រះភាគ ក៏ប្រតិស្ឋានស្នាមព្រះបាទទុក លើផ្ទាំងថ្ម នា****ភ្នំសច្ចពន្ធបព៌ត*** *មានឧបមា ដូចស្នាមត្រា ដែលបុគ្គលប្រថាប់ដាក់ទុក លើផ្ទាំងថ្មដែលសើម ព្រះអង្គ ក៏ត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ* ***មុនិនោ ចក្កវត្តិនោ ចេតិយកថា សង្គហនយោ*** *ន័យដែលសង្គ្រោះចូលជាចេតិយកថា ពោលដោយ ចេតិយដ្ឋាននៃព្រះពុទ្ធជាម្ចាស់ និងស្ដេច ចក្រពត្តិត្រាធិរាជក៏ចប់ត្រឹម តែប៉ុណ្ណោះ ។ សម្ពុទ្ធចក្កវត្តិចេតិយកថា ចប់*

*(គម្ពីរសារត្ថសង្គហ: ភាគទី១ ទំព័រ ១៥៩-១៦៦)*

## ៨.សម្មជ្ជនានិសំសកថា
## (រឿងព្រះបុស្សទេវថេរ បោសសម្អាតទីលានព្រះចេតិយមារមករំខាន)

*លំដាប់ទៅនេះ* ***ព្រះនន្ទាចារ្យ*** *ទើបដោះស្រាយក្នុងបទមាតិកា គឺស*

*ម្មជ្ជនានិសង្សបន្តទៅ ដោយលោកលើកយកព្រះបាលីក្នុង **គម្ពីរបរិវារ** នៃព្រះវិន័យបិដកមកសម្ដែងទុកក្នុងមាតិកាថា **បញ្ចានិសំសា សម្មជ្ជនិយា** បុគ្គលដែលបានបោសសម្អាតទីលានព្រះចេតិយ នៃព្រះសិរីមហាពោធិព្រឹក្សនោះ មានអានិសង្សឃើញប្រចក្សក្នុងជាតិនេះ ៥ ប្រការ **សកចិត្តំ បសីទតិ** គឺញ៉ាំងចិត្តរបស់ខ្លួនឱ្យជ្រះថ្លាប្រការ ១ **បរចិត្តបសីទតិ** គឺញ៉ាំងចិត្តរបស់អ្នកដទៃ ឱ្យជ្រះថ្លាក្នុងខ្លួនប្រការ ១ ទេវតាទាំងឡាយក៏សរសើរត្រេកអរផងដែរប្រការ ១ បានឈ្មោះថាសន្សំនូវបុណ្យដែលនឹងឱ្យមានរូបឆោមស្អាត ជាទីនាំមកនូវសេចក្ដីជ្រះថ្លាប្រការ ១ លុះបែកធ្លាយរាងកាយទៅហើយ ក៏បានកើតក្នុងសុគតិ មានមនុស្ស និងទេវតាប្រការ ១ រួមជា ៥ ប្រការដូច្នេះ ។*

*បុគ្គលដែលព្យាយាមឧស្សាហ៍ក្នុងការបោសសម្អាត នឹងបានអានិសង្សឃើញប្រចក្សក្នុងបច្ចុប្បន្នជាតិក៏មានឧទាហរណ៍ពីមុនខ្លះ ។*

*បានឮមកថា **បុស្សទេវថេរោ** ព្រះមហាថេរៈ ១រូប មាននាមប្រាកដថា **បុស្សទេវត្ថេរ កាលន្ធកាឡវាសី** លោកម្ចាស់អង្គនោះ មានប្រក្រតីគង់នៅក្នុងកាលកាឡវិហារ **ចេតិយង្គណំ សម្មជ្ជិត្វា** អ្នកបោសសម្អាតទីលានព្រះចេតិយ មិនឱ្យមានសំរាម ហើយក៏គ្រងចីវរឆៀងស្មាម្ខាង សម្លឹងមើលទីលានព្រះចេតិយមានដីខ្សាច់ដែលខ្លួន ពង្រាបស្មើដេរដាសដោយផ្កា ហើយពិចារណាយកគុណនៃព្រះពុទ្ធជាម្ចាស់មកជាអារម្មណ៍ ក៏បាននូវ**បីតិបាមោជ្ជ**កើតឡើងពេញក្នុងសន្ដាននៃខ្លួន **តស្មឹ កាលេ** ក្នុងកាលនោះ **ស្ដេចមារ**ទើបនិម្មិតភេទជាសត្វ**ស្វាក្រិស**មួយ ធ្វើអាការហាក់បីដូចកើតទៀបដើងភ្នំ កាន់យកអាចម៍គោស្រស់ ពង្រាយពាសពេញនៅក្នុងទី*

លានព្រះចេតិយ ធ្វើឱ្យប្រឡាក់ក្នុងទីនោះ ព្រះថេរៈឃើញអាការដែល ***ស្វាក្រិស***ធ្វើដូចនោះ ក៏មានចិត្ត កម្រើក មិនអាចនឹងបានសម្រេចដល់ ***ព្រះអរហត្ត***បាន ហើយក៏បានបោសសម្អាត កើបប្រមូលអាចម៍គោស្រស់ នោះចេញ រួចហើយក៏បាន ត្រឡប់មកកាន់អាវាសនៃខ្លួនវិញ ***ទុតិយទិវសេ*** ក្នុងថ្ងៃជាគម្រប់ពីរនោះព្រះមហាថេរៈក៏ទៅបោសសម្អាតក្នុងទីលាន ព្រះចេតិយទៀត ***ជរគាវោ ហុត្វា*** ចំណែក***ស្តេចមារនោះ*** ក៏និម្មិតជា***គោចាស់*** ហើយក៏មកបន្ទោបង់ នូវមូត្រលាមកពាសពេញប្រឡាក់ ក្នុងទីលានព្រះចេតិយនោះទៀតព្រះមហាថេរៈឃើញ***គោចាស់***មកធ្វើដូច្នេះ ក៏មានចិត្តកម្រើកមិនអាចធ្វើចិត្ត ឱ្យសម្រេច***ព្រះអរហត្ត***បាន បោសសម្អាត រួចហើយ ក៏តឡប់មកវិញ ***តតិយទិវសេ*** ក្នុងថ្ងៃជាគម្រប់បីនោះ ព្រះថេរៈ ក៏ទៅបោសសម្អាតម្តងទៀត កាល បោសសម្អាតរួចហើយ ក៏ក្រឡេក មើលនូវទីលានព្រះចេតិយ ក៏មានចិត្ត ត្រេកអររីករាយ មាន***បីតិបាមោជ្ជ*** មានពុទ្ធគុណជាអារម្មណ៍ ថ្ងៃនោះ ***ស្តេចមារ***ក៏និម្មិតភេទ ជា***បុរសមានអវយវៈពិការ*** ហើយក៏ដើរឈូស ពង្រាយដីខ្សាច់ក្នុងទីនោះ ព្រះមហាថេរៈ ឃើញបុរសមានអវយវៈពិការ នោះគិតថា ក្នុងស្រុកដែលអាត្មាអញធ្លាប់គោចរត្រាច់ទៅបិណ្ឌបាត មានបរិមណ្ឌលបានមួយយោជន៍ជុំវិញ ទៅក្នុងទីទាំងពួង មិនបានមានបុរសរូបរាងគួរស្អប់ គួររង្កៀស ដូចនេះ មិនមាន បុរសនេះយល់ថា ***ជាមារក្លែងភេទ*** ដើម្បីឱ្យយើងខ្ពើមរអើម បន្សាបនូវ***បីតិ***ពីសន្តាន មិនឱ្យយើងសម្រេចដល់***បីតិសម្ពោជ្ឈង្គ*** ដែលជាអង្គនៃការត្រាស់ដឹងមគ្គ ***និងផល*** គិតដូចនេះហើយ ព្រះមហាថេរៈ ក៏សួរថា ***មារោសិ ត្វំ*** នៃមារ ខ្លួនអ្នកជាស្តេចមារពិតមែនឬ ? ***អាម ភន្តេ*** ព្រះ

*ករុណាលោកម្ចាស់ ខ្ញុំករុណា ជាស្តេចមារ ព្រះមហាថេរៈ ទើបគិតថា ស្តេចមារនេះធ្វើ អន្តរាយដល់បីតិរបស់យើងនេះ ៣ ថ្ងៃហើយ ចាំយើងនឹងដោះស្រាយ បញ្ឆោតឱ្យ ស្តេចមារនេះវង្វេងបន្តិចសិន គិតដូចនេះហើយ ព្រះថេរៈ ក៏សួរថា នែមារ* ***ទិដ្ឋបុព្វោ តថាគតោ*** *ខ្លួនអ្នកធ្លាប់បានឃើញអង្គនៃព្រះសម្ពុទ្ធជាម្ចាស់ ឬថា មិនបានឃើញប្រការណា* ***អាម ទិដ្ឋបុព្វោ*** *បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាធ្លាប់បានឃើញហើយ នែមារ អាត្មាបានឮកិត្តស័ព្ទគេពោលថា ធម្មតាស្តេចមារនោះ មានអានុភាពច្រើនអាចនិម្មិតវត្ថុណានោះ ក៏សម្រេចបានគ្រប់ប្រការ ក៏អង្គព្រះសម្មាសម្ពុទ្ធ ព្រះ-អង្គចូលកាន់និព្វានទៅហើយនោះ អាត្មាកើតមកក្រោយ មិនទាន់បានឃើញព្រះអង្គ* ***ឥង្ឃ*** *អាត្មារឭកព្រះអង្គ អ្នកមានអានុភាព ចូរអនុគ្រោះដល់អាត្មា ចូរអ្នកនិម្មិតអង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឱ្យអាត្មាបានឃើញម្តងផងចុះ ។ បពិត្រលោកម្ចាស់ ខ្ញុំពះករុណានិម្មិតឱ្យដូចពិតៗ នោះមិនបានទេ បើនិម្មិតល្មមតែរូបប្រៀបធៀបស្រដៀងនោះបាន ប្តេជ្ញាដូច្នេះហើយ* ***សកភាវំ វិជ្ជហិត្វា*** *ស្តេច មារនោះក៏លះបង់នូវភេទនៃខ្លួន ហើយនិម្មិតភេទជាអង្គព្រះសម្មាសម្ពុទ្ធ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និង***អនុព្យញ្ជនៈ** *៨០ មាន***ព្រះឆព្វណ្ណរង្សី** *ព័ទ្ធជុំវិញប្រមាណ ១ ព្យាម* ***ថេរោ មារំ ឱលោកេត្វា*** *ព្រះមហាថេរៈសម្លឹងមើលនូវស្តេចមារហើយ គិតថា* ***អយំ មារោ*** *ស្តេច មារនេះប្រកបដោយ***រាគៈ ទោសៈ មោហៈ** *កាលនិម្មិតរូប ដូចយ៉ាង រូបព្រះពុទ្ធជាម្ចាស់ ស្អាតដល់ត្រឹមប៉ុណ្ណោះ ឯអង្គព្រះសម្មាសម្ពុទ្ធព្រះអង្គ ប្រាសចាក***រាគៈ ទោសៈ មោហៈ** *ដោយប្រការទាំងពួង គួរតែស្អាត ប្រសើរលើសលប់ក្រៃលែងជាងនេះជាពិតប្រាកដ*

*គិតដូច្នេះហើយ **ពុទ្ធារម្មណំ បដិលភិត្វា** ព្រះមហាថេរៈក៏បាននូវ**បីតិ** មានព្រះ សម្មាសម្ពុទ្ធជាអារម្មណ៍ **បីតិ**នោះកើតខ្លាំងក្លា ដល់នូវ**បីតិសម្ពោជ្ឈង្គ** **វិបស្សនំ វឌ្ឍេត្វា** ព្រះមហាថេរៈក៏ចម្រើននូវ**វិបស្សនា** ក៏បានសម្រេច ដល់**ព្រះអរហត្ត** កាត់ផ្ដាច់នូវកិលេសជា**សមុច្ឆេទ**ក្នុងគ្រានោះស្ដេចមារមើលអាការព្រះថេរៈ ក៏គិតថា បានសម្រេចធម៌វិសេស ទើប ញ៉ាំងភេទ ព្រះពុទ្ធនិម្មិតនោះឱ្យបាត់ទៅ ក៏ពោលនឹងព្រះមហាថេរៈថា **វញ្ចិតោម្ហិ តយា ភន្តេ** បពិត្រលោកម្ចាស់ៗ បញ្ឆោតខ្ញុំព្រះករុណាបាន **ជរមារ** នៃមារចាស់ អាត្មាបញ្ឆោតបុគ្គលដូចជាលោកនេះយកប្រយោជន៍អ្វី កាលព្រះមហាថេរៈតបដូចនេះហើយ មារក៏បាត់អំពីទីនោះទៅ សម្ដែងមកដូច្នេះ ក៏ឱ្យឃើញសេចក្ដីថា **ព្រះបុស្សទេវត្ថេរ**បានសម្រេច**បីតិសម្ពោជ្ឈង្គ** ដែលជាអង្គនៃការបានសម្រេច**មគ្គ** និង**ផល**នោះ ក៏អាស្រ័យដល់ការបោសសម្អាតទីលានព្រះចេតិយជាដើម រឿងដែលបោសសម្អាតព្រះចេតិយនោះមានច្រើនណាស់ លោកដែលឧស្សាហ៍ ក្នុងការបោសសម្អាត បានសម្រេច**មគ្គ** **ផល**នោះ មិនមែនមានតែ**ព្រះបុស្សទេវត្ថេរ** មួយប៉ុណ្ណោះឡើយ ។*

*(គម្ពីរសារត្ថសង្គហៈភាគទី ១ ទំព័រ ១៦៧-១៧២)*

## ៩.រឿងព្រះទត្តភិក្ខុកំលោះ បោសសម្អាតទីលានព្រះចេតិយបានសម្រេចមគ្គផល

***ទត្តោ នាម ទហរភិក្ខុ** មានភិក្ខុកំលោះ ១ រូប មានឈ្មោះថា **ព្រះទត្តភិក្ខុ** នៅក្នុង**លោកន្ទរវិហារ** ភិក្ខុកំលោះនោះ ត្រេកអរក្នុងការបោសសម្អាត គ្រាបោសសម្អាតទីលានព្រះចេតិយរួចហើយ សម្លឹងមើលព្រះ*

*ចេតិយ ដែលប្រាសចាកសំរាម និងដេរដាសទៅដោយ ដីខ្សាច់ពណ៌ស ក៏បានសម្រេច**ឱទាតកសិណ** គ្រាបាន**ឱទាតកសិណ**ជាអារម្មណ៍ហើយ ក៏បានសម្រេចនូវ**សមាបត្តិ** ៨ប្រការ **តតោ វិបស្សនំ វឌ្ឍេត្វា** លោកក៏ចម្រើន**វិបស្សនាញាណ**បន្តទៅ ក៏បានសម្រេច នូវ**សោតាបត្តិផល សកទាគាមិផល អនាគាមិផល** ព្រោះហេតុដែល បោសសម្អាតទីលានព្រះចេតិយនោះជាដើម ដែលឧស្សាហ៍ក្នុងការបោសសម្អាត ជាទីញុំាងចិត្តរបស់ខ្លួនឱ្យជ្រះថ្លាត្រេកអរ ដូចមានប្រវត្តិនិទាន**ព្រះបុស្សទេវត្ថេរ និងព្រះទត្តភិក្ខុ**កំលោះជាដើម ។*

## ១០.រឿងតិស្សភិក្ខុនៅក្នុងជម្ពូលោកវិហារ

*សេចក្តីដែលថា ញុំាងចិត្តអ្នកដទៃឱ្យជ្រះថ្លានោះ មានពាក្យប្រវត្តិនិទានថា : **តិស្សោ នាម ទហរភិក្ខុ ជម្ពុកោលេ ចេតិយង្គណេ សម្មជ្ជិត្វា** មានភិក្ខុកំលោះ ១ រូប មាននាមប្រាកដឈ្មោះថា **តិស្សភិក្ខុ**នៅក្នុង **ជម្ពូលោកវិហារ** ភិក្ខុកំលោះនេះបោសសម្អាតព្រះចេតិយរួចហើយ ក៏កាន់បង្គីជញ្ជូនសំរាមនោះ **តស្មឹ ខណេ** ក្នុងខណៈ នោះមានព្រះមហាថេរៈមួយអង្គ ឈ្មោះថា **តិស្សទត្តត្ថេរ** លោកចុះចាក សំពៅនៅកំពង់**ជម្ពូកោលៈ**ហើយ ក៏ចៀងចូលទៅក្នុង**ជម្ពូកោលវិហារ ចេតិយង្គណំ ឱលោកេនតោ** សម្លឹងមើលទីលានព្រះចេតិយឃើញស្អាត ប្រាសចាកសំរាម ដីរាបស្មើស្អាតល្អ ក៏មានចិត្តជ្រះថ្លា យល់ចូលចិត្តថា ទីនេះជាទីបោសសម្អាតរបស់ភិក្ខុអ្នកចម្រើន**សមាធិចិត្ត** កាលចូល ចិត្ត ដូចនេះហើយ **ព្រះតិស្សទត្តត្ថេរ**ក៏ចូលទៅកាន់សម្នាក់នៃភិក្ខុកំលោះ ដែលកំពុងជញ្ជូនសំរាមនោះ*

ៗ **បញ្ហាសហស្សំ បុច្ឆិ** ព្រះថេរៈបានសួរ ប្រស្នា ១០០០ ខ.ចំពោះភិក្ខុកំលោះៗ នោះក៏ឆ្លើយបានទាំងអស់ សរុបសេចក្តីមកថា ជាធម្មសាកច្ឆាមាន ប្រស្នាដល់ ១០០០ ប្រស្នា ដូច្នេះ ក៏អាស្រ័យដោយការបោសសម្អាតទីលានព្រះចេតិយជាមូលហេតុ ដូច្នេះឯង ទើបពោលសរសើរថា ការបោសសម្អាតទីលានព្រះចេតិយ ព្រះសិរីមហាពោធិ៍នេះជាទីញ៉ាំងចិត្តឱ្យអ្នកដទៃជ្រះថ្លា ៕

(គម្ពីរសារត្ថសង្គហៈភាគទី ១ ទំព័រ ១៧២-១៧៣)

## ១១.រឿងព្រះមហាថេរៈ ៤ រូប បានសម្រេចឈានសមាបត្តិ

មានប្រវត្តិនិទានមួយ **ព្រះនន្ទាចារ្យ** លើកមកសម្តែងថា**អញ្ញតរស្មឹ ហិ វិហារេ ថេរោ ចេតិយង្គណំ សម្មជ្ជិត្វា** មានព្រះមហាថេរៈមួយរូប នៅក្នុងអាវាសដែលមានឈ្មោះមិនប្រាកដ ក្នុងវារៈព្រះបាលី ព្រះមហាថេរៈរូបនេះ បានបោសសម្អាតទីលានព្រះចេតិយហើយ ក៏ដញ្ជូនសំរាមទៅចោល ធ្វើ**សម្មជ្ជនកវត្ត** ឱ្យសម្រេចក្នុងខណៈនោះ **ចត្តារោ ថេរា** មានព្រះថេរៈ ៤ រូប នាំគ្នានិមន្តមកអំពី**ក្រុងយោនកៈ** ដើម្បីនមស្ការនូវព្រះចេតិយនៃព្រះពុទ្ធជាម្ចាស់ កាលនាំគ្នានិមន្តមកដល់វិហារនោះ ឃើញទីលានព្រះចេតិយ ដែលព្រះមហាថេរៈម្ចាស់អាវាសបានបោសសម្អាតជីពបស្មើជានិច្ច ក៏កើតការជ្រះថ្លាក្រៃលែង **អន្តោ បវិសិត្វា** ព្រះមហាថេរៈទាំង ៤ រូបនោះ ទើបនិមន្តចូលទៅក្នុងទីលានព្រះចេតិយ ឈរក្បែរខ្លោងទ្វារខណៈនោះក៏បានសម្រេច ឈានសមាបត្តិត្រាស់ ដឹងនូវ**បុព្វេនិវាសានុស្សតិញ្ញាណ** គឺជាញាណដែលរឭកជាតិកន្លងហើយបាន

*ព្រះថេរៈមួយរូបនោះរឭកបាន ៨ កប្ប មួយរូបរឭកបាន ១៦ កប្ប មួយរូបរឭកបាន ២០ កប្ប មួយរូបរឭកបាន ៣០កប្ប បានសម្រេចនូវធម៌វិសេស ទាំងនេះក៏ជាហេតុដែល ជ្រះថ្លាក្នុងទីលាន ព្រះចេតិយ ដែលព្រះមហាថេរៈចៅអាវាសបានបោសសម្អាតរួចហើយ នោះជាដើម ការសរសើរនូវការបោសសម្អាតទីលានព្រះចេតិយនោះថា ជាញុំាងចិត្តរបស់អ្នកដទៃឱ្យជ្រះថ្លា ។*

*(គម្ពីរសារត្ថសង្គហៈភាគទី ១ ទំព័រ ១៧៣-១៧៥)*

## ១២.រឿងភិក្ខុធ្វើវត្តបដិបត្តិចំពោះព្រះចេតិយ និងព្រះពោធិព្រឹក្សទេវតាបូជាផ្កាទិព្វ

***ទេវតា អត្តមនា ហោន្តិ*** *ប្រការដែលថា ឧស្សាហ៍ក្នុងការ បោសសម្អាត ឯទេវតាក៏ត្រេកអរផងនោះ ក៏មានប្រវត្តិនិទាន* ***ព្រះនន្ទាចារ្យ*** *លើកយកមកសម្ដែងទុកថា* ***ឯកស្មឹ កិរ ឯកោ ភិក្ខុ*** *បានឮមកថា ក្នុងអាវាសមួយកន្លែងនោះមានភិក្ខុមួយរូប ប្រកបដោយវត្តបដិបត្តិដ៏ល្អ* ***ចេតិយង្គណំ សម្មជ្ជិត្វា*** *ភិក្ខុនោះបោសសម្អាតនូវទីលានព្រះចេតិយ នៃព្រះសិរីមហាពោធិ៍រួចស្រេចហើយ ក៏និមន្តទៅស្រង់ទឹកជម្រះកាយ ចំណែកឯទេវតាដែលស្ថិតនៅក្នុងអាវាសនោះ មួយអង្គៗ ក៏ជ្រះថ្លាចំពោះភិក្ខុរូបនោះ* ***បុប្ផហត្ថា*** *ទេវតាទាំងឡាយ ក៏កាន់ផ្កាទិព្វ កម្រងផ្កាទិព្វ ទៅឈរតាមលំដាប់ៗ គ្នា ដើម្បីធ្វើសក្ការបូជាចំពោះភិក្ខុនោះ លុះស្រង់ទឹករួចហើយ ក៏ត្រឡប់មកវិញ ឃើញទេវតាទាំងឡាយមកឈរនៅតាមលំដាប់គ្នា ក៏សម្គាល់ថា ជាមនុស្ស មិនបានដឹងថាជាទេវតា ទើបសួរ*

ថា នៃឧបាសក ឧបាសិកា ទាំងឡាយ **កតរំ គាមវាសី** អ្នកនៅស្រុកជិត ឬស្រុកឆ្ងាយ **ឥធ វសាម** ព្រះករុណាម្ចាស់ ខ្ញុំព្រះករុណាទាំងឡាយនេះ ជាទេវតាស្ថិតនៅ ក្នុងទីនេះ **ឥមស្ស វិហារស្ស កតកាលតោ បដ្ឋាយ** បពិត្រលោកម្ចាស់ វិហារនេះចាប់ផ្តើមតាំងអំពីខ្ញុំព្រះករុណាទាំងឡាយកសាងហើយនោះ រកភិក្ខុរូបណានីមួយ បំពេញវត្តបដិបត្តិបោសសម្អាតទីលានព្រះចេតិយ ព្រះមហាពោធិ៍ ឃើញដូចលោកម្ចាស់ដូច្នេះមិនមានទេ **តុម្ហាកំ វត្តេ បសីទិត្វា** ខ្ញុំព្រះករុណាទាំងឡាយនេះជ្រះថ្លាក្នុងវត្តបដិបត្តិរបស់លោក ម្ចាស់ ខ្ញុំព្រះករុណាទាំងឡាយ ទើបកាន់នូវផ្កាទិព្វ និងកម្រងផ្កាទិព្វឈរ នៅទីនេះ ដើម្បីធ្វើសក្ការបូជាចំពោះលោកម្ចាស់ក្នុងកាលឥឡូវនេះ សម្តែងនូវសេចក្តីដូច្នោះក៏យល់ថា បុគ្គលដែលឧស្សាហ៍បោសសម្អាត នូវទីលានព្រះចេតិយនៃសិរីមហាពោធិព្រឹក្សនេះ ទេវតាទាំងឡាយ រមែងជ្រះថ្លា ត្រេកអររីករាយជាមួយផង ដូចពណ៌នាមកនេះឯង ៕

(គម្ពីរសារត្ថសង្គហៈភាគទី ១ ទំព័រ ១៧៥-១៧៦)

## ១៣.រឿងព្រះអភយត្ថេររូបស្អាត

សេចក្តីដែលពោលថា អានិសង្សនៃការបោសសម្អាតឱ្យកើតរូបស្អាតនោះ ក៏មានប្រវត្តិនិទាន **ព្រះនន្ទាចារ្យ**ក៏លើកយកមកសម្តែង ទុកក្នុងទីនេះថា **ឯកំ ករិ អមច្ចបុត្ត អភយត្ថេរញ្ច អារព្ភ អយំ កថា ឧទបាទិ** គ្រាមួយនោះ ជនទាំងឡាយប្រារព្ធនូវអភយត្ថេរ និងបុត្រ អាមាត្យ ហើយក៏ប្រកែកគ្នានិងគ្នា ម្ខាងនោះពោលថា ព្រះថេរៈរូបស្អាត ម្ខាងទៀតនោះ

ពោលថា បុត្រអាមាត្យរូបស្អាត មិនចុះសម្រុងគ្នា ទើប ប្រឹក្សាគ្នាថា កុំធ្វើដូច្នោះឡើយ លោកម្ខាងឯណោះប្រកាន់ថា បុត្រអាមាត្យរូបស្អាត ចូរអ្នកទៅរកបុត្រអាមាត្យមក យើងខាងនេះប្រកាន់ថា ព្រះអភយត្ថេររូបស្អាត ពួកយើងនឹងទៅអារាធនាព្រះអភយត្ថេរមកឱ្យ បុត្រអាមាត្យ និងព្រះអភយត្ថេរមកប្រជុំគ្នា ហើយពួកយើងទាំងពីរខាង ក៏មើលជនទាំងពីរក្នុងទីនេះជាមួយគ្នា កាលបើមកក្បែរគ្នាហើយ នរណាល្អ ឬអាក្រក់ នឹងបានឃើញ ទាំងអស់គ្នា កាលប្រឹក្សាគ្នាសម្រេច ដូច្នេះហើយ ពួកដែលជាជាតិនៃបុត្រអាមាត្យ រូបស្អាតនោះ ក៏នាំគ្នាតាក់តែងស្អិតស្អាងនៃបុត្រអាមាត្យនោះ ដោយគ្រឿងប្រដាប់ប្រដាផ្សេងៗ ហើយក៏នាំគ្នាមក ដើម្បីនមស្ការនូវព្រះមហាចេតិយ **ថេរមាតា** ចំណែកនាងជាមាតានៃព្រះអភយត្ថេរនោះ ក៏បានឱ្យមនុស្ស ធ្វើនូវចីវរសាច់ល្អ ជាទីនាំមកនូវសេចក្តីជ្រះថ្លាស្រេចហើយ ក៏បញ្ជូនទៅប្រគេនដល់ **ព្រះអភយត្ថេរ** ដែលត្រូវជាបុត្រប្រាប់ទៅថា ឱ្យបុត្រ របស់យើងកោរសក់ ហើយគ្រងនូវចីវរទាំងនេះ មានភិក្ខុហែហមហើយ សូមនិមន្តទៅនមស្ការនូវព្រះចេតិយ ក្នុងកាលថ្ងៃនេះ **ព្រះអភយត្ថេរ** ក៏ធ្វើតាមពាក្យរបស់ញោមស្រី កោរសក់ហើយក៏គ្រងនូវចីវរ ដែលញោមស្រីបញ្ជូន មកប្រគេន មានភិក្ខុហែហមហើយ ក៏និមន្តទៅ ដើម្បីនឹង នមស្ការនូវព្រះចេតិយ ចំណែកបុត្រអាមាត្យនោះវិញ ក៏ហែហមទៅ ដោយពួកញាតិហើយក៏ចូលទៅកាន់ទីលានព្រះចេតិយ ដោយខ្លោងទ្វារ ទិសខាងកើត **ព្រះអភយត្ថេរ**ក៏មានភិក្ខុហែហមចូលទៅកាន់ទីលានព្រះចេតិយ តាមខ្លោងទ្វារខាងត្បូង ទៅជួបគ្នានឹងបុត្រអាមាត្យ ព្រះមហាថេរៈ មានថេរវាចាថា នៃអាវុសោ អ្នកនេះបានជញ្ជូន

សំរាមក្នុងទីដែល**ព្រះថេរៈចាស់**បោសសម្អាត ហេតុដូចម្ដេចអ្នកប្រៀបធៀបជាមួយនឹងយើង ហេតុដូចម្ដេច**ព្រះអភយត្ថេរ** ទើបថាដល់បុត្រអាមាត្យដូច្នេះ ក្នុងអតីត ជាតិព្រះអភយត្ថេរនេះ បានកើតជា**ព្រះថេរៈចាស់** បានបោសសម្អាត ទីលានព្រះចេតិយក្នុងប្រទេសនៃ**ការជគាម** ចំណែកខាងបុត្រអាមាត្យ នោះ បានកើតជា**មហាឧបាសក** បានជញ្ជូនសំរាមក្នុងទីដែលព្រះ មហាថេរៈចាស់បោសសម្អាតនោះទៅចោល បានធ្វើកុសល មកអំពី អតីតជាតិនោះដូច្នេះ ហេតុនោះ **ព្រះអភយត្ថេរ** ទើបពោលដល់ បុត្រអាមាត្យថា លោកជាអ្នកជញ្ជូនសំរាមក្នុងទីដែលព្រះថេរៈចាស់ បោស ហេតុម្ដេចក៏មកពោលប្រកាន់ថា ជាគូប្រៀបធៀបគ្នាជាមួយនឹង យើង ក្នុងទីនេះយល់ដោយអត្ថនោមត្យាធិប្បាយថា **ព្រះអភយត្ថេរ**នោះ រូបស្អាតជាងបុត្ររបស់អាមាត្យ ហេតុថា លោកម្ចាស់ជាអ្នកបោស លោកម្ចាស់ជាអ្នកធ្វើមុនបុត្រអាមាត្យនោះអាស្រ័យលោកម្ចាស់ ទើបបានធ្វើ ការប្រមូលជញ្ជូន ក្នុងពេលក្រោយ ។

ការបោសនោះមានបាលីថា ឱ្យកើតរូបស្អាត ការដែលជញ្ជូននោះមិនបានមានក្នុងបាលីថា ឱ្យកើតរូបស្អាត ប៉ុន្តែប្រសិនបើការជញ្ជូននោះជាអនុលោមតាមការបោស ឃើញថា ផលនោះស្រដៀងគ្នានឹងផលដែលបោស ពោលគឺបុត្រអាមាត្យនោះ មានរូបស្អាតស្មើ**ព្រះអភយត្ថេរ**នោះឃើញមិនទាន់ស្មើទេ អ្នកមានបញ្ញាគប្បី**មនសិការ**ទុកជាសេចក្ដីថា ការដែលបោសសម្អាត ទីលានព្រះចេតិយនៃសិរីមហាពោធិព្រឹក្សនោះប្រកបដោយអានិសង្ស ៥ ប្រការ គឺរមែងញ៉ាំងចិត្ត នៃខ្លួន និងចិត្តអ្នកដទៃឱ្យជ្រះថ្លា ជាទីរីករាយនៃទេវតាទាំងឡាយ ហើយ ក៏បានមានរូប

ស្អាតក្នុងបរលោក បានសម្បត្តិមនុស្ស សម្បត្តិទេវតា សម្រេចតាមសេចក្តីប្រាថ្នាដូចមនោរថ **អយមេត្ត សម្មជ្ជនីយោ ផលសង្គហនយោ** ន័យដែលសង្គ្រោះយកនូវសម្មជ្ជនានិសង្សកថា ពោលដោយផលនៃការបោសសម្អាតតាមលំដាប់បទមាតិកា ក៏ចប់ត្រឹម តែប៉ុណ្ណេះ ៕

ចប់ **សម្មជ្ជនានិសង្សកថា**

(គម្ពីរសារត្ថសង្គហៈភាគទី ១ ទំព័រ ១៧៦-១៧៩)

## ១៤.ការសាងចេតិយ

នៅក្នុងអដ្ឋកថា **ធម្មបទ** និង**អដ្ឋកថាវិមានវត្ថុ**បានពោលដល់ការសាងចេតិយ ក្នុងវេលាដែលព្រះកស្សបសម្មាសម្ពុទ្ធទ្រង់ បរិនិព្វានហើយ។

ក្នុងមហាវគ្គ មានពោលដល់ការកសាង ព្រះចេតិយរបស់ **ព្រះវិបស្សីសម្មាសម្ពុទ្ធ**, ព្រះអង្គទ្រង់ត្រាស់ការបូជាផ្កាឈូកដល់ព្រះ ចេតិយថា មានប្រយោជន៍ធំដល់អ្នកបូជា ។

ក្នុងគម្ពីរ**ទីឃនិកាយមហាវគ្គ** (១៦) មានពោលដល់ការ សាងព្រះចេតិយ ១០ កន្លែងសម្រាប់ជាគ្រឿងបូជារបស់ទេវតានិងមនុស្សទាំងឡាយអស់កាលយូរអង្វែង ។

នៅក្នុងគម្ពីរមិលិន្ទប្បញ្ហាបករណ៍ (**មិលិន្ទ.៣៤៨**) ត្រង់ អនុមានបញ្ហាកណ្ឌព្រះនាគសេនពោលឧបមាដល់ ព្រះចេតិយថា ដូចជាផ្សារលក់ទំនិញរបស់ទាំងពួង ជាវត្ថុប្រសើរអាចឱ្យសម្បត្តិទាំងពួង ដូចតទៅ ៖

ស្តេចមិលិន្ទសួរព្រះនាគសេន ថា **ភន្តេ នាគសេន កតមំ ពុទ្ធស្ស ក**

***គវតោ សញ្ញាបណំ*** ។ បពិត្រព្រះនាគសេនដ៏ចំរើន

*តើអ្វីជាហាងលក់ទំនិញទាំងពួងរបស់ព្រះសម្មាសម្ពុទ្ធ?*

*ព្រះនាគសេនឆ្លើយតបនឹងស្តេចមិលិន្ទថា* ***សញ្ញាបណំ ខោ មហារាជ ភគវតោ នវង្គំ ពុទ្ធវចនំ សារីរិកានិ បរិភោគកានិ ចេតិយានិ សង្ឃរតនញ្ច ។ល។ ឥទំ វុច្ចតិ មហារាជ "ភគវតោ សញ្ញាបណា" ន្តិ*** *បពិត្រមហារាជ ព្រះពុទ្ធវចនៈប្រកបដោយអង្គ ៩ ព្រះបរមសារីរិកធាតុ ព្រះចេតិយ ជាគ្រឿងប្រើប្រាស់នៃព្រះដ៏មានព្រះភាគ រួមទាំងព្រះសង្ឃ រតនៈ ជាហាងលក់ទំនិញទាំងពួង របស់ព្រះសម្មាសម្ពុទ្ធ។ បពិត្រមហារាជ ព្រះដ៏មានព្រះភាគ ទ្រង់ដាក់លក់****ជាតិសម្បត្តិ ភោគសម្បត្តិ អាយុសម្បត្តិ អារោគ្យសម្បត្តិ វណ្ណសម្បត្តិ បញ្ញាសម្បត្តិ មានុសិកសម្បត្តិ ទិព្វសម្បត្តិ និងនិព្វានសម្បត្តិ*** *ក្នុងហាងលក់ទំនិញ ទាំងពួងនោះ ។ បុគ្គលឯណា ចង់បាននូវសម្បត្តិនោះៗ គ្រាន់តែ ចំណាយនូវដើមទុន គឺកម្មនឹងអាច ទិញនូវសម្បត្តិនោះៗ តាមសេចក្តី ប្រាថ្នារបស់ខ្លួនបាន ។ បុគ្គលខ្លះទិញ សម្បត្តិនោះៗ ដោយការសមាទាន សីល, បុគ្គលខ្លះទិញសម្បត្តិនោះៗ ដោយការក្សាឧបោសថ យ៉ាងណា មហាបពិត្រ ពួកគេរមែងបាននូវ សម្បត្តិផ្សេងៗ ព្រោះអាស្រ័យដើមទុន គឺកម្ម សូម្បីបន្តិចបន្តួច ។ បពិត្រ មហារាជ ដូចជាទីផ្សារ លក់លូ សណ្តែកបាយ សណ្តែករាជមាស អ្នកទិញអាចទិញលូ សណ្តែកបាយ សណ្តែករាជមាស ដោយប្រើអង្ករ សណ្តែកបាយ សណ្តែករាជមាស ដូរក៏បាន ឬអាចទិញដោយដើមទុន គឺកម្មសូម្បី បន្តិចក៏បាន យ៉ាងណា មហាបពិត្រ អាត្មាពោលថា ពួកគេ តែងបានសម្បត្តិផ្សេងៗ ព្រោះអាស្រ័យ ដើមទុនគឺកម្មសូម្បីបន្តិចបន្តួច ក៏ដូច្នោះដែរ ។*

***ភីណិត្វា សទ្ធាមូលេន សមិទ្ធា ហោថ ភិក្ខវេ ។***

ម្នាលភិក្ខុទាំងឡាយ សូមពួកលោកចូរទិញនូវសម្បត្តិទាំងនោះ និងជាអ្នកបរិបូណ៌ដោយដើមទុន គឺសទ្ធាចុះ ។

ក្នុងគម្ពីរមិលិន្ទប្បញ្ហាបករណ៍នេះ ព្រះនាគសេនបានដោះស្រាយ និងស្តេចមិលិន្ទថា ព្រះបរមសារីរិកធាតុក្តី ព្រះចេតិយក្តី ជាគ្រឿងប្រើ-ប្រាស់របស់ព្រះអង្គ មានចីវរ និងដើមពោធិព្រឹក្សជាដើម និងព្រះពុទ្ធ-វចនៈគឺព្រះត្រៃបិដក ។ វត្ថុទាំងនេះ តែងនាំមកនូវប្រយោជន៍ទាំងពួង តាមសេចក្តីត្រូវការរបស់សព្វសត្វ ។ បុគ្គលណាចង់បានសម្បត្តិយ៉ាង ណាមួយ គឺមានជាតិខ្ពង់ខ្ពស់ មានទ្រព្យច្រើន មានអាយុវែង មិនមាន រោគ មានពណ៌សម្បុរល្អ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិដ៏ វិសេសគឺព្រះនិព្វាន បុគ្គលនោះបានបូជាព្រះចេតិយដោយ វត្ថុទាំងឡាយ មានគ្រឿង ក្រអូបជាដើម រមែងបានសម្បត្តិទាំងនោះ ដោយពិត ។

***សួរថា៖*** *បានព្រោះហេតុអ្វី?*

ព្រោះបានបូជាព្រះអរហន្តសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលជា**ទក្ខិ-ណេយ្យបុគ្គល** ជា**បូជារហបុគ្គល**ក្នុងលោកនិងដោយកុសលចេតនាជ្រះ ថ្លាចំពោះព្រះអង្គ ដោយតាំងចិត្តថា អាត្មាអញសូមបូជានូវវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើមនេះ ដល់ព្រះដ៏មានព្រះភាគអង្គនោះ ។

កុសលកម្មដែលបានធ្វើពេលនោះ ជាវិបាកនាំមកនូវផល គឺការបាននូវសម្បត្តិទាំងពួង តាមសេចក្តីប្រាថ្នារបស់ខ្លួន ។

***យេ លោកិយសម្បត្តី ច លោកុត្តរសម្បត្តី ច***
***តស្មាហិ សព្វំ ឥច្ឆន្តិ សេដ្ឋំ ចេតិយំ បូជេយ្យុំ។***

*ព្រោះហេតុនោះឯង បុគ្គលណា ប្រាថ្នានូវសម្បត្តិទាំងពួង គឺ **លោកិយសម្បត្តិនិងលោកុត្តរសម្បត្តិ** បុគ្គលនោះគប្បីបូជានូវ ព្រះចេតិយ ដ៏ប្រសើរចុះ។*

*(ប្រវត្តិព្រះបរមសារីរិកធាតុ ព្រះចេតិយ និងពិធីពុទ្ធាភិសេក ទំព័រ១៥៧-១៦២)*

## ១៥.ទោសនៃការមិនទៅព្រះចេតិយ

*ទោសនៃការមិនទៅកាន់ព្រះចេតិយ ឈ្មោះថា* **មិនគោរព ព្រះពុទ្ធ** *នៅក្នុងអដ្ឋកថា លោកសម្ដែងច្រើនកន្លែងអំពីទោសនៃការមិនទៅកាន់ព្រះចេតិយថា* "**មិនគោរពព្រះពុទ្ធ**" មានគម្ពីរសមន្តប្បាសាទិកា (សមន្ត.៣/៤៣៦) និងក្នុងគម្ពីរសារត្ថប្បកាសិនី (សំ.អដ្ឋ.២/ ២២៧) ជាដើមថា ៖

***យោ ពុទ្ធេ ធរមានេ ឧបដ្ឋានំ ន គច្ឆតិ, បរិនិព្វុតេ ចេតិយដ្ឋានំ ពោធិដ្ឋានំ ន គច្ឆតិ, ចេតិយំ វា ពោធឹ វា ន វន្ទតិ, ចេតិយង្គណេ សឆត្តោ សឧបាហនោ ចរតិ, នត្ថេតស្ស ពុទ្ធេ គារវោតិ វេទិតព្វោ ។***

*កាលព្រះពុទ្ធទ្រង់ព្រះធរមាននៅឡើយ បុគ្គលណា មិនទៅកាន់ទីឧបដ្ឋាកព្រះអង្គ, ពេលព្រះអង្គ**ទ្រង់បរិនិព្វាន**ទៅហើយ បុគ្គលណា មិនទៅកាន់ទី**ព្រះចេតិយ** កន្លែង**ដើមពោធិព្រឹក្ស** បុគ្គលណា មិនថ្វាយបង្គំព្រះចេតិយក្ដី, មិនថ្វាយបង្គំដើមពោធិព្រឹក្សក្ដី, បុគ្គលណា* **បាំងឆត្រពាក់ស្បែកជើង ដើរលើលានចេតិយ**, *បណ្ឌិតគប្បីជ្រាបថា សេចក្ដីគោរពក្នុងព្រះពុទ្ធរបស់បុគ្គលនោះ មិនមានបន្តិចទាល់តែសោះ ។*

*តាមសេចក្ដីក្នុងអដ្ឋកថា លោកបញ្ជាក់នេះ សឱ្យឃើញថា ព្រះ* **ចេតិយក្ដី ដើមពោធិព្រឹក្សក្ដី** *ទុកតំណាង**ព្រះពុទ្ធ** ស្មើនិងព្រះអង្គគង់ នៅ*

*សព្វថ្ងៃ យើងគួរទៅកាន់ទីព្រះចេតិយដើមពោធិព្រឹក្ស ឱ្យបានជានិច្ចកាល ដើម្បីនមស្ការបូជា ថ្វាយបង្គំ កុំបីខាន ។*

***ពុទ្ធេ គារវំ ករោតិ យោ ចេតិយំ វា ពោធិំ វា***
***សោ សព្វកាលេ វន្ទេយ្យ ឯតស្ស សុវត្ថិ ហោតិ ។***

*បុគ្គលណាធ្វើនូវសេចក្ដីគោរពក្នុង**ព្រះពុទ្ធ** បុគ្គលនោះគប្បីថ្វាយបង្គំនូវ**ព្រះចេតិយ** និង **ដើមពោធិព្រឹក្ស**ឱ្យបានសព្វ ៗ កាលសិរីសួស្ដីនឹងមានដល់បុគ្គល (អ្នកថ្វាយបង្គំព្រះចេតិយជាដើម) នោះ ជានិច្ចកាលដែរ ៕*

*(ប្រវត្តិព្រះបរមសារីរិកធាតុ ព្រះចេតិយ និងពិធីពុទ្ធាភិសេក ទំព័រ ១៦២-១៦៨)*

## ១៦.បុគ្គលអ្នកទំលាយចេតិយ មានទោសស្មើអនន្តរិយកម្ម

*នៅក្នុងគម្ពីរ **មនោរថបូរណី** (អំ.អដ្ឋ.២/១៩១) និង**គម្ពីរបបញ្ចសូទនី** (ម.អដ្ឋ.៣/៧៧) និងគម្ពីរ**សម្មោហវិនោទនី** (អដ្ឋកថាវិភង្គ ១/៤៥៧) បានសម្ដែងទោសនៃបុគ្គលបៀតបៀនព្រះសារីរិកធាតុ ព្រះចេតិយ និងដើមពោធិព្រឹក្សមានបាលីថា ៖*

***អថ យេ ច បរិនិព្វុតេ តថាគតេ ចេតិយំ ភិន្ទន្តិ,***
***ពោធឹ ឆិន្ទន្តិ, ធាតុម្ហិ ឧបក្កមន្តិ, តេសំ កឹ ហោតីតិ ។***
***ភារិយំ កម្មំ ហោតិ អនន្តរិយសទិសំ ។***

***សួរថា** តមកកាលព្រះតថាគត **ទ្រង់បរិនិព្វានទៅហើយ** បុគ្គលណា ទំលាយ**ព្រះចេតិយ** ទំលាយ**ដើមពោធិព្រឹក្ស** ប្រទូសរ៉ាយ នឹង**ព្រះ***

**បរមសារីរិកធាតុ** តើកម្មអ្វីតែងមានដល់បុគ្គលនោះ ?

**ឆ្លើយថា** (កាលបុគ្គលនោះធ្វើដូច្នោះ) ជាកម្មធ្ងន់ស្មើដោយ**អនន្តរិយកម្ម** ។

**សធាតុកំ បន ថូបំ វា បដិមំ វា ពាធមានំ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ ។ សចេបិ តត្ថ និលីនា សកុណា ចេតិយេ វច្ចំ បាតេន្តិ, ឆិន្ទិតុំ វដ្ដតិយេវ ។ បរិភោគចេតិយតោ ហិ សរីរចេតិយំ មហន្តតរំ ។**

តែបើកាត់នូវមែកដើមពោធិព្រឹក្សដែលបៀតបៀននូវស្តូប ដែលតម្កល់នូវព្រះសារីរិកធាតុក្តី ព្រះពុទ្ធបដិមាក្តី ក៏គួរ ។ ប្រសិនបើសត្វស្លាប (មានចាបជាដើម) ដែលនៅលើដើមពោធិព្រឹក្សនោះ ជុះអាចម៍ដាក់ព្រះចេតិយ កាត់ដើមពោធិព្រឹក្សនោះចេញក៏គួរ ។ ព្រោះសារីរិកចេតិយ គឺព្រះបរមសារីរិកធាតុ សំខាន់ជាង**បរិភោគចេតិយ** (ដើមពោធិព្រឹក្ស) ។

**ចេតិយវត្ថុំ ភិន្ទិត្វា គច្ឆន្តំ ពោធិមូលម្បិ ឆិន្ទិត្វា ហរិតុំ វដ្ដតិ ។ យា បន ពោធិសាខា ពោធិឃរំ ពាធតិ, តំ គេហរក្ខនត្ថំ ឆិន្ទិតុំ ន លព្ភតិ, ពោធិអត្ថំ ហិ គេហំ, ន គេហត្ថំ ពោធិ ។** សូម្បីកាត់នូវឫសដើមពោធិព្រឹក្ស ដែលជុះចាក់ទំលាយព្រះចេតិយ ក៏គួរ ។ ចំណែកមែកដើមពោធិព្រឹក្សណា បៀតបៀននូវផ្ទះនៃដើមពោធិព្រឹក្ស នឹងកាត់នូវមែកពោធិព្រឹក្សនោះចេញ ដើម្បីរក្សាផ្ទះមិនគួរ, ព្រោះថាផ្ទះធ្វើដើម្បីប្រយោជន៍ ដល់ដើមពោធិព្រឹក្ស មិនមែនដើមពោធិព្រឹក្សនោះជាប្រយោជន៍ដល់ផ្ទះទេ ។

**អាសនឃរេបិ ឯសេវ នយោ ។ យស្មឹ បន អាសយនឃរេ ធាតុ និទហិត្វា ហោតិ, តស្ស រក្ខនត្ថាយ ពោធិសាខំ**

***ធិន្នំតុំ វដ្តតិ ។ ពោធិជគ្គនត្តំ ឱតរណសាខំ វា បូតិដ្ឋានំ វា***

***ធិន្នំតុំ វដ្តតិយេវ ។*** *សូម្បីក្នុងផ្ទះអាសនៈ ក៏មានន័យដូចគ្នា ។ ក៏ព្រះបរមសារីរិកធាតុ តម្កល់ក្នុងផ្ទះអាសនៈណា នឹងកាត់មែកដើមពោធិព្រឹក្សដើម្បីរក្សានូវផ្ទះអាសនៈនោះគួរ ។ នឹងកាត់ចេញនូវមែក ដែលឱនចុះក្តីដែលស្អុយក្តី ដើម្បីទំនុកបំរុងនូវដើមពោធិព្រឹក្ស គួរមែន ពិត ។*

***ភគវតោ សិរីរប្បដិជគ្គនេ វិយ បុញ្ញម្បិ ហោតិ*** *។ (ការរក្សាដើមពោធិព្រឹក្សនេះ) បុណ្យក៏បានដូចការបដិបត្តិព្រះសិរីរៈព្រះដ៏មានព្រះភាគ ៕*

*(ប្រវត្តិព្រះបរមសារីរិកធាតុ ព្រះចេតិយ*
*និងពិធីពុទ្ធាភិសេក ទំព័រ ១៦៤-១៦៧)*

## ១៧.បូជនីយដ្ឋានដែលមានក្នុងទេវលោក នឹងព្រហ្មលោក

*ក្នុងទេវលោកតាវតឹសភូមិមានបូជនីយដ្ឋាន ១ កន្លែងឈ្មោះថា* ***ចូឡាមណីចេតិយ***[(១)] *ដែលប្រតិស្ឋានព្រះចង្កូមកែវខាងស្តាំ និងព្រះកេសាដែលព្រះពុទ្ធអង្គទ្រង់កាត់ចោល ក្នុងខណៈពេលព្រះអង្គចេញកាន់* ***មហាអភិនេស្រ្កមណ៍*** *។*

*ចំណែកក្នុងព្រហ្មលោកវិញនោះ ក្នុង**អកនិដ្ឋភូមិ** ក៏មានបូជនីយដ្ឋានដ៏សំខាន់ ១កន្លែងដែរ គឺ **ទុស្សចេតិយ** ជាព្រះចេតិយដែលប្រតិស្ឋាន គ្រឿងអាភរណៈរបស់ព្រះសម្មាសម្ពុទ្ធក្នុងខណៈដែលទ្រង់នៅជាព្រះសិទ្ធត្ថរាជកុមារ ទ្រង់បានប្រើប្រាស់ក្នុងខណៈដែលស្តេចចេញចាកព្រះនគរដើម្បីកាន់**មហាភិនេស្រ្កមណ៍** ។*

---

(១). *ព្រះចេតិនេះមានកម្ពស់១យោជន៍ ធ្វើពីកែវមរកត(ពណ៌ត្រួយចេក) កសាងដោយព្រះឥន្ទ ។*

*ក្នុងខណៈដែលព្រះអង្គទ្រង់ផ្លាស់សំពត់នោះចេញ* ***ឃដិការមហា-ព្រហ្ម*** *បានចុះមកអំពី**អកនិដ្ឋភូមិ** នាំយកគ្រឿងបរិក្ខារ ៨ប្រការមកថ្វាយដល់ព្រះសិទ្ធត្ថៈ និងទទួលយកគ្រឿងប្រដាប់ដែលព្រះអង្គផ្លាស់ចេញទៅប្រតិស្ឋានទុកក្នុងព្រះចេតិយ ឈ្មោះថា **ទុស្សចេតិយ** មានកម្ពស់ ១២ យោជន៍ក្នុង**អកនិដ្ឋភូមិ**នេះឯង ។ ដូចសាធកបាលីក្នុងពុទ្ធវំសអដ្ឋក ថាសម្តែងទុកថា **សុទ្ធាវាសព្រហ្មលោកេ ឃដិការោ នាម មហាព្រហ្មា អដ្ឋបរិក្ខារេ ទត្វា តស្ស ពោធិសត្តស្ស វត្ថាលង្ការានិ គហេត្វា ព្រហ្មលោកេ ទ្វាទសយោជនិកំ ទុស្សថូបំ អកាសិ ៕***

*(បរមត្ថជោតិកមហាអភិធម្មសង្គហដីកា*
*បរិច្ឆេទទី ៥ ភាគទី ១ ទំព័រ ១៥៥)*

## ១៨.វិនិច្ឆ័យការលួចទ្រព្យដែលជាបូជនីយវត្ថុ (ចេតិយអវហារណាវិនិច្ឆ័យ)

*បូជនីយវត្ថុមានព្រះពុទ្ធរូប ព្រះបរមសារីរិកធាតុ ដើមពោធិព្រឹក្សជាដើមចែកចេញជា ២ ប្រការគឺ:*

***១.គោបិតរក្ខិត*** *បូជនីយវត្ថុដែលមានបុគ្គលថែរក្សា*

***២.អគោបិតរក្ខិត*** *បូជនីយវត្ថុដែលគ្មានបុគ្គលថែរក្សា។*

*បណ្តាបូជនីយវត្ថុទាំងឡាយនោះមានព្រះពុទ្ធរូបជាដើម ជាវត្ថុដែលពុំមែនបុគ្គលណាម្នាក់ក្នុងលោកនេះជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ឡើយ សូម្បីតែព្រះពុទ្ធរូបដែលត្រូវបុគ្គលកសាងឡើងសម្រាប់បូជាក្នុងគេហដ្ឋានរបស់ខ្លួនក៏ដោយ ក៏បុគ្គលអ្នកកសាងនោះមិនហៅថាម្ចាស់*

របស់ ព្រះពុទ្ធរូបដែរ ត្រឹមតែជា**គោបិតរក្ខិតបុគ្គល** គឺបុគ្គលថែរក្សាប៉ុណ្ណោះ ។ ទាំងនេះ ក៏ព្រោះហេតុថា បុគ្គលដែលបានឈ្មោះថាម្ចាស់នៃវត្ថុទាំងឡាយនេះណាមួយបាននោះ រមែងមានសិទ្ធិធ្វើអ្វី ៗ គ្រប់យ៉ាងបានតាមចិត្តដែលខ្លួនត្រូវការ ពោលគឺ កាលបើខ្លួនមិនពេញចិត្តចំពោះវត្ថុនោះហើយក៏អាចបំផ្លាញនូវវត្ថុនោះបាន ឬផ្លាស់ប្ដូរជារូបរាងសណ្ឋានដទៃទៀតបាន ឬថានឹងលក់ចោលក៏បានដែរ ។ ចំណែកបូជនីយវត្ថុទាំងនោះ ការធ្វើដូចពោលមកនេះមិនបានឡើយ បើបុគ្គលណាធ្វើហើយនឹងជាអកុសលកម្ម ប៉ុន្តែអកុសលកម្មប្រភេទនេះធ្ងន់ស្រាលអាស្រ័យលើចេតនារបស់បុគ្គលអ្នកធ្វើនោះតែប៉ុណ្ណោះ ។

ចំពោះបុគ្គលជាអ្នកលួចយកបូជនីយវត្ថុដែលបុគ្គលដទៃថែរក្សានោះរមែងជាអទិន្នាទានៈ ។ ចំណែកការកាន់យកបូជនីយវត្ថុដែលគ្មានបុគ្គលដទៃថែរក្សានោះមិនមែនជាអទិន្នាទានៈទេ ដូចព្រះដីកាចារ្យបានពោលទុកក្នុងសារត្ថទីបនីដីកានិងកង្ខាវិតរណីដីកាថា **ទេវតាយ បន ឧទ្ទិស្ស ពលិកម្មំ ករោន្តេហិ រុក្ខាទីសុ លម្ពិតសាដកេ វត្តព្វមេវ នត្ថិ តញ្ច ខោ អារក្ខកេហិ អបរិគ្គហិតេយេវ, បរិគ្គហិតំ បន គហេតុំ ន វដ្ដតិ** "ក្នុងការកាន់យកសំពត់ដែលព័ន្ធព័ទ្ធលើដើមឈើជាដើម ត្រូវមនុស្សទាំងឡាយធ្វើនូវពលិកម្មឧទ្ទិសថ្វាយចំពោះទេវតានោះរមែងមិនមានហេតុពិសេសយ៉ាងណា (មិនមែនជាអាបត្តិ) ប៉ុន្តែសេចក្ដីនេះសំដៅយកនូវ សំពត់នោះមិនបានទទួលការថែរក្សាពីអ្នកថែរក្សាទាំងឡាយ ទើបសម គួរកាន់យកបាន បើសំពត់នោះមានការថែរក្សាពីបុគ្គលកំពុងថែរក្សា ក៏ កាន់យកមិនបាន " ។

## វិនិច្ឆ័យការកាន់យកបូជនីយវត្ថុដែលមានអ្នកថែរក្សា

បូជនីយវត្ថុមានព្រះពុទ្ធរូប ព្រះបរមសារីរិកធាតុជាដើម ដែលមានបុគ្គលថែរក្សា ប៉ុន្តែស្ថានទីដែលប្រតិស្ឋានបូជនីយវត្ថុទាំងនោះមិនសមគួរ កាលបុគ្គលមានសេចក្តីជ្រះថ្លាបានចាត់ចែងស្ថានទីដ៏សមគួរឡើងថ្មីហើយ និងបាននាំយកព្រះពុទ្ធរូប ឬព្រះបរមសារីរិកធាតុជាដើមនោះ ទៅប្រតិស្ឋានទុកក្នុងស្ថានទីថ្មីនោះ ដោយគ្មានបំណងនាំយកជាប្រយោជន៍របស់ខ្លួន គឺគ្មានថេយ្យចិត្ត ត្រូវការនាំទៅសម្រាប់ធ្វើសក្ការៈបូជាតែប៉ុណ្ណោះ ។ ការធ្វើយ៉ាងនេះ សូម្បីតែគ្មានការអនុញ្ញាតអំពីបុគ្គលដែលជាអ្នកថែរក្សាក៏ដោយ ក៏មិនចាត់ថាកន្លងកម្មបថនិង គ្មានទោសទេ ប៉ុន្តែ បើបុគ្គលអ្នកធ្វើនោះជាភិក្ខុវិញទើបជាអាបត្តិ ។ ដូច **ព្រះឥន្រ្ទាធិរាជ** បាននាំយក**ព្រះចង្កូមកែវស្តាំខាងលើ** ពីផ្នួងសក់ទោណ ព្រាហ្មណ៍ ហើយបានសាងចេតិយសម្រាប់បញ្ចុះ ឈ្មោះ**ជាចូឡាមណី** ដើម្បីបានជាទីសក្ការបូជាជាដើមនោះ ឈ្មោះថាមិនកន្លងកម្មបថ និង ឈ្មោះថាគ្មានទោស មានតែជាគុណាប្រព្រឹត្តទៅជាប្រយោជន៍ ។ រឿង នេះ ព្រះអដ្ឋកថាចារ្យបានសម្តែងទុកក្នុងអង្គុត្តរនិកាយ មហាវគ្គអដ្ឋកថាយ៉ាងនេះថា **ព្រាហ្មណោបិ ទាឋាយ អនុច្ឆវិកំ សក្ការំ កាតុំ ន សក្ខិស្សតិ, គណ្ហាមិ នន្តិ វេឋន្តរតោ គហេត្វា សុវណ្ណចង្កោដកេ ឋបេត្វា ទេវលោកំ នេត្វា ចុឡាមណិចេតិយេ បតិដ្ឋាបេសិ**[១] "សក្កទេវរាជព្រះតម្រិះថា ទោណព្រាហ្មណ៍នឹងមិនអាចដើម្បីធ្វើនូវសក្ការៈដ៏សមគួរដល់ព្រះចង្កូម កែវ អញនឹងកាន់យកនូវព្រះចង្កូមកែវនោះ ហើយលោក ក៏យកព្រះ ចង្កូវកែវអំពីផ្នួងសក់

---

(១) ក្នុងច្បូបវិសបករណ៍មានបាលីប្លែកគ្នាថា "**ព្រហ្មណោ.................សុវណ្ណចង្កោដកេ** ដោយបន្ថែម "បិ ឬ អបិ" សព្ទត្រង់បទថា "ព្រាហ្មណោ...និងបទថា សុវណ្ណចង្កោដកេ គម្ពីរនេះថា "សុវណ្ណចង្កោដកេ" ។ (មតិអ្នកប្រែ)

*ព្រាហ្មណ៍មកបញ្ចុះក្នុងប្រអប់មាសនាំទៅកាន់**ឋានតាវតិង្សហើយ** ប្រតិស្ឋានទុកក្នុង**ចូឡាមណីចេតិយ**" ៕*

*(គម្ពីរបរមត្ថជោតិកមហាអភិធម្មសង្គហដីកា បរិច្ឆេទទី ៥ ភាគទី២ ទំព័រ ១០៨-១១០)*

## ១៩.ទោសនៃការលួចពុទ្ធបូជា ធម្មបូជា និងសង្ឃបូជាជាដើម

***មហារោរុវនរក*** *ប្រែថា «នរកបានសម្រែកពោទ៍ខ្លាំង» ។ គឺ នរកនេះ មានផ្កាឈូកដែកឆេះភ្លើង សត្វនរកនៅក្នុងផ្កាឈូកនោះ ត្រូវភ្លើងក្តៅ ក៏បម្រះនឿលស្ទុះបំប្រោងឡើង ត្រូវនាយនិរយបាលចាក់កាប់រាល់ថ្ងៃ គ្មានស្រាក ហើយស្រែកពោទ៍កងរំពងជានិច្ច ។ ទោសធ្លាក់នរកនេះ មកពី លួចទ្រព្យ**ពុទ្ធបូជា ធម្មបូជា សង្ឃបូជា**, បៀតបៀនសត្វនិងមនុស្សដោយ ភ្លើង ដុតផ្ទះគេ, លួចទ្រព្យម៉ែឪ, លួចទ្រព្យគ្រូបាធ្យាយ, ប្លន់អ្នកស្រុក ។ អាយុនរកនេះ ៨០០០ឆ្នាំទិព្វ ។ ចំនួន ២៣០កោដិ ៤០សែនមនុស្សយើង បានតែ ១ថ្ងៃ ១យប់ នរកនេះ ៕*

*(សៀវភៅព្រះមាល័យទេសនា ទំព័រ ១៦)*

## ២០.កាលបានទាន់សាសនាព្រះសិរិអារមេត្រីសម្ពុទ្ធ និងមិនទាន់ (ព្រះមាល័យថេរៈសន្ទនាជាមួយព្រះពោធិសត្វសិរិអារមេត្រី)

***សិរិអារមេត្រី*** *: មហាជនក្នុងជម្ពូទ្វីប បើមានប្រាថ្នាចង់កើតជួបនឹងញោម សូមឱ្យប្រឹងប្រែងដោយយកចិត្តទុកដាក់ នាំគ្នាបង្កើតឱ្យមាន ទេសនា**មហាវេស្សន្តរជាតក** យ៉ាងហោចណាស់ក្នុង ១ឆ្នាំ ឱ្យមាន*

*ម្តង ។ ហើយនៅចាំស្តាប់ឱ្យបានចប់ក្នុង ១ថ្ងៃព្រមទាំងបូជាសក្ការៈផ្សេងៗ មួយមុខ ១ពាន់, ឱ្យត្រូវគ្រប់នឹងព្រះគាថា ១ពាន់ក្នុង វេស្សន្តរជាតកដែរ គឺបូជាប្រទីប ១ពាន់, ផ្កាឈើ ១ពាន់, ឆត្រ, ផ្កាឈូកលឿង, ផ្កាឈូកខៀវ ផ្កាឈូកក្រហម, ផ្កាឈូកស, ផ្កាព្រលិត ផ្កាទាំងអស់នេះក្នុងមួយមុខៗ ១ពាន់ ។ ផ្កាឈូកបើរកពណ៌ដូចនេះ មិនបាន ឱ្យយកផ្កាចម្ប៉ា ផ្កាម្ទេះ ផ្កានេាងជាដើមជំនួសក៏បានដែរ ។ ហើយនឹងបូជាដោយផ្លែចេក, ដំឡូង, ដូង, ស្វា, ក្រូច, មៀន ត្របែក, ព្រូស, ជន្ទូសសេមាន់, អំពៅ, ខ្នុរ, ស្កុរ តែ ទៀន ធូប ទឹកដោះគោ កាហ្វេ ទឹកក្រូច នុំនែក អំបុក ម្ទូ បារីជាដើម ឱ្យបាន ១មុខ ១ពាន់ ទើបបាន កើតទាន់នឹងសាសនារបស់ញោម ហើយ បានសម្រេចដល់* ***អរហត្តបដិ សម្ភិទាញាណ****ជាប្រាកដ ។*

*ម្យ៉ាងទៀតមនុស្សធ្វើ* ***អនន្តរិយកម្ម៥*** *គឺ សម្លាប់បិតា ១ សម្លាប់មាតា ១ សម្លាប់ព្រះអរហន្ត ១ ប្រទុស្តព្រះពុទ្ធឱ្យចេញលោហិត ១ បំបែកសង្ឃ ១ និងមនុស្សមានទោសចិត្ត ទម្លាយព្រះស្តូប, ព្រះចេតិយ, ព្រះពុទ្ធរូប កាប់គាស់ដើមពោធិ, សម្លាប់ព្រះពោធិសត្វ, កំណាញ់ស្វិតស្វាញ, មនុស្សមិច្ឆាទិដ្ឋិ ជនទាំងអស់នេះមិនជួបនឹង សាសនារបស់ញោមទេ ។ ចំណែកដើមពោធិ៍ បើគាស់យកទៅដាំក្នុង ទីសមគួរ, កាប់ផ្ការមែកខ្វះមិនសមដែលពារលើវត្ថុមានតម្លៃ បែបនេះ គ្មានទោសអ្វីឡើយ ។ ចេតិយ, ព្រះពុទ្ធរូបដែលបាក់បែកពុកផុយ ហើយ ជួសជុល កែឡើងវិញ ក៏គ្មានទោសដែរ រឹតបានតែផលល្អឡើង ។...*

*(សៀវភៅ ព្រះមាល័យទេសនា ទំព័រ ៥៤-៥៥)*

# ២១.រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល

## *សេចក្តីខាងដើម*

*ព្រះបរមសាស្តា កាលស្តេចត្រាច់ទៅកាន់ទីចារិកទ្រង់ប្រារព្ធព្រះចេតិយមាស របស់**ព្រះកស្សបទសពល** ទើបត្រាស់ព្រះធម្មទេសនានេះថា "**បូជារហេ**" ជាដើម ។*

*សេចក្តីពិស្តារថា ព្រះតថាគតមានភិក្ខុសង្ឃមួយពួកធំជាពុទ្ធបរិវារ ស្តេចចេញចាកក្រុងសាវត្ថីហើយ ស្តេចទៅកាន់ក្រុងពារាណសីដោយលំដាប់ ស្តេចដល់**ទេវស្ថាន**មួយ ដែលនៅជិត**ស្រុកតោទេយ្យគ្រាម**ក្នុងចន្លោះផ្លូវ ។ ព្រះសុគត ស្តេចគង់នៅជិត**ទេវស្ថាន**នោះ ទ្រង់បញ្ជា**ព្រះធម្មភណ្ឌាគារិក** (គឺព្រះអានន្ទអ្នកជាឃ្លាំងធម៌) ឱ្យនិមន្តទៅប្រាប់ព្រាហ្មណ៍ដែលកំពុងធ្វើនូវកសិកម្មដែលនៅជិតនោះចូលមកគាល់ ។ ព្រាហ្មណ៍នោះមកដល់ហើយ មិនថ្វាយ**អភិវាទ**ចំពោះព្រះតថាគតទេ ប៉ុន្តែថ្វាយបង្គំ**ទេវស្ថាន**នោះ ហើយឈរនៅចំណែកម្ខាង ។*

***ព្រះសុគតក៏សួរថា** "ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ប្រទេសនេះថាជាទីអ្វី ? ព្រាហ្មណ៍ក៏ក្រាបទូលថា "បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំថ្វាយបង្គំទីនេះដោយតាំងចិត្តថា ទីនេះជា**ចេតិយស្ថាន**តាមប្រពៃណីរបស់ពួកខ្ញុំ" ។ ព្រះសុគតក៏ញ៉ាំងព្រាហ្មណ៍នោះ ឱ្យរីករាយត្រេកអរដោយព្រះតម្រាស់ថា "ម្នាលព្រាហ្មណ៍ អ្នកថ្វាយបង្គំស្ថានទីនេះ ឈ្មោះថា បានធ្វើនូវអំពើដ៏ប្រពៃហើយ" ។ ភិក្ខុទាំងឡាយ បានស្តាប់នូវព្រះពុទ្ធតម្រាស់នោះហើយ ក៏កើតសេចក្តីសង្ស័យថា "ព្រះមានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យ*

ត្រេកអរយ៉ាងនេះដោយហេតុអ្វីហ្ន៎ ។ គ្រានោះ ព្រះសាស្ដាដើម្បីទ្រង់ដោះនូវសេចក្ដីសង្ស័យ របស់ភិក្ខុទាំងនោះទើប ត្រាស់ទេសនានូវ **ឃដិការសូត្រ ក្នុងមជ្ឈិមនិកាយ** ហើយទ្រង់**និម្មិតព្រះចេតិយមាស** របស់**ព្រះកស្សបទសពល**កម្ពស់មួយយោជន៍ និងព្រះចេតិយមួយអង្គទៀតទុកក្នុងអាកាស ទ្រង់សម្ដែងឱ្យមហាជនឃើញហើយត្រាស់ថា "**ម្នាលព្រាហ្មណ៍ ការបូជាដែលបុគ្គលគួរបូជាប្រភេទដូច្នេះ រមែងសមគួរជាងពិត**" ដូច្នេះហើយ ក៏ទ្រង់ប្រកាសនូវបូជារហបុគ្គល ៤ជំពូក មានព្រះពុទ្ធជាដើម តាមន័យដូចដែលត្រាស់ទុក ក្នុងមហាបរិនិព្វានសូត្រនោះឯង ហើយទ្រង់សម្ដែងដោយពិស្ដារនូវព្រះចេតិយ ៣ ប្រភេទ គឺ **សរីរចេតិយ ១ ឧទ្ទិសចេតិយ ១ បរិភោគចេតិយ ១** ។

លុះទ្រង់ត្រាស់ចេតិយ ៣ ប្រភេទចប់ហើយ បានទ្រង់ភាសិតនូវព្រះគាថានេះថា ៖

**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ**<br>**បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ**<br>**តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ**<br>**ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។**

កាលបុគ្គលបូជាចំពោះបូជារហបុគ្គល គឺ ព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្ដីសោក និងខ្សឹកខ្សួល ឬកាលបូជាចំពោះ បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណ

ប៉ុណ្ណោះបានឡើយ ។

## **អធិប្បាយគាថា**

បុគ្គលដែលគួរបូជា អធិប្បាយ ថា អ្នកគួរដើម្បីបូជា ឈ្មោះថា **បូជារហបុគ្គល**ក្នុងព្រះគាថានោះ ។ ពាក្យថា របស់បុគ្គលអ្នកបូជានូវលោកអ្នកដែលគួរបូជា សេចក្តី ថា អ្នកបូជាដោយការឱនលំទោនមានការក្រាបថ្វាយបង្គំ ជាដើម នឹងដោយបច្ច័យ ៤ ។ ព្រះមានព្រះភាគទ្រង់ សម្តែងបូជារហបុគ្គលដោយពាក្យថា **ពុទ្ធេ** គឺព្រះពុទ្ធទាំង ឡាយ ។ បទថា **ពុទ្ធេ** បានដល់ ព្រះសម្មាសម្ពុទ្ធ ។ ស័ព្ទ **និបាតថា យទិ** បានដល់ **យទិវា** អធិប្បាយថា **អថវា** ។ ពាក្យថា នូវ **ព្រះបច្ចេកពុទ្ធ**ទាំងឡាយ ក៏ជាការដែលត្រាស់ ទុកហើយក្នុងព្រះគាថានោះ ។ ( ឬថា ) **ព្រះសាវ័ក**ទាំងឡាយផង ។ បទថា អ្នកកន្លងផុត**បបញ្ចធម៌**ហើយ សេចក្តី ថា បបញ្ចធម៌ គឺ**តណ្ហា ទិដ្ឋិ មានះ** លោកឈានកន្លងផុតហើយ ។

ពាក្យថា អ្នកមានសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួលកន្លងផុតហើយ បានដល់អ្នកមានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលកន្លងផុតទៅហើយ ។ **អធិប្បាយថា** កន្លងផុតបានទាំងពីរយ៉ាង ។ ភាពជាអ្នកគួរដល់ការបូជា ព្រះមានព្រះភាគត្រាស់ ដោយបទវិសេសនៈ (គុណបទ) ទាំងនោះ ។ ពាក្យថាទាំងនោះ បានដល់ព្រះពុទ្ធជាដើម ។ ពាក្យថា អ្នកដូច្នោះ បានដល់អ្នកប្រកបដោយគុណដូច្នោះ ដោយអំណាចនៃគុណដូចពោលហើយ ។ ពាក្យថា **និព្វាន** ហើយ បានដល់ **និព្វាន**ដោយការរំលត់**កិលេសមានរាគៈ** ជាដើម ។ ភ័យអំពីទីណាៗ គឺអំពីភព ឬអំពីអារម្មណ៍រមែងមិនមានដល់បុគ្គល ដែលគួរបូជាទាំងនោះ ដូច្នោះ បុគ្គលទាំងនោះទើប

ឈ្មោះថា មិនមានភ័យអំពីទីណាៗ ។ ចំពោះបុគ្គលដែលមិនមានភ័យអំពីទីណាៗ ទាំងនោះ ។

ពាក្យថា បុគ្គលណាមួយមិនអាចរាប់បុណ្យបាន សេចក្ដីថា មិនអាចគណនាបុណ្យបាន ។ ប្រសិនបើមានពាក្យសួរសើកចូលមកថា រាប់យ៉ាងណា ? គប្បីឆ្លើយថា នរណាៗ ក៏មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ **អធិប្បាយថា** នរណាៗ ក៏មិនអាចនឹងរាប់ថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ បុណ្យនេះមានប្រមាណប៉ុណ្ណោះ ។ **អបិ** គប្បីភ្ជាប់នឹងបទថា **កេនចិ** ។ អធិប្បាយថា ដែលបុគ្គលណាៗ ឬពោលដោយការរាប់វិធីណាៗ ក្នុងពាក្យទាំងពីរនោះ ពាក្យថា ដែលបុគ្គលបានដល់ ដែលបុគ្គលនោះមានព្រះព្រហ្មជាដើម ។ ពាក្យថា ដោយការរាប់បានដល់ដោយការរាប់ ៣ យ៉ាងគឺ **ដោយការគណនេយ្យ ដោយការថ្លឹង និងដោយការវាល់** ។ ការគណនេយ្យដោយន័យថា វត្ថុនេះមានប្រមាណប៉ុណ្ណេះ ឈ្មោះថា **គណនេយ្យ** ការថ្លឹងដោយ គ្រឿងថ្លឹង ឈ្មោះថា **ថ្លឹង** ការធ្វើឱ្យពេញ (វាល់) ដោយអំណាច នៃកន្ទះទូកដៃ មួយទូកដៃ បំពង់ និងនាឡិជាដើម ឈ្មោះថា **វាល់** ។ បុគ្គលណាៗ ក៏មិនអាចរាប់បុណ្យរបស់អ្នកបូជា ចំពោះបុគ្គលដែលគួរ បូជា មានព្រះពុទ្ធជាដើម ដោយការរាប់ទាំង៣វិធីនេះដោយ អំណាចនៃ វិបាក គឺផល ព្រោះវៀរចាកទីបំផុតដូច្នេះ ។ ផលនៃទានរបស់បុគ្គល អ្នកបូជាក្នុងស្ថានទាំងពីរ ជាយ៉ាងណា ?

បុណ្យរបស់បុគ្គលអ្នកបូជាចំពោះព្រះពុទ្ធជាដើម ដែលទ្រង់នៅមានព្រះជន្ម នរណាៗ ក៏មិនអាចរាប់បាន ។ បុណ្យរបស់បុគ្គលអ្នក បូជាចំពោះព្រះពុទ្ធជាដើម ដូច្នោះ សូម្បីនិព្វានទៅហើយ ដោយខន្ធ- បរិ

និព្វាន ដែលមានកិលេសបរិនិព្វានជានិមិត្ត នរណាៗ ក៏មិនអាចរាប់ បាន ព្រោះដូច្នោះ គួរនឹងផ្សេងគ្នាខ្វះ ។ ព្រោះហេតុ (តែមាន សេចក្តីសង្ស័យ) នោះឯង ទើបសក្កទេវរាជពោលក្នុង វិមានវត្ថុថា ៖

"កាលព្រះសម្ពុទ្ធជាដើម ទ្រង់នៅមានព្រះជន្មក្តី

និព្វានទៅហើយក្តី កាលចិត្តស្មើគ្នា ផលក៏រមែង

ស្មើគ្នា ព្រោះហេតុគឺសេចក្តីជ្រះថ្លានៃចិត្តសត្វ

ទាំងឡាយ រមែងទៅកាន់សុគតិ" ដូច្នេះឯង ។

ក្នុងអវសាននៃព្រះធម្មទេសនា ព្រាហ្មណ៍នោះ

បានជាសោតាបន្ន ។

ព្រះចេតិយមាសកម្ពស់ទាំងយោជន៍ បានតាំង (លេចឡើង) នៅក្នុងអាកាសអស់ ៧ ថ្ងៃ ។ ក៏សមាគមបានមានហើយដោយជនជាច្រើន ពួកគេបូជាព្រះ- ចេតិយដោយប្រការផ្សេងៗ អស់៧ថ្ងៃ ។ តអំពីនោះ សេចក្តីផ្សេងគ្នា នៃលទ្ធិ របស់អ្នកមានលទ្ធិផ្សេងគ្នាបានកើតមាន ។

ព្រះចេតិយនោះ បានទៅកាន់ទីរបស់ខ្លួនវិញដោយ**ពុទ្ធានុភាព**, ក្នុងខណៈនោះ **ព្រះចេតិយសិលា**ដ៏ធំផុស ឡើងហើយក្នុងទីនោះ ។

ប្រជាសត្វ ៨៤០០០ បានសម្រេច**ធម្មាភិសម័យ** (គឺត្រាស់ដឹងធម៌) ហើយក្នុងសមាគមនោះ ៕

( រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល ចប់ )

ពុទ្ធវគ្គវណ្ណនាទី ១៤ ចប់

(អដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ នៃព្រះសុត្តន្តបិដក លេខ ៥៤ ភាគ ២ ទំព័រ ១៥៤-១៥៩)

# ២២.រឿងបុព្វកម្មរបស់ព្រះអង្គ
# (ផលនៃការកសាងព្រះចេតិយព្រះបច្ចេកពុទ្ធជាដើម)

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលគង់នៅក្នុង**វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ បុព្វកម្មរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះថា "**មត្តាសុខបរិច្ចាគា**" ជាដើម ។*

### *[កើតភ័យ ៣ យ៉ាងក្នុងក្រុងវេសាលី]*

*សេចក្ដីពិស្ដារថា សម័យមួយ ក្នុង**វេសាលី**នោះជាក្រុងស្ដុកស្ដម្ភ ក្រុងរីករាយ មានប្រជាជនច្រើន ជាក្រុងមានមនុស្សកុះករ ។ ក៏ក្នុង**ក្រុងវេសាលី**នោះមានក្សត្រ គ្រប់គ្រងរាជសម្បត្តិតាមវារៈ **៧៧០៧ ព្រះអង្គ** ។ ប្រាសាទសម្រាប់ជាទីគង់នៅនៃក្សត្រទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះដែរ, ផ្ទះកំពូលក៏មានប្រមាណប៉ុណ្ណោះដែរ, សួន និងស្រះបោក្ខរណីសម្រាប់ជាទីគង់នៅក្នុងព្រះរាជឧទ្យាន ក៏មានប្រមាណប៉ុណ្ណោះដែរ ។*

*សម័យខាងក្រោយមក ក្រុងវេសាលីនោះ ជាក្រុងមាន**ភិក្ខា**រកបានដោយក្រ ជាក្រុងមានសន្ទូងខូចខាត ។ ដំបូង **មនុស្សទុគ៌ត**ក្នុងក្រុងវេសាលីនោះ ស្លាប់យ៉ាងច្រើន ដោយទោស គឺ**ការអត់ឃ្លាន** ។ ពួក**អមនុស្ស**ក៏ចូលទៅកាន់ព្រះនគរដោយសារក្លិនសាកសព របស់មនុស្សទាំងនោះ ដែលគេបោះចោលក្នុងទីនោះៗ, មនុស្សទាំងឡាយបានស្លាប់ច្រើនក្រៃលែង ដោយសារ**ឧបទ្រព**ដែលកើតអំពី**អមនុស្ស** ។ **អហិវាតករោគ** (អាសន្នរោគ) កើតឡើងដល់សត្វទាំងឡាយ ព្រោះបដិកូលដោយក្លិនសាកសពនៃមនុស្សទាំងនោះ ។ ភ័យ ៣ យ៉ាង គឺ "ភ័យកើតអំពីភិក្ខា*

*រកបានដោយក្រ ( **ទុព្ភិក្ខភ័យ** ) ១ ភ័យកើតអំពីអមនុស្ស ( **អមនុស្សភ័យ**) ១ ភ័យកើតអំពី រោគ ( **រោគភ័យ** ) ១" កើតឡើងហើយ ដោយប្រការ ដូច្នេះ ។*

*អ្នកនគរប្រជុំគ្នាហើយ ក្រាបទូលព្រះរាជាថា "បពិត្រ មហារាជ ភ័យ ៣ យ៉ាងកើតឡើងហើយក្នុងព្រះនគរនេះ, ក្នុងកាលមុនអំពីកាល នេះ រហូតដល់ព្រះរាជា ៧ជំនាន់ ឈ្មោះភ័យបែបនេះ មិនធ្លាប់កើត ឡើងឡើយ, ព្រោះថា ក្នុងរាជកាលរបស់ព្រះរាជាអ្នកទ្រទ្រង់ធម៌ ទាំងឡាយ ភ័យបែបនេះរមែងមិនកើតឡើង " ។*

*ព្រះរាជា បញ្ជារាជបុរសឱ្យធ្វើការប្រជុំជនទាំងឡាយ ក្នុងព្រះរាជ **សណ្ឋាគារ** ហើយត្រាស់ថា " ប្រសិនបើការមិន ទ្រទ្រង់ធម៌របស់យើង មានសោត , អ្នកទាំងឡាយ ចូរពិចារណារកមើលនូវហេតុនោះ " ។*

*អ្នក**ក្រុងវេសាលី** ពិចារណារកមើលនូវប្រពៃណីទាំងពួង មិន ឃើញទោសអ្វីៗ របស់ព្រះរាជា ទើបក្រាបទូលថា បពិត្រមហារាជ ទោស របស់ព្រះអង្គមិនមានទេ "ទើបព្រឹក្សាគ្នាថា" ភ័យរបស់ពួកយើង នេះ គប្បីដល់នូវការស្ងប់ រម្ងាប់ទៅដោយប្រការដូចម្ដេចហ្ន៎ ? "បណ្ដា ជនទាំង នោះ កាលជនពួកខ្លះពោលថា " ភ័យគប្បីដល់ការស្ងប់ ដោយ **ពលីកម្ម** ដោយការ**បួងសួង** ដោយការធ្វើនូវ**មង្គល**", ជន ទាំងនោះធ្វើ ពិធីនោះ ទាំងអស់ហើយ ក៏មិនអាចកម្ចាត់ភ័យ នោះបាន ។*

*គ្រានោះ ជនពួកដទៃពោលយ៉ាងនេះថា "គ្រូទាំង ៦ មានអានុភាព ច្រើន, កាលគ្រូទាំង ៦ នោះមកដល់ទីនេះភ្លាម, ភ័យនឹងស្ងប់រម្ងាប់ទៅ" ។ មួយពួកទៀតពោលថា "ព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងហើយក្នុងលោក,*

*ព្រះមានព្រះភាគអង្គនោះមាន**ឫទ្ធិច្រើន** ទ្រង់ មាន**អានុភាពច្រើន ទ្រង់សម្តែងធម៌** ដើម្បីប្រយោជន៍ដល់**សព្វសត្វ**, កាលព្រះអង្គ ស្ដេចមកកាន់ទីនេះ , ភ័យទាំងនេះនឹងស្ងប់រម្ងាប់បាន " ។ ជនសូម្បីទាំងអស់ ពេញចិត្តនឹងពាក្យរបស់ជនទាំងនោះហើយ ពោលថា "ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់គង់នៅទីណាហ្ន៎ ?" ។*

**[ អ្នកក្រុងវេសាលីឱ្យទៅអារាធនាព្រះសាស្ដា ]**

*ក៏ក្នុងកាលនោះ កាលតិថីជាទីចូលចាំវស្សាជិតមក ដល់ហើយ, ព្រះសាស្ដាទ្រង់ប្រទានការប្ដេជ្ញាដល់**ព្រះបាទពិម្ពិសារ** ហើយទ្រង់គង់នៅក្នុង**វត្តវេឡុវ័ន** ។*

*ក៏ក្នុងសម័យនោះ **ស្ដេចលិច្ឆវីព្រះនាមមហាលិ** ដែលជា **សោតាបន្នបុគ្គល** ជាមួយនឹងព្រះរាជាព្រះនាម**ពិម្ពិសារ** ក្នុងសមាគម **ព្រះបាទពិម្ពិសារ** ទ្រង់គង់នៅក្នុងទីជិតនៃបរិស័ទ ទាំងនោះ ។*

*អ្នកក្រុងវេសាលីចាត់ចែងបណ្ណាការដ៏ធំ ហើយបញ្ជូនទៅថ្វាយ**ស្ដេចលិច្ឆវីព្រះនាមមហាលិ** និងបុត្ររបស់ បុរោហិតដោយផ្ដាំថា " អ្នកទាំងឡាយ ចូរញ៉ាំង**ព្រះបាទពិម្ពិសារ** ឱ្យទ្រង់យល់ព្រមហើយ នាំព្រះសាស្ដាមកកាន់ នគរនេះ " ។ **ស្ដេចលិច្ឆវីព្រះនាមមហាលិ** និងបុត្ររបស់បុរោហិតនោះទៅហើយ ថ្វាយបណ្ណាការដល់ព្រះរាជា ក្រាបទូលព្រឹត្តិការណ៍នោះឱ្យទ្រង់ជ្រាបហើយទូលអង្វរថា "បពិត្រមហារាជ សូមព្រះអង្គទ្រង់បញ្ជូនព្រះសាស្ដាទៅកាន់នគរ របស់ខ្ញុំព្រះអង្គ" ។*

*ព្រះរាជាត្រាស់ថា "អ្នកទាំងឡាយចូរដឹងខ្លួនឯងចុះ" ហើយមិនទ្រង់ទទួល (បណ្ណាការនោះ) ។ ជនទាំងនោះ ចូលទៅគាល់ព្រះមាន ព្រះភាគថ្វាយបង្គំហើយ ទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន ក្នុង ក្រុងវេសាលីកើតភ័យ ៣យ៉ាង, កាលព្រះអង្គស្ដេចទៅ, ភ័យទាំងនោះ នឹងស្ងប់រម្ងាប់, សូមព្រះអង្គស្ដេចយាងទៅកាន់នគរនោះចុះ ខ្ញុំព្រះអង្គទាំងឡាយ នឹងទៅ" ។ ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ ជនទាំងនោះហើយ ទ្រង់រំពឹងមើលក៏ទ្រង់ជ្រាបថា "ក្នុង**ក្រុងវេសាលី** កាលតថាគតសូត្យ**រតនសូត្រ**, អាជ្ញានឹងផ្សាយទៅកាន់ **សែនកោដិ ចក្រវាឡ**, ក្នុងកាលចប់ព្រះសូត្រ ការសម្រេចធម៌នឹងមានដល់**សត្វ ៨៤០០០**, ភ័យទាំងនោះក៏នឹងស្ងប់រម្ងាប់ទៅ" ហើយទ្រង់ទទួលការ អារាធនារបស់ជនទាំងនោះ ។*

## [ **ព្រះសាស្ដាស្ដេចទៅកាន់ក្រុងវេសាលី** ]

***ព្រះបាទពិម្ពិសារ** ទ្រង់ព្រះសណ្ដាប់ថា "ព្រះសាស្ដទ្រង់ទទួលការអារាធនារបស់អ្នក**ក្រុងវេសាលី**ហើយ" ហើយបញ្ជាឱ្យធ្វើការឃោសនាក្នុងព្រះនគរ ចូលទៅគាល់ព្រះសាស្ដាទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទទួលការអារាធនារបស់អ្នក**ក្រុងវេសាលី**ហើយឬ?" កាលព្រះសាស្ដាត្រាស់ថា "ថ្វាយព្រះពរ មហាបពិត្រ "ទូលថា បើដូច្នោះ សូមព្រះអង្គទ្រង់រង់ចាំសិន, ខ្ញុំព្រះអង្គនឹងចាត់ ចែងផ្លូវសិន" ហើយទ្រង់បញ្ជាឱ្យធ្វើផែនដីប្រមាណ ៥យោជន៍ ក្នុងចន្លោះ**ក្រុងរាជគ្រឹះ និងទន្លេគង្គា**ឱ្យរាបស្មើ ឱ្យចាត់ចែង**វិហារ**ទុកក្នុងទីមួយយោជន៍ៗ (មួយយោជន៍*

មួយកន្ទែង) ហើយទើបក្រាបទូលកាលជាទីស្តេចទៅចំពោះព្រះសាស្តា ។

គ្រានោះ ព្រះសាស្តាស្តេចយាងទៅកាន់ផ្លូវនោះជាមួយនឹង**ភិក្ខុ ៥០០**រូប ។ ព្រះរាជាទ្រង់បញ្ជាឱ្យរោយផ្កាឈើ **៥ ពណ៌** កម្ពស់ប្រមាណត្រឹមជង្គង់ ក្នុងចន្លោះមួយយោជន៍ៗ ហើយត្រាស់ឱ្យលើក**ទង់ជ័យ ទង់ផ្ទាំង សំពត់** និង**ដើមចេក**ជាដើមឡើង ត្រាស់ឱ្យ**បាំងស្វេតច្ឆត្រពីរជាន់**ចំពោះព្រះមានព្រះភាគ ត្រាស់ឱ្យ**បាំងស្វេតច្ឆត្រមួយជាន់**ដល់ភិក្ខុមួយរូបៗ ព្រមទាំងបរិវារ ទ្រង់បូជាផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់អារាធនាព្រះសាស្តាឱ្យគង់ក្នុងវិហារនីមួយៗ ទ្រង់ថ្វាយ**មហាទាន**ហើយ ញ៉ាំងព្រះសាស្តាឱ្យស្តេចដល់**ឆ្នេរទន្លេគង្គា**ដោយ ៥ថ្ងៃ ទ្រង់តាក់តែងទូកក្នុងទីនោះ ទ្រង់បញ្ជូនដំណឹងទៅ ប្រាប់អ្នក**ក្រុងវេសាលី**ថា“ អ្នកក្រុង**វេសាលី**ទាំងឡាយ ចូរតាក់តែងផ្លូវ ចូរធ្វើការក្រោកទទួលព្រះសាស្តាចុះ " ។

### [អ្នកក្រុងវេសាលីចាត់ការទទួលព្រះសាស្តា]

**អ្នកក្រុងវេសាលី**ទាំងនោះ គិតថា“ យើងទាំងឡាយនឹងធ្វើការបូជាជា**ទ្វេគុណ** ហើយធ្វើផ្ទៃដីប្រមាណ ៣យោជន៍ ក្នុងចន្លោះ**ក្រុងវេសាលី និងទន្លេគង្គា**ឱ្យរាបស្មើ ហើយចាត់ចែង**ឆត្រតម្រួតឆត្រ ៤ជាន់**ដើម្បីព្រះមានព្រះភាគ ដើម្បី**ភិក្ខុមួយរូបៗ ២ជាន់** ធ្វើការបូជាព្រះមានព្រះភាគ ហើយមកឈរនៅនា**ឆ្នេរទន្លេគង្គា** ។

**ព្រះបាទពិម្ពិសារ** ទ្រង់ចាត់ឱ្យគាបទូកពីរ ឱ្យធ្វើ**មណ្ឌប** ឱ្យប្រដាប់ដោយគ្រឿងប្រដាប់ទាំងឡាយមានចង្កោមផ្កាជាដើម ឱ្យក្រាល**ពុទ្ធាសនៈ**ដែលសម្រេចដោយរតនៈទាំងពួង ។ ព្រះមានព្រះភាគទ្រង់គង់លើ **ពុទ្ធា**

**សនៈ**នោះ។ ចំណែកពួកភិក្ខុក៏ឡើងកាន់ទូក ហើយគង់ចោមរោម ព្រះមានព្រះភាគ ។ ព្រះរាជាកាលទ្រង់ជូនព្រះមានព្រះភាគទៅ ស្តេចទៅកាន់ទឹកទន្លេប្រមាណត្រឹម**ព្រះសុរង** (ក) ក្រាបទូលថា "បពិត្រព្រះអង្គ ដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅនា**ឆ្នេរទន្លេគង្គា**នេះដរាបដល់ព្រះមានព្រះភាគស្តេចត្រឡប់មក" បញ្ជូនទូកទៅហើយក៏ស្តេចត្រឡប់មកវិញ ។ ព្រះសាស្តា ស្តេចទៅតាម**ទន្លេគង្គា**អស់ចម្ងាយផ្លូវប្រមាណ ១យោជន៍ ទើបដល់ព្រំដែននៃអ្នក**នគរវេសាលី** ។

**ស្តេចលិច្ឆវី**ទាំងឡាយ ទ្រង់ទទួលព្រះសាស្តា ស្តេចចូលទៅកាន់ទឹកប្រមាណត្រឹម**ព្រះសុរង** នាំទូកចូលទៅកាន់ឆ្នេរហើយ អារាធនាព្រះសាស្តាឱ្យស្តេចចុះចាកទូក ។ គ្រាន់តែព្រះសាស្តា ស្តេចចុះចាកទូកជាន់លើ**ឆ្នេរទន្លេគង្គាភ្លាម**, **មហាមេឃ**ក៏តាំងឡើងហើយ បង្អុរចុះមកនូវ**ភ្លៀងបោក្ខរព័ស្ស** ( ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក ) ។ ទឹកមានប្រមាណត្រឹមជង្គង់ ត្រឹមភ្លៅ ត្រឹមចង្កេះជាដើមក្នុងទីទាំងពួង ហូរនាំយកសាកសពទាំងពួងចូលទៅកាន់ **ទន្លេគង្គា**។ ប្រទេសជាចំណែកនៃផែនដីជាប្រទេសដ៏ស្អាត។ **ស្តេចលិច្ឆវី**ទាំងឡាយ អារាធនា ព្រះសាស្តា ឱ្យគង់នៅក្នុងទីមួយយោជន៍ៗ ថ្វាយ**មហាទាន**ធ្វើការបូជា **ជាទ្វេគុណ** នាំព្រះសាស្តាចូលទៅកាន់**ក្រុងវេសាលី**ដោយ ៣ថ្ងៃ ។ **សក្កទេវរាជ**ដែលមានពួកទេវតាចោមរោមហើយ ស្តេចបានទៅកាន់ទីនោះ ។ **អមនុស្ស**ទាំងឡាយរត់គេចចេញទៅយ៉ាងច្រើន ដោយសារទេវតាទាំងឡាយអ្នកមាន**សក្តិធំ**ប្រជុំគ្នាហើយ ។

## [ទឹកមន្តនៃព្រះបរិត្តមានអានុភាពខ្លាំង]

ព្រះសាស្តា ទ្រង់ឈរនៅជិតទ្វារព្រះនគរក្នុងវេលាល្ងាច ត្រាស់ហៅ**ព្រះអានន្ទ**មកហើយ ត្រាស់ថា " ម្នាល**អានន្ទ** អ្នកចូររៀន**រតនសូត្រ**នេះហើយ ត្រាច់ទៅជាមួយ នឹង**លិច្ឆវីកុមារ**ទាំងឡាយ ចូរធ្វើ**ព្រះបរិត្ត**ក្នុងចន្លោះនៃកំពែង ៣ ជាន់នៃ**ក្រុងវេសាលី** " ។

ព្រះថេរៈ **រៀនរតនសូត្រ**ដែលព្រះសាស្តាប្រទានឱ្យ ហើយយកបាត្រដែល**សម្រេចអំពីថ្ម**របស់ព្រះសាស្តាដង់ទឹក ឈរនៅក្បែរទ្វារព្រះ-នគរហើយពិចារណាដល់**ព្រះពុទ្ធគុណ**របស់ព្រះតថាគតគ្រប់ទាំងអស់ ចាប់ដើមអំពីសេចក្តី ផ្តើមតាំងប្រាថ្នាជាព្រះពុទ្ធមកថា "បារមី៣០ គឺ **បារមី១០ ឧបបារមី១០ បរមត្ថបារមី១០ មហាបរិច្ចាគ៥ ចរិយា៣ គឺលោកត្ថចរិយា១ ញាតត្ថចរិយា១ ពុទ្ធត្ថចរិយា១** កិរិយាយាងចុះកាន់ គភ៌នៃ**ព្រះមាតា**ក្នុងបច្ឆិមភព កិរិយា**ប្រសូត** កិរិយា**យាងចេញសាង អភិនេស្រ្កម** កិរិយា**បំពេញនូវទុក្ករកិរិយា** កិរិយា**ផ្ចាញ់មារ** កិរិយា **ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ**លើពោធិបល្ល័ង្កការញ៉ាំង**ព្រះធម្មចក្រ**ឱ្យ ប្រព្រឹត្តទៅ **និងលោកុត្តរធម៌ ៩** "ហើយចូលទៅកាន់ព្រះនគរធ្វើ**ព្រះបរិត្ត** ក្នុងចន្លោះកំពែងទាំងអស់ ៣ នៃរាត្រី ។ ពាក្យត្រឹមតែថា " **យំ កិញ្ចិ**" ជាដើម គ្រាន់តែ**ព្រះអានន្ទ**ពោលហើយប៉ុណ្ណោះ ទឹកដែល**ព្រះអានន្ទ** បាចទៅខាងលើនោះ ធ្លាក់ចុះមកលើក្បាល**អមនុស្ស**ទាំងឡាយ ។

ចាប់ផ្តើមអំពីការពោលគាថាថា "**យានីធ ភូតានិ**" ជាដើម, តំណក់ទឹកដូចជាក្រវិលប្រាក់អណ្តែតឡើងទៅឰដ៏អាកាស ហើយធ្លាក់ចុះមក

*លើក្បាលមនុស្សឈឺទាំងឡាយ ។ មនុស្សឈឺទាំងនោះ ជាសះស្បើយរោគក្នុងខណៈនោះភ្លាម ហើយក្រោកឡើងចោមរោមព្រះថេរៈ ។*

*ចាប់ផ្តើមពីបទថា " **យំ កិញ្ចិ** " ជាដើម គ្រាន់តែ**ព្រះអានន្ទ** ពោលហើយប៉ុណ្ណោះ **អមនុស្ស**ទាំងឡាយដែលមិន ទាន់រត់ទៅក្នុងកាល មុនដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានគំនរសម្រាម និងជញ្ជាំងផ្ទះ ជាដើម ត្រូវតំណក់ទឹកពាល់ត្រូវហើយ ក៏រត់ទៅតាមទ្វារនោះៗ ។ ទ្វារទាំងឡាយមិនមានឱកាស ។ **អមនុស្ស**ទាំងនោះកាលមិនបាន ឱកាស ក៏ទម្លាយកំពែងរត់ចេញទៅ ។ មហាជនប្រោសព្រំរោងទទួលភ្ញៀវ ដែលនៅកណ្តាលព្រះនគរដោយគ្រឿងក្រអូបទាំងពួង ចងពិតានដែល វិចិត្រដោយផ្កាយមាសជាដើមខាងលើ តាក់តែង**ពុទ្ធាសនៈ**ហើយ អារាធនាព្រះសាស្តាមកកាន់រោងនោះ ។*

*ព្រះសាស្តា ទ្រង់គង់លើអាសនៈដែលគេតាក់តែងហើយ ។ ទាំងភិក្ខុសង្ឃ ទាំងពួក**ស្តេចលិច្ឆវី**ក៏គង់ចោមរោមព្រះសាស្តា ចំណែក **សក្កទេវរាជ**ដែលមានពួកទេវតាចោមរោមហើយ បានប្រថាប់ឈរក្នុង ឱកាសដ៏សមគួរ ។ ចំណែក **ព្រះអានន្ទ** ក៏ត្រាច់ទៅកាន់ព្រះនគរ ទាំងមូលដោយលំដាប់ ហើយមកជាមួយនឹងមហាជនដែលមានរោគជា សះស្បើយហើយ ថ្វាយបង្គំព្រះសាស្តា ព្រះសាស្តាទ្រង់ទតមើលបរិស័ទ ហើយ បានទ្រង់**ភាសិតរតនសូត្រ**នោះទៀត ។ ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌បានមានដល់**សត្វ ៨៤០០០** ។*

*ព្រះសាស្តា ទ្រង់សម្តែង**រតនសូត្រ**នោះអស់ ៧ថ្ងៃ ទ្រង់ជ្រាបថាភ័យទាំងពួងស្ងប់រម្ងាប់ហើយ ទ្រង់ដាស់តឿនពួក**ស្តេចលិច្ឆវី** ហើយ ស្តេ*

*បចេញចាកក្រុង**វេសាលី** ។ **ស្តេចលិច្ឆវី**ទាំងឡាយ បូជាព្រះសាស្តា ជា **ទ្វេគុណ** ហើយនាំព្រះសាស្តាទៅកាន់**ឆ្នេរទន្លេគង្គា**អស់ ៣ ថ្ងៃទៀត ។*

### *[ ពួកស្តេចនាគធ្វើការបូជាព្រះសាស្តា ]*

***ស្តេចនាគ**ទាំងឡាយ ដែលកើតនៅក្នុង**ទន្លេគង្គា**នោះ គិតថា "មនុស្សទាំងឡាយ រមែងធ្វើសក្ការបូជាចំពោះព្រះតថាគត, យើងទាំងឡាយនឹងធ្វើអ្វីហ្ន៎ ?" ស្តេចនាគទាំងនោះ **និម្មិតទូកមាស ទូកប្រាក់ និងទូកកែវមណី** ហើយតាក់តែង**បល្ល័ង្កមាស ប្រាក់ និងកែវមណី** ធ្វើទឹកឱ្យដេរដាសទៅដោយ**ផ្កាឈូក ៥ពណ៌** ហើយទូលអារាធនា ព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការឡើងកាន់ទូករបស់ខ្លួនៗ ថា" បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ធ្វើសេចក្តីអនុគ្រោះដល់ពួក ខ្ញុំព្រះអង្គទាំងឡាយចុះ" ។ **មនុស្ស** និង**នាគ**ទាំងឡាយ រមែងធ្វើការបូជា ព្រះតថាគត ។*

*ទេវតាទាំងឡាយ ចាប់តាំងពី**ភុម្មទេវតា**រហូតដល់ **ព្រហ្មលោក** ឈ្មោះ**អកនិដ្ឋ** គិតថា "ពួកយើងនឹងធ្វើអ្វីហ្ន៎ ?" ហើយធ្វើ សក្ការៈបូជាព្រះតថាគត ។*

*បណ្តាមនុស្ស **និងអមនុស្ស**ទាំងនោះ **នាគ**ទាំងឡាយ លើកឆត្រតម្រួតឆត្រឡើងប្រមាណមួយយោជន៍ ។ ឆត្រដែលត្រួតគ្នា ដែល**មនុស្ស និងអមនុស្ស**ទាំងឡាយលើកនោះ គឺ**នាគ**លើកឡើងពួដ៏ខាងក្រោម **មនុស្ស**ទាំងឡាយលើកឡើងលើផ្ទៃផែនដី **ភុម្មទេវតា**លើកឡើងពួដ៏ប្រទេសទាំងឡាយ មានដើមឈើ គុម្ពឈើ និងភ្នំជាដើម ពួកទេវតា ដែលឋិតនៅពួដ៏អាកាសលើកឡើងពួដ៏អាកាស **មនុស្ស និង អមនុស្ស** លើក*

ឆត្រឡើងហើយ ចាប់តាំងពី**ពិភពនាគ**រហូតដល់**ព្រហ្មលោក**ដោយ ជុំវិញ**ចក្រវាឡ** ដោយប្រការដូច្នេះ ។ ក្នុងចន្លោះឆត្រមានទង់ជ័យ, ក្នុងចន្លោះទង់ជ័យមានទង់ផ្កាំងសំពត់, ក្នុងចន្លោះៗ នៃទង់ទាំងនោះ មានគ្រឿងសក្ការៈទាំងឡាយ មានភួងផ្កា លម្អិតនៃគ្រឿងអប់ និងធូបជាដើម ។ ទេវបុត្រទាំងឡាយប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកភេទជាអ្នកលេង**មហោស្រព** ត្រាច់ទៅក្នុងអាកាសញ៉ាំងសំឡេងឱ្យគឹកកង ។

បានឮថា សមាគម ៣ គឺសមាគមក្នុងវេលាសម្ដែង**យមកប្បាដិហារ្យ ១** សមាគមក្នុងវេលាស្ដេចចុះចាក**ទេវលោក ១** សមាគមក្នុងវេលាស្ដេចចុះកាន់**ទន្លេគង្គានេះ ១** ជាសមាគមធំ ។

**[ព្រះបាទពិម្ពិសារត្រាស់ឱ្យត្រៀមរៀបចំទទួលព្រះពុទ្ធម្ដងទៀត]**

ចំណែក**ព្រះបាទពិម្ពិសារ** ទ្រង់ចាត់ចែងសក្ការៈជាទ្វេគុណ អំពី សក្ការៈដែលពួក**ស្ដេចលិច្ឆវី**ធ្វើ កាលទ្រង់ទន្ទឹងរង់ចាំព្រះដំណើររបស់ព្រះមានព្រះភាគ ក៏បានយាងមកឈរនៅ នាត្រើយខាងនាយ ។ ព្រះសាស្ដាទ្រង់ទត**មហាបរិច្ចាគ**របស់ព្រះរាជាទាំងឡាយ ក្នុងចំណែកទាំងពីរនៃ**ឆ្នេរទន្លេគង្គា**ហើយទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វទាំងឡាយ មាន**នាគ**ជាដើម ហើយទ្រង់**និម្មិតព្រះពុទ្ធនិម្មិត**មួយព្រះអង្គៗ មានភិក្ខុ ៥០០ ជាបរិវារក្នុងទូកមួយៗ ។ ព្រះពុទ្ធដែលព្រះអង្គទ្រង់**និម្មិត**នោះ ដែលមានពួក**នាគ**ចោមរោមហើយ ទ្រង់គង់នៅក្រោមស្វេតឆត្រមួយដើមៗ និងដើម**កប្បព្រឹក្ស**មួយដើមៗ និងភួងផ្កាមួយដើមៗ ។

ទ្រង់**និម្មិតព្រះពុទ្ធនិម្មិត**មួយអង្គៗ មួយអន្លើដោយបរិវារក្នុងឱកាសមួយៗ សូម្បីក្នុងទេវតាទាំងឡាយ មាន**ភុម្មទេវតា**ជាដើម ។ កាលផ្ទៃ

**ចក្រវាឡ**ទាំងអស់ដូចជាមានរបាំ និងមហោស្រពតែមួយ ដោយប្រការយ៉ាងនេះហើយ, ព្រះសាស្តា កាលនឹងទ្រង់ធ្វើសេចក្តីអនុគ្រោះដល់**នាគ**ទាំងឡាយ បានស្តេចឡើងកាន់**ទូកកែវមួយ** ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូបៗ ក៏ឡើងកាន់**ទូកកែវ**នីមួយៗ ដែរ ។

**ស្តេចនាគ**ទាំងឡាយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឱ្យចូលទៅកាន់**នាគភព** ស្តាប់ធម្មកថាក្នុងសំណាក់ព្រះសាស្តារហូតមួយយប់ទល់ភ្លឺ ក្នុងថ្ងៃទី២ **អង្គាស**ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយ វត្ថុដែលគួរទំពាស៊ី និងវត្ថុដែលគួរបរិភោគដ៏ជា**ទិព្វ** ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ចេញចាក**នាគភព** ដែលទេវតាក្នុង**សកលចក្រវាឡ**បូជាហើយ ទ្រង់ឆ្លង**ទន្លេគង្គា**ដោយទូក ៥០០ ។

ព្រះរាជា ទ្រង់ទទួលព្រះសាស្តាហើយ ទ្រង់អារាធនាឱ្យស្តេចចុះចាកទូក ទ្រង់ធ្វើសក្ការៈជាទ្វេគុណ អំពីសក្ការៈ ដែល**ស្តេចលិច្ឆវី**ទាំងឡាយធ្វើក្នុងវេលាស្តេចមក ទ្រង់នាំព្រះសាស្តាមកកាន់**ក្រុងរាជគ្រឹះ** អស់ ៥ថ្ងៃ ដូចក្នុងកាលមុនដែរ ។

### [ពួកភិក្ខុសរសើរពុទ្ធានុភាព]

ក្នុងថ្ងៃទី២ ពួកភិក្ខុត្រឡប់មកពីបិណ្ឌបាត ហើយក្នុងវេលារសៀលអង្គុយសន្ទនាគ្នាក្នុង**ធម្មសភា**ថា "គួរឱ្យសរសើរពិតមែនហ្ន៎ ! អានុភាពរបស់ព្រះពុទ្ធទាំងឡាយ គួរឱ្យអស្ចារ្យពិតមែនហ្ន៎ ! ទេវតា និងមនុស្សទាំងឡាយ នាំគ្នាជ្រះថ្លានឹងព្រះសាស្តា, ព្រះរាជាទាំងឡាយ ទ្រង់ធ្វើផែនដីឱ្យមានផ្ទៃស្មើក្នុងផ្លូវ ៨ យោជន៍ ទាំងត្រើយខាងអាយ ទាំងត្រើយខាងនាយនៃ**ទន្លេគង្គា** ទ្រង់រោយដីខ្សាច់ ក្រាលផ្កាឈើ ដែល មាន

ពណ៌ផ្សេងៗ ប្រមាណត្រឹមជង្គង់ ដោយសេចក្តីជ្រះថ្លាដែលប្រព្រឹត្ត ទៅក្នុងព្រះពុទ្ធ, ទឹកក្នុង**ទន្លេគង្គា**ក៏ដេរដាសដោយផ្កាឈូក ៥ ពណ៌ ដោយអានុភាពរបស់នាគ, ទេវតាទាំងឡាយលើកឆត្រឡើងរហូតដល់ **អកនិដ្ឋភព**, ផ្ទៃនៃចក្រវាឡទាំងមូល ហាក់ដូចជាមានគ្រឿងអលង្ការ តែមួយ និងដូចជាមានរបាំតែមួយ " ។

ព្រះសាស្តា ស្តេចមកហើយត្រាស់សួរថា " ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយ**កថាអ្វីហ្ន៎** ?" កាលភិក្ខុទាំងឡាយនោះក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ", ទើបត្រាស់ថា គ្រឿងបូជានិងសក្ការៈនេះ មិនមែនកើតឡើងដល់តថាគតដោយ**ពុទ្ធានុភាពទេ**, មិនមែនកើតឡើងដោយអានុភាពរបស់**នាគ**, **ទេវតានិងព្រហ្មទេ**, ប៉ុន្តែថា កើតឡើងដោយអានុភាពនៃការ**បរិច្ចាគ**ដែលមានប្រមាណតិចក្នុង**អតីត** "កាលភិក្ខុទាំងឡាយទូល អារាធនាហើយប្រាថ្នានឹងប្រកាសសេចក្តីនោះ ទើបទ្រង់នាំនិទានមកត្រាស់ថា:

## [ រឿងសុសិមមាណព ]

ក្នុងអតីតកាល ក្នុងក្រុង**តក្កសិលា** មានព្រាហ្មណ៍ម្នាក់ ឈ្មោះ **សង្ខៈ**។ ព្រាហ្មណ៍នោះ មានបុត្រម្នាក់ ជាមាណព ឈ្មោះ**សុសិមៈ** មានអាយុប្រហែល ១៦ឆ្នាំ ។ ក្នុងថ្ងៃមួយ **សុសិមមាណព**នោះចូលទៅរកបិតាហើយ ពោលថាបពិត្របិតា ខ្ញុំចង់ចូលទៅកាន់ក្រុង**ពារាណសី**ដើម្បីរៀនមន្ត" ។ គ្រានោះ បិតាពោលទៅកាន់បុត្រថា "ហៃបា ព្រាហ្មណ៍ ឯណោះជាសម្លាញ់របស់បិតា ដូច្នោះ កូនឯងចូរទៅកាន់ សម្នាក់របស់សម្លាញ់នោះ ហើយរៀនចុះ"។ **សុសិមៈ** ទទួលពាក្យថា "ប្រពៃហើយបិតា" ហើយ

ទៅដល់**ក្រុងពារាណសី**ដោយលំដាប់ ចូលទៅរកព្រាហ្មណ៍នោះ ហើយប្រាប់ព្រាហ្មណ៍នោះថា កាលដែលខ្លួនមកនេះដោយសារបិតា បញ្ជូនមក ។

គ្រានោះ ព្រាហ្មណ៍នោះទទួល**សុសិមៈ** ដោយគិតថា "បុត្រសម្លាញ់របស់យើង" ហើយផ្តើមប្រាប់បន្តដល់**សុសិមមាណព** អ្នកមានសេចក្តីក្រវល់ក្រវាយស្ងប់ហើយដោយថ្ងៃដ៏ចម្រើន ( ជាថ្ងៃមង្គល ) **សុសិមមាណព**នោះរៀនរហ័សផង រៀនបានច្រើនផង ទ្រទ្រង់ចាំនូវមន្តដែលរៀនហើយៗ មិនឱ្យវិនាសទៅ ដូចជាទ្រទ្រង់នូវប្រេង (ខ្លាញ់) **សីហៈ** ដែលគេដាក់នៅក្នុង**ភាជនៈមាស** មិនយូរប៉ុន្មានបានរៀនមន្ត ទាំងអស់ដែលខ្លួនគប្បីរៀនអំពីមាត់របស់អាចារ្យ ធ្វើការស្វាធ្យាយ រមែង ឃើញខាងដើម និងកណ្តាលនៃសិល្បៈ ដែលខ្លួនរៀនហើយ ប៉ុណ្ណោះ, (ប៉ុន្តែ) មិនឃើញទីបំផុត ។

**សុសិមមាណព**នោះ ចូលទៅរកអាចារ្យហើយពោលថា "បពិត្រអាចារ្យ ខ្ញុំរមែងឃើញខាងដើម និងកណ្តាលនៃ សិល្បៈនេះ ប៉ុណ្ណោះ, តែមិនឃើញទីបំផុត", កាលអាចារ្យ ពោលថា "ម្នាលកូន សូម្បីខ្ញុំក៏មិនឃើញដែរ", ទើបសួរថា "បពិត្រអាចារ្យ កាលបើដូច្នោះ នរណាទៅនឹងដឹងទីបំផុត", កាលអាចារ្យពោលថា "ហៃកូន ឥសីទាំងឡាយ ដែលនៅក្នុងព្រៃ**ឥសិបតនៈ** រមែងដឹង, កូនឯងចូលទៅកាន់សម្នាក់ របស់ឥសីទាំងនោះហើយសួរចុះ" ក៏ចូលទៅរក**ព្រះបច្ចេកពុទ្ធ**ទាំងឡាយ ហើយសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា លោកម្ចាស់ទាំងឡាយរមែងដឹងនូវទីបំផុតឬ ?" ។

**បច្ចេកពុទ្ធ**: ចម្រើនពរ ឧបាសក ។

**សុសិមៈ** បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយប្រាប់ខ្ញុំព្រះករុណា។

**បច្ចេកពុទ្ធ**: អាត្មាទាំងឡាយ រមែងមិនប្រាប់អ្នកដែលមិនមែនជាបព្វជិត, ប្រសិនបើអ្នកត្រូវការដឹងនូវទីបំផុត, ចូរបួសចុះ ។

**សុសិមមាណព**នោះយល់ព្រមដោយពាក្យថា "ប្រពៃហើយ លោកម្ចាស់" ហើយបួសក្នុងសម្នាក់ទាំងនោះ ។ គ្រានោះ **ព្រះបច្ចេក ពុទ្ធ**ទាំងនោះប្រាប់សុសិមៈ ថា "អ្នកចូរសិក្សា**អភិសមាចារិកវត្ត** (វត្តប្រកបដោយរបៀបដែលបព្វជិតគប្បីប្រព្រឹត្តឱ្យសមរម្យ) នេះជាមុន" ហើយប្រាប់**អភិសមាចារិកវត្ត**ដោយន័យជាដើមថា "អ្នកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ" ។

**សុសិមមាណព**នោះ សិក្សា**អភិសមាចារិកវត្ត**នោះ ព្រោះខ្លួនជាអ្នកមានឧបនិស្ស័យសំបូរណ៍ មិនយូរប៉ុន្មានក៏ ជាក់ច្បាស់នូវ**បច្ចេក ពោធិញ្ញាណ** ល្បីល្បាញក្នុង**ក្រុងពារាណសី**ទាំងមូល ដូចជាព្រះចន្ទ ពេញវង់ក្នុងផ្ទៃពពក ជាអ្នកដល់ព្រមដោយ**លាភ** និង**យស** ។ មិនយូរ ប៉ុន្មាន **សុសិមបច្ចេកពុទ្ធ**នោះក៏**បរិនិព្វាន**ទៅ ព្រោះភាវៈនៃកម្មដែល ប្រព្រឹត្តទៅដើម្បីភាពជាអ្នកមានអាយុតិចដែលលោកធ្វើហើយ ។

គ្រានោះ **ព្រះបច្ចេកពុទ្ធ**ទាំងឡាយ និង**មហាជន** (ជួយគ្នា) **ធ្វើសរីរកិច្ច**របស់លោកហើយកាន់យកធាតុទៅ តម្កល់ក្នុង**ព្រះស្តូប** ដែលនៅជិតទ្វារ**ព្រះនគរ** ។

ចំណែក**សង្ខព្រាហ្មណ៍** គិតថា "បុត្ររបស់យើងទៅ សិក្សាអស់កាលយូរហើយ, យើងនឹងដឹងនូវសុខទុក្ខរបស់ គេ" ប្រាថ្នានឹងឃើញ

បុត្រនោះ ទើបចេញចាកក្រុង**តក្កសិលា** ទៅដល់ក្រុង**ពារាណសី** ដោយលំដាប់ ឃើញពួកមហាជន ដែលប្រជុំគ្នាហើយ គិតថា "បណ្តាមហាជនទាំងនោះ ប្រាកដជាមានម្នាក់ដឹងនូវការប្រព្រឹត្តទៅនៃបុត្ររបស់យើងដោយពិត" ។ ក៏ចូលទៅរកហើយសួរថា "មាណព ឈ្មោះ**សុសិម:** មកកាន់ទីនេះ, អ្នកទាំងឡាយស្គាល់គេទេ?" មហាជនតបថា "អើ ព្រាហ្មណ៍ យើងទាំងឡាយស្គាល់, **សុសិមមាណព** នោះស្វាធ្យាយ**ត្រៃវេទ** ក្នុងសម្នាក់ព្រាហ្មណ៍ឯណោះ បួសហើយធ្វើឱ្យ ជាក់ច្បាស់នូវ**បច្ចេកពោធិបញ្ញា** បរិនិព្វានហើយ, នេះស្តូបរបស់លោក ដែលយើងទាំងឡាយ បានចាត់ចែងប្រតិស្ឋានហើយ" ។

សង្ខព្រាហ្មណ៍នោះ ប្រហាផែនដីដោយដៃ យំកន្ទក់កន្ទេញហើយទៅកាន់លានព្រះចេតិយ**ដកស្មៅ** ហើយយកសំពត់ដណ្តប់នាំខ្សាច់មកពោយរាយឰដ៏លាន**ព្រះចេតិយ** ប្រស់ព្រំដោយ**ទឹកក្នុងឃ្នោក** បូជា ព្រះចេតិយដោយ**ផ្កាឈើព្រៃទាំងឡាយ លើកទង់ផ្ទាំងសំពត់**ដោយ សំពត់សាដក **ចងឆត្រ**របស់ខ្លួនខាងលើ**ព្រះចេតិយ**ហើយក៏ចៀសចេញ ទៅ ។

**[អានិសង្សនៃការបរិច្ចាគសុខល្មមប្រមាណ]**

**ព្រះសាស្តា** លុះទ្រង់នាំអតីតនិទាននោះមកហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះតថាគតជា **សង្ខព្រាហ្មណ៍**, តថាគតបានដកស្មៅក្នុងលាន**ព្រះចេតិយ** របស់ព្រះបច្ចេកពុទ្ធឈ្មោះ**សុសិម:**, ដោយផលនៃកម្មរបស់ គថាគតនោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឱ្យប្រាសចាកដង្គត់ និងបន្ទា ធ្វើឱ្យស្អាត ឱ្យមានផ្ទៃរាបស្មើ, តថាគតបាន**ពោយខ្សាច់**ដាក់ក្នុងលានព្រះចេតិយនោះ, ដោយផលនៃ

*កម្មនោះ ទើបជនទាំងឡាយ**ពោយខ្សាច់**ក្នុងផ្លូវ ៨យោជន៍, តថាគតបូជាព្រះចេតិយនោះដោយ**ផ្កាឈើព្រៃ**, ដោយផលនៃកម្មនោះ ទើបជនទាំងឡាយបាចផ្កា មានពណ៌ផ្សេងៗ ក្នុង៨យោជន៍, ទើបទឹកក្នុង**ទន្លេគង្គា**ដែលមាន ប្រមាណ មួយយោជន៍ដេរដាសដោយផ្កាឈូក ៥ ពណ៌, តថាគតបាន ប្រស់ព្រំលានព្រះចេតិយនោះ ដោយទឹកក្នុង**ឃ្លោក**, ដោយផលនៃកម្មនោះ ទើបភ្លៀង**បោក្ខរព័ស្ស**ធ្លាក់ចុះក្នុង**ក្រុងវេសាលី**, តថាគតបានលើក ទង់ផ្ទាំងសំពត់ឡើង និងចងឆត្រលើព្រះចេតិយ នោះ, ដោយផលនៃកម្មនោះ ទើបផ្ទៃចក្រវាឡទាំងមូល ហាក់ដូចជាមានមហោស្រពតែមួយ ដោយទង់ជ័យទង់ផ្ទាំងសំពត់ និងឆត្រតួតជាដើមរហូតដល់**អកនិដ្ឋព្រហ្ម**, ម្នាលភិក្ខុទាំងឡាយគ្រឿងបូជា និង សក្ការៈនោះកើតឡើងដល់តថាគត ដោយ**ពុទ្ធានុភាព**ក៏ទេ, កើតឡើង ដោយអានុភាព នៃ**នាគទេវតា** និង **ព្រហ្ម**ក៏ទេ ប៉ុន្តែកើតឡើងដោយ អានុភាពនៃការ**បរិច្ចាគ**មានប្រមាណតិច ក្នុងអតីតកាលដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ ទើបត្រាស់ ព្រះគាថា នេះថា :*

***មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ***
***ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។***

*បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់*
*សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញ*
*សុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។*

### *អធិប្បាយគាថា*

*បណ្តាបទទាំងនោះ បទថា **មត្តាសុខបរិច្ចាគា** សេចក្តីថា ព្រោះ*

*លះបង់សុខតិចតួចល្មមប្រមាណ ដែលព្រះមានព្រះភាគត្រាស់ថា "**មត្តាសុខំ**" ។ សុខដ៏ទូលាយ បានដល់សុខក្នុង**ព្រះនិព្វាន** ព្រះមាន ព្រះភាគត្រាស់ថា សុខដ៏ទូលាយសេចក្តីថា បើបុគ្គលឃើញសុខដ៏ ទូលាយនោះ ។*

*លោកអធិប្បាយទុកដូច្នេះថា " ឈ្មោះថា សុខល្មមប្រមាណ រមែងកើតឡើងដល់បុគ្គល អ្នកប្រើគេឱ្យចាត់ចែង ថាសភោជនមួយ ថាសហើយបរិភោគ, ចំណែក**និព្វានសុខ** ជាសុខដ៏ទូលាយ គឺដ៏ ក្រៃលែងរមែងកើតឡើងដល់បុគ្គល អ្នកលះបង់សុខល្មមប្រមាណនោះចេញហើយ **ធ្វើឧបោសថខ្វះ ឱ្យទានខ្វះ**, ព្រោះហេតុនោះ បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះបង់សុខល្មមប្រមាណនោះ យ៉ាងនោះ, កាលបើដូច្នោះ បណ្ឌិតកាលឃើញសុខដ៏ទូលាយនោះដោយប្រពៃហើយ គប្បីលះបង់សុខល្មមប្រមាណនោះ ។*

*ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេច**អរិយផល**ទាំងឡាយ មាន**សោតាបត្តិផល**ជាដើម ៕*

***(រឿងបុព្វកម្មរបស់ព្រះអង្គ ចប់ )***

*(អដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ នៃព្រះសុត្តន្តបិដកលេខ៥២ ភាគ៣ ទំព័រ ៣៥៣-៣៧៨ )*

## ២៣.រឿងនាងសេសវតី

(បាក វិ.ខុ.)

***(លទ្ធផលនៃការបូជាព្រះសារីរិកធាតុ)***

*ក្នុងសាសនា**ព្រះសម្ពុទ្ធកស្សបៈ** ព្រះអង្គបរិនិព្វានទៅហើយ, ពួក*

មហាជនទាំងឡាយ បាននាំគ្នាយកមាសទៅកសាងចេតិយកម្ពស់ មួយយោជន៍ ដើម្បីបញ្ចុះព្រះសារីរិកធាតុ ។ កាលនោះមានឧបាសិកា ម្នាក់បាននាំនាងទារិកាជាកូនរបស់ខ្លួនទៅមើលជាងទងដែលកំពុង រំលាយមាសធ្វើឥដ្ឋ ។ នាងទារិកាឃើញជាងកំពុងរំលាយមាស ក៏សួរទៅ មាតាថា បពិត្រអ្នកម្តាយ គេរំលាយមាសធ្វើអ្វី? មាតាប្រាប់ថា គេធ្វើ ចេតិយបញ្ចុះសារីរិកធាតុព្រះសម្ពុទ្ធ ។ នាងទារិកា បានឮដូច្នោះ ក៏មាន ចិត្តជ្រះថ្លាចំពោះព្រះសម្ពុទ្ធ ទើបប្រាប់ម្តាយថា ខ្សែមាសពាក់នូវករបស់ ខ្ញុំនេះ ខ្ញុំយកទៅចូលធ្វើចេតិយនឹងគេ, មាតាឆ្លើយថាល្អហើយកូនស្រី ម្តាយ ក៏យកខ្សែមាសនោះ ទៅចូលធ្វើចេតិយនឹងគេទៅ ។

សង្ខេបសេចក្តីតែប៉ុណ្ណោះ លុះដល់នាងក្ស័យជីវិតទៅ បានទៅកើតក្នុងសុគតិភព ជាអនុលោមបដិលោម អស់មួយ**ពុទ្ធន្តរ**[១] ដល់មកសាសនាព្រះសម្ពុទ្ធបរមគ្រូរបស់យើងនេះ បានមកកើតក្នុងស្រុក **នាឡន្ទគ្រាម** មានឈ្មោះថា**សេសវតី** កាលនាងមានអាយុ ១៥ឆ្នាំ មាតាបានប្រើឱ្យទៅទិញប្រេងឯផ្សារ ។ ក្នុង**ស្រុកនាឡន្ទគ្រាម**នោះ មានគហបតីម្នាក់ធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះទ្រព្យសម្បត្តិមាសប្រាក់កែវទាំង ៧ ប្រការដែលមាតាបិតាចែកឱ្យទាំងប៉ុន្មាន ដល់មាតាបិតាស្លាប់ទៅ របស់ទាំងនោះ ក៏ក្លាយទៅជា**ថ្មនោសិលា**អស់ឥតសល់ ។ អតីតគហបតី បានយក**ថ្មនោសិលា**នោះ ទៅដាក់លក់ក្នុងពានផ្សារផ្សងរកអ្នកមានបុណ្យដោយមានគំនិតថា បើអ្នកមានបុណ្យដើរមកឃើញ របស់ទាំងនេះនឹងក្លាយទៅជាមាសប្រាក់ជាកែវ ៧ ប្រការដូចដើមវិញ ពុំខាន ។ កាលនោះ **នាងសេសវតី** កាន់ដបប្រេងដើរ ចូលទៅផ្សារ បានចាក់គរសុទ្ធតែមាស

(១).**ពុទ្ធន្តរ** ន. កាល ឬសម័យជាចន្លោះនៃព្រះពុទ្ធ គឺរវាងពីព្រះពុទ្ធមួយព្រះអង្គទៅមួយព្រះអង្គ ទៀត។ *(សទ្ទានុក្រមព្រះពុទ្ធសាសនា)*

ប្រាក់នឹងកែវទាំង ៧ ប្រការ នាងក៏ចូលទៅមើល ហើយសួរទៅម្ចាស់ពាន ថា បពិត្រអ្នកដ៏ចម្រើន ហេតុអ្វីក៏យកមាសប្រាក់កែវមកចាក់គរលើពានដូច្នេះ របស់ទាំងនេះគេតែងទុកដាក់លាក់បំពួនក្នុងហឹបក្នុងឃ្លាំង ។ អ្នកម្ចាស់ពានឮដូច្នោះហើយ ត្រេកអរណាស់ ទើបសួរទៅ**នាងសេសវតី**ថា នាងនៅទីណា? ជា កូនចៅអ្នកណា ? នាងប្រាប់ថាខ្ញុំជាកូនអ្នកស្រែ នៅក្នុងស្រុកនេះឯង, អ្នកម្ចាស់ពាន ក៏កើបមាសប្រាក់ច្រកក្នុងបាវ ហើយនាំ**នាងសេសវតី**ទៅផ្ទះរបស់ខ្លួន បាននិយាយប្រាប់នាងថា កាលពីដើម ខ្ញុំជាគហបតីមួយ នៅក្នុងស្រុកនេះ ឥឡូវធ្លាក់ខ្លួនទៅជាអ្នកក្រ ព្រោះមាសប្រាក់កែវទាំងប៉ុន្មាន ក្លាយទៅជា**ថ្មនោសិលា**អស់ បានជាខ្ញុំយកថ្មនោះ ទៅដាក់នៅពានផ្សារ ដើម្បីផ្សងរកអ្នកមានបុណ្យ, ឥឡូវទ្រព្យទាំងអស់នេះ ជាទ្រព្យរបស់នាងហើយ ព្រោះនាងជាអ្នកមានបុណ្យ ។ **គហបតី**បាននាំ**នាងសេសវតី** ទៅចាក់ឃ្លាំងមើលទៀត គ្រាន់តែនាងចូលទៅដល់របស់ក្នុងឃ្លាំងទាំងប៉ុន្មាន ក៏ក្លាយទៅជាមាសប្រាក់កែវដូចដើមវិញទាំងអស់ ។ **គហបតី**នោះ ក៏ជូន**នាងសេសវតី**ទៅផ្ទះ និយាយប្រាប់ឪពុកម្ដាយនាងដោយសព្វគ្រប់ ទើបដណ្ដឹងនាងឱ្យជាភរិយាកូនកំលោះរបស់ខ្លួន, លុះរៀបអាពាហ៍ពិពាហ៍ហើយ **មាតាបិតាក្មេក** បាននាំ**នាងសេសវតី** ទៅនៅក្នុងសម្នាក់របស់ខ្លួន។ ក្នុងកាលជាខាងក្រោយមក **ព្រះសារីបុត្តត្ថេរ** ជាធម្មសេនាបតីបាន រំពឹងមើលអាយុសង្ខាររបស់លោក ឃើញថាអស់ហើយ ក៏ចូលទៅថ្វាយបង្គំលព្រះសម្ពុទ្ធ សុំទៅបរិនិព្វាន ឯស្រុក**នាឡន្ទគ្រាម** ដើម្បីប្រោស**មាតាបិតា**ដែលជាជន**មិច្ឆាទិដ្ឋិ**, លុះ ទូន្មានមាតាបិតាហើយ ក៏បរិនិព្វានក្នុងបន្ទប់ ដែលលោកប្រសូតនោះ ទៅ។ កន្លងមក

បាន ៧ថ្ងៃ ពួកពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើជើងថ្កល់ កម្ពស់ មួយរយហត្ថ ដើម្បីបូជាសពរបស់លោក ។ កាលនោះ **នាងសេសវតី** មានគភ៌ជិតគ្រប់ខែហើយ បានឮថាពុទ្ធបរិស័ទទាំងឡាយ នាំគ្នាធ្វើបុណ្យរំលាយសព **ព្រះសារីបុត្ត** ក៏សុំលាមាតាបិតាក្មេក យក មាសប្រាក់កែវក្រវិលផ្កាទៅបូជាសព**ព្រះសារីបុត្ត** ។ មាតាបិតាឃាត់ថា នាងទៅពុំកើតទេ ព្រោះគភ៌ចាស់គ្រប់ខែហើយ។ **នាងសេសវតី** ជាស្ត្រីមានសេចក្តីជ្រះថ្លាខ្លាំងទ្រាំមិនបាន ក៏លាមាតាបិតា នាំបរិវារកាន់ មាសប្រាក់កែវក្រវិលផ្កា ដើរសំដៅទៅកន្លែងតម្កល់សព**ព្រះសារីបុត្ត** ។ ក្នុងពេលនោះមានមនុស្សច្រើនណែនណាន់ចង្អៀតជាទីបំផុត ប៉ុន្តែ នាង**សេសវតី**ជាស្ត្រីស្តុកស្តម្ភដោយភោគសម្បត្តិ, ពួកមហាជនបាន ឃើញហើយ ក៏បើកឱកាសឱ្យចូលទៅជិតសព, នាងយកមាសប្រាក់ កែវក្រវិលផ្កា ទៅចាក់គរក្បែរគ្គារមឈូស ហើយថយមកអង្គុយប្រណម្យ អញ្ជលី នមស្ការ ។

ក្នុងពេលនោះ ចំហាយរបស់មនុស្សដែល កកកុញនោះក៏ បណ្តាលឱ្យ**នាងសេសវតី** ទៅជាខ្យល់ចាប់ សន្ធប់នៅទីនោះ ។ ឯដំរីរបស់ពួក**ឥស្សរជន**ទាំងឡាយ ដែលជិះទៅក្នុងទីនោះ ក៏ផ្អើលស្ទុះស្រែកជាខ្លាំង ពួកមហាជនភ័យនឹងដំរី ស្ទុះរត់ច្រួលច្របល់ទៅជាន់ **នាងសេសវតី**នោះស្លាប់ទៅ, នាងបានទៅកើតក្នុងស្ថាន **ត្រៃត្រឹង្ស ទេវលោក**ស្ថិតនៅក្នុងវិមានប្រាសាទមាស រំលេចដោយកែវ ៧ ប្រការ មានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ។ ថ្ងៃមួយនាង**សេសវតី ទេពធីតា** បានរលឹកឃើញបុព្វកម្មរបស់នាង ក៏ចុះមកទាំងវិមាន មកថ្វាយបង្គំព្រះសម្ពុទ្ធក្នុង**វត្តជេតពន** ។ កាលនោះ**ព្រះវង្គិស្សត្ថេរ** លោកកំពុងអង្គុយគាល់ព្រះមាន

ព្រះភាគ បានឃើញនាងទេពធីតានោះ ក៏សួរបុព្វកម្មរបស់នាង បានប្រាប់ដោយសព្វគ្រប់ ។ ព្រះសម្ពុទ្ធទ្រង់ ប្រារព្ធហេតុនោះហើយក៏សម្តែងនូវធម្មទេសនា សរសើរអានិសង្សនៃ ការបូជា**ព្រះសារីរិកធាតុ** ជាភិយ្យោភាពតទៅ ៕

*(ប្រជុំរឿងនិទានជាតកភាគ១ នាងសេសវតី ទំព័រ ៦២-៦៦)*

## ២៤.រឿងនាគទេវបុត្រ

(បាក វិ.ខុ.)

**(គុណនៃការបូជាផ្កាឈើ ដល់ព្រះចេតិយ)**

កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅ**វត្តជេតពន**, កាលនោះ**ព្រះមោគ្គល្លាន** ចូលទៅថ្វាយបង្គំលាព្រះសម្ពុទ្ធ និមន្តទៅ**ទេវលោក** ដើម្បីពិនិត្យមើលទិព្វសម្បត្តិរបស់ពួកទេវតាក្នុង**ឆកាមាសួគ៌**, ព្រះសម្ពុទ្ធក៏ទ្រង់អនុញ្ញាតឱ្យទៅៗ ដល់ស្ថាន**តាវតឹង្ស**បានឃើញទេវបុត្រមួយរូប **ជិះដំរីមាឌធំ**សំបើមអស្ចារ្យ មានអវយវៈទាំងអស់សសុទ្ធ, ដំរីនោះមាន ភ្លុកពីរវែងក្នុងភ្លុកមួយៗ មាន**ស្រះបោក្ខរណី**មួយៗ, ក្នុងស្រះមួយៗ មានផ្កាឈូក៧, ក្នុងផ្កាឈូកមួយៗ មានស្រីទេពអប្សរមួយៗ, ច្រៀងរាំ ប្រគំដេញដំតូរ្យតន្ត្រីថ្វាយដល់ទេវបុត្រនោះ ។ **ព្រះមោគ្គល្លាន**បាននិមន្ត ទៅឈរពីមុខដំរីនោះ, ទេវបុត្របានឃើញហើយ ក៏ចុះទៅថ្វាយបង្គំ ដោយគោរព លុះថ្វាយបង្គំរួច **ព្រះមោគ្គល្លាន**មានថេរដីកាសួរអំពី ឈ្មោះ និងប្រវត្តិរបស់ទេវបុត្រនោះៗ បានទូលតបថេរដីកាថា ខ្ញុំព្រះ ករុណាឈ្មោះ**នាគទេវបុត្រ** កាលសាសនាព្រះសម្ពុទ្ធទ្រង់ព្រះនាម **កស្សប**ព្រះអង្គបរិ

និព្វានហើយ, កាលនោះពួកមហាជន នាំគ្នាដង្ហែព្រះ សារីរិកធាតុទៅបញ្ចុះក្នុង**ចេតិយមាស**កម្ពស់មួយយោជន៍ ហើយនាំគ្នា យកផ្កាភ្ញីទៅបូជា**ព្រះចេតិយ** ។ ក្នុងសម័យនោះខ្ញុំព្រះករុណា កើតជា ឧបាសកមួយរូបមានសទ្ធាជឿជាក់ក្នុងគុណ**ព្រះរតនត្រ័យ** បានយកលុយ **៨ កហាបណៈ** ទៅទិញផ្កាអំពីនាយ**មាលាការ**ម្នាក់ ។ ពេលនោះផ្កា ក្រជាទីបំផុតក្នុងសួនរបស់នាយមាលាការ នោះរកផ្កាមួយទងគ្មានឡើយ ព្រោះមហាជននាំគ្នាទិញយកទៅបូជាព្រះចេតិយគ្រប់ៗ គ្នា ។ នាយមាន ការបានប្រាប់ខ្ញុំព្រះករុណាថា ផ្កាគ្មានទេ បើអ្នកត្រូវការខានមិនបាន អញ្ជើញរកមើលបេះខ្លួនឯងចុះ ។

ខ្ញុំព្រះករុណាក៏បានចូលទៅក្នុងសួន ខំរកមើលតាំងពីដើមសួនរហូតដល់ចុងសួនឃើញផ្កា **៨ទង**ជ្រុះនៅក្បែរគល់ ក៏រើសយកទៅបង្ហាញនាយ **មាលាការ**បានឱ្យថ្លៃ **៨កហាបណៈ** នាយ**មាលាការ**មិនព្រមយក បែរជានិយាយថា ផ្កានេះជាលាភរបស់អ្នកហើយ អ្នកអញ្ជើញយកចុះ, ខ្ញុំព្រះករុណា ក៏យកទៅបូជា**ព្រះចេតិយ**នោះទៅ ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំព្រះករុណា ធ្វើមរណកាល ក៏បានមកកើត ក្នុងទីនេះតែម្តង ។ **ព្រះមោគ្គល្លាន**បាន ជ្រាបដំណឹងនោះហើយ និមន្តហួសទៅទីដទៃទៀតទៅ ។\

*(ប្រជុំរឿងនិទានជាតកភាគ១ នាគទេវបុត្រ ទំព័រ ១១០-១១២)*

## ២៥.រឿងអាយលម្ពាយចាប់ពស់

*(ចាក ម.វា.)*

*(គុណនៃព្រះរតនត្រ័យ ជាឱសថវិសេសផុតក្នុងលោក)*

*កាលសាសនាព្រះសម្ពុទ្ធ**ព្រះនាមកស្សប** ព្រះអង្គបរិនិព្វានហើយ កាលនោះពួកពុទ្ធបរិស័ទនាំគ្នាសាង**ព្រះចេតិយមាស**វិចិត្រដោយកែវ ៧ ប្រការកម្ពស់ ១យោជន៍, មនុស្សទាំងឡាយក្នុងសម័យនោះច្រើនជា**សម្មាទិដ្ឋិ**តែងសូត្រធម៌រំឭកគុណព្រះរតនត្រ័យថា: **នមោ ពុទ្ធាយ នមោ ធម្មាយ នមោ សង្ឃាយ** ដូច្នេះគ្រប់ៗ គ្នា ។*

*កាលនោះមានព្រាហ្មណ៍ម្នាក់ឈ្មោះ**អាយលម្ពាយ**ចាប់ពស់ ជាមនុស្ស**មិច្ឆាទិដ្ឋិ**មិនជ្រះថ្លាក្នុងគុណ**ព្រះរតនត្រ័យ** ត្រេកអរតែក្នុងការចាប់ពស់ លុះចាប់បានហើយយកមកបង្រៀនឱ្យលេងល្បែងផ្សេងៗ ដួលឱ្យអ្នកនគរមើលយកថ្លៃឈ្នួលចិញ្ចឹមជីវិត ។ ថ្ងៃមួយ**អាយលម្ពាយ**ឮពួក ពុទ្ធបរិស័ទ នាំគ្នាសូត្រថា: **នមោ ពុទ្ធាយ** ដូច្នេះ ក៏សើចចំអកធ្វើ ត្រាប់តាមហើយដើរទៅរកចាប់ពស់ក្បែរដំបូកមួយ ។*

*គ្រានោះមាន**នាគរាជ**មួយមានឫទ្ធិច្រើនជ្រះថ្លាក្នុងគុណ**ព្រះរតនត្រ័យ** បានទៅបូជាគោរពព្រះចេតិយដែលបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធ **ព្រះនាមកស្សប**, គោរពបូជាព្រះចេតិយហើយលូនត្រឡប់មកវិញ ក៏ជួបនឹង**អាយលម្ពាយ**ៗ ឃើញ**នាគរាជ**នោះស្ទុះចូលទៅជិតហើយ**រាយមន្ត**ដើម្បីនឹងចាប់ ។ **នាគរាជ**ឮមន្តនោះហើយក៏កើត**ទោសៈ**ក្រេវក្រោធស្ទុះដេញ**អាយលម្ពាយ**នោះវិញបំណងនឹង ចឹកសម្លាប់ ។ **អាយលម្ពាយ***

*ដឹងថា**នាគរាជ**មិនស្តាប់បន្ទូខ្លួនហើយ ក៏កិតភ័យជាខ្លាំងប្រឹងស្ទុះរត់ចេញដោយ រហ័សមិនបានឈ្ងោកមើល ក្រោម ក៏ទង្គិចជើងនឹងដុំថ្មដួលភ្ញាត់មាត់ថា: **នមោ ពុទ្ធាយៗ** ព្រោះធ្លាប់ មាត់កាលធ្វើត្រាប់អ្នកនគរ ។*

*ឯ**នាគរាជ**គ្រាន់តែឮថា **នមោ ពុទ្ធាយ** ដូច្នេះក៏រលត់បាត់នូវសេចក្តីក្រោធមួយរំពេច ហាក់ដូចដុំភ្លើងធ្លាក់ចុះទៅក្នុងទឹក ទើបនិយាយទៅរក**អាយលម្ពាយ**ថា ម្នាលសម្លាញ់អ្នកកុំកិតភ័យអ្វីឡើយ យើងមាន សេចក្តីជ្រះថ្លាចំពោះអ្នកក្រៃពេក សូមអ្នកទទួលយកគ្រឿងបណ្ណាការ នេះចុះ ។ **នាគរាជ**ក៏ខ្ជាក់ផ្កាមាស ៣ដុំ ពីក្នុងមាត់ឱ្យដល់**អាយលម្ពាយ** ហើយប្រាប់ថា ផ្កាមាសនេះ ១ដុំតម្លៃ មួយពាន់ កហាបណ: អ្នកយក ១ដុំ ទៅបូជាព្រះចេតិយកបុណ្យរបស់អ្នកចុះ ១ដុំ យកទៅបូជាព្រះចេតិយឱ្យខ្ញុំ ១ដុំទៀតអ្នកយកទៅលក់យកលុយ ចិញ្ចឹមជីវិតចុះ ។ **អោយលម្ពាយ** ក៏មានសេចក្តីជ្រះថ្លាចំពោះគុណព្រះរតនត្រ័យយ៉ាងមុតមាំ បានថ្វាយខ្លួនជា**ឧបាសក**តាំងពីពេលនោះមក លុះស្លាប់ទៅបានទៅកើតក្នុងស្ថានសួគ៌បរិបូណ៌ដោយទិព្វសម្បត្តិជាសុខ ក្សេមក្សាន្តអស់កាលជាយូរអង្វែង ៕*

*(ប្រជុំរឿងនិទានជាតកភាគ២ អាយលម្ពាយចាប់ពស់ ទំព័រ ១៩-២១)*

## ២៦.រឿងនាងភាញ្ញានទេវី

(ចាក ម.វា.)

### (*គុណនៃការបូជាបាត្រព្រះសម្ពុទ្ធ និងអានិសង្សស្តាប់ទេសនា*)

*កាលព្រះសម្ពុទ្ធបរមគ្រូបរិនិព្វានហើយពួកពុទ្ធបរិស័ទទាំងឡាយក្នុង**ទេវបុត្តនគរ**នាំគ្នាយកបាត្រព្រះសម្ពុទ្ធទៅបញ្ចុះក្នុង**ចេតិយកែវ** មុន*

បញ្ចុះក្នុងចេតិយនោះ ព្រះរាជាបានចាត់ចែងធ្វើក្បួនហែយ៉ាងអស្ចារ្យ គឺឱ្យរាជបុរសហៅជាងទងជាច្រើនរូបមក ឱ្យយកដើមឬស្សី ១ដើម យ៉ាងធំមករចនាស្រោបមាសរំលេចដោយ**កែវ ៧ ប្រការ** យកបាត្រដាក់ ភ្ជាប់លើចុងឫស្សីហើយលើកឡើងដម្កល់លើ**រាជរថមាស**ហែប្រទក្សិណទីក្រុងបីជុំ ទើបនាំចូលទៅបញ្ចុះក្នុង**ចេតិយកែវ** ប្រជុំគ្នាធ្វើបុណ្យ សម្ពោធ ឆ្លងអស់វារ ៧ ថ្ងៃ មានធម្មកថិក សម្តែងធម៌ទេសនារាល់រាត្រី ។ ពួក**មនុស្សនឹងទេវតា នាគគ្រុឌ**ជាច្រើន បាននាំគ្នាមកស្តាប់ធម្មទេសនា ។ កាលនោះមាន**នាគរាជ** មួយមាន ឫទ្ធិអស្ចារ្យបានមកស្តាប់ធម៌ដែរ បានឃើញនារីម្នាក់មានរូបល្អប្រិមប្រិយ ជាស្រីមានសទ្ធាមាំក្នុងព្រះ ពុទ្ធសាសនា ។

**នាគរាជ**មានសេចក្តីស្នេហានិម្មិតជាមាណព ទៅនិយាយលួងលោមនាង យកនាងជាភរិយា នាងមិនព្រម ក៏មានសេចក្តីក្រោធខឹងនិម្មិតខ្លួនជា**ពស់នាគ**យ៉ាងធំរុំព័ទ្ធនាងនោះជិតតាំងពីបាតជើងទៅ ហើយបើកពពារគ្របពីលើ បំណងឱ្យនាងស្លាប់ ប៉ុន្តែនាងតាំងចិត្តមាំក្នុងការគោរព**ព្រះចេតិយ និងព្រះធម៌ទេសនា**តែម្យ៉ាង ឥតរំភើបញាប់ញ័រអ្វីឡើយ មិនយូរប៉ុន្មាន**នាគរាជ**ក្តៅក្រហាយ រលាក្អែនស្ទុះចេញឆ្ងាយអំពីនាង នឹកស្ញើចអស្ចារ្យ កើតសេចក្តីជ្រះថ្លា ចំពោះនាង ទើប**និម្មិតខ្លួនមានពពារ ១រយ** ឱ្យនាងអង្គុយពីលើក្នុងទីកណ្តាលហ្វូង **ពុទ្ធបរិស័ទ** ហើយបូជាដោយកហាបណៈជាច្រើនពាន់ ។ ចំណែកពុទ្ធបរិស័ទទាំងឡាយឃើញហេតុអស្ចារ្យដូច្នោះហើយ កើតសេចក្តីជ្រះថ្លា នាំគ្នាយកកហាបណៈទៅបូជានាងរួមទាំងអស់ ១៨កោដិ ។ នាងបាន សម្បត្តិច្រើនដូច្នេះហើយ ខំធ្វើ**ទានសីល**ដរាបដល់អស់អាយុ ក៏ទៅចាប់ កំណើត

កើតក្នុងផ្ទៃព្រះអគ្គមហេសីនៃព្រះមហាក្សត្រក្នុង**ទេវបុត្តនគរ**នោះឯង ដល់ពេលដែលប្រសូតមានហេតុអស្ចារ្យ **ភ្លៀងកែវ ៧ ប្រការ** ធ្លាក់ចុះមកពេញ**ទេវបុត្តនគរ**ទាំងមូល ទើបព្រះបរមរាជវង្សានុវង្សថ្វាយ ព្រះនាមថា: **កាញ្ចនទេវី** ។

រីឯខាង**កាញ្ចនទេវី**នេះ មានរូបល្អស្រស់ដូចជារូប**ស្រីទេពអប្សរ** មានពន្លឺផ្សាយចេញពីកាយប្រវែង**មួយហត្ថជានិច្ច** ដោយអានិសង្ស ដែលនាងបាន**បូជាបាត្រ**ព្រះសម្ពុទ្ធ និងអានិសង្ស**ស្តាប់ធម៌ទេសនា** ។ ស្តេចក្នុង**ជម្ពូទ្វីប**ទាំងមូលនាំគ្នាបញ្ជូនគ្រឿងបណ្ណាការមកថ្វាយព្រះរាជបិតា ដើម្បីដណ្តឹងនាង។ មិនព្រមយក ព្រោះជាស្ត្រីមាននិស្ស័យខ្ពស់ នាងសូមអង្វរព្រះរាជបិតា សូមចេញចាកព្រះរាជនិវេសន៍**ទៅបួស**ក្នុងសម្នាក់**ភិក្ខុនី** ព្រះរាជបិតាទ្រង់ព្រះរាជាអនុញ្ញាតតាមសូម ទើបដង្ហែនាងចេញពីព្រះរាជនិវេសន៍ យ៉ាងមហោឡារិកអស្ចារ្យទៅ**បួសជាភិក្ខុនី** មិនយូរប៉ុន្មាននាងបានសម្រេច**អរហត្តផល** ព្រមទាំង**បដិសម្ភិទា**(១) មាន នាមប្រាកដថា **កាញ្ចថេរី** ដល់អស់អាយុក៏បរិនិព្វានទៅ ៕

(ប្រជុំរឿងនិទានជាតកភាគ២ នាងកាញ្ចទេវី ទំព័រ ៤៧-៤៩)

---

(១).**បដិសម្ភិទា** ន. ការបែកប្រាជ្ញាយល់ច្បាស់, ប្រាជ្ញាដែលបែកអាចយល់ធ្លុះធ្លាយឥតទើសទាក់, ប្រាជ្ញាដែលក្លៀវក្លាអាចពិចារណាយល់ជាក់ប្រាកដភ្លាមៗនូវហេតុផលនៃកិច្ចការទាំងពួង។ បដិសម្ភិទាមាន៤យ៉ាងគឺ

១- អត្ថប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយ ក្នុងអត្ថ(សេចក្តី) និងព្យញ្ជនៈ ។

២- ធម្មប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងធម៌ ។

៣- និរុត្តិប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងនិរុត្តិ ។

៤- បដិភាណប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយ នៅក្នុងបដិភាណ...។

សទ្ទានុក្រមព្រះពុទ្ធសាសនា

## ២៧.រឿងឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ

*(បាក ម.វា.)*

*(គុណព្រះសម្ពុទ្ធតែងញ៉ាំងបំណងអ្នកមានសទ្ធាមាំឱ្យសម្រេច)*

*កាលព្រះសម្ពុទ្ធបរិនិព្វានហើយមានព្រះខីណាស្រព ១ ព្រះអង្គបានយក**ឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ**ដាក់ក្នុងយាមនិមន្តទៅកាន់ជនបទ មួយ ស្ថិតនៅខាងត្បូងនៃមហាពោធិព្រឹក្ស ។ ក្នុងជនបទជាសម្មាទិដ្ឋិ ទាំងឡាយ បានឃើញព្រះខីណាស្រពយក**ឈើទ្រនាប់ព្រះបាទសម្ពុទ្ធ** ទៅក្នុងស្រុករបស់ខ្លួនហើយ មានសទ្ធាជ្រះថ្លាចំពោះគុណព្រះសម្ពុទ្ធ ដ៏ក្រៃលែង បាននាំគ្នាជញ្ជូនដីខ្សាច់យ៉ាងស្អួតល្អមកធ្វើជា**ស្តូបចេតិយ** បញ្ចុះ**ឈើទ្រនាប់ព្រះបាទនោះ** ហើយនាំគ្នាគោរពបូជាធ្វើសក្ការៈរាល់ៗ ថ្ងៃ ។ ឯជន**មិច្ឆាទិដ្ឋិ**ទាំងឡាយ នាំគ្នាគោរពបូជាធ្វើសក្ការៈចំពោះឥស្សរ ទេវតា គឺ (អារក្ស, អ្នកតា, ខ្មោច, បីសាច) មិនបានជ្រះថ្លាចំពោះគុណ ព្រះសម្ពុទ្ធឡើយ ។*

*ថ្ងៃមួយពួកជនទាំងពីរពួកនេះ បណ្តាលឱ្យកើតចលាចលយ៉ាងអស្ចារ្យ គឺជជែកភ្នាល់គ្នាអួតគុណរៀងៗ ខ្លួន, ពួកជន**សម្មាទិដ្ឋិ** អួតថាគុណព្រះសម្ពុទ្ធពូកែវិសេសអស្ចារ្យផុតក្នុងលោក ឥតមានគុណអ្វី ប្រៀបស្មើបាន, ឯជន**មិច្ឆាទិដ្ឋិ**អួតថា គុណឥស្សរទេវតា គឺ អារក្ស អ្នកតា ខ្មោច បិសាច ពូកែផុតផ្តាច់ក្នុងលោក ។*

*រឿងជជែកនេះកាន់តែធំឡើងៗ ក៏នាំភ្នាល់ថាបើគុណខាងណាពូកែផុតក្នុងលោក សូមឱ្យគុណនោះធ្វើជាបាដិហារ្យឱ្យប្រាកដដល់ភ្នែក*

មហាជនទាំងអស់ លុះព្រមក្នាល់គ្នាយ៉ាងនេះហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះមហាក្សត្ររបស់ខ្លួន, ព្រះមហាក្សត្រ ក៏កំណត់ថ្ងៃឱ្យក្នាល់គ្នា ហើយឱ្យរាជអមាត្យនាំគ្នាវាយស្គរដើរទៅក្នុងព្រះរាជអាណាចក្រទាំងមូលថា នៅ ៧ ថ្ងៃទៀតនឹងមានក្នាល់**គុណព្រះសម្ពុទ្ធ** នឹង**គុណឥស្សរទេវតា** ក្នុងព្រះរាជអាណាចក្រយ៉ាងអស្ចារ្យ ឱ្យមហាជនមកជួបជុំដើម្បីធ្វើសាក្សី ។

ឯពួកជន**សម្មាទិដ្ឋិ** នាំគ្នាជម្រះស្មៅធ្វើមណ្ឌបតុបតែង**ព្រះស្តូបចេតិយ** ដែលបញ្ចុះ**ឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធ**។ ពួកជន**មិច្ឆាទិដ្ឋិ**នាំគ្នាធ្វើខ្ទម អ្នកតា រានទេព្តា, ធ្វើស្វាធម៌បាយសីគ្រប់ទីកន្លែងដែលខ្លួនតែងទៅបន់ ស្រន់ ។

កាលបើថ្ងៃទី ៧ មកដល់ហើយ ពួកមហាជនក្នុងព្រះរាជាណាចក្រទាំងមូល នឹងពួកជនបរទេសជាច្រើនបានមកជួបជុំគ្នាក្នុង ទីក្នាល់រាប់រយលាននាក់ ។ ពួកជន**មិច្ឆាទិដ្ឋិ** ក៏រៀបតុបតែងរានទេព្តា ខ្ទមអ្នកតាបូជាដោយសាធម៌បាយសីខ្លះក៏បញ្ឆាន់អារក្ស បញ្ចូលបង់បត់ ព្ទសូរស្គរនឹង សំឡេងហ៊ោកញ្ជ្រៀវលោន់រំពង ។ ឯពួកជន**សម្មាទិដ្ឋិ** ទាំងឡាយនាំគ្នាទៅនមស្ការ**ព្រះស្តូបចេតិយ** ដែលបញ្ចុះ**ឈើទ្រនាប់ ព្រះបាទព្រះសម្ពុទ្ធ** ហើយមានបណ្ឌិតជនម្នាក់ក្រោកឈរឡើង ថ្លែង សច្ចវាចាសរសើរគុណព្រះសម្ពុទ្ធរៀបរាប់តាម**ពុទ្ធជ័យមង្គល**ដែលព្រះអង្គទ្រង់ឈ្នះសត្រូវទាំងឡាយមានឈ្នះមារាធិរាជជាដើម ហើយនាំ គ្នាអធិដ្ឋានថា "សូមឱ្យ**ឈើទ្រនាប់ព្រះបាទ**ដែលបញ្ចុះក្នុងចេតិយ ធ្វើ**បាដិហារ្យ**ឱ្យអស្ចារ្យក្នុងពេលឥឡូវនេះ ដើម្បីប្រកាសគុណព្រះសម្ពុទ្ធ ឱ្យប្រាកដដល់មហាជន

នឹងជួយសង្គ្រោះកម្ចាត់បង់នូវ**មិច្ឆាទិដ្ឋិ**របស់ជនទាំងឡាយផង ។ កាលបើបណ្ឌិតជនធ្វើសច្ចកិរិយាបួងសួងចប់ហើយ **ឈើទ្រនាប់ព្រះបាទ**ដែលបញ្ចុះក្នុង **ពាលុកចេតិយ** ក៏បញ្ចេញសំឡេង លាន់រំពងក្នុងចេតិយកម្រើកញ័រមហាប្រឹថពី មួយស្របក់ក៏បែកព្រះ ចេតិយជាពីរហើយអណ្តែតឡើងទៅប្រតិស្ឋានឰដ៏នភាល័យ បញ្ចេញ ពន្លឺរស្មី ៦ ពណ៌គួរឲ្យផ្អើតអស្ចារ្យ ។ ពួកមហាជនទាំង**សម្មាទិដ្ឋិ** និង**មិច្ឆាទិដ្ឋិ**សម្បើមព្រឺព្រួចក្នុងចិត្តដរាបដល់ទន់ជង្គង់ក្រាបចុះទៅលើផែនដីថ្វាយបង្គំនមស្ការស្រែកប្រកាសឮលាន់រំពងថាសូម ដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹកដរាបដល់អស់ជីវិត ទាំងព្រះមហាក្សត្រ ក៏បានថ្វាយព្រះអង្គជា**ឧបាសក**យកព្រះពុទ្ធជាទីពឹងទីរលឹកដរាបដល់ទីបំផុតព្រះជន្ម ។ ឯ**ឈើទ្រនាប់ព្រះបាទ**កាលបើធ្វើបាដិហារ្យហើយក៏បន្ទាបចុះទៅ ប្រតិស្ឋានក្នុង**ពាលុកចេតិយ**ដូចដើម ។ តាំងពីនោះមកពួក**មិច្ឆាទិដ្ឋិ**ជនគោរពរាប់អានជឿគុណព្រះសម្ពុទ្ធ ជាមួយនឹងពួកជន**សម្មាទិដ្ឋិ**ទាំងឡាយដរាបដល់អស់អាយុគ្រប់ៗ គ្នា ។

ពួកជនទាំងឡាយក្នុងកាលនោះ លុះអស់អាយុហើយឥតមានជនណាមួយទៅ**អបាយភូមិឡើយ** ខ្លះបានទៅកើតក្នុង**ស្ថានសួគ៌ ៦ ជាន់** ខ្លះបានកើតក្នុង**មនុស្សលោក**នេះបរិបូណ៌ដោយសេចក្តីសុខចម្រើន ។

*(ប្រជុំរឿងនិទានជាតកភាគ២ ឈើទ្រនាប់ព្រះបាទព្រះសម្ពុទ្ធទំព័រ ៦២-៦៥)*

## ២៨.រឿងគហបតិប្រេត

(ចាក បេ.ខុ)

**(*ទោសនៃការមើលងាយព្រះសារីរិកធាតុ*)**

*កាលព្រះសម្ពុទ្ធបរមគ្រូបរិនិព្វានហើយ ពួកពុទ្ធបរិស័ទទាំងឡាយមាន**ព្រះបាទមល្លរាជ**ជាប្រធាន បានរៀបបូជាព្រះបរមសពព្រះសម្ពុទ្ធលុះបូជាហើយ ព្រះមហាក្សត្រទាំងឡាយក្នុង**ជម្ពូទ្វីប** លើកទ័ពមកច្បាំងដណ្តើមព្រះបរមធាតុ, កាលនោះ**ទោណអាចារ្យ**បានសម្រុះសម្រួលចែកព្រះបរមធាតុដល់ព្រះរាជាទាំងឡាយនោះ ដោយ**សន្តិវិធី** ។ ព្រះរាជាទាំងឡាយនោះ ក៏នាំយកព្រះបរមធាតុ ទៅនគររៀងពល់ព្រះអង្គ ។ ឯព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង បានរៀបចាត់ចែងធ្វើពិធីដង្ហែយ៉ាងឧឡារិកសន្ធឹកមហិមា ចាប់តាំងពីចេញ ដំណើរពី**ក្រុងកុសិនារា**ទៅ ដរាបដល់**ក្រុងរាជគ្រឹះ** គឺតម្កល់ព្រះបរម ធាតុលើព្រះរាជរថជ័យដែលវិចិត្ររតន ៧ប្រការ, កាលបើចេញហែ បានចម្ងាយប្រវែង ១ រាជរថហើយឈប់ធ្វើបុណ្យម្តងចំនួន ៧យប់ ៧ថ្ងៃ ចេះតែធ្វើតាមលំដាប់ដូច្នេះដរាប ដល់**ក្រុងរាជគ្រឹះ**។ រួបរួមរយៈវេលា ដែលហែចេញពី**ក្រុងកុសិនារា**ទៅដល់**ក្រុងរាជគ្រឹះ**អស់ ៧ឆ្នាំ ៧ខែ ៧ថ្ងៃទើបដល់ ។*

*ពួកបរិស័ទទាំងអស់ក្នុង**ក្រុងរាជគ្រឹះ**មានសេចក្តីជ្រះថ្លា សប្បាយរីករាយយ៉ាងក្រៃលែង ។ ឯពួកជន**មិច្ឆាទិដ្ឋិ**ជាង ៨ ម៉ឺននាក់ មិនជ្រះថ្លាបែរនិយាយត្អូញត្អែរថាធ្វើបុណ្យយូរយ៉ាងនេះ គ្មានអ្នកណារកស៊ីធ្វើអ្វីកើតទេ ។ ម្យ៉ាងទៀតគ្មានប្រយោជន៍ អ្វីអំពីឆ្អឹងដែល គេដុតជាធ្យូងនោះ*

ទេ ។ ពួកជនទាំងនោះចង់**សេចក្ដីក្រោធ** ចំពោះ**ព្រះធាតុ និងព្រះមហា-កស្សត្រ**ជាដើមរាល់ពេលវេលា ។ បណ្ដាមនុស្ស **មិច្ឆាទិដ្ឋិ**ជាង ៨ ម៉ឺននោះ មាន**គហបតី**ម្នាក់មានទ្រព្យច្រើន, ជាអ្នក **មិច្ឆាទិដ្ឋិ**ចំណាប់មួយដែរ ឯភរិយាបុត្រីកូនប្រសាគាត់ជា**សម្មាទិដ្ឋិ**មានចិត្តជ្រះថ្លាទៅហៃព្រះសារីរិកធាតុ ធ្វើបុណ្យជាមួយគេឯងរាល់ពេល វេលា ទោះបីគហបតីស្ដីដេរយ៉ាងណាក៏មិនធ្វើជាដឹងឮ ។ លុះធ្វើ មរណកាល តាមលំដាប់សង្ខាររបស់ខ្លួនទៅ, គហបតីកើតជា**ប្រេត**ជាមួយពួកជន**មិច្ឆាទិដ្ឋិ**ទាំង ៨ ម៉ឺននាក់នោះ នៅចន្លោះ**ភ្នំគិជ្ឈកូដ** ។ ឯភរិយាបុត្រីបុត្រប្រសាទៅកើតជាទេវតា នៅ**ស្ថានសួគ៌** ។

ថ្ងៃមួយ **ព្រះមហាកស្សបត្ថេរ**ចេញពីនិរោធហើយពិចារណាឃើញមនុស្សស្លាប់ទៅកើតជាប្រេត នរកច្រើន ទើបលោកនិមន្តទៅឈរត្រង់ទីលានមុខព្រះចេតិយដែលបញ្ចុះព្រះបរមធាតុហើយថ្វៃឫទ្ធិ ធ្វើឱ្យ**នរក ប្រេត មនុស្ស ទេវតា**មើលគ្នាឃើញទៅវិញទៅមក ។

ឯគហបតីប្រេតនោះ ក្រឡេកមើលទៅឰដ៏អាកាសឃើញភរិយាបុត្រី កូនប្រសាខ្លួនកើតជាទេវតាសោយទិព្វសម្បត្តិដូច្នោះ នឹកក្ដៅក្រ-ហាយ នឹងវាសនារបស់ខ្លួនក៏ចូលទៅជិត**ព្រះបរមកស្សប**ហើយប្រកាស ថាឱ្យតែបានរួចពី**ប្រេតវិស័យ**ទៅកើតជាមនុស្សវិញ នឹងខំគោរពបូជា ព្រះសារីរិកធាតុគ្រប់ពេលវេលា។ មួយស្របក់ក្រោយមក**ព្រះមហា កស្សប** រំសាយឫទ្ធិលែងឱ្យឃើញ នៅដូចធម្មតាវិញ។ ពួកពុទ្ធបរិស័ទ ទាំងឡាយឃើញ ហេតុអស្ចារ្យដូច្នោះក៏ចូលទៅថ្វាយបង្គំសួរបុព្វកម្ម របស់**នរក ប្រេត** ដែលខ្លួនបានឃើញផ្សេងៗ គ្នា ។ ព្រះមហាថេរៈ ក៏ប្រារព្ធយករឿង

*ប្រេតជាង ៨ ម៉ឺននាក់មានគហបតីប្រេតមកសម្ដែង តាមដំណើរបុព្វកម្ម របស់ប្រេតទាំងនោះ ក្នុងកាលនោះឯង ។ ឯពួក ប្រេតជាង ៨ ម៉ឺននាក់ មានគហបតីជាប្រធាននៅរងទុក្ខវេទនាដរាបដល់ សព្វថ្ងៃ, ព្រោះតែការ មើលងាយព្រះសារីរិកធាតុនោះឯង ៕*

*(ប្រជុំរឿងនិទានជាតកភាគ៣ គហបតិប្រេត ទំព័រ ១-៣)*

## ២៩.រឿងព្រះបាទអជាតិសត្រូវសម្លាប់បិតា (*ទោសនៃការពាក់ ស្បែកជើងឡើងព្រះចេតិយ*) (*សង្ខេប*)

*...**ព្រះបាទអជាតិសត្រូវ**សួររាជបុរសថា បិតាអញរស់នៅដោយ អាការយ៉ាងណា ? ក្រាបទូលតម្កល់លើត្បូងរស់នៅដោយការ**ចង្រ្កម**, ទើបទ្រង់បញ្ជូន**ខ្មាន់ព្រះកេស*** (*អ្នកកាត់សក់*) *ទៅបង្គាប់ថា អ្នក ទាំងឡាយចូរយកកាំបិតដ៏មុតទៅវះ **អង្គន់ព្រះបាទ**បិតាអញហើយយក អំបិល និងប្រេងលាបឱ្យសព្វ យកអុសគគីរធំៗ មកគរដុតជាភ្នក់ ហើយ យកជើងបិតាអញទាំងពីរ ទៅឆ្អើលើភ្នក់ភ្លើងនោះ ។ ខ្មាន់ព្រះកេស ទាំងឡាយយកដំណឹងនោះទៅក្រាបទូល**ព្រះបាទពិម្ពិសារ** ទ្រង់ក៏ ពោល ថា អ្នកទាំងឡាយចូរធ្វើបង្គាប់ព្រះទ័យព្រះរាជាអ្នកចុះ កុំញញើតឱ្យ សោះ ។ ពួកខ្មាន់ព្រះកេសពោលម្ដងទៀតថាបពិត្រព្រះសម្មតិទេព សូម ស្ដេចប្រថាប់ចុះ, ទូលព្រះបង្គំទាំងឡាយនឹងធ្វើអាជ្ញាដល់ព្រះអង្គ, សូម ទ្រង់កុំខ្វាល់នឹងទូលព្រះបង្គំ ព្រោះសុទ្ធតែជាអ្នកទទួលព្រះរាជអាជ្ញា ផ្ទាល់ **ទាំងកម្មដ៏លាមក**នេះសោត ក៏មានសភាពមិនសមគួរដល់ព្រះអង្គ ដែលជាស្ដេច**ប្រកបដោយធម៌សោះ** លុះពោលរួចហើយ ក៏ចាប់ព្រះ-*

*បាទាព្រះរាជាវះអង្គន់ហើយប្រឡាក់ដោយអំបិលនិងប្រេង ទើបយកអុសគគីរមកគរដុតរោលកម្ដៅ។ **ព្រះបាទពិម្ពិសារ**មានព្រះកាយពលឈឺផ្សា ដោយកម្មនោះណាស់ ព្រោះស្បែកព្រះបាទទាំងគូរដែលគេវះ ចេញឈាមថ្មីៗ ហើយត្រូវគេយកអំបិល និងប្រេងមកប្រឡាក់ ទាំងរោលដោយរងើកភ្លើងទៀត រីងរឹតតែឈឺផ្សាក្រៃលែង គួរអាសូរព្រះអង្គណាស់!*

*បើអត់អាហារក៏អត់ទៅចុះមិនថាទេ ថែមទាំងគេវះអង្គន់ព្រះបាទមិនឱ្យដើរចង្ក្រមរួចទៀត រងទុក្ខវេទនាជាមហិមា តែព្រះអង្គជា**អរិយ-បុគ្គល**មិនអើពើនឹងកម្មនោះឡើយ។*

*សេចក្ដីថា កាលពី**បុរេជាតិ** ព្រះរាជាស្ដេចពាក់**ទ្រនាប់ព្រះបាទ**ជាន់**ប្រាង្គចេតិយ** ជាបូជនីយដ្ឋានដែលគេរោយរាយដោយផ្កា មានក្លិនក្រអូបជាដើម, អាចារ្យពួកខ្លះពោលថាទ្រង់ជាន់កន្ទេលផែង ដែលគេក្រាលសម្រាប់ឱ្យភិក្ខុសង្ឃគង់ នេះជា**បុព្វកម្ម**ដែលទ្រង់រងក្នុង បច្ចុប្បន្ន។*

*ព្រះរាជារងវេទនាជាខ្លាំងក៏លាន់ព្រះឱស្ដថា **ឱព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ**! ជាពំនឹងដ៏ប្រសើររបស់ខ្ញុំ! ទើបសោយព្រះទីវង្គតទៅ កើតជាយក្សឈ្មោះ**ជនវសភ**ជារាជបម្រើ**ព្រះបាទវេស្សវ័ណ**នាឋានចាតុម្មហារាជិកា ដោយអំណាចនៃសេចក្ដីត្រេកអរដែលទ្រង់សន្សំហើយអស់ កាលដ៏យូរ ព្រោះទ្រង់ធ្លាប់កើតក្នុងឋានចាតុម្មហារាជិកានោះច្រើនជាតិ មកហើយ។*

*(ប្រជុំរឿងនិទានជាតកភាគ៣ ព្រះបាទអជាសត្រូវសម្លាប់បិតា ទំព័រ ១០២-១០៣)*

# ៣០.រឿងអភ័យចោរ

(ចាក ម.ម.)

## (បដិសណ្ឋារៈជាផ្លាក់ ឬជាទឹកសម្រាប់រំលត់ចិត្តឃោរឃៅ)

*មានចោរម្នាក់ឈ្មោះ**អភ័យ** មានកូនចោរ ៥ រយជាបរិវារនៅអាស្រ័យក្នុងសីហឡទ្វីប (សិរីលង្កា)។ ថ្ងៃជាខាងក្រោយ អភ័យមេចោរនោះ បាននាំកងទ័ពមកឈប់នៅភូមិមួយធ្វើឱ្យអ្នកភូមិភ្ញាក់ផ្អើលខ្លាចជាពន្ទឹក ។ តាំងពីពួកចោរចូលមកនៅក្នុងទីនោះ ជនអ្នក **អនុរាធបុរី** មិនដែលហ៊ានចុះទៅដងទឹកនៅស្ទឹងឈ្មោះ**កលម្ពកៈ** ឡើយ ព្រោះខ្លាចអំពើយង់ឃ្នងនៃក្រុមចោរ ។ ការត្រាច់ទៅមកនៃពួកជនត្រង់ ផ្លូវក្បែរ**វត្តចេតិយគិរី** ក៏ស្ងាត់ឈឹង ។ ថ្ងៃមួយក្រុមចោរទាំងនោះ បបួលគ្នាទៅប្លន់**វត្តចេតិយគិរី** ។ ពួកញោមវត្តឃើញក្រុមចោរដើរសំដៅ ទៅរកវត្តដូច្នោះ ក៏រត់យ៉ាង លឿនទៅទូលព្រះថេរៈឈ្មោះ **ទីឃភាណកអភ័យ** ចៅអធិការវត្តឱ្យបានជ្រាបដំណឹងជាមុន ។ ហេតុតែ ព្រះថេរៈជាបុគ្គលឈ្លាសវៃក្នុង**បដិសណ្ឋារកិច្ច** ក៏សួរញោមវត្តទាំងនោះ ថាមានភេសជ្ជៈ គឺសប្បិ ទឹកដោះរាវ និងស្ករអំពៅជាដើមដែរឬ? "ទានប្រោសមាន" ។ "អើអ្នកទាំងឡាយ ទុកចាំឱ្យពួកចោរ" ។ លោកសួរទៀតថា "ចុះអង្ករមានដែរឬ"? "ទានប្រោស អង្ករក្តី បន្លែស្រស់ក្តី រសសាច់គោក្តី ដែលពួកជននាំមកដើម្បីធ្វើចង្ហាន់ថ្វាយព្រះភិក្ខុសង្ឃមាន" ។ ព្រះថេរៈ បង្គាប់ញោមវត្ត ឱ្យចាត់ចែងភត្តទុកឱ្យពួកចោរទាំងនោះ ។*

*ញោមវត្តទាំងឡាយក៏ចាត់ចែងភត្តបម្រុងទុកឱ្យចោរទាំងនោះ*

លុះពួកចោរមកដល់ ក៏លើកកត្តនោះ ទៅសមគួរ ទើបពួកចោរសួរថា "អ្នកណានាំឱ្យចាត់ចែងធ្វើ**បដិសណ្ឋារៈ**នេះ"? ព្រះថេរអភ័យជាម្ចាស់នៃយើង ជាអ្នកចាត់ចែង**បដិសណ្ឋារកិច្ច**នេះៗ ចោរព្ធដូចោះក៏បបួលគ្នាទៅថ្វាយបង្គំព្រះថេរៈពោលរៀបរាប់ថា យើងទាំងឡាយមកនេះប៉ងនឹង ប្លន់យកទ្រព្យរបស់សង្ឃផងរបស់ចេតិយ (ទ្រព្យដែលកប់ទុកក្នុង ចេតិយ) ផងតែដោយលោកម្ចាស់មានការជ្រះថ្លាចាត់ចែង ឱ្យគេធ្វើ **បដិសណ្ឋារៈ** ដល់យើងខ្ញុំៗ ក៏ខានប្លន់ទៅវិញ ចាប់ពីពេលនេះយើងនឹង ប្តេជ្ញាខ្លួនរក្សាធម៌នៅក្នុងវត្តនេះ អ្នកនគរទាំងឡាយចូរមកឱ្យទាន ថ្វាយបង្គំ**ព្រះចេតិយ**តាមធម្មតាចុះ ។ តាំងពីថ្ងៃដែលចោរឱ្យទូវអភ័យ មក ពួកអ្នកនគរតែងទៅឱ្យទានតាមប្រក្រតី ដោយពួកចោរទាំងនោះនាំ ចូលទៅវត្ត ហើយតាមថែរក្សាការពារកយន្តរាយគ្រប់បែប ។ ឯអ្នកនគរ កាលបើភិក្ខុទាំងឡាយឆាន់នៅសល់កត្តក៏ឱ្យចោរទាំងឡាយបរិភោគ ដរាប ដល់ឆ្អែតស្កប់ស្កល់ ។ លុះអ្នកនគរមកវិញ ពួកចោរក៏ជូនមកដល់ត្រើយស្ទឹង ។ កាលយ៉ាងនេះ ចេះតែប្រព្រឹត្តទៅដោយស្រួលរវាងពួកចោរ នឹងអ្នកស្រុក ព្រមទាំងភិក្ខុសង្ឃក៏មានពាក្យតិះដៀល កើតឡើងថាព្រះថេរចៅអធិការ អាងតែលោកជាធំ ចេះតែឱ្យទ្រព្យសង្ឃ ដល់ពួកចោររាល់ថ្ងៃៗ ព្រះថេរក៏ប្រជុំអស់ពួកឧបាសក ឧបាសិកាចំណុះជើងវត្តហើយពោលថា ចោរទាំងឡាយមកនេះ បម្រុងប្លន់យកទ្រព្យសង្ឃ និងទ្រព្យក្នុងចេតិយ តែបានអាត្មាចាត់ចែងធ្វើ**បដិសណ្ឋារៈ**ប៉ុណ្ណោះ ទើបឈប់ប្លន់, បើមិនដូច្នោះទេទ្រព្យនឹងវិនាសដោយពិត ពាក្យចោទតិះដៀលក៏ស្ងប់រម្ងាប់ដូចជាប្រទីបអស់ទាំងប្រេងឆេះ ៕

(ប្រជុំរឿងនិទានជាតកភាគ៤ អភ័យចោរ ទំព័រ ១១៧-១១៨)

១.រឿងជោតិកសេដ្ឋី (អានិសង្សធ្វើគន្ធកុដិ) ទំព័រ ២-៤៥។

២.រឿងមេណ្ឌកសេដ្ឋី (អានិសង្សធ្វើព្រះគន្ធកុដិ) ទំព័រ ៧៦-៨៦។

៣.រឿងកុនាលរាជកុមារ (អានិសង្សការជួសជុលចេតិយ) ទំព័រ ៧០-៨៣។

***(ក្នុងរឿងទាំងបីនេះជារឿងវែងៗ សូមអ្នកអានគប្បីមើលក្នុងសៀវភៅ "ប្រជុំនិទានជាតក" ដើម្បីជ្រាបច្បាស់សាច់រឿង)***

## II- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៥៥ ខ្លះៗ

### ១.គុត្តិទិលវិមាន

### (ផលនៃការប្រស់ព្រំគ្រឿងក្រអូបទៅលើព្រះស្តូបព្រះពុទ្ធកស្សប)

*...ម្នាលទេវតា នាងមានសម្បុររុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុរ របស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុរ របស់នាង ក៏ភ្លឺច្បាស់សព្វទិស ។ ទេវតានោះ ដែល***ព្រះមោគ្គល្លាន** *សួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថាខ្ញុំបានឱ្យនូវគ្រឿងប្រស់ព្រំ មានក្លិនក្រអូបលើស្តូបនៃព្រះមានព្រះភាគទ្រង់***ព្រះនាមកស្សប** *សូមលោករមិលមើលនូវវិមាន របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរ ទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស...។*

*(គុត្តិលវិមាន បិដកភាគ៥៥ ទំព័រ៦៤-៦៥)*

### ២.វិសាលក្ខិវិមាន

### (ផលនៃការបូជាព្រះស្តូប)

(*សក្កទេវរាជសួរថា*) *ម្នាលនាងមានភ្នែកទូលាយ នាងឈ្មោះអ្វីបានជា មានពួកនារីចោមរោម ហើយដើរក្រឡឹងជុំវិញ* **ព្រៃចិត្តលតា** *ជាទីរីករាយពួកទេវតាជាន់តាវត្តិង្ស ចូលទៅកាន់ព្រៃនេះ ក្នុងកាលណា* (*កាលនោះ*) *ពួកទេវតាទាំងអស់ ព្រមទាំងយាន ព្រមទាំងរថ ដ៏វិចិត្រ ក៏មកក្នុងទីនុះ នាងកាលមកដល់ក្នុងទីនេះហើយត្រាច់ទៅក្នុងឧទ្យាន ចិត្ត*

រមែងប្រាកដដោយកាយ រូបរបស់នាងក៏ប្រាកដដូច្នេះ តើដោយហេតុដូចម្តេច? "ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះអង្គជាធំជាងទេវតា **រូបរបស់ខ្ញុំ គតិ រឹទ្ធិ** និង**អានុភាព**របស់ខ្ញុំ (កើតឡើង) ដោយកម្មណា បពិត្រព្រះអង្គទ្រង់**ព្រះនាមបុរិន្ទទៈ** សូមព្រះអង្គស្តាប់ នូវកម្មនោះចុះ

ខ្ញុំជាឧបាសិកា ឈ្មោះ**សុនន្ទា** នៅក្នុង**ក្រុងរាជគ្រឹះ**ជាទីត្រេកអរ ជាស្រ្តីបរិបូណ៌ ដោយសទ្ធា និងសីល ត្រេកអរក្នុងការចែករំលែក

នូវទាន មានចិត្តជ្រះថ្លា បានឱ្យសំពត់សម្រាប់ស្លៀកដណ្តប់ផង ភត្តផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួក**ព្រះអរិយបុគ្គល** អ្នកមានចិត្តត្រង់សព្វៗកាល ខ្ញុំបានរក្សាឧបោសថប្រកបដោយ**អង្គ៨** អស់ថ្ងៃទី១៤ ទី១៥ និងថ្ងៃទី៨ នៃ**បក្ខ**ផង អស់**បាដិហារិយបក្ខ**ផង បានសង្រួមក្នុងសីលទាំងឡាយផង **វៀរបាណាតិបាត**ផង សង្រួម**ចាកមុសាវាទ**ផង ឆ្ងាយចាកការលួចផង ចាកការប្រព្រឹត្តិកន្លង (ចិត្តស្វាមី)ផង ចាកការផឹកទឹកស្រវឹងផង សព្វៗកាល ហើយត្រេកអរ ក្នុងសិក្ខាបទ ទាំង៥ ឈ្លាសក្នុងអរិយសច្ចទាំងឡាយ ជាឧបាសិកានៃ**ព្រះគោតម** ព្រះអង្គមាន**បញ្ញាចក្ខុ** មានយស ឯត្រកូលនៃញាតិរបស់ខ្ញុំនោះ តែងយកកម្រងផ្កា មកឱ្យខ្ញុំសព្វៗកាល ខ្ញុំបានបូជាកម្រងផ្កានោះទាំងអស់ ចំពោះ**ព្រះស្តូប នៃព្រះមានព្រះភាគ** ។ ខ្ញុំមានចិត្តជ្រះថ្លា បានទៅក្នុងថ្ងៃឧបោសថ ហើយបូជាកម្រងផ្កា គ្រឿងក្រអូបគ្រឿងលាប ចំពោះ**ព្រះស្តូប** ដោយដៃរបស់ខ្លួន បពិត្រព្រះអង្គជាធំជាងទេវតា **រូបរបស់ខ្ញុំ គតិ រឹទ្ធិ** នឹង**អានុភាព**របស់ខ្ញុំ (កើតឡើង) ដោយកម្មនោះ ដែលខ្ញុំបានបូជាកម្រងផ្កាក្តី ដែលខ្ញុំជាស្រ្តី

មាន**សីលក្ដី** ការបូជានូវកម្រងផ្កា និងការរក្សាសីល របស់ខ្ញុំនោះ មិនទាន់ឱ្យផលនៅឡើយ បពិត្រព្រះអង្គជាធំជាងទេវតា តែសេចក្ដីប្រាថ្នារបស់ខ្ញុំថា សូមឱ្យខ្ញុំបានជា**សកទាគាមិនី**” ។

(ចប់ វិសាលក្ខិវិមាន បិដក ភាគ៥៥ ទំព័រ៨០-៨២)

## ៣.បីតវិមាន
## (ផលនៃការបូជាផ្កាននោងព្រៃ ចំពោះព្រះស្តូប)

(ទេវរាជសួរថា) “ម្នាលនាងដ៏ចម្រើន មានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់**ផ្កាឧប្បលលឿង** មានប្រាសាទ និងទីដេកលឿង មានទីអង្គុយលឿង មានភោជនៈលឿង មានឆត្រលឿង មានរថលឿង មានសេះលឿង មានផ្លិតលឿង នាងបានធ្វើអំពើដូចម្ដេច ក្នុងកពជារបស់មនុស្ស ក្នុងកាលមុន ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី” ។

(ទេវធីតាឆ្លើយថា) “បពិត្រព្រះអង្គដ៏ចម្រើន **វល្លិ៍ឈ្មោះកោសាតកី (វល្លិ៍ននោងព្រៃ)** ជាជាតិវល្លិ៍ល្វីង ដែលគេមិនត្រូវការ ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំយក**ផ្កាននោងព្រៃ ៤ទង** ទៅបូជា**ព្រះស្តូប** ឧទ្ទិសចំពោះ**ព្រះសរីរៈធាតុ**នៃព្រះសាស្ដា ខ្ញុំម្ចាស់កំពុងមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុនៃព្រះមានព្រះភាគនោះ មិនបានក្រឡេកមើលផ្លូវគោនោះ គ្រានោះមេគោមកជល់ខ្ញុំម្ចាស់ ដែលមានអជ្ឈាស្រ័យ មិនទាន់ដល់**ព្រះស្តូប** (ស្លាប់ទៅ) បើខ្ញុំម្ចាស់សន្សំបុណ្យនោះសម្រេច ម៉្លេះសមជាមានសម្បត្តិដ៏

លើសលុបជាងនេះ បពិត្រព្រះអង្គជាធំជាងទេវតា **នាមមឃវៈ ជាទេវកុញ្ជរៈ** ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ" ។

**ព្រះឥន្ទ្រ នាមមឃវៈ** ជាទេវកុញ្ជរៈ ជាធំជាងទេវតាក្នុងជាន់ត្រៃត្រឹង្ស បានស្តាប់ពាក្យនេះហើយ ក៏ញ៉ាំងទេវធីតាឱ្យជ្រះថ្លា ក្នុងកពតាវត្តឹង្សហើយ បានពោលពាក្យនេះ នឹង**មាតលិទេវបុត្រ**ថា ម្នាល**មាតលិ** អ្នកចូរមើលសេចក្តីអស្ចារ្យ នេះជាផលនៃកម្មដ៏វិចិត្រ **ទេយ្យវត្ថុ** សូម្បីបន្តិចបន្តួចដែលគេធ្វើហើយ ជាបុណ្យមានផលច្រើន កាលបើចិត្តជ្រះថ្លាចំពោះ**ព្រះតថាគតជាសម្ពុទ្ធ** ឬសាវ័ករបស់ព្រះតថាគតហើយ **ទក្ខិណាទាន** ឈ្មោះថាមានផលតិចមិនមែនឡើយ ម្នាល**មាតលិ** អ្នកចូរមក យើងទាំងឡាយនឹងបូជាព្រះធាតុព្រះតថាគតឱ្យលើសលុបជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ កាល**ព្រះតថាគតឋិត**នៅក្តី **បរិញ្វាន**ទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ ដ្បិតថាសត្វទាំងឡាយ មានការដំកល់ចិត្តទុកជាហេតុ ទើបទៅកាន់ សុគតិបានទាយកទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជាចំពោះ**ព្រះតថាគត**ទាំងឡាយណា **ព្រះតថាគត**ទាំងនោះ បានកើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ។

(ចប់ បីតវិមាន បិដកភាគ ៥៥ ទំព័រ៩៩-១០១)

# ៤.ចូឡរថវិមាន

## (*ផលនៃការបូជាព្រះសរីរធាតុព្រះពុទ្ធជាម្ចាស់*)

...(*ព្រះថេរៈសួរថា*) "*ព្រះអាទិត្យមានរស្មីច្រើន មានពន្លឺធំបែបណា ចរទៅក្នុងអាកាស រមែងបំភ្លឺនូវទិសបានយ៉ាងណា រថធំរបស់អ្នកនេះ មានប្រការបែបនោះដែរ រថជុំវិញខាងបណ្តោយមួយរយយោជន៍ស្រោបជុំវិញ ដោយផែនមាស គល់ចន្ទោល វិចិត្រដោយ**កែវមុក្តា** និង**កែវមណី** ក្បាច់ជាវិការៈនៃ**កែវពិទូរ្យ** រំលេចឲ្យដ៏ផែនមាស និងប្រាក់ ញុំាងរថឱ្យរុងរឿងចុងចន្ទោលរបស់រថសម្រេចដោយ**កែវពិទូរ្យ** នឹមវិចិត្រដោយកែវទទឹម ទាំងខ្សែក៏ប្រដាប់ដោយមាស នឹងប្រាក់ សេះទាំងនេះមានសន្ទុះទាន់ចិត្ត រមែងញុំាងរថឱ្យរុងរឿង ព្រះអង្គក៏ប្ញុំថ្កើងត្រដែកលើរថមាស មានពាហនៈទឹមដោយសេះ ដ៏ច្រើន ដូចព្រះឥន្ទ្រ បពិត្រអ្នកមានយស អាត្មាសូមសួរអ្នកជាបុគ្គលឈ្លាសវៃ តើយសដ៏ប្រសើរលើសលុបនេះ អ្នកបានដោយគុណអ្វី*"។

(*ទេវបុត្រតបថា*) "*បពិត្រលោកដ៏ចម្រើន ក្នុងកាលមុន ខ្ញុំជាព្រះរាជបុត្រ **ឈ្មោះសុជាតៈ** លោកម្ចាស់បានអនុគ្រោះ ដល់ខ្ញុំនោះបានញុំាងឱ្យតាំងនៅក្នុងសេចក្តីសង្រួមលោកម្ចាស់បានដឹងនូវខ្ញុំ ថាអស់អាយុ ហើយបានប្រទានសរីរធាតុព្រះសាស្តាដល់ខ្ញុំ ។ លោកម្ចាស់បានប្រាប់ថា ម្នាលសុជាតរាជកុមារ ព្រះអង្គចូរបូជានូវព្រះសរីរធាតុនេះចុះការបូជានោះ នឹងបានជាប្រយោជន៍ដល់ព្រះអង្គ ខ្ញុំក៏បានប្រឹងប្រែងបូជានូវព្រះសរីរធាតុនោះ ដោយគ្រឿងក្រអូប និងកម្រងផ្កាទាំងឡាយ លុះលះបង់នូវរាងកាយ ជារបស់មនុស្ស ក៏បានមកកើត ក្នុងទីមនោរម្យដ៏*

*ប្រសើរ គួរត្រេកត្រអាលពន់ពេក ប្រកបដោយពួកទេវតា ផ្សេងៗ ជាដើម ខ្ញុំក៏ត្រេកអរដោយការរាំ និងច្រៀង ដែលពួកទេពអប្សរចោមរោម ត្រៀបត្រា" ។*

*(ចប់ចូឡរថវិមាន បិដកភាគ៥៥ ទំព័រ១៣៤-១៣៥)*

## ៥.អនេកវណ្ណវិមាន

## (*ផលនៃការថ្វាយបង្គំព្រះចេតិយកែវ*)

...(*ព្រះមោគ្គល្លានសួរថា*) *"អ្នកមានពួកស្រីអប្សរហែហម ហើយឡើងកាន់វិមាន ដែលមានពណ៌ដ៏ច្រើន ជាទីធ្វើនូវសេចក្តីក្រវល់ក្រវាយ និងសេចក្តីសោកឱ្យវិនាស មានរូបវិចិត្រច្រើនប្រការ សប្បាយរីករាយដូចទេវរាជឈ្មោះ**សុនិម្មិតទេវបុត្រ** ដែលប្រហែលស្មើរដោយអ្នកក៏មិនមាន* (ចំណង់បើ) *ទេវបុត្រដែលប្រសើរលើសដោយយសផង បុណ្យផង ឫទ្ធិផង នឹងមានមកពីណា? ពួកទេវតាក្នុងជាន់តាវត្តិង្សទាំងអស់ ប្រជុំគ្នានមស្ការអ្នក ដូចទេវតា និងមនុស្ស នមស្ការនូវ**ចន្ទទេវបុត្រ** ដែលមានស្នាមរូបទន្សាយក្នុងវង់ដូច្នោះ ស្រីអប្សរទាំងឡាយនេះ តែងរាំច្រៀងរីករាយជុំវិញអ្នក អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិស តើដោយបុណ្យអ្វី"? ទេវបុត្រនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃបុញ្ញកម្មនេះថា "បពិត្រលោកដ៏ចម្រើន កាលជាតិមុន ខ្ញុំនោះ ជាសាវ័ករបស់**ព្រះជិនស្រី ព្រះនាមសុមេធៈ** ខ្ញុំនៅជា**បុថុជ្ជន** មិន*

*ទាន់បាន ត្រាស់ដឹងសច្ចៈទាំង ៤ នៅឡើយ ខ្ញុំនោះបួសបាន៧វស្សា កាល* ***ព្រះជិនស្រី*** *ជាសាស្តា**ព្រះនាមសុមេធៈ*** *ជា**តាទិបុគ្គល**[១] ទ្រង់ធ្វងអន្ទង់ ទាំង ៤ហើយ ទ្រង់បរិនិព្វាន ខ្ញុំនោះទៅថ្វាយ បង្គំចេតិយកែវ ស្រោប ដោយបណ្តាញមាស ធ្វើចិត្តឱ្យជ្រះថ្លា ចំពោះ**ព្រះស្តូប** ខ្ញុំមិនបានឱ្យទាន ទេ ទាំងទេយ្យវត្ថុសម្រាប់ឱ្យទានក៏មិនមាន ប៉ុន្តែខ្ញុំបានបបួលពួកជនដទៃ ក្នុងការឱ្យទានថា អ្នកទាំងឡាយចូរបូជាព្រះធាតុ របស់ព្រះសាស្តា ជាវត្ថុ គួរដល់ការបូជាចុះ ខ្ញុំឮថាអ្នកទាំងឡាយ* (**ច្យុត**) *អំពីមនុស្សនេះនឹងទៅ កាន់ឋានសួគ៌ កុសលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយ ទើបខ្ញុំបានសេច ក្តីសុខជាទិព្វដោយខ្លួនឯង ខ្ញុំរីករាយ ក្នុងកណ្តាលពួកទេវតា បុណ្យរបស់ ខ្ញុំនោះ មិនចេះអស់ឡើយ" ។*

*(ចប់ អនេកវណ្ណវិមាន បិដកភាគ៥៥ ទំព័រ១៧០-១៧១)*

## ៦.សុនិក្ខិត្តវិមាន

## (ផលនៃការរៀបចំផ្កាកម្រងតម្កល់ព្រះស្តូប)

...(*ព្រះមោគ្គល្លានសួរថា*) *"វិមានដ៏ខ្ពស់នេះ មានសសរជាវិការៈ នៃកែវមណី មានទំហំជុំវិញ ១២យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឱឡារិក មានសសរ ជាវិការៈនៃកែវពិទូរ្យ ក្រាលដោយកម្រាល ដ៏រុងរឿង ជាផ្ទះ កំពូលដ៏ល្អ អ្នករមែងឋិតនៅ ផឹក ស៊ី ក្នុងវិមាននោះផង ពិណជាទិព្វ ទាំងឡាយ លាន់ឮពីរោះផង កាមគុណទាំង៥ មានរសទិព្វ* (*តែងបរិបូ ណ៌*) *ក្នុងវិមាននោះផង ពួកនារី ដែលបិទបាំងដោយគ្រឿងមាស តែងរាំ ច្រៀង ក្នុងវិមាននេះផង សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយ*

*បុណ្យអ្វី ផលសម្រេចដល់អ្នកក្នុងវិមាននេះផង ភោគៈទាំងឡាយណា នីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់អ្នកផង តើដោយ បុណ្យដូចម្ដេច?*

*នៃទេវតា អ្នកមានអានុភាពច្រើន អាត្មាសួរអ្នក*
*តើអ្នកកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី*
*ទើបអ្នកមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ*
*របស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី"?*

*ទេវបុត្រនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នារួចហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ថា*

*"ខ្ញុំបានរៀបចំល្អ នូវកម្រងផ្កា ដែលគេរៀបចំ មិនល្អ បានតម្កល់ ទុកចំពោះព្រះស្តូប* ***នៃព្រះសុគត (ព្រះនាមកស្សប)*** *បានជាខ្ញុំមានរិទ្ធិ ច្រើន មានអានុភាពច្រើន បរិបូណ៌ដោយកាមគុណទាំងឡាយជាទិព្វ ហេតុនោះបានជា សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ផលសម្រេចដល់ខ្ញុំ ក្នុង វិមាននេះផង ភោគៈទាំងឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង ដោយបុណ្យនោះ ទើបខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយបុណ្យនោះ"។*

*(ចប់ សុនិក្ខិត្តវិមាន បិដកភាគ ៥៥ ទំព័រ១៨៩-១៩១)*

## ចប់ បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៥៥

## III- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧២ ខ្លះៗ

## ១.មហាកស្សបត្ថេរាបទាន

*(ផលនៃការកសាងវិមាន)*

*កាលព្រះមានព្រះភាគ ទ្រង់ព្រះនាម**បទុមុត្តរៈ** ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ជាទីពឹងនៃសត្វលោក ទ្រង់បរិនិព្វានទៅ ពួកជននាំគ្នាធ្វើការបូជាព្រះសាស្តាអង្គនោះៗ ប្រជុំជនមានចិត្តខ្ពស់ មានចិត្តសប្បាយ រីករាយ កាលញាតិនិងមិត្តនៃខ្ញុំទាំងនោះ កំពុងកើតសង្វេគ **បីតិ**កើតឡើងដល់ខ្ញុំ ។ ខ្ញុំប្រជុំញាតិនិងមិត្តទាំងឡាយ ទើបពោលពាក្យនេះថា ព្រះលោកនាថ មានព្យាយាមធំ ទ្រង់បរិនិព្វានហើយ បើដូច្នោះ យើងនឹងធ្វើការបូជា ។ ញាតិ និងមិត្តទាំងនោះទទួលស្តាប់ថា ប្រពៃហើយ ក៏ញុំាងសេចក្តីរីករាយឱ្យកើតដល់ខ្ញុំដោយច្រើន ខ្ញុំបានធ្វើនូវការសន្សំបុណ្យ ក្នុងព្រះពុទ្ធជាទីពឹង នៃសត្វលោក អង្គនោះ ។ ខ្ញុំបានសង់វិមានមានកម្ពស់ ១០០ហត្ថ មានទំហំ ១៥០ហត្ថ ខ្ពស់ទើសអាកាស ជាវិមានមានតម្លៃ ដែលរចនាយ៉ាងល្អ។*

*ខ្ញុំសង់វិមានដ៏មានតម្លៃ វិចិត្រដោយគំនរកុសលទាំងឡាយក្នុងទីនោះហើយ បានញុំាងចិត្តរបស់ខ្លួនឱ្យជ្រះថ្លា បានបូជានូវចេតិយដ៏ប្រសើរ ។ ឯចេតិយនោះរុងរឿងដូចគំនរភ្លើង ឬដូចស្តេច**សាលព្រឹក្ស**មានផ្ការីកភ្លឺស្វាងក្នុងទិសទាំង ៤ ដូចឥន្ទធនូក្នុងអាកាស ។ ខ្ញុំញុំាងចិត្តឱ្យជ្រះថ្លា ក្នុងជាតុចេតិយនោះ ហើយធ្វើកុសលដ៏ច្រើន ខ្ញុំបានទៅកើតក្នុង**ឋានតាវត្តឹង្ស** ព្រោះរឭកនូវបុព្វកម្មនោះ ។ ខ្ញុំជិះយានទិព្វ ទឹមដោយសេះមួយ*

ពាន់ ឯវិមាន ៧ ជាន់ខ្ពស់ កើតឡើងសម្រាប់ខ្ញុំ។ ផ្ទះមានកំពូលមួយពាន់ ជាវិការៈនៃមាសសុទ្ធ រុងរឿងជានិច្ច ទិសទាំងពួង សឹងតែភ្លឺដោយតេជះ របស់ខ្លួន ។ ផ្ទះខាងមុខដទៃទៀត ជាវិការៈនៃកែវក្រហម មានក្នុងកាល នោះ ផ្ទះទាំងនោះភ្លឺរន្ទាល ដោយរស្មី ទៅកាន់ទិសទាំង ៤ ដោយជុំវិញ ។ ផ្ទះមានកំពូលទាំងឡាយ កើតឡើងដោយបុញ្ញកម្ម ដ៏តាក់តែងល្អ ជាវិការៈនៃកែវមណី តែងភ្លឺប្រាលទៅកាន់ទិសតូចទិសធំ ដោយជុំវិញ ។

ផ្ទះកំពូលទាំងនោះកាលភ្លឺឡើង រស្មីធំទូលាយ ខ្ញុំគ្របសង្កត់នូវទេវតាទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្ប ៦ ហ្មឺនអំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិព្រះនាម**ឧព្វិទ្ធ** មានសមុទ្រទាំង ៤ ជាព្រំដែន ជាស្តេចឈ្នះលើផែនដី គ្រប់គ្រងផែនដី ។ ក្នុងភទ្ទកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិមានកម្លាំងច្រើន អស់៣០ដង ខ្ញុំបានប្រារព្ធនូវកម្មរបស់ខ្លួន (ប្រព្រឹត្តខ្ជាប់ដោយរាជធម៌ ១០) ។ ខ្ញុំបរិបូណ៌ដោយកែវទាំង ៧ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ប្រាសាទរបស់ខ្ញុំ ខ្ពស់ភ្លឺផ្លេកដូចផ្លេកបន្ទោរ ក្នុងរជ្ជកាលនៃស្តេចចក្រពត្តិនោះៗ ទីក្រុងឈ្មោះ **រម្មកៈ** មានបណ្តោយ ២៤យោជន៍ ទទឹង ១២យោជន៍ មានកំពែងនិងក្លោងទ្វារដ៏មាំ ។ ឯកំពែងនោះ បណ្តោយ ៥០០ យោជន៍ មានទទឹង ២៥០យោជន៍ កុះករដោយពួកជនទាំងឡាយ ដូចជាបុរីនៃទេវតា ក្នុងជាន់**ត្រៃត្រឹង្ស**។

ម្ជុលមានចំនួន ២៥ ដែលគេយកទៅច្រក ក្នុងបំពង់ម្ជុល ពេញណែន រមែងកកិតជិតជាប់គ្នា យ៉ាងណាមិញ ។ ទីក្រុងរបស់ខ្ញុំ កុះករដោយដំរី សេះ រថ ទីក្រុងនោះ ច្រើនដោយពួកមនុស្ស ជាក្រុងវិសេសគួរជាទីត្រេកអរ ក៏យ៉ាងនោះដែរ ។ ខ្ញុំបរិភោគ (ភោជន) ផង ផឹកទឹកផង ក្នុង

បុរីនោះ រួចហើយទៅកាន់អត្តភាពជាទេវតាទៀត ក្នុងបច្ឆិមភព ខ្ញុំបរិបូណ៌ដោយត្រកូលខ្ពង់ខ្ពស់ ។ ខ្ញុំកើតក្នុងត្រកូល ព្រាហ្មណ៌ អ្នកសម្បូណ៌ដោយរតនៈច្រើន បានលះបង់ ហិរញ្ញៈចំនួន ៨០ កោដិ ហើយចេញបួស។ **បដិសម្ភិទា ៤ វិមោក្ខ ៨**[១] **និងអភិញ្ញា ៦**[២] នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ក៏បានប្រតិបត្តិហើយ។

បានឮថា **ព្រះមហាកស្សបត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ។

(ចប់ មហាកស្សបត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ៧៦-៧៩)

---

(១).វិមោក្ខ ឬ វិមោក្ស ន. ការរួច ឬផុតស្រលះ, សេចក្តីរួចផុតចាកកិលេស(ព្រះនិព្វាន) ។

(២).អភិញ្ញា ន. សេចក្តីដឹងយ៉ាងខ្ពស់, សេចក្តីដឹងយ៉ាងពិសេស ដែលកើតអំពីកម្លាំងនៃឈាន, បញ្ញាជាគ្រឿងដឹងខ្ពស់ គឺដឹងដល់កំពូលដែលជាគុណសម្បត្តិរបស់ព្រះអរហន្ត (Supernormal know, Passess of knowledge) ។ អភិញ្ញាមាន៦យ៉ាងគឺ

១- ឥទ្ធិវិធិ សម្តែងឫទ្ធិផ្សេងៗបាន ។

២- ទិព្វសោត មានត្រចៀកទិព្វ (អាចស្តាប់សំឡេងគ្រប់ទីកន្លែងបានទាំងអស់ មិនមានទើសទាក់) ។

៣- ចេតោបរិយញ្ញាណ ប្រាជ្ញាដឹងចិត្តរបស់អ្នកដទៃបាន។

៤- បុព្វេនិវាសានុស្សតិ រឭកជាតិបាន។

៥- ទិព្វចក្ខុ ភ្នែកទិព្វ (អាចមើលឃើញគ្រប់ទីកន្លែងបានទាំងអស់) ។

៦- អាសវក្ខយញ្ញាណ ប្រាជ្ញាធ្វើកិលេសឱ្យអស់ទៅបាន។

(សទ្ទានុក្រមព្រះពុទ្ធសាសនា).

## ២.បិលិន្ទវច្ឆត្ថេរាបទាន
### (*ផលនៃការបូជាព្រះស្តូបព្រះសុមេធៈសម្ពុទ្ធ*)

*កាលព្រះលោកនាថព្រះនាម**សុមេធៈ** ទ្រង់ជាអគ្គបុគ្គល ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើនូវការបូជា **ព្រះស្តូប** ។ ព្រះខីណាស្រពទាំងឡាយណា ដែលបានអភិញ្ញា ៦ មានឫទ្ធិច្រើន នៅក្នុងទីនោះ ខ្ញុំក៏បានប្រជុំព្រះខីណាស្រពទាំងនោះ ក្នុងទីនោះហើយ បានធ្វើសង្ឃភត្ត ។ កាលនោះ ព្រះថេរៈឈ្មោះ **សុមេធៈ** ឧបដ្ឋាករបស់ ព្រះមានព្រះភាគ ព្រះនាម**សុមេធៈ** ព្រះថេរៈ នោះ បានធ្វើអនុមោទនា ក្នុងកាលនោះ ។*

*ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានចូលទៅក្នុងវិមាន ដែលមានស្រីអប្សរ ៨៦ពាន់ កើតឡើងសម្រាប់ខ្ញុំ ។ ពួកស្រីអប្សរនោះ ប្រព្រឹត្ត តម្រូវចិត្តខ្ញុំ ដោយកាមទាំងពួង សព្វៗ កាល ខ្ញុំគ្របសង្កត់នូវទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៥ កាលនោះ ខ្ញុំបានជា ស្តេចចក្រពត្តិឈ្មោះ**វរុណៈ** មានភោជនដ៏បរិសុទ្ធ ។ មនុស្សទាំងឡាយ នោះ មិនបាច់សាបព្រោះពូជ មិនបាច់ភ្ជួរដោយនង្គ័ល តែងបរិភោគស្រូវ សាលី ដែលដុះក្នុងទីមិនបាច់ភ្ជួរ ។ខ្ញុំសោយរាជ្យ ក្នុងអត្តភាពជាមនុស្ស នោះហើយ ក៏បានទៅ កាន់អត្តភាពជាទេវតាម្តងទៀត ការបរិបូរណ៍ ដោយភោគៈបែបនេះ ក៏កើតឡើងសម្រាប់ខ្ញុំ ក្នុងកាលនោះ ។ សត្វទាំងអស់ ទោះបីជាមិត្តក្តី មិនមែនជាមិត្តក្តី មិនដែលបៀតបៀនខ្ញុំ ខ្ញុំរមែងជាទីស្រឡាញ់នៃសត្វ*

ទាំងពួង នេះជា ផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣០ពាន់ ព្រោះហេតុដែលខ្ញុំបានឱ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃគ្រឿងក្រអូប និងគ្រឿងលាប ។

ក្នុងកទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជនមានអានុភាពច្រើន ជា**រាជឥសី** មានកម្លាំងច្រើន ។ ខ្ញុំនោះតាំង នៅក្នុងសីល ៥ ហើយញ៉ាំងពួកជនច្រើននាក់ឱ្យដល់នូវសុគតិ ខ្ញុំជាទីស្រឡាញ់ នៃទេវតាទាំងឡាយ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យ ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា **ព្រះបិលិន្ទវច្ឆត្ថេរ** មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ៕

(ចប់ បិលិន្ទវច្ឆត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ១៣៤-១៣៦)

## ៣.ឧបវាណត្ថេរាបទាន
## (ផលនៃការថ្វាយទង់ ចំពោះព្រះស្តូបព្រះបទុមុត្តរៈសម្ពុទ្ធ)

ព្រះជិនស្រីសម្ពុទ្ធ ព្រះនាម**បទុមុត្តរៈ** ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។

មហាជនមកជួបជុំគ្នា បូជាព្រះតថាគត ធ្វើជើងថ្ករដ៏វិចិត្រ ហើយលើកតម្កល់ព្រះសរីរៈ ។ ពួកមហាជនទាំងនោះ ព្រមទាំងទេវតា និងមនុស្ស លុះធ្វើព្រះសរីរៈកិច្ចរួចហើយ ប្រមូលព្រះធាតុត្រង់កន្លែងជើង

ថ្ករនោះ មកធ្វើព្រះពុទ្ធស្តូប ។ ជាន់ទី ១ ធ្វើដោយ**មាស** ជាន់ទី ២ ធ្វើដោយ**កែវមណី** ជាន់ទី ៣ ធ្វើដោយ**ប្រាក់** ជាន់ទី ៤ ធ្វើដោយ**កែវផលិក** ។ ជាន់ទី ៥ នៃព្រះស្តូបនោះ ធ្វើដោយ**កែវទទឹម** ជាន់ទី ៦ ធ្វើដោយ**កែវមរកត** ខាងលើធ្វើដោយ**រតនៈ**គ្រប់យ៉ាង ។ ទ្រនាប់ខ្សាច់ (នៃព្រះស្តូប) ធ្វើដោយ**កែវមណី** បង្កាន់ដៃធ្វើដោយ**កែវ** តួព្រះស្តូប ធ្វើដោយ**មាសសុទ្ធ**ទាំងអស់ កម្ពស់ឡើងទៅលើមួយយោជន៍ ។ កាលនោះ ទេវតាមកជួបជុំគ្នា ត្រង់កន្លែងនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ជាតាទិបុគ្គល ។ ព្រះធាតុឥតមានបែកខ្ញែកចេញពីគ្នា ព្រះសារីរិកធាតុនៅជាដុំមួយ (បើដូច្នោះ) ពួកយើង នឹងធ្វើព្រះស្តូបស្រោបលើ**ព្រះពុទ្ធស្តូប**នេះ ។

ពួកទេវតាបានបង្កើនកម្ពស់មួយយោជន៍ដទៃទៀត ដោយកែវទាំង ៧ ប្រការ ព្រះស្តូបនោះទៅជាមានកម្ពស់ ២ យោជន៍ តែងកំចាត់បង់ នូវងងឹត សព្វៗ កាល ។ គ្រានោះ **ពួកនាគ**មកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស និងទេវតា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្សនិងទេវតា មិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ **ពួកនាគ**ទាំងនោះ ប្រមូល**កែវឥន្ទនីល កែវមហានីល**ទាំង**កែវមណី** មានរស្មីរុងរឿង ក្នុងទីជាមួយគ្នា ហើយស្រោបព្រះពុទ្ធស្តូប ។ ព្រះពុទ្ធចេតិយទាំងមូល ប្រដាប់ដោយ**កែវមណី** មាន**កំពស់** ៣ យោជន៍ តែងផ្សាយចេញនូវពន្លឺ ក្នុងកាលនោះ ។ កាលនោះ **ពួកគ្រុឌ**មកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា **ពួកមនុស្ស ទេវតានិងនាគ**ទាំងឡាយ

បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្ស និង ទេវតាទាំងឡាយ មិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើ ព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។

**គ្រុឌ**ទាំងនោះបានធ្វើព្រះស្តូប ប្រដាប់ដោយ**កែវមណី**សុទ្ធឱ្យជាគ្រឿងស្រោប មានទំហំប៉ុនគ្នា **ពួកគ្រុឌ**ទាំងនោះ បានធ្វើ **ពុទ្ធចេតិយ** ឱ្យមានកម្ពស់កើនមួយយោជន៍ទៀត ។ **ព្រះពុទ្ធស្តូប** ទៅជាមានកម្ពស់ ៤ យោជន៍ រុងរឿងញាំងទិសទាំងអស់ឱ្យភ្លឺ ដូចព្រះ- អាទិត្យដែលរះឡើង ។ កាលនោះ **ពួកកុម្ភណ្ឌ**មកជួបជុំគ្នា ហើយប្រឹក្សា ជាមួយ **ពួកមនុស្សទេវតា នាគនិងគ្រុឌ**ទាំងឡាយ បាននាំគ្នាធ្វើ**ព្រះស្តូប** ដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរ ផ្សេងៗគ្នា ពួកយើងកុំធ្វេសប្រហែស ឡើយ ព្រោះមនុស្ស និង ទេវតាទាំងឡាយមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើ**ព្រះស្តូប** ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយដោយកែវទាំងឡាយតទៅទៀត ។ **ពួកកុម្ភណ្ឌ**ទាំងនោះ បានធ្វើ**ពុទ្ធចេតិយ** ឱ្យកើនកម្ពស់មួយយោជន៍ ទៅទៀត **ព្រះស្តូប**ទៅជាមានកម្ពស់ ៥យោជន៍ តែងរុងរឿងក្នុង កាលនោះ ។

លំដាប់នោះ **ពួកយក្ខ**មកជួបជុំគ្នា ត្រង់កន្លែង**ព្រះស្តូប**នោះហើយប្រឹក្សាជាមួយគ្នាថា **ពួកមនុស្ស ទេវតា នាគ កុម្ភណ្ឌ** និងគ្រុឌ ទាំងឡាយ បានធ្វើ**ព្រះស្តូប**ដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្សនិងទេវតាទាំងឡាយ មិនប្រហែស ពួកយើងនឹងធ្វើ**ព្រះស្តូប**ថ្វាយព្រះលោកនាថ ព្រះអង្គជា**តាទិបុគ្គល** ពួកយើងនឹងស្រោប**ពុទ្ធចេតិយ** ដោយ**កែវផលិក** តទៅទៀត ។ **ពួកយក្ខ**ទាំង

នោះ បានធ្វើ**ពុទ្ធចេតិយ**ឱ្យកើនកម្ពស់ ១យោជន៍ទៅទៀត **ព្រះស្តូប**ទៅជាមានកម្ពស់ ៦យោជន៍ តែងរុងរឿង ក្នុងកាលនោះ ។ គ្រានោះ **ពួកគន្ធព្វ**ប្រជុំប្រឹក្សាក្នុងទីជាមួយគ្នាថា **ពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ និងយក្ខ**ទាំងឡាយ ទាំងអស់គ្នាបានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ឯពួកយើងមិនបានធ្វើស្តូប ក្នុងទីនោះឡើយ បើដូច្នោះពួកយើងនឹងធ្វើ**ព្រះស្តូប**ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។

**ពួកគន្ធព្វ**ទាំងនោះ បានធ្វើថ្នាក់ ៧ ជាន់ ដរាប់តាំងពីទ្រនាប់ខ្សាច់ឡើងទៅ បានធ្វើ**ព្រះស្តូប**សុទ្ធតែជាវិការៈនៃ**មាស**ទាំងអស់ ក្នុងកាលនោះ ។ **ព្រះស្តូប**ទៅជាមានកម្ពស់ ៧ យោជន៍ តែងរុងរឿងក្នុងកាល នោះ គេឥតដឹងថាយប់ថ្ងៃ ព្រោះពន្លឺមាននៅសព្វ ៗ កាល ។ ព្រះចន្ទ ព្រះអាទិត្យពួកផ្កាយ គ្របសង្កត់ពន្លឺ**ព្រះស្តូប**នោះមិនបាន ឯប្រទីបរុង រឿងតែក្នុងទីចម្ងាយ ១០០យោជន៍ជុំវិញ ។ ក្នុងកាលនោះមនុស្ស ទាំងឡាយណាមួយ បូជា**ព្រះស្តូប** មនុស្សទាំងនោះ មិនឡើងកាន់ **ព្រះស្តូប** មនុស្សទាំងនោះ តែងបោះទៅឮដ៏ អាកាស។ មាន**យក្ខ**មួយ ឈ្មោះ**អភិសម្មតៈ** ដែលពួកទេវតាតាំងទុកហើយ ចាំទទួលទង់ ឬកម្រងផ្កាឮដ៏ខាងលើ ។ មនុស្សទាំងនោះ មិនឃើញ**យក្ខ**នោះទេ ឃើញតែកម្រងនៃផ្កាអណ្តែតទៅ លុះឃើញកម្រងផ្កាទាំងនោះ ហើយក៏ដើរទៅ ពួកមនុស្សទាំងអស់នោះឯង តែងទៅកាន់**សុគតិ** ។

ពួកមនុស្ស ទាំងអ្នកខុសក្នុងសាសនា ទាំងអ្នកជ្រះថ្លា ក្នុងសាសនាដែលចង់ឃើញបាដិហារ្យ តែងបូជា**ព្រះស្តូប** ។

គ្រានោះ ខ្ញុំកើតជាអ្នកកំសត់នៅក្នុង**ក្រុងហង្សវតី** បានឃើញជន

*រីករាយហើយ ក៏គិតយ៉ាងនេះក្នុងកាលនោះថា* ***ព្រះស្តូប****ដែលបញ្ចុះព្រះសារីរិកធាតុ ប្រាកដដូចនេះ របស់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនុ៎ះ មានបុណ្យដ៏លើសលុប ពួកជននេះមានចិត្តត្រេកអរហើយ ចំពោះជនអ្នកធ្វើនូវសក្ការៈ រមែងមិនក្តៅក្រហាយ ។ អាត្មាអញនឹងធ្វើសក្ការៈ ថ្វាយព្រះលោកនាថ ជាតាទិបុគ្គលដែរ នឹងបានជាព្រះទាយាទក្នុងធម៌ របស់ព្រះលោកនាថអង្គនោះ ក្នុងកាលអនាគត ។ ខ្ញុំក៏លើកឡើងនូវសំពត់ របស់ដាំងជ្រលក់ដែលបោកគក់ យ៉ាងស្អាត ភ្ជួរនឹងចុងឫស្សី ហើយលើកឡើងជាទង់ ឮដ៏អាកាស ។* ***អភិសម្មតយក្ស*** *រីករាយកាន់ទង់របស់ខ្ញុំ (បិតនៅ) ឮដ៏អាកាស ខ្ញុំឃើញទង់ ដែលត្រូវខ្យល់បក់រវិចហើយ ក៏ញុំាងសេចក្តីរីករាយ ឱ្យកើតដោយក្រៃលែង ។ ខ្ញុំធ្វើចិត្តឱ្យជ្រះថ្លា ចំពោះទង់នោះហើយ ក៏ចូលទៅរកព្រះសមណៈ ថ្វាយបង្គំទូលសួរនូវផលទង់នឹងភិក្ខុនោះ ។*

*ភិក្ខុនោះសម្តែងនូវកិរិយាកើតឡើង នៃសេចក្តីត្រេកអរ និង****បីតិ*** *របស់ខ្ញុំ ប្រាប់ខ្ញុំថា អ្នកនឹងបានទទួលផលរបស់ទង់ នោះ សព្វៗ កាល ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពល ថ្មើរជើង នឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ តូរ្យន្ត្រី ៦០ ពាន់និងស្គរដែលគេតាក់តែងយ៉ាងល្អ នឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ ពួកនារី ៨៦ ពាន់ មានខ្លួនតាក់តែងយ៉ាងល្អ មានសំពត់និងគ្រឿងអម្ពរដ៏វិចិត្រ ពាក់កែវមណី និងកុណ្ឌល ។ ពួកនារីទាំងនោះមានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានដងខ្លួនរៀវល្អ នឹងចោមរោមអ្នក អស់កាល ជានិច្ច នេះជាផលនៃការថ្វាយទង់ ។*

អ្នកនឹងរីករាយ ក្នុងទេវលោកអស់ ៣០ ពាន់កប្ប នឹងបានសោយ**ទេវរាជ្យ** ជាធំជាងទេវតា អស់ ៨០ ដង ។ នឹងបានជាស្តេច**ចក្រពត្តិ** អស់មួយពាន់ដង នឹងសោយ ប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយ**អសង្ខៃយ្យ**ជាតិ ។

កន្លងទៅមួយសែនកប្ប ព្រះសាស្តា**ព្រះនាមគោតម** ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ អ្នកនឹង ច្យុតចាកទេវលោកមក ត្រូវកុសលមូលដាស់តឿន ប្រកបដោយបុញ្ញកម្ម នឹងកើតជាព្រាហ្មណ៍ ។ អ្នកនឹងលះចោលទ្រព្យ ៨០ កោដិ និងទាសកម្មករជាច្រើន ហើយបួសក្នុងសាសនា របស់ព្រះមានព្រះភាគ**ព្រះនាមគោតម** ។ អ្នកនឹង មានឈ្មោះថា**ឧបវាណៈ** ញុំាងព្រះសម្ពុទ្ធ**ព្រះនាមគោតម** ដ៏ប្រសើរជាង**ពួកសក្យៈ** ឱ្យត្រេកអរ ហើយនឹងបានជាសាវ័ក របស់ព្រះសាស្តា ។

កុសលកម្មដែលខ្ញុំធ្វើហើយ ក្នុងរវាងមួយសែនកប្ប បានឱ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំផុតស្រឡះហើយ (ចាកអាសវធម៌) ដូចសន្ទុះ នៃព្រួញ (ដែលផុតស្រឡះចាកធ្នូ) ខ្ញុំដុតបំផ្លាញនូវកិលេសទាំងឡាយ របស់ខ្ញុំហើយ ។ កាលដែលខ្ញុំកើតជាស្តេចចក្រពត្តិ ជាឥស្សរៈ ក្នុងទ្វីប ទាំង ៤ ទង់ផុសឡើង ក្នុងរវាង ៣ យោជន៍ដោយជុំវិញ សព្វៗ កាល ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការថ្វាយទង់ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និង អភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ក៏បានប្រតិបត្តិ ហើយ ។

*បានឮថា **ព្រះឧបវាណត្ថេរ** មានអាយុ បានសម្ដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។*

*(ចប់ ឧបវាណត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ១៥៩-១៦៨)*

## ៤.ធូបទាយកត្ថេរាបទាន

## (*ផលនៃការបូជាធូប ក្នុងព្រះកុដិ ព្រះសិទ្ធត្ថៈសម្ពុទ្ធ*)

*ខ្ញុំមានចិត្តជ្រះថ្លាបានថ្វាយធូប សម្រាប់អុជក្នុង**កុដិ**ចំពោះព្រះមានព្រះភាគ ព្រះនាម**សិទ្ធត្ថៈ** ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំចាប់កំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ខ្ញុំរមែងជាទីស្រឡាញ់ របស់ជនទាំងពួង នេះជាផលនៃការថ្វាយធូប ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយធូប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយធូប ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។*

*បានឮថា **ព្រះធូបទាយកត្ថេរ** មានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ ធូបទាយកត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ១៧៨)*

## ៥.មហាកច្ចាយនត្ថេរាបទាន

## (*ផលនៃការធ្វើចេតិយ និងការលាបទឹកមាសជាដើម*)

*ខ្ញុំបានធ្វើចេតិយឈ្មោះ**បទុមៈ** ជាវិការៈនៃផ្កាំងថ្មលាប ដោយ*

ទឹកមាស ថ្វាយព្រះលោកនាថ ព្រះនាម**បទុមុត្តរៈ**។

ខ្ញុំលើកឆត្រជាវិការៈនៃ**កែវ** និងផ្ទិតពោមសត្វ ថ្វាយព្រះពុទ្ធ ជា ផៅពង្សនៃលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ គ្រានោះ ពួក**កុម្មទេវតា**ទាំងអស់ ទាំងប៉ុន្មាន បានមកប្រជុំគ្នាថា **ព្រះលោកនាថ**(១) នឹងសម្តែងផលនៃ**អាសនៈ** និងឆត្រជាវិការៈនៃ**កែវ** ។ ពួកយើងនឹងស្តាប់ នូវផលទាំងពួងនោះ កាលបើព្រះសាស្តាកំពុងសម្តែង ពួកយើងនឹង ញ៉ាំងសេចក្តីរីករាយ ឱ្យកើតដោយក្រៃលែង ក្នុងសាសនារបស់ ព្រះសម្មាសម្ពុទ្ធ ។ **ព្រះសយម្ភូ**(២) ជាអគ្គបុគ្គល ភិក្ខុសង្ឃចោមរោម ទ្រង់គង់លើអាសនៈមាសហើយ ត្រាស់នូវគាថា ទាំងឡាយនេះថា

កុលបុត្រណា បានថ្វាយ**អាសនៈមាស** ប្រដាប់ដោយ**កែវ**នេះ តថាគតនឹងសម្តែងសរសើរកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតសម្តែងចុះ ។ កុលបុត្រនោះនឹងបាន ជាធំជាងទេវតា សោយទេវរាជ្យអស់ ៣០កប្ប នឹងមានរស្មីគ្របសង្កត់ទី ១០០ យោជន៍ ដោយ ជុំវិញ ។ កុលបុត្រនោះ លុះត្រឡប់មកកាន់មនុស្សលោកវិញ នឹងបានជា ស្តេចចក្រពត្តិ មាននាមថា**បភស្សរៈ** នឹងមានតេជៈដ៏ខ្ពង់ខ្ពស់ ។

ព្រះបរមក្សត្រនោះ នឹងរុងរឿង អស់ទី ៨ ហត្ថដោយជុំវិញទាំងថ្ងៃទាំងយប់ ដូចជាព្រះអាទិត្យរះឡើង ។ កន្ទង់ទៅមួយសែនកប្ប និងមានព្រះសាស្តា ព្រះនាម**គោតម** កើតក្នុង**ឱក្កាក**ត្រកូល ត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ ច្យុតចាកឋានតុសិតមក ត្រូវកុសលមូលដាស់តឿន នឹង

(១).លោកនាថ អ្នកដែលជាពំនាក់របស់សត្វលោក គឺព្រះសម្មាសម្ពុទ្ធ ។

(២).សយម្ភូ ន. អ្នកកើតឯង, អ្នកបានសម្រេចគុណវិសេសខ្លួនឯង, ព្រះអរហន្តសម្មាសម្ពុទ្ធ, ព្រះបច្ចេកពុទ្ធ ។ (សទ្ទានុក្រមព្រះពុទ្ធសាសនា)

*បានជាព្រាហ្មណ៍ មាន**នាមកច្ចានៈ** ។ លុះកាលជាខាងក្រោយមក**កច្ចានៈ** នោះចេញបួស នឹងបានជាអ្នកប្រាជ្ញ មិនមានអាសវៈ **ព្រះគោតមជា** ប្រទីបក្នុងលោក ទ្រង់នឹងតាំង (កច្ចានៈនោះ) ក្នុងទីជា**ឯតទគ្គៈ** ។ **កច្ចានៈ** នោះ នឹងសម្តែងនូវប្រស្នាដែលគេសួរយ៉ាងសង្ខេប ដោយពិស្តារបាន មួយវិញទៀត **កច្ចានៈ**នោះ កំពុងសម្តែងនូវប្រស្នានោះ អាចនឹងបំពេញ អធ្យាស្រ័យ (របស់អ្នកសួរ) បាន ។ កុលបុត្រនោះ កើតក្នុងត្រកូលស្តុក-ស្តម្ភ ជាព្រាហ្មណ៍ដល់នូវត្រើយនៃមន្ត លះបង់ទ្រព្យនិងស្រូវ ចូលទៅ កាន់ផ្នួស ។*

*កាលបើមានប្រស្នា ដែលជនទាំងឡាយសួរដោយបំប្រួញ ខ្ញុំសម្តែងដោយពិស្តារ បំពេញអធ្យាស្រ័យ នៃពួកជននោះ ខ្ញុំញ៉ាំងព្រះសម្ពុទ្ធ ប្រសើរជាងសត្វជើងពីរ ឱ្យត្រេកអរ ។*

***ព្រះសយម្ភូ** ជាអគ្គបុគ្គល ព្រះអង្គមានព្យាយាមធំ ដែលខ្ញុំធ្វើឱ្យរីករាយហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយទ្រង់តាំង ខ្ញុំក្នុងទីជា**ឯតទគ្គៈ**។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះកច្ចាយនត្ថេរ**មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

*(ចប់ កច្ចាយនត្ថេរាបទាន បិដកភាគ ៧២ ទំព័រ១៩០-១៩៣)*

# ៦.អាយាគទាយកត្ថេរាបទាន

## (ផលនៃការថ្វាយបង្គំព្រះស្តូប និងការធ្វើរោងសម្នាក់)

*កាលព្រះលោកនាថ ព្រះនាម**សិខី** ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ បរិនិព្វានហើយ ខ្ញុំរីករាយ បានថ្វាយបង្គំ **ព្រះស្តូប**ដ៏ប្រសើរ ដោយចិត្តរីករាយ ។ កាលនោះ ខ្ញុំបានឱ្យជាងឈើ និយាយកាត់ថ្លៃ ហើយឱ្យថ្លៃ ខ្ញុំរីករាយឱ្យជាងឈើធ្វើរោងសម្នាក់ ដោយចិត្តរីករាយ ។ ខ្ញុំនៅជាប់ មិនដាច់ក្នុងទេវលោក អស់ ៨កប្ប ខ្ញុំអន្ទោលទៅរាត់រាយ ក្នុង កប្បដ៏សេស ។ ពិសមិនជ្រាបទៅក្នុងកាយ ទាំងគ្រឿងសស្ត្រាក៏មិនមុតខ្ញុំ ខ្ញុំមិនស្លាប់ក្នុងទឹក នេះជាផលនៃរោងសំណាក់ ។ បើខ្ញុំប្រាថ្នាទឹកភ្លៀង មហាមេឃក៏បង្អុរភ្លៀងមក ទាំងពួកទេវតា តែងលុះអំណាច របស់ខ្ញុំ នេះជាផល នៃបុញ្ញកម្ម ។ ខ្ញុំបរិបូណ៌ដោយកែវ ៧ ប្រការអស់ ៣០ដង ពួកជនណាមួយ មិនមើលងាយខ្ញុំឡើយ នេះជាផលនៃ បុញ្ញកម្ម ។*

*ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឱ្យជាងធ្វើរោងសម្នាក់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃរោងសម្នាក់ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះអាយាគទាយកត្ថេរ** មានអាយុ បានសម្តែង គាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ អាយាគទាយកត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ២០២-២០៣)*

## ៧.កប្បរុក្ខិយត្ថេរាបទាន
## (ផលនៃការដាំដើមកប្បព្រឹក្ស និងព្យួរនូវសំពត់ដ៏វិចិត្រ)

ខ្ញុំបានដាំនូវដើម**កប្បព្រឹក្ស**មួយដើម ព្រមទាំងព្យួរនូវសំពត់ដ៏**វិចិត្រ** ទាំងឡាយ នៅខាងមុខនៃ**ព្រះស្តូប** ដ៏ប្រសើរ របស់ព្រះមានព្រះ-ភាគ **ព្រះនាមសិទ្ធត្ថៈ** ។

ខ្ញុំទៅចាប់កំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស សឹងមានដើម**កប្បព្រឹក្ស**ដ៏ល្អ ប្រតិស្ឋានទៀបមាត់ទ្វារផ្ទះនៃខ្ញុំ ។ យើងទាំងឡាយ គឺ ខ្ញុំផង បរិស័ទផង ពួកជនណានីមួយដែលមានផ្ទាំស្មើគ្នានឹងខ្ញុំផង តែងកាន់យកសំពត់ អំពីដើម**កប្បព្រឹក្ស**នោះមកស្លៀកដណ្តប់ ក្នុងកាលនោះ ។ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ ដាំដើមឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃដើម**កប្បព្រឹក្ស** ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានជា**ក្សត្រិយ៍ ចក្រពត្តិ ៨ ដង** ព្រះនាម**សុចេលៈ**ដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទាំងមានកម្លាំងច្រើន ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ក៏បានប្រតិបត្តិហើយ ។

បានឮថា **ព្រះកប្បរុក្ខិយត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕

(ចប់ កប្បរុក្ខិយត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ២០៤-២០៥)

## ៨.សុគន្ធត្ថេរាបទាន
## (ផលនៃការបូជាទង់ដ៏វិចិត្រចំពោះព្រះស្តូប) សង្ខេប

ខ្ញុំប្រកបព្រមហើយ ដោយបុព្វកម្មរបស់ខ្លួន មានចិត្តមូលតែមួយ មានចិត្តតាំងមាំ ជា**ធម្មនិម្មិត** ជាបុត្រកើតអំពីទ្រូងរបស់**ព្រះសម្មាសម្ពុទ្ធ** ។ ខ្ញុំចូលទៅអង្គុយជិតព្រះពុទ្ធជា**ធម្មរាជ** ហើយសួរប្រស្នាដ៏ប្រសើរ ឯព្រះអង្គកាលនឹងសម្តែងនូវប្រស្នាដល់ខ្ញុំ ទ្រង់នាំមកនូវ**ធម្មសោតៈ** ។

ខ្ញុំដឹងនូវធម៌ របស់**ព្រះធម្មរាជ**នោះហើយ ត្រេកអរនឹងសាសនា កំណត់ដឹងនូវ**អាសវៈ**ទាំងពួង ជាអ្នកមិនមាន**អាសវៈ** ។ ក្នុងកប្បទីមួយសែន អំពី**ភទ្ទកប្ប**នេះ ព្រះនាយកព្រះនាម **បទុមុត្តរៈ** ទ្រង់បរិនិព្វាន មិនមានឧបាទាន ដូចប្រទីបដែលរលត់ ព្រោះអស់ប្រេង ។ **ព្រះស្តូប**ជាវិការៈនៃកែវ ប្រកបដោយយោជន៍ ៧ណា ខ្ញុំបានបូជាទង់ដ៏ល្អ ជាទង់ទាំងអស់ ជាទីរីករាយនៃចិត្ត ចំពោះ**ព្រះស្តូប**នោះ ។ កូនដែលកើតអំពីទ្រូងរបស់ខ្ញុំ **ឈ្មោះតិស្សៈ** អគ្គសាវ័ក របស់ព្រះពុទ្ធ ព្រះនាម**កស្សបៈ** ជាទាយាទក្នុងសាសនានៃ**ព្រះជិនស្រី**[១] ។ ខ្ញុំមានចិត្តថោកទាប បានពោលពាក្យមិនពីរោះ ដល់**ព្រះតិស្សៈ**នោះ ព្រោះតែផលកម្មប៉ុណ្ណោះ ទើបខ្ញុំមានសេចក្តីល្អ ក្នុងកាលជាខាងក្រោយបំផុត ។ **ព្រះមុនី**ទ្រង់មានព្យាយាមធំ ស្វែងរកប្រយោជន៍ មានសេចក្តីករុណា ទ្រង់ឈ្នះកិលេស បានបំបួសខ្ញុំ ក្នុង**បច្ឆិមសយនៈ** ក្នុង**សាលវ័ន** ជាទីសម្រាប់ចេញចូល។ ឥឡូវនេះ **បព្វជ្ជា**(របស់ខ្ញុំ) មានក្នុងថ្ងៃនេះ **ឧបសម្បទា** ក៏មានក្នុងថ្ងៃនេះ បរិនិព្វានក៏មានក្នុងថ្ងៃនេះ ក្នុងទីចំពោះព្រះភ័ក្ត្រ នៃព្រះសម្ពុទ្ធទ្រង់ឧត្តម

---

(១).ជិនស្រី ន. លោកអ្នកឈ្នះមានសិរីសួស្តី (ព្រះសម្មាសម្ពុទ្ធ) ។

ជាង៌សត្វជើងពីរ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ក៏បានប្រតិបត្តិហើយ ។

បានឮថា **ព្រះសុភទ្ទត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ៕

(ចប់ សុភទ្ទត្ថេរាបទាន បិដកភាគ ៧២ ទំព័រ២២៨-២៣០)

## ៩.ចន្ទត្ថេរាបទាន
## (ផលនៃការធ្វើចេតិយ ស្រោបដោយផ្កាម្លិះ)

ខ្ញុំធ្វើ**ចេតិយ** ស្រោបដោយផ្កាម្លិះទាំងឡាយ បូជាចំពោះព្រះមានព្រះភាគ ព្រះនាម**សិទ្ធត្ថៈ** ជាច្បងក្នុងលោកទ្រង់មិនញាប់ញ័រ ដោយលោកធម៌ ។ លុះខ្ញុំរៀបចំស្រេចហើយ ទើបបង្អោនថ្វាយផ្កានោះ ចំពោះព្រះពុទ្ធ ហើយយកផ្កាដ៏សេសបង្អោនថ្វាយទៀត ។ ខ្ញុំមានចិត្តជ្រះថ្លាមានចិត្តរីករាយ នាំចេតិយទៅថ្វាយ ចំពោះព្រះពុទ្ធ អគ្គនាយកក្នុងលោក ព្រះអង្គប្រាកដស្មើដោយ**ចេតិយមាស** ។

ព្រះសម្ពុទ្ធ មានសេចក្តីសង្ស័យកន្ទង់បង់ហើយ មានពួក**ព្រះខីណាស្រព**ដែលមានអន្ទង់ធ្នង់ផុតចោមរោមហើយ ព្រះអង្គគង់នៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្រណា បានថ្វាយដល់តថាគត នូវ**ចេតិយ**ដែលធ្វើដោយផ្កាមានក្លិនដូចជាទិព្វផ្សាយទៅ តថាគតនឹងសម្តែងសរសើរ នូវកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនេះ លុះច្យុត

ចាកអត្តភាពនេះទៅ នឹងទៅកើតក្នុងទេវលោក មានពួកទេវតាចោមរោម ជាអ្នកបរិបូណ៌ដោយផ្កាម្ទិះ ។ ទីនៅរបស់កុលបុត្រនោះ ដ៏ខ្ពស់ ជាវិការៈនៃមាស និងកែវមណី ប្រាសាទទាំងឡាយ ដែលបុញ្ញកម្មតាក់តែងហើយ នឹងកើតប្រាកដ ។ កុលបុត្រនោះ នឹងសោយទេវរាជ្យ នឹងសោយទិព្វសម្បត្តិ មានពួកស្រ្តីអប្សរចោមរោមអស់ ៧៤ដង ។ នឹងសោយរាជសម្បត្តិ លើផែនដី គ្រប់គ្រងផែនដីអស់ ៣០០ដង នឹងបានជាស្តេចចក្រពត្តិអស់ ៧៥ដង ។

កុលបុត្រនោះ នឹងកើតជាក្សត្រ ជាអធិបតីនៃមនុស្ស មាននាមថា **ទុជ្ជយៈ** អាស្រ័យនូវបុញ្ញកម្មរបស់ខ្លួន ហើយរងនូវផលបុណ្យនោះ ។ កុលបុត្រនោះនឹងមិនទៅយកកំណើត ជា**វិនិបាត**ឡើយ ។ ទៅយក អត្តភាពតែជាមនុស្ស កុលបុត្រនោះ បានសន្សំប្រាក់ទុកច្រើន រាប់រយ កោដិ ។ កុលបុត្រនោះ នឹងកើតក្នុងកំណើតជាព្រាហ្មណ៍ ជាអ្នកចេះដឹង មានប្រាជ្ញា ជាឱរសជាទីស្រឡាញ់នៃ**វង្គន្តព្រាហ្មណ៍ និងនាង សារីព្រាហ្មណី** ។ លុះកាលជាខាងក្រោយ កុលបុត្រនោះ មាននាមថា **ចូឡចុន្ទៈ** នឹងបានបួសក្នុងសាសនា របស់ព្រះសម្ពុទ្ធ ជា**អង្គីរស** នឹងបានជាសាវ័ក របស់ព្រះសាស្តា ។ **ចូឡចុន្ទៈ**នោះ ជាសាមណេរ មានសន្តានស្ងប់ស្ងាត់ បានជា**ព្រះខីណាស្រព** កំណត់ដឹងនូវ**អាសវៈ** ទាំងពួង ជាអ្នកមិនមាន**អាសវៈ នឹងបរិនិព្វាន** ។

ខ្ញុំបានបម្រើព្រះសម្ពុទ្ធ មានព្យាយាមធំផង បម្រើពួកភិក្ខុអ្នកមាន**សីល**ជាទីស្រលាញ់ដទៃច្រើនអង្គផង បម្រើ**ព្រះថេរៈ**ជាបងនៃខ្ញុំផង ដើម្បីសម្រេចប្រយោជន៍ ដ៏ខ្ពង់ខ្ពស់ ។

ខ្ញុំបម្រើ**ព្រះថេរៈ**ជាបង៍ របស់ខ្ញុំរួចហើយ រើស**ព្រះធាតុ**ដាក់ក្នុងបាត្រ នាំមកថ្វាយព្រះសម្ពុទ្ធ ជាច្បងក្នុងលោក ដ៏ប្រសើរជាង**នរៈ** ។ ព្រះពុទ្ធ (ព្រះអង្គប្រសើរ) ក្នុងលោក ព្រមទាំងទេវលោក ទ្រង់ទទួល ដោយព្រះហស្តទាំងពីរ ហើយ បង្ហាញនូវ**ព្រះធាតុ**នោះ ទើបប្រកាស តាំងជា**អគ្គសាវ័ក** ។ ឯចិត្តរបស់ខ្ញុំ រួចស្រឡះហើយ សទ្ធារបស់ខ្ញុំ តម្កល់ ខ្ជាប់ហើយ ខ្ញុំកំណត់ដឹង នូវ**អាសវៈ**ទាំងពួង ជាអ្នកមិនមាន **អាសវៈ** ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំ បានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា **ព្រះចុន្ទត្ថេរ** មានអាយុបានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕

(ចប់ ចុន្ទត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ២៣០-២៣៣)

## ១០.នាគសមាលត្ថេរាបទាន

## (ផលនៃការបូជាផ្កាដែលរើសតាមផ្លូវធំ)

ខ្ញុំបានរើសផ្កាដែលគេបោលក្នុងផ្លូវធំ ហើយបូជា**ព្រះស្តូប**របស់**ព្រះសិខី** ជាផៅពង្សនៃលោក ។ ក្នុងកប្បទី៣១ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃការបូជាចំពោះ**ព្រះស្តូប** ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ព្រះនាម**បុប្ផិយៈ** ទ្រង់មានកម្លាំងបរិបូណ៌ ដោយរតនៈ៧ប្រការ ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ៕

*បានឮថា **ព្រះនាគសមាលត្ថេរ** មានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។*

*(ចប់ នាគសមាលត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ២៦៩)*

## ១១.សុធាបិណ្ឌិយត្ថេរាបទាន

## (ផលនៃការជួសជុលចេតិយព្រះសិទ្ធត្ថៈសម្ពុទ្ធ)

*កាលបុគ្គលបូជា ចំពោះបុគ្គលគួរបូជា ទោះបីព្រះពុទ្ធ **ឬសាវ័ក** ដែលកន្លងផុតនូវធម៌ជាគ្រឿងយឺតយូរ ឆ្លងផុតនូវសេចក្ដីសោកនិងការខ្សឹកខ្សួល ។ កាលបុគ្គលបូជាចំពោះ បុគ្គលទាំងនោះ ដែលមានសភាពដូច្នោះ មានទុក្ខរលត់ហើយ លោកមិនមានភ័យអំពីទីណា បុគ្គលណាមួយមិនអាចនឹងរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ ឬមានប្រមាណប៉ុណ្ណោះឡើយ ។ ក្នុងលោកនេះ បុគ្គលណា មួយទទួលនូវភាពជាធំ ក្នុងទ្វីបទាំង ៤ ទទួលនូវ ឥស្សរភាពនេះ របស់បុគ្គលនុ៎ះ មិនដល់មួយចំណែក ទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លា បានបូកបាយអ ក្នុងចន្លោះឥដ្ឋចេតិយ របស់ព្រះសម្ពុទ្ធ ព្រះនាម **សិទ្ធត្ថៈ**ទ្រង់ប្រសើរជាងពួក**នរៈ** ។ ក្នុងកប្ប ៩៤ អំពីកប្បនេះ ព្រោះហេតុដែល បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំ មិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃការជួសជុល**ចេតិយ** ។*

*ក្នុងកប្បទី ៣០ អំពីកប្បនេះ ខ្ញុំបានជាស្ដេចចក្រពត្តិ ១៣ដង មាននាមថា**បដិសង្ខារសៈ** ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ។ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា*

*របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះសុជាបិណ្ឌិយត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ សុជាបិណ្ឌិយត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ២៩៨-២៩៩)*

## ១២.គន្ធមាលិយត្ថេរាបទាន

## (*ផលនៃការកសាងព្រះស្តូបប្រកបដោយគ្រឿងក្រអូប*)

*ខ្ញុំបានកសាងព្រះស្តូប ប្រកបដោយគ្រឿងក្រអូប ស្រោបបិទបាំងដោយ **ផ្កាម្ទិះ**ដ៏សមគួរដល់ព្រះពុទ្ធ (ថ្វាយ) ចំពោះព្រះមានព្រះភាគ ព្រះនាម**សិទ្ធត្ថៈ** ។ (ខ្ញុំថ្វាយបង្គំ) ព្រះសម្ពុទ្ធជាអគ្គនាយកក្នុងលោក ប្រាកដស្មើដោយ**ចេតិយ** ជាវិការៈនៃមាស ទ្រង់រុងរឿងដូច**ផ្កាពជព្រឹក្ស** ឬដូចភ្លើងកំពុងឆេះ ទ្រង់ប្រសើរ ដូចខ្លាធំនិងគោឧសភៈ ឬដូចកេសររាជសីហ៍មានជាតិដ៏ខ្ពស់ ទ្រង់គង់លើអាសនៈ ទ្រង់ជាកំពូលនៃពួកសមណៈ មានភិក្ខុសង្ឃចោមរោម។ លុះខ្ញុំ ថ្វាយបង្គំព្រះបាទា របស់ព្រះសាស្តាហើយ បែរមុខទៅឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ បានថ្វាយគ្រឿងក្រអូប និងកម្រងផ្កា ក្នុងកាលណា ។ (កាលនោះ) ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** ដោយផលនៃសក្ការៈដែល ខ្ញុំធ្វើចំពោះព្រះពុទ្ធដោយវិសេស នេះជាផលនៃ**ពុទ្ធបូជា** ។*

*ក្នុងកប្បទី៣៩ ខ្ញុំបានជាក្សត្រចក្រពត្តិ ១៦ដង ព្រះនាម **ទេវគន្ធៈ** ដូចគ្នា ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យ ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ក៏បានប្រតិបត្តិ ហើយ ។*

បានឮថា **ព្រះគន្ធមាលិយត្ថេរ** មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ៕

(ចប់ គន្ធមាលិយត្ថេរាបទាន បិដកភាគ ៧២ ទំព័រ ៣០៣-៣០៤)

**នៅក្នុងបិដកភាគ ៧២ នោះមានអានិសង្សដទៃទៀត ដូចជាការបូជាដើមពោធិព្រឹក្សជាដើម សូមលោកអ្នកអានមើលក្នុងបិដកផងចុះ។**

**(ចប់បកិណ្ណកៈ រឿងព្រះចេតិយក្នុងបិដកភាគ ៧២)**

## IV- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៣ ខ្លះៗ

### ១.បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន

### (ផលនៃការធ្វើព្រះស្តូប បញ្ចុះព្រះសារីរិកធាតុ)

កាលព្រះសុគត**ព្រះនាមអត្ថទស្សី** ទ្រង់បរិនិព្វាន ខ្ញុំបានទៅកើតក្នុងកំណើត**យក្ខ**ក្នុងលំដាប់ស្មើគ្នា កាលនោះ ខ្ញុំបានដល់នូវយស ។ ខ្ញុំគិតថា អត្តភាពជាមនុស្ស អាត្មាអញ បានមិនល្អ ភ្លឺស្វាងមិនល្អ តាំងឡើងមិនល្អ ព្រោះថាកាល ដែលភោគៈ របស់អាត្មាអញនៅមាន ព្រះសម្ពុទ្ធមានចក្ខុ ទ្រង់បរិនិព្វាន ។ សាវ័កឈ្មោះ**សាគរៈ** ជ្រាបច្បាស់នូវតម្រិះរបស់ខ្ញុំ លោកប្រាថ្នានឹងស្រង់ខ្ញុំ ទើបនិមន្តមកក្នុងសម្នាក់ ខ្ញុំ(ហើយពោលថា) នៃបុរសអ្នកមានប្រាថ្នាល្អ អ្នកយំ សោកពីរឿងអ្វី អ្នកកុំខ្លាចឡើយ ចូរប្រព្រឹត្តធម៌ចុះ ការបរិបូរណ៍ ដោយពូជគឺកុសល របស់សត្វទាំងអស់ ព្រះ

*ពុទ្ធជា ម្ចាស់បានប្រគល់ឱ្យហើយ ។ បុគ្គលណា បូជាព្រះសម្ពុទ្ធជាលោកនាយ ដែលទ្រង់គង់ព្រះជន្មនៅក្តី បូជាព្រះ សារីរិកធាតុ ប្រមាណប៉ុនគ្រាប់ស្ពៃ របស់ព្រះសម្ពុទ្ធដែលបរិនិព្វាន ហើយក្តី កាលបើចិត្តមានសេចក្តីជ្រះថ្លាស្មើ បុណ្យជា**មហគ្គតកុសល** ស្មើគ្នា (គង់ចម្រើនដល់បុគ្គលនោះ) ហេតុនោះអ្នក ចូរធ្វើ**ព្រះស្តូប** បញ្ចុះ ព្រះសារីរិកធាតុ របស់ព្រះជិនស្រីចុះ ។*

*ខ្ញុំបានស្តាប់វាចា**ព្រះសាគរត្ថេរ** ហើយខ្ញុំកសាងនូវ**ពុទ្ធស្តូប** ថែទាំ**ព្រះស្តូប**ដ៏ប្រសើររបស់ព្រះមុនី អស់ ៥ឆ្នាំ ។ បពិត្រ ព្រះអង្គជាធំ ជាងសត្វជើងពីរ ជាច្បងក្នុងលោកជា**នរាសភៈ** ខ្ញុំសោយសម្បត្តិ បាន ដល់នូវ**អរហត្ត** ដោយកុសលកម្មនោះ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ បានកើតជាស្តេចចក្រពត្តិ ៤ជាតិ ទ្រង់មានប្រាជ្ញាក្រាស់ដូចផែនដី បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះបច្ចុបដ្ឋានសញ្ញកត្ថេរ** មានអាយុបានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ២៨-២៩)*

## ២.ញាណសញ្ញកត្ថេរាបទាន

## *(ផលនៃការឃើញផ្នូកខ្សាច់)*

*ខ្ញុំនៅនាភ្នំហិមពាន្ត ឃើញផ្នូកខ្សាច់ដ៏ល្អក្នុងចន្លោះភ្នំ ខ្ញុំរឭកនូវ*

ព្រះសម្ពុទ្ធដ៏ប្រសើរថា ការប្រៀបធៀប ក្នុងញាណ (របស់ព្រះសាស្តា) មិនមានឡើយ សង្គ្រាមរបស់ព្រះសាស្តា ក៏មិនមានដែរ ព្រះសាស្តាបាន ជ្រាបនូវធម៌ទាំងពួង ទ្រង់ស៊ប់សួនដោយញាណ ។ បពិត្រព្រះអង្គជា បុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរស ដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ សភាពដទៃស្មើដោយញាណរបស់ព្រះ អង្គមិនមានឡើយ មានតែញាណរបស់ព្រះអង្គ ទើបឧត្តមជាកំណត់ ។ ខ្ញុំញុំាងចិត្តឱ្យជ្រះថ្លា ក្នុងញាណហើយ ក៏បានទៅរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ខ្ញុំបានកសាងកុសល ក្នុងកប្បដ៏សេស ។ ក្នុងកប្បទី៩១ អំពី កប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសំគាល់ ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសំគាល់ក្នុងញាណ ។

ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ជាតិ ព្រះនាម**បុឡិនបុប្ផិយៈ** ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំង ច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និង អភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។ បានឮថា **ព្រះ ញាណសញ្ញកត្ថេរ**មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយ ប្រការ ដូច្នេះ ៕

(ចប់ ញាណសញ្ញាកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៤៦-៤៧)

## ៣.អធិឆត្តិយត្ថេរាបទាន

## (ផលនៃការធ្វើឆត្ររួតដាក់ត្រង់ព្រះស្តូប)

កាលព្រះមានព្រះភាគ ព្រះនាម**អត្ថទស្សី** ទ្រង់ប្រសើរជាងពួក**នរៈ**

*ទ្រង់បរិនិព្វានហើយ ខ្ញុំបានឱ្យគេធ្វើ**ឆត្ររួត** ហើយឱ្យលើកឡើងត្រង់**ព្រះស្តូប** ។ ខ្ញុំបានមកនមស្ការព្រះលោកនាយក សព្វៗ កាល ហើយធ្វើគ្រឿងប្រក់ដោយផ្កា លើកឡើងតម្កល់ពីខាងលើនៃ**ឆត្រ** ។ ក្នុង កប្បទី១១៧ អំពីកប្បនេះ ខ្ញុំបានសោយជាទេវរាជ ខ្ញុំមិនដែលទៅកើត ជា មនុស្សម្តងឡើយ នេះជាផលនៃស្តូបបូជា ។* **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ *ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះអធិឆត្តិយត្ថេរ**មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ អធិឆត្តិយត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៦៥)*

## ៤.ថម្ភារោបកត្ថេរាបទាន

## (*ផលនៃការធ្វើដងទង់ ត្រង់ព្រះចេតិយ*)

*កាលព្រះលោកនាថព្រះនាម**ធម្មទស្សី** ជា**នរាសភៈ**ទ្រង់បរិនិព្វាន ខ្ញុំបានលើកដងទង់ ត្រង់ចេតិយរបស់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបាន ធ្វើជណ្តើរសម្រាប់ឡើងទៅកាន់**ព្រះស្តូប**ដ៏ប្រសើរ បានទាំងយកផ្កា **ជាតព្រឹក្ស**ទៅដោតលើ**ព្រះស្តូប** ដោយតាំងចិត្តថា ព្រះពុទ្ធជាបុគ្គល អស្ចារ្យព្រះធម៌ជា សភាពអស្ចារ្យ សម្បទារបស់ព្រះសាស្តានៃយើង ជារបស់អស្ចារ្យ ។ ដោយសារកុសលកម្មនេះ ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃ**ស្តូបបូជា** ។ ក្នុងកប្បទី៩៤ អំពីកប្បនេះ ខ្ញុំបានកើត ជាស្តេចចក្រពត្តិ ១៦ជាតិ ព្រះនាម**ថូបសិខៈ** ដូចគ្នា ទ្រង់មាន កម្លាំងច្រើន ។* **បដិសម្ភិទា៤**

***វិមោក្ខ៨ និងអភិញ្ញា៦*** *នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិ ហើយ ។*

*បានឮថា* ***ព្រះថម្ភារោបកត្ថេរ****មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

*(ចប់ ថម្ភារោបកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៦៦)*

## ៥.វេទិការកត្ថេរាបទាន
## (ផលនៃការសាងខឿនព្រះចេតិយ)

*កាលព្រះលោកនាថ ព្រះនាម****បិយទស្សី*** *ជានរៈដ៏ឧត្តម ទ្រង់ បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងខឿន* ***ចេតិយ****សម្រាប់ជាពុទ្ធបូជា ។ ខ្ញុំព័ទ្ធខឿននោះ ដោយ****កែវមណី*** *ហើយរៀបចំធ្វើបុណ្យឆ្លងខឿនដ៏ប្រសើរ ហើយក៏ធ្វើមរណកាល ក្នុងវេលានោះ ។ ខ្ញុំទៅកើតក្នុងកំណើតណា ៗ ទោះបីជាទេវតា ឬជាមនុស្ស ទេវតាទាំងឡាយ តែងបាំង****កែវមណី****ឮដ៏អាកាស (ចំពោះខ្ញុំ) នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី១១៦ អំពីកប្បនេះ បានកើតជា ស្តេចចក្រពត្តិ ៣៦ជាតិ ព្រះនាម****មណិប្បភាស*** *ដូចគ្នា ទ្រង់មានកម្លាំង ច្រើន ។* ***បដិសម្ភិទា៤ វិមោក្ខ៨ និង អភិញ្ញា៦*** *នេះ ខ្ញុំបានធ្វើឱ្យជាក់ ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា* ***ព្រះវេទិការកត្ថេរ****មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

*(ចប់ វេទិការកត្ថេរាបទាន បិដកភាគ៧៣ ទំព័រ ៦៧)*

## ៦.សបវារិយត្ថេរាបទាន

## (ផលនៃការចូលទៅបម្រើព្រះស្តូប)

*ព្រះជិនស្រីសម្ពុទ្ធ ព្រះនាម**បទុមុត្តរៈ** ជាច្បងក្នុងលោកជា **នរាសភៈ** រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។លុះ **ព្រះមហាវីរៈ** ទ្រង់បរិនិព្វានហើយ **ព្រះស្តូប**ជារបស់ធំ សម្បើមគឺកើតមាន ឡើង (ក្នុងកាលនោះ) ពួកជនតែងនាំគ្នាចូលទៅបម្រើព្រះស្តូប ត្រង់ល្វែងតម្កល់ព្រះធាតុដ៏ប្រសើរឧត្តម ។ កាលនោះខ្ញុំមានចិត្តជ្រះថ្លា មានចិត្ត សោមនស្ស បាន សាងខឿនខ្ទឹមចន្ទ៍ បានថ្វាយធូបនិងគ្រឿងក្រអូបដ៏សម គួរដល់**ព្រះស្តូប** ។កាលខ្ញុំកើតក្នុងភព (ណាៗ) ទោះបីជា ទេវតា ឬជាមនុស្ស ខ្ញុំមិនបាន ជួបនូវភាពថោកទាបឡើយ នេះជាផលនៃ បុញ្ញកម្ម ។ ក្នុងកប្បទី ១១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាម**សមត្តៈ**ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំបាន ធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ បានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះសបវារិយត្ថេរ**មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ សបវារិយត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៦៨-៦៩)*

## ៧.ឧម្មាបុប្ផិយត្ថេរាបទាន

## (ផលនៃការយកផ្កាទៅដោតលើព្រះស្តូប)

*កាលព្រះមានព្រះភាគព្រះនាម**សិទ្ធត្ថៈ** ដែលពួក សត្វលោកបូជាហើយ គួរទទួលនូវគ្រឿងបូជា ទ្រង់បរិនិព្វានហើយ ក៏មានការធ្វើង**ព្រះស្តូប**ដ៏ធំ ។ កាលដែលកំពុងរៀបចំធ្វើង**ព្រះស្តូប** ខ្ញុំក៏បានយកផ្កាទៅដោត*

*លើ**ព្រះស្តូប** នៃ**ព្រះសិទ្ធត្ថៈ**មហេសី ។ ក្នុងកប្បទី៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃបុប្ផបូជា ។ ក្នុងកប្បទី៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨៥ជាតិ ព្រះនាម**សោមទេវៈ**ដូចជាគ្នា ទ្រង់មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះឧម្មាបុប្ផិយត្ថេរ**មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ ឧម្មាបុប្ផិយត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៦៩-៧០)*

## ៨.បញ្ចង្គុលិយត្ថេរាបទាន

## *(ផលនៃការបូជាផ្កាកម្រងក្នុងព្រះគន្ធកុដិ)*

*ព្រះមានព្រះភាគ ព្រះនាម**តិស្សៈ** ជាទីពឹងនៃសត្វលោកជា**នាសកៈ** ខ្ញុំបានឃើញ**ព្រះពុទ្ធមហាមុនី**[(១)] ព្រះអង្គជាអ្នកឈ្នះវៃក្នុង**វិហារធម៌**[(២)] កំពុងចូលគន្ធកុដិ ទើបកាន់នូវផ្កាកម្រងមានក្លិនក្រអូបហើយ ដើរទៅកាន់សំណាក់ព្រះជិនស្រី ។ ខ្ញុំមាន**សទ្ធា**តិចតួចសោះ បានថ្វាយ នូវគ្រឿង ក្រអូប ប្រស់ព្រំដោយម្រាមដៃប្រាំ ចំពោះព្រះសម្ពុទ្ធ ។*

*ក្នុងកប្បទី៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រឿងក្រអូប ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃគ្រឿង ក្រអូប ដែលប្រស់ព្រំ*

---

(១).*មហាមុនី ន. អ្នកប្រាជ្ញធំ, ព្រះសព្វញ្ញុពុទ្ធ* (ម. ព. មុនី ផង) ។

(២).*វិហារធម៌ ន. ធម៌ ឬសភាវៈជាទីសម្រាកចិត្ត, ឈាន, សមាបត្តិ។ ធម៌ដែលជាគោលក្នុងដំណើរជីវិត, ធម៌ដែលជម្រះចិត្ត, ធម៌ជាជម្រកនៃចិត្ត ។ (សទ្ទានុក្រមព្រះពុទ្ធសាសនា)*

ដោយប្រមាមដៃប្រាំ ចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៧២ អំពីនេះខ្ញុំបាន កើតជាស្តេចក្រពត្តិ ព្រះនាម**សយម្បកៈ**ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំបានធ្វើឱ្យ ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា **ព្រះបញ្ចង្គុលិត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ៕

*(ចប់ បញ្ចង្គុលិយត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ៩៨-៩៩)*

## ៩.ខណ្ឌផុល្លិយត្ថេរាបទាន

## (ផលនៃការសម្អាត និងជួសជុលព្រះស្តូប)

ព្រះស្តូបរបស់ព្រះមានព្រះភាគ ព្រះនាម**ផុស្សៈ**នៅក្នុងព្រៃ ធំក្នុង កាលនោះ (ព្រះស្តូបនោះ) ត្រូវពួកដំរីកម្ទេចហើយ ដើមឈើដុះ ទ្រុប ទ្រុល ក្នុងទីនោះ ។ ខ្ញុំធ្វើកន្ទេងរដិបរដុប (ប្រេះឆា) ឱ្យស្មើហើយ លាប បាយអ ខ្ញុំត្រេកអរដោយគុណទាំងឡាយ របស់សត្វក្នុងត្រៃលោក។ ក្នុង កប្បទី៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើ កុសល កម្ម ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃដុំបាយអ ។ ក្នុងកប្ប ទី៧៧ ខ្ញុំ បានកើតជាស្តេចចក្រពត្តិ ១៦ជាតិ ព្រះនាម**ជិតសេនៈ**ដូចគ្នា ទ្រង់បរិបូ ណ៌ដោយ កែវ ៧ ប្រការ មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និង អភិញ្ញា៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា **ព្រះខណ្ឌផុល្លិយត្ថេរ** មានអាយុ បានសម្តែង នូវគាថា

*ទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ ខណ្ឌផុល្លិយត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ១២៦)*

## ១០.ជគតិការកត្ថេរាបទាន
## (ផលនៃការជម្រះផែនដីត្រង់កន្លែងព្រះស្តូប)

*កាល**ព្រះអត្ថទស្សី**ជាលោកនាថ ទ្រង់ប្រសើរជាងពួក**នរៈ** ព្រះអង្គបរិនិព្វានហើយ ខ្ញុំបានឱ្យគេជម្រះ ផែនដី ត្រង់កន្លែងព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធ ។ ក្នុងកប្បទី ១,៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផល នៃ(ការជម្រះ)ផែនដី ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។*

*បានឮថា **ព្រះជគតិការកត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៕*

*(ចប់ ជគតិការកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ១៧៧)*

## ១១.កុដិធូបកត្ថេរាបទាន
## (ផលនៃការបង្ហុយផ្សែងអប់ក្នុងកុដិព្រះសិទ្ធិត្ថៈសម្ពុទ្ធ)

*ខ្ញុំជាអ្នករក្សាកុដិ របស់ព្រះមានព្រះភាគ ព្រះនាម**សិទ្ធិត្ថៈ** ខ្ញុំជ្រះថ្លាបានបង្ហុយផ្សែងអប់ ដោយដៃរបស់ខ្លួនអស់កាល ទាំងពួង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំ*

*មិនដែល ស្គាល់**ទុគ្គតិ** នេះជាផលនៃ**ធូបទាន** ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំង សាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ៕*

*បានឮ **ព្រះកុដិធូបកត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ៕*

*(ចប់កុដិធូបកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ១៨២)*

## ១២.ធាតុបូជកត្ថេរាបទាន

## *(ផលនៃការបូជាព្រះធាតុព្រះសិទ្ធត្ថៈសម្ពុទ្ធ)*

*កាលព្រះលោកនាថ ព្រះនាម**សិទ្ធត្ថៈ** ឧត្តមជាងពួក**នរៈ** ទ្រង់ បរិនិព្វានហើយ ខ្ញុំបានព្រះធាតុមួយអង្គ របស់**ព្រះសិទ្ធត្ថៈ** ព្រះអង្គ ប្រសើរជាងសត្វជើងពីរ ជា**តាទិបុគ្គល** ។*

*ខ្ញុំកាន់យកព្រះធាតុនោះ របស់ព្រះពុទ្ធជាផៅពង្សនៃ**ព្រះអាទិត្យ** ហើយបម្រើអស់ ៥ឆ្នាំ ដូចកាលបម្រើព្រះអង្គជា បុគ្គលឧត្តម ជាងពួក **នរៈ**កាលទ្រង់គង់ព្រះជន្មនៅឡើយ ដែរ ។ ក្នុងកប្បទី៩៤ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានបូជា**ព្រះធាតុ** ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃការបម្រើ**ព្រះធាតុ** ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិ ហើយ ។*

*បានឮថា **ព្រះធាតុបូជកត្ថេរ** មានអាយុ បានសម្តែងនូវគាថា ទាំង*

*នេះ ដោយប្រការដូច្នេះ ។*

*(ចប់ ធាតុបូជកត្ថេរាបទាន បិដកភាគ ៧៣ ទំព័រ ១៨៣-១៨៤)*

- ❖ *រឿងទាំង ១៣នេះ មានរឿងអានិសង្សការបូជាដើមពោធិព្រឹក្ស ជាដើម សូមលោកអ្នកអានមើលក្នុងបិដកផងចុះ។*

***១.ឯកាសនិយត្ថេរាបទាន*** *(ផលនៃការតួរ្បតន្ត្រីទាំងពួង ទៅកាន់ពោធិព្រឹក្ស) ទំព័រ ២០,*

***២.ចិតកបូជកត្ថេរាបទាន*** *(ផលនៃការបូជាគ្រឿងសក្ការនៅដើងថ្កូវ) ទំព័រ ២៣-២៤,*

***៣.អនុលោមទាយកត្ថេរាបទាន*** *(ផលនៃការធ្វើខឿនព្រះពោធិព្រឹក្ស) ទំព័រ ៧០-៧១,*

***៤.តម្ពបុប្ផិយត្ថេរាបទាន*** *(ផលនៃការថ្វាយបង្គំដើមពោធិព្រឹក្ស) ទំព័រ ៧៨-៧៩,*

***៥.និស្សេណីទាយកត្ថេរាបទាន*** *(ផលនៃការធ្វើជណ្ដើរសម្រាប់ឡើងកាន់ប្រសាទ) ១០២-១០៣*

***៦.ឯកទីបិយត្ថេរាបទាន*** *(ផលនៃការថ្វាយប្រទីបមួយ ដល់ព្រះ បទុមុត្តរៈទៀបដើមស្រល់) ទំព័រ ១០៧,*

***៧.ពោធិឧបដ្ឋាយកត្ថេរាបទាន*** *(ផលនៃការវាយសំភោថ្វាយនូវដើមពោធិព្រឹក្ស) ទំព័រ ១១៧,*

***៨.សន្និតត្ថេរាបទាន*** *(ផលនៃការរលឹកព្រះពុទ្ធ) ទំព័រ ១៥២,*

***៩.មិញ្ជវដំសកិយត្ថេរាបទាន*** *(ផលនៃការបូជាដើមពោធិព្រឹក្ស*

*ដេរដាសដោយផ្កា ប្រដាប់ក្បាល) ទំព័រ ១៦៦-១៦៧*

***១០.វេទិទាយកត្ថេរាបទាន*** *(ផលនៃការបានឱ្យគេធ្វើខឿន ពោធិព្រឹក្ស) ទំព័រ ១៧៣-១៧៤,*

***១១.តេលមក្ខិយត្ថេរាបទាន*** *(ផលនៃការលាបប្រេងត្រង់ខឿន ពោធិព្រឹក្ស) ទំព័រ ១៩៩,*

***១២.អឌ្ឍចន្ទិយត្ថេរាបទាន*** *(ផលនៃការធ្វើក្បាច់អឌ្ឍចន្ទ ចំពោះ ពោធិព្រឹក្ស) ទំព័រ ២០០,*

***១៣.ឯកបុប្ផិយត្ថេរាបទាន*** *(បិសាចថ្វាយផ្កាមួយ ចំពោះព្រះ វិបស្សីសម្ពុទ្ធ) ទំព័រ ២២២។*

*(ចប់ បកិណ្ណកៈ រឿងព្រះចេតិយក្នុង បិដកភាគ ៧៣)*

## V- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៤ ខ្លះៗ

### ១.អាសនត្ថវិកត្ថេរាបទាន

### (ផលនៃការអញ្ជលីសរសើរព្រះសិខីសម្ពុទ្ធ)

*កាលនោះ ខ្ញុំដើរសំដៅទៅឯ**ឧត្តមចេតិយ** នៃ**ព្រះលោកពន្ធុ ព្រះនាមសិខី** ដែលនៅក្នុងព្រៃធំ ។ កាលខ្ញុំដើរចេញមកអំពីព្រៃវិញ ក៏បានឃើញព្រះពុទ្ធគង់លើ**សីហាសនៈ** ខ្ញុំធ្វើសម្ពត់ឆៀងស្មាម្ខាង ហើយ ធ្វើអញ្ជលីសរសើរព្រះលោកនាយក ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធអគ្គនាយកក្នុងលោក អស់ចំណែកមួយថ្ងៃ ជាអ្នកមានចិត្តរីករាយ បានពោលវាចានេះថា បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ សូមនមស្ការព្រះអង្គ បពិត្រ ព្រះអង្គមានព្យាយាមធំ ជាចម្បងក្នុងលោក ទ្រង់ប្រសើរជាងពួក**នរៈ** ព្រះអង្គជាសព្វញ្ញុពុទ្ធ ។ លុះបានសរសើរព្រះ សម្ពុទ្ធព្រះនាម**សិខី** ដោយការធ្វើនិមិត្តហើយ ក៏ថ្វាយបង្គំព្រះអង្គ ដែលទ្រង់កំពុងគង់នៅ រួចដើរចេញទៅឈមមុខទៅកាន់ឧត្តរទិស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានសរសើរព្រះពុទ្ធ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផល នៃការសរសើរ ។ ក្នុងកប្បទី២៧ អំពីកប្បនេះ ខ្ញុំបានកើតជា ស្តេចចក្រពត្តិ ៧ជាតិ **ព្រះនាមអតុល្យៈ** ទ្រង់បរិបូណ៌កែវ ៧ ប្រការ មានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

បានឮថា **ព្រះអាសនត្ថវិកត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*(ចប់ អាសនត្ថវិកត្ថេរាបទាន បិដកភាគ ៧៤ ទំព័រ ១៨-១៩)*

## ២.បុន្នាគបុប្ផិយត្ថេរាបទាន
## (ផលនៃការយកផ្កាបុន្នាគ ធ្វើជាព្រះស្តូបលើផ្នូកខ្សាច់)

ខ្ញុំបានកើតជាព្រានព្រៃ អាស្រ័យនៅក្នុងព្រៃធំ បានឃើញនូវឈើ **បុន្នាគ** ដែលមានផ្ការីក ក៏នឹកដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបេះ យកផ្កាដែលមានក្លិនក្រអូបឈ្ងុយឈ្ងប់ល្អនោះ ធ្វើជា**ព្រះស្តូប**លើផ្នូក ខ្សាច់ ហើយបូជាចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយព្រះអង្គ ព្រះនាម**តមោនុទៈ** ទ្រង់បរិបូណ៌ ដោយកែវ ៧ ប្រការមានកម្លាំងច្រើន ។ **បដិសម្ភិទា៤ វិមោក្ខ ៨ និងអភិញ្ញា៦** នេះ ខ្ញុំក៏បានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុន្នាគបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*(ចប់ បុន្នាគបុប្ផិយត្ថេរាបទាន បិដកភាគ ៧៤ទំព័រ ៤៦-៤៧)*

## ៣.បត្ថទារត្ថេរាបទាន
## (ផលនៃការសម្អាតព្រះស្តូបក្នុងព្រៃ)

*ចេតិយរបស់ព្រះមានព្រះភាគ ព្រះនាម**បទុមុត្តរៈ**ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ តាំងនៅក្នុងព្រៃធំ ជាទីកុះករដោយម្រឹគសាហាវ ។ បុគ្គលណាមួយមិនអាច នឹងទៅថ្វាយបង្គំចេតិយបានឡើយ ចេតិយនោះត្រូវស្មៅនិង ឈើវល្លិរួបរឹតរលើងរលំ ។ កាលនោះ ខ្ញុំជាអ្នកធ្វើការងារ ក្នុងព្រៃ ជាមួយបិតានិងជីតា ក៏បានឃើញ**ព្រះស្តូប**ក្នុងព្រៃ ធំដែលមានស្មៅវល្លិរួបរឹតរលើងរលំនោះ ។ លុះខ្ញុំឃើញ **ពុទ្ធស្តូប**ហើយ ក៏តាំងចិត្តគោរពថា ព្រះស្តូបរបស់ ព្រះសម្ពុទ្ធ ដ៏ប្រសើរនេះ នៅក្នុងព្រៃរលើងរលំខូចខាតអស់ អ្នកស្គាល់ គុណនិងទោសនៃចេតិយនោះ បើមិនបានជម្រះនូវ**ពុទ្ធស្តូប** ដែលមិន កំបាំង មិនសមគួរ ត្រឡប់ទៅប្រកបការងារដទៃវិញការណ៍នោះមិនសម គួរទេ ។ ទើបខ្ញុំជម្រះស្មៅនិងឈើវល្លិ លើព្រះចេតិយ ហើយថ្វាយបង្គំ រួចថយក្រោយអស់ ៨ជំហាន រួចដើរចេញទៅ ។ លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្ម ដែលខ្លួនសាងល្អនោះផង ដោយការតាំងចេតនានោះផង ។ វិមានរបស់ខ្ញុំដែលបុញ្ញកម្មតាក់តែងល្អហើយ ក្នុងឋានតាវតិង្សនោះ មានវណ្ណៈភ្លឺផ្លេកដូចមាស មានកម្ពស់ ៦០យោជន៍ មានទំហំ ៣០យោជន៍ ។ ខ្ញុំបានសោយទេវរាជ្យ អស់ ៣០០ដង បានកើតជាស្តេចចក្រពត្តិ ២៥ ដងទៀត ។ ខ្ញុំកាលអន្ទោលទៅក្នុងភពធំភពតូច រមែងបានភោគៈច្រើន ការខ្វះខាតដោយភោគៈ របស់ខ្ញុំមិនមានឡើយ*

*នេះជាផលនៃការ*

*ជម្រះ ។ កាលខ្ញុំទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬជិះលើ-កដំរី ខ្ញុំទៅកាន់ទិសណាៗ ព្រៃរមែងសម្រេចជាទីពឹង (របស់ខ្ញុំក្នុងទិសនោះៗ) ។ ខ្ញុំប្រកបហើយដោយបុញ្ញកម្ម មិនដែលឃើញដង្កត់ឬបន្លាដោយចក្ខុឡើយ ដង្កត់ជាដើមនោះ តែងចៀសចេញទៅឯងៗ ។ ខ្ញុំមិនដែលកើតរោគឃ្លង់ ពក ស្រែង ឆ្កួតជ្រូក ឃ្លង់ដែក ដំនួចពិស ឬ កមរមាស់ឡើយ នេះជាផលនៃការជម្រះ ។*

*ខ្ញុំមានសេចក្ដីអសារ្យដទៃទៀត គឺព្រោះតែ**ពុទ្ធស្តូប** ដែលខ្ញុំជម្រះនោះ ខ្ញុំមិនដែលស្គាល់ពក ឬឆ្អួច កើតក្នុងកាយ របស់ខ្ញុំទេ ។ ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែ**ពុទ្ធស្តូប** ដែលខ្ញុំជម្រះនោះ ខ្ញុំតែងអន្ទោលទៅកើតក្នុងភពពីរ គឺ**ទេវតា ឬមនុស្ស** ។ ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែ**ពុទ្ធស្តូប**ដែលខ្ញុំជម្រះនោះ ខ្ញុំមានសម្បុរដូចមាសមានរស្មីរុងរឿងក្នុងទីទាំងពួង ។ ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀតគឺ ព្រោះតែ**ពុទ្ធស្តូប**ដែលខ្ញុំជម្រះនោះ សេចក្ដីមិនគាប់ចិត្តតែងចៀសវាង សេចក្ដីគាប់ចិត្តតែង ប្រាកដឡើង ។ ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែ**ពុទ្ធស្តូប**ដែលខ្ញុំជម្រះនោះ ចិត្តរបស់ខ្ញុំស្អាតល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តខ្ជាប់ខ្ជួន ។ ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែ**ពុទ្ធស្តូប**ដែលខ្ញុំជម្រះនោះ ខ្ញុំអង្គុយលើអាសនៈតែមួយ ក៏បានដល់នូវ**ព្រះអរហត្ត** ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការជម្រះ ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ*

ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា **ព្រះបកគ្គុលត្ថេរ**មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

(ចប់ បកគ្គុលត្ថេរាបទាន បិដកភាគ ៧៤ ទំព័រ ៥៣-៥៦)

❖ ***រឿងទាំង ៥នេះ*** មានរឿងការយល់សប្តិឃើញព្រះពុទ្ធជាដើម សូមលោកអ្នកអានមើលក្នុងបិដកផងចុះ។

**១.ពុទ្ធសញ្ញិកត្ថេរាបទាន** (ផលនៃការយល់សប្តិឃើញព្រះសិទ្ធត្ថៈសម្ពុទ្ធ) ទំព័រ ១០,

**២.ធជទាយកត្ថេរាបទាន** (ផលនៃការលើកឡើងនូវទង់ថ្វាយព្រះតិស្សៈសម្ពុទ្ធ) ទំព័រ ៧១-៧២,

**៣.នឡាគារិកត្ថេរាបទាន** (ផលនៃការធ្វើរោងបបុះប្រក់ស្មៅថ្វាយព្រះសយម្ភូ) ទំព័រ ៧៣-៧៤,

**៤.បត្តិបុប្ផិយត្ថេរាបទាន** (ផលនៃការបូជាផ្កា នូវព្រះសរីរៈព្រះបទុមុត្តរៈ) ទំព័រ ១០៤-១០៥,

**៥.សលឡមណ្ឌបិយត្ថេរាបទាន** (ផលនៃការយកកម្រងផ្កាស្រល់មកធ្វើជាមណ្ឌប) ទំព័រ ២០២-២០៣៕

**(ចប់បកិណ្ណកៈ រឿងព្រះចេតិយ ក្នុងបិដកភាគ ៧៤)**

## VI- បរិច្ឆេទៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៥ ខ្លះៗ

## ១.សោណ្ណកិង្កណិយត្ថេរាបទាន
## (*ផលនៃការធ្វើព្រះស្តូបដ៏ឧត្តម លើផ្នូកខ្សាច់*)

*ខ្ញុំចេញទៅកាន់ផ្នួស ដោយសទ្ធា ទ្រទ្រង់ចីវរសម្បកឈើ ពឹងផ្អែកនូវ**តបោកម្ម** ។ ក្នុងសម័យនោះព្រះមានព្រះភាគ **ព្រះនាមអត្ថទស្សី** ជាច្បងក្នុងលោក ប្រសើរជាង**នរៈ** បានត្រាស់ឡើង ហើយចម្លងនូវមហាជន ។ កម្លាំងរបស់ខ្ញុំអស់ហើយ ដោយការព្យាធិយ៉ាងធ្ងន់ ខ្ញុំរលឹកនូវព្រះសម្ពុទ្ធដ៏ប្រសើរ ហើយធ្វើ**ព្រះស្តូប**ដ៏ឧត្តម លើផ្នូកខ្សាច់។ ខ្ញុំមានចិត្តរីករាយ មានចិត្តខ្ពង់ខ្ពស់ មានសេចក្តីជ្រះថ្លា បានរោយរាយនូវផ្កាកណ្តឹងមាសទាំងឡាយ ។*

*ខ្ញុំបម្រើនូវ**ព្រះស្តូប** នៃព្រះមានព្រះភាគ ព្រះនាម**អត្ថទស្សី** ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ដោយចិត្តជ្រះថ្លានោះ ដូចជាបម្រើព្រះសម្ពុទ្ធ ក្នុងទីចំពោះព្រះភក្ត្រ ។ កាលខ្ញុំទៅកើតក្នុងទៅទេវលោក រមែងបាននូវសេចក្តីសុខដ៏ធំទូលាយ ជាអ្នកមានសម្បុរដូចមាស ក្នុងទេវលោកនោះ នេះជាផលនៃពុទ្ធបូជា ។ នារីទាំងឡាយរបស់ខ្ញុំ ៨០ កោដិ មានខ្លួនតាក់តែងល្អៗ បម្រើខ្ញុំសព្វៗ កាល នេះជាផលនៃពុទ្ធបូជា ។ តូរ្យតន្ត្រី ៦ម៉ឺន ស្គរ រនោត ស័ង្ខ និងស្គរធំ មានសំឡេង ពីរោះប្រគំក្នុងទីនោះ ។ ដំរីទាំងឡាយ ៨ម៉ឺន ៤ពាន់ប្រដាប់តាក់តែងល្អ **ដំរីមាតង្គៈ**ទាំងឡាយចុះប្រេងបីអន្លើ អាយុ ៦០ឆ្នាំទើបថយកម្លាំង ដ៏ដេរដាសដោយបណ្តាញមាស ធ្វើនូវការបម្រើខ្ញុំ ខ្ញុំមិនមានការខ្វះខាត ពួកពល*

ក្នុងភពឡើយ ។ ខ្ញុំតែងទទួលផលនៃផ្កាកណ្ដឹងមាស ខ្ញុំសោយរាជ្យជាស្ដេចនៃទេវតា អស់ ៥៨ ដង ។

ខ្ញុំបានជាស្ដេចចក្រពត្តិ អស់ ៧១ ដង បានសោយរាជ្យលើផែនដី អស់ ១០១ដង ។ ឥឡូវនេះ ខ្ញុំបានដល់ព្រះនិព្វាន ឈ្មោះ**អមតៈ**(១) ជាបទដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយកម្រ **សំយោជនៈ**(២) ទាំងឡាយ (របស់ខ្ញុំ) អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ១,៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតចោលអស់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមាន **អាសវៈ** ដូចជាដំរីដ៏ប្រសើរផ្ដាច់នូវទន្ទីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮ **ព្រះសោណ្ណកឹកណិយត្ថេរ** មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

(ចប់ សោណ្ណកឹកណិយត្ថេរាបទាន បិដកភាគ ៧៥ ទំព័រ ៦៤-៦៧)

---

(១).**អមត ឬ អមតៈ** គុ. ដែលមិនស្លាប់, មិនចេះស្លាប់, ដែលមិនដាច់, មិនស្រេក (ដែលមាន ជានិច្ច) ។ ន. ដំណើរមិនស្លាប់, ព្រះនិព្វាន, ទឹកទិព្វ, សុធាភោជន។

(២).**សំយោជនៈ** ន. ធម្មជាតិរួបរឹតសត្វទុកក្នុងវដ្ដ, សំយោជនៈមាន១០យ៉ាង គឺ: ១-កាមរាគសំយោជនៈ សេចក្ដីរួបរឹត គឺកាម ។

២-បដិឃសំយោជនៈ ...។ល។ (សទ្ទានុក្រមព្រះពុទ្ធសាសនា)

## ២.ធាតុបូជកត្ថេរាបទាន

## (ផលនៃការបូជា ព្រះធាតុព្រះសិទ្ធត្ថៈសម្ពុទ្ធ)

*កាល**ព្រះលោកនាថ**ព្រះនាម**សិទ្ធត្ថៈ** ជាលោកនាយក ស្តេចបរិនិព្វានហើយ ខ្ញុំបានប្រជុំពួកញាតិរបស់ខ្ញុំ ហើយធ្វើនូវការបូជាព្រះធាតុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលបានបូជាព្រះធាតុ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់**ទុគ្គតិ** នេះជាផលនៃការបូជាព្រះធាតុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមាន**អាសវៈ** ព្រោះបានកាត់បំណង ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។*

*ឱ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា៣ ខ្ញុំបាន ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦**នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮ **ព្រះធាតុបូជកត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។*

*(ចប់ ធាតុបូជកត្ថេរាបទាន បិដកភាគ ៧៥ ទំព័រ ១៧៥-១៧៦)*

## ៣.បុឡិនថូបិយត្ថេរាបទាន

## (ផលនៃការ ធ្វើបុឡិនចេតិយ)

ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយ ឈ្មោះ**យមកៈ** អាស្រមខ្ញុំបានធ្វើហើយ **បណ្ណសាលា** ក៏ខ្ញុំបានសាងល្អហើយក្បែរជើងភ្នំនោះ ។ ខ្ញុំជាជដិល[១] ឈ្មោះ**នារទៈ** ជាអ្នកមានព្យាយាមខ្ពង់ខ្ពស់ សិស្ស ១៤,០០០ តែងបម្រើខ្ញុំ សព្វវេលា ។ ខ្ញុំជាអ្នកចូលចិត្តសេចក្ដីស្ងប់ស្ងាត់ មានចិត្តស្ងប់រម្ងាប់ ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា មហាជនតែងបូជាអាត្មាអញ ៗ មិនបានបូជាអ្នកណាមួយ ។ ជនអ្នកឱ្យឱវាទដល់អាត្មាអញមិនមាន ជនអ្នកស្ដីថាណាម្នាក់ ក៏មិនមាន អាត្មាអញមិនមានអាចារ្យ និងឧបជ្ឈាយ៍ អាត្មាអញ សម្រេចការនៅក្នុងព្រៃ ។ អាត្មាអញចូលទៅបម្រើបុគ្គលណាដែលមានចិត្តធ្ងន់ បុគ្គលនោះ ជាអាចារ្យរបស់អាត្មាអញមិនមាន ការនៅក្នុងព្រៃ ឈ្មោះថាឥតប្រយោជន៍ ។ អាត្មាអញគប្បីស្វែងរកគ្រូដែលគួរបូជា និងគ្រូដែលគួរសរសើរ អាត្មាអញនឹងនៅជាមួយបុគ្គល គួរជាទីពឹងអាស្រ័យបាននោះ ទើបបុគ្គលណាមួយ នឹងមិនតិះដៀលអាត្មាអញឡើយ ។

ស្ទឹងមានច្រាំងរាក់មានកំពង់ល្អ ជាទីរីករាយនៃចិត្ត ដេរដាសដោយផ្នូកខ្សាច់-សសុទ្ធ តាំងនៅជិតអាស្រមរបស់ខ្ញុំ ។ កាលនោះ ខ្ញុំបានដើរចូលទៅរកស្ទឹងឈ្មោះ**អមរិកៈ** ហើយប្រមូលយកផ្នូកខ្សាច់ មកធ្វើជា **បុឡិនចេតិយ** (ចេតិយខ្សាច់) ។ ព្រះសម្ពុទ្ធទាំងឡាយអង្គណា ទ្រង់ធ្វើនូវទីបំផុតនៃភព ជាអ្នកប្រាជ្ញ **ព្រះស្តូប**នៃព្រះសម្ពុទ្ធទាំងឡាយនោះ

---

(១).**ជដិល** ន. អ្នកមានផ្នួងសក់, អ្នកទុកផ្នួងសក់ (តាបស) ។ អ្នកបួសក្នុងនិកាយមួយពួកនៅ ប្រទេសឥណ្ឌាសម័យ បុរាណបួងសក់ជាផ្នួងឡើងខ្ពស់ប្រកាន់លទ្ធិបូជាភ្លើង។ (សទ្ទានុក្រមព្រះពុទ្ធសាសនា).

ក៏ប្រាកដដូច្នោះ ខ្ញុំធ្វើនូវ**ព្រះស្តូប**នោះ ឱ្យជានិមិត្ត ។ លុះខ្ញុំធ្វើរួចហើយ ខ្ញុំបានសាងនូវ**ព្រះស្តូប** ជាវិការៈនៃមាសលើផ្នូកខ្សាច់ ខ្ញុំបានបូជានូវផ្កាកណ្ដឹងមាស អស់ ៣ ពាន់ ។ ខ្ញុំមាន**បីតិ**កើតហើយ ធ្វើនូវអញ្ជលី**នមស្ការ**រាល់ល្ងាចព្រឹក ថ្វាយបង្គំ**ចេតិយផ្នូកខ្សាច់** ហាក់ដូចជាថ្វាយបង្គំនូវព្រះសម្ពុទ្ធ ក្នុងទីចំពោះព្រះភ័ក្ត្រ ។ កាលណា កិលេសទាំងឡាយកើតឡើង **វិតក្កៈ**ទាំងឡាយ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ (កើតឡើង ក្នុងកាលនោះ) ខ្ញុំរំលឹកដល់**ព្រះស្តូប** ដែលខ្ញុំធ្វើល្អហើយ ខ្ញុំពិចារណា ឃើញច្បាស់ក្នុងខណៈនោះឯង ។

ខ្ញុំបានចូលទៅរក**ព្រះស្តូប** នៃព្រះលោកនាយក ទ្រង់ដឹកនាំសត្វដូចពួកឈ្មួញ ហើយទូន្មានខ្លួនថា នែអ្នក **និរទុក្ខ**[១] បើអ្នកហ៊ានបិទបាំងកិលេស ការដែលមកបិទបាំងកិលេសនេះ ជាអំពើមិនគួរដល់អ្នកទេ ។ កាលណា ខ្ញុំរំពឹងនឹក**ព្រះស្តូប** ឈ្មោះថាខ្ញុំបានសេចក្ដីគោរព ក្នុងកាលនោះ ខ្ញុំបានបន្ទោបង់នូវ**វិតក្កៈ**អាក្រក់ ដូចដំរីដ៏ប្រសើរ ដែលត្រូវគេចាក់ដោយកង្វេរ ។ មច្ចុរាជតែងញាំញីខ្ញុំកាលនៅយ៉ាងនេះ លុះខ្ញុំធ្វើមរណកាលក្នុងទីនោះ បានទៅកើតឯព្រហ្មលោក ។ ខ្ញុំនៅក្នុងព្រហ្មលោកដរាបដល់អស់អាយុ ហើយចយមកកើតក្នុងឋានត្រៃត្រិង្ស បានជាធំជាងទេវតា សោយរាជ្យក្នុងទេវលោក អស់ ៨០ដង ។ ខ្ញុំបានជាស្ដេចចក្រពត្តិ អស់ ៣០០ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិ មិនអស់ ។ ខ្ញុំបានសោយនូវផល នៃផ្កាកណ្ដឹងមាសទាំង នោះ ជន ២ ម៉ឺន ២ពាន់ តែងចោមរោមខ្ញុំ ក្នុងភព ។

---

**(១).និរទុក្ខ** (គុណសព្ទ) ( សំ. និទ៌ុះខ; បា. និទ្ទុក្ខ ) ដែលឥតទុក្ខ, ឥតព្រួយ ។ សរសេរក្លាយជា នេរទុក្ខ ក៏មាន ។ (វចនានុក្រមសម្ដេច ជួនណាត).

ព្រោះខ្ញុំបានសាង**ព្រះស្តូប** លំអងធូលីមិនប្រឡាក់កាយនៃខ្ញុំ ញើសទាំងឡាយក្នុងខ្លួនមិនហូរចេញ ខ្ញុំមានពន្លឺល្អ។ ឱ! **ព្រះស្តូប**ខ្ញុំបាន ធ្វើល្អហើយ ស្ទឹងឈ្មោះ**អមរិកៈ** ខ្ញុំបានឃើញល្អហើយ ព្រោះខ្ញុំបានធ្វើ **ព្រះស្តូបខ្សាច់** ទើបបានសម្រេចនូវព្រះនិព្វាន ជាធម្មជាតមិនកម្រើក ។ សត្វមានសេចក្តី ប្រាថ្នាធ្វើកុសល ជាអ្នកប្រកាន់នូវធម៌មាន ខ្លឹម មិនចាំបាច់មានទីជាស្រែ ឬទីមិនជាស្រែឡើយ ស្រេចហើយត្រឹមតែ សេចក្តីប្រតិបត្តិជាគុណមានខ្លឹម។ បុរសមានកម្លាំង អាចឆ្លងសមុទ្របាន ព្រោះកាន់កំណាត់ឈើតូច ។ ខ្ញុំឆ្លងសមុទ្រធំ ព្រោះអាស្រ័យកំណាត់ឈើនេះ នរជនគប្បីឆ្លងសមុទ្រ ដោយសេចក្តីព្យាយាមប្រឹងប្រែង មានឧបមាយ៉ាងណា ។ អំពើណា ទោះតិចតួចក្តី ថោកទាបក្តី ដែលខ្ញុំធ្វើហើយ ខ្ញុំបានឆ្លងសង្សារ ព្រោះអាស្រ័យអំពើនោះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

លុះដល់បច្ឆិមភព ខ្ញុំត្រូវកុសលមូលដាស់តឿន បានកើត ក្នុងត្រកូលមហាសាល ដែលស្តុកស្តម្ភល្អ ក្នុងក្រុងសាវត្ថី ។ មាតាបិតារបស់ខ្ញុំមានសទ្ធាបានយកព្រះពុទ្ធជាទីពឹង ជន ទាំងពីរនាក់នោះ ក៏អនុវត្តតាមពុទ្ធសាសនា ។ ពួកជនបានកាន់ យកក្រមរពោធិ ទៅធ្វើ**ព្រះស្តូប**ជាវិការៈនៃមាស តែង**នមស្ការ**ចំពោះព្រះភ័ក្ត្រព្រះសក្យបុត្ត រាល់ល្ងាចព្រឹក ។ ក្នុងថ្ងៃឧបោសថ ពួកជននាំយកព្រះស្តូបមាស ហើយពោលសរសើរគុណព្រះពុទ្ធ ញ៉ាំងកាលមានយាម ៣ ឱ្យកន្លងទៅ ។ លុះខ្ញុំបានឃើញព្រះស្តូបហើយ ក៏រលឹកឃើញនូវ**ចេតិយផ្នូកខ្សាច់** អង្គុយលើអាសនៈមួយ ក៏បានដល់**អរហន្ត** ...។

(ចប់ ភាណវារៈទី ២២ បិដកភាគ៧៥ ទំព័រ ២១១-២១៥)

## ៤.ពោធិសម្មជ្ជកត្ថេរាបទាន
## (ផលនៃការរើសស្លឹកពោធិដែលជ្រុះ ចេញពីលានព្រះចេតិយ)

ក្នុងភពមុន ខ្ញុំបានរើសស្លឹកពោធិ ដែលជ្រុះក្នុងលានព្រះចេតិយ ហើយយកទៅចោល ខ្ញុំបាននូវគុណ ២០ ។ ខ្ញុំអន្ទោលក្នុងភពតូចភពធំ តែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ដោយតេជះនៃកម្ម នោះ ។ លុះខ្ញុំច្យុតចាកទេវលោក មកកាន់ភពរបស់មនុស្ស តែងកើតក្នុង ត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។ បរិបូណ៌ដោយអវយវៈតូចធំ មាន កម្ពស់និងទំហំសមរម្យ មានរូបល្អ មានសម្បុរស្អាត មានរាងកាយពេញ លេញមិនខ្វះខាត ។

ខ្ញុំកើតក្នុងទេវលោក ឬក្នុងមនុស្សលោក ឬក៏ក្នុងភពណា មួយ តែងមានសម្បុរល្អដូចមាស ឬប្រៀបដូចមាសឆ្អិន ។ សម្បុររបស់ខ្ញុំ ទន់ ល្វន់ល្វាសជិតស្និទ ល្អិតផូរផង់សព្វៗ កាល ព្រោះបានយក ស្លឹក ពោធិ ទៅចោល ។ ទឹកដែលច្រឡំដោយធូលី មិនដែលប្រឡាក់ ក្នុងប្រជុំសរីរៈ (របស់ខ្ញុំ) ក្នុងកាលណាម្តងឡើយ នេះជាផល ក្នុងការ យកស្លឹកពោធិ ទៅ ចោល ។ ខ្លួនរបស់ខ្ញុំនោះ (ឋិតនៅ) ក្នុងទី មានខ្យល់និង កំដៅថ្ងៃដ៏ក្តៅក្តី ឬត្រូវកំដៅភ្លើងក្តី ញើសទាំងឡាយក៏មិន ដែលហូរចេញ នេះជាផលក្នុង ការយកស្លឹកពោធិទៅចោល ។ រោគឃ្លង់ ពក ស្រែង ប្រជ្រុយ បូស ដំរួច ពិស មិនដែល មានក្នុងកាយ (របស់ខ្ញុំឡើយ) នេះជាផលក្នុងការយក ស្លឹកពោធិទៅចោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូច និងភពធំ គឺរោគ ទាំងឡាយ មិនដែលកើតក្នុងកាយរបស់ខ្ញុំឡើយ នេះជា

ផលក្នុងការយកស្ទឹកពោធិទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺ អន្តរាយជាគ្រឿងបៀតបៀន ដែលកើតអំពីចិត្ត មិនដែលមានឡើយ នេះជាផល ក្នុងការយកស្ទឹកពោធិទៅចោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺពួកសត្រូវ មិនដែលមានដល់ខ្ញុំនោះ ក្នុងការយកស្ទឹកពោធិទៅចោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺភោគៈ មិនដែលខ្វះខាតឡើយ នេះជាផល ក្នុងការយកស្ទឹកពោធិទៅចោល ។គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺភ័យ អំពីភ្លើង និងស្តេច អំពីចោរនិងទឹក មិនដែលមានឡើយ ។ មានគុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺពួកខ្ញុំស្រីខ្ញុំប្រុស ជាអ្នកប្រព្រឹត្តតាម ជាអ្នកលុះអំណាចចិត្តរបស់ខ្ញុំ ។ បុគ្គលកើតក្នុងភព ជារបស់មនុស្ស មានកំណត់អាយុត្រឹមណា អាយុរបស់ខ្ញុំមិនថយ ចុះអំពីកំណត់ត្រឹមនោះ តែងឋិតនៅដរាបដល់អស់អាយុ ។

ពួកជនទាំងអស់ អ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាសេចក្តី សុខ ទោះនៅខាងក្នុងក្តី ខាងក្រៅក្តី អ្នកនិគមក្តី អ្នកដែនក្តី សុទ្ធតែជា អ្នកប្រកបតាមខ្ញុំ ។ ខ្ញុំជាអ្នកមានភោគៈ មានយសមានសិរី មានពួកញាតិ ជាអ្នកឥតមានវេរា ប្រាសចាក សេចក្តីតក់ស្លុត តែងមានក្នុងភព សព្វៗកាល ។ ពួក **ទេវតា មនុស្ស អសុរៈ គន្ធព្វ យក្ខ អារក្សទឹក** អ្នកទាំងអស់នោះ តែងរក្សាខ្ញុំ ដែលអន្ទោលទៅក្នុងភព សព្វៗ កាល ។ ខ្ញុំទទួលយសទាំងពីរក្នុងទេវលោកផង ក្នុងមនុស្សលោកផង រួចខ្ញុំបាន ដល់នូវព្រះ

និព្វាន ជា**សិវដ្ឋាន**ដ៏ប្រសើរ ក្នុងកាលជាទីបំផុត ។ បុរសណា ឧទ្ទិស ចំពោះព្រះសម្ពុទ្ធ ឬចំពោះដើមពោធិរបស់ព្រះសាស្តានោះ គប្បី ទទួលនូវផលបុណ្យ (ផលទាំងអស់) ឈ្មោះថាបុរសនោះបានដោយ ក្រដូចម្តេចបាន ។ បុគ្គល (ដែលឋិតនៅ) ក្នុងមគ្គ ក្នុងផល ក្នុងបរិយត្តិ ក្នុងគុណគឺឈាន និងអភិញ្ញា ជាបុគ្គលប្រសើរក្រៃលែងជាងពួកជនដទៃ ជាអ្នកមិនមាន**អាសវៈ** តែងបរិនិព្វាន ។

ក្នុងភពមុន ខ្ញុំមានចិត្តរីករាយ បានយកស្ទឹកពោធិទៅចោល ទើបជាអ្នកបរិបូណ៌ដោយអង្គ២០ នេះ សព្វៗកាល ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ដកចោលហើយ ខ្ញុំជាអ្នកមិនមាន **អាសវៈ** ព្រោះបានកាត់ចំណង ដូចជាដំរីគាត់ផ្តាច់នូវទន្ទីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮ **ព្រះពោធិសម្មជ្ជកត្ថេរ** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូរច្នេះ ៕

*(ចប់ ពោធិសម្មជ្ជកត្ថេរាបទាន បិដកភាគ ៧៥ ទំព័រ ២៦៩-២៧៣)*

# ៥.លកុណ្ឌកផលិយត្ថេរាបទាន

## (ផលនៃការធ្វើព្រះស្តូបកម្ពស់ ៧ យោជន៍ ដោយកែវ ៧ប្រការ)

## សង្ខេប

...ខ្ញុំកើតជាសត្វតាវៅ-ស នៅលើដើមស្វាយក្បែរគន្ធកុដិ ក្នុង **នន្ទារាម** របស់ព្រះសាស្តានោះ ។ គ្រានោះ ខ្ញុំបានឃើញព្រះជិនស្រី ទក្ខិណេយ្យបុគ្គលដ៏ខ្ពង់ខ្ពស់ ស្តេចកំពុងទៅបិណ្ឌបាត្រ ហើយញ៉ាំងចិត្តឱ្យជ្រះថ្លា ក៏ស្រែករំពង ដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានហើរទៅកាន់ឧទ្យានស្តេច ហើយពាំយកផ្លែស្វាយទុំ មានសម្បុរនៃសម្បកដូចមាស បង្អោនទៅជិតព្រះសម្ពុទ្ធ ។ ព្រះជិនស្រី ទ្រង់ប្រកបដោយមហាករុណាជានាយក ទ្រង់ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំហើយ ក៏យកបាត្រអំពីរដៃភិក្ខុជាឧបដ្ឋាក (ហើយចង្អោនបាត្រទៅរកខ្ញុំជាសត្វតាវៅនោះ) ។

ខ្ញុំមានចិត្តរីករាយ បានដាក់ផ្លែស្វាយក្នុងបាត្រ ថ្វាយព្រះ មហាមុនីរួចធ្វើអញ្ជលីដោយស្លាបទាំងពីរ ស្រែកដោយ សំឡេងដ៏ពីរោះ កាលស្រែកដោយសំឡេង គួរត្រេកអរ គួរស្តាប់ ដ៏ទន់ពីរោះ ដើម្បី ពុទ្ធបូជា ហើយ ក៏ហើរទៅកាន់ទ្រនំ ហើយដេកលក់ ។ គ្រោះនោះ សត្វខ្វែង ជាសត្វចិត្តអាក្រក់ ហើរមកឆាបយកខ្ញុំ ដែលកំពុងមានចិត្តរីករាយមានអធ្យាស្រ័យស្រឡាញ់ ចំពោះព្រះពុទ្ធ។ ខ្ញុំច្យុតចាក អត្តភាពនោះ ក៏បានទទួលមហាសុខ ក្នុងឋានតុសិត (លុះច្យុតចាកឋានតុសិត) ក៏បានមកកាន់កំណើតមនុស្ស ព្រោះអានិសង្សនៃ កុសលកម្មនោះឯង ។ ក្នុងកប្បនេះ ព្រះពុទ្ធ**ព្រះនាម កស្សបៈ**ដោយគោត្រ មានផៅពង្សប្រសើរ មានយសធំ ព្រះអង្គ ប្រសើរជាងពួកអ្នកប្រាជ្ញ ស្តេចកើតឡើង ។ ព្រះអង្គបំភ្លឺ

*សាសនា គ្របសង្កត់**តិរ្ថិយ**អាក្រក់ ទ្រង់ទូន្មានពួក**វេនេយ្យសត្វ** រួចហើយ ព្រះអង្គព្រមទាំងពួកសាវ័ក បរិនិព្វានទៅ ។*

*កាលព្រះអង្គ ជាបុគ្គលប្រសើរជាងសត្វលោក បរិនិព្វានហើយ ពួកជនច្រើនគ្នា កើតសេចក្ដីជ្រះថ្លា នាំគ្នាធ្វើ**ព្រះស្តូប** ដើម្បីជាពុទ្ធបូជា ចំពោះព្រះសាស្ដា ។ ពួកជនទាំងនោះ ប្រឹក្សាគ្នាយ៉ាងនេះថា យើងទាំងឡាយ នឹងឱ្យពួកជាងធ្វើព្រះស្តូបកម្ពស់ ៧យោជន៍ ស្អិតស្អាងដោយកែវ ៧ ប្រការ ថ្វាយព្រះពុទ្ធជាមហេសី ។ កាលនោះ ខ្ញុំជានាយកនៃសេនារបស់ព្រះបាទ**កិកិដែនកាសី** បានបង្គាប់ឱ្យគេធ្វើចេតិយ ដែលត្រូវមានទំហំធំ ឱ្យមកជាតូចវិញ ។ គ្រានោះ ពួកជនទាំងនោះ ក៏នាំគ្នាធ្វើចេតិយតាមពាក្យខ្ញុំ កម្ពស់មួយយោជន៍ សឹងស្អិតស្អាងដោយកែវផ្សេង ៗ ថ្វាយព្រះពុទ្ធ អ្នកជាប្រាជ្ញ ប្រសើរជាងជន ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី **ក្រុងសាវត្ថី** ជាក្រុងដ៏ប្រសើរ ស្ដុកស្ដម្ភទូលាយ មានទ្រព្យច្រើន ។*

*ខ្ញុំឃើញព្រះសុគត កំពុងចូលទៅក្នុងបុរី ក៏មានចិត្តស្ញប់ស្ញែង បានចូលទៅបួស មិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេច **ព្រះអរហត្ត**។ ខ្ញុំបានធ្វើចេតិយឱ្យមានទំហំតូចណា ព្រោះអំពើនោះឯង បានជាខ្ញុំកើតមកមានសរីរៈតឿ គួរដល់ការ មើលងាយ (នៃអ្នកផង) ។ ខ្ញុំបានដល់នូវភាពជាបុគ្គល ប្រសើរ (នាងមានសំឡេងពីរោះ) ជាងពួកភិក្ខុដែលមានសំឡេងពីរោះ ព្រោះបានបូជាព្រះពុទ្ធ ជាឥសីទី ៧ ដោយ សំឡេងដ៏ពីរោះ ។ ខ្ញុំ*

បានសម្រេចនូវសាមញ្ញផល ឥតមាន **អាសវៈ** ព្រោះបានថ្វាយផ្លែស្វាយ ដល់ព្រះពុទ្ធ និងការនឹក រលឹកគុណនៃព្រះពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំ ដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមាន **អាសវៈ** ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អ ហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា៣ ខ្ញុំ បានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើហើយឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា **ព្រះលកុណ្ឌកភទ្ទិយត្ថេរ** មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

*(ចប់ លកុណ្ឌកភទ្ទិយត្ថេរាបទាន បិដកភាគ ៧៥ ទំព័រ ៣៥៧-៣៦១)*

**(ចប់ បកិណ្ណកៈ រឿងព្រះចេតិយក្នុងភាគ ៧៥)**

## VII- បកិណ្ណកៈរឿងព្រះចេតិយក្នុងបិដកភាគ ៧៦-៧៧ ខ្លះៗ

## ១.មេខលទាយិកាថេរិយាបទាន

## *(ផលនៃការធ្វើព្រះស្តូប និងថ្វាយខ្សែក្រវាត់ចំពោះព្រះសិទ្ធត្ថសម្ពុទ្ធ)*

*ខ្ញុំបានធ្វើ**ព្រះស្តូប**ថ្វាយព្រះមានព្រះភាគ ព្រះនាម**សិទ្ធត្ថៈ** ហើយបានថ្វាយ**ខ្សែក្រវាត់**ចំពោះព្រះសាស្តា ដើម្បីនវកម្ម កាលមហា**ស្តូប**សម្រេចហើយ ខ្ញុំមានចិត្តជ្រះថ្លា ។ បានបូជា**ខ្សែក្រវាត់** ចំពោះព្រះមុនីលោកនាថ ដោយដៃរបស់ ខ្លួនទៀត ។ ក្នុងកប្បទី ៩៤ អំពី**កប្ប**នេះ ព្រោះហេតុដែល ខ្ញុំបានថ្វាយ**ខ្សែក្រវាត់** ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើ**ស្តូប** ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមាន**អាសវៈ** ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ **បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា **ព្រះមេខលទាយិកាភិក្ខុនី** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយបការដូច្នេះ ។*

*(ចប់ មេខលទាយិកាថេរិយាបទាន បិដកភាគ ៧៦ ទំព័រ៥)*

## ២.មណ្ឌបទាយិកាថេរិយាបទាន

**(ផលនៃការធ្វើមណ្ឌប និងថ្វាយព្រះស្តូប ដល់ព្រះកោនាគមនៈសម្ពុទ្ធ)**

*ខ្ញុំបានកសាង**មណ្ឌប**ថ្វាយព្រះពុទ្ធ ព្រះនាម**កោនាមនៈ** ហើយថ្វាយ **ព្រះស្តូប**ដ៏ប្រសើរ ដល់ព្រះពុទ្ធ ជាផៅពង្សនៃ លោកថែមទៀត ។ ខ្ញុំទៅកាន់ជនបទ និគម រាជធានីណា ៗ ជាស្រីត្រូវគេបូជាក្នុងទីទាំងពួងនេះជាផលនៃបុញ្ញកម្ម ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមាន**អាសវៈ** ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ **បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦** នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។*

*បានឮថា **ព្រះមណ្ឌបទាយិកាភិក្ខុនី** មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយបការដូច្នេះ ។*

*(ចប់ មណ្ឌបទាយិកាថេរិយាបទាន បិដកភាគ ៧៦ ទំព័រ ៦)*

- ***រឿងទាំង ៣នេះ** មានរឿងការសាងភាជន៍ បូជាព្រះស្តូបជាដើម សូមលោកអ្នកអានមើលក្នុងបិដកភាគ ៧៦ផងចុះ*

***១.បញ្ចទីបិកាថេរិយាបទាន** (ផលនៃការជ្រះថ្លាចំពោះពោធិព្រឹក្ស) ទំព័រ ១៧-២១, **២.បញ្ចទីបទាយិកាថេរិយាបទាន** (ផលនៃការអធិដ្ឋានឱ្យពោធិព្រឹក្សធ្វើបាដិហារ្យ) ទំព័រ៣៦-៤០, **៣.ភទ្ទកាបិលានីថេរិយាបទាន** (ផលនៃការសាងភាជន៍ បូជាព្រះស្តូប) ទំព័រ ១៦១-១៧២ ។*

## ៣.ប្រវត្តិព្រះពុទ្ធទាំងប្រាំព្រះអង្គក្នុងភទ្ទកប្បយើងនេះ (ដោយសង្ខេប)

**១.ព្រះកកុសន្ធោ** ទ្រង់ជាព្រាហ្មណ៍ ព្រះនគរ **ខេមបូរី ព្រះបិតា អគ្គិទត្តព្រាហ្មណ៍** ព្រះមាតា**វិសាខា**, ព្រះអង្គទ្រង់គ្រប់គ្រងផ្ទះ ៤ពាន់ឆ្នាំ , អគ្គមហេសីព្រះអង្គ **ព្រះនាងរោចិនី** និងព្រះឱរស**ឧត្តរៈកុមារ**។

ព្រះអង្គទ្រង់យាងទៅបួសដោយ **យានរថ** ទ្រង់ព្យាយាមអស់ ៨ខែ គត់ បានត្រាស់ជាព្រះពុទ្ធ ក្រោមដើម**សិរិសព្រឹក្ស**(ច្រេស) ទ្រង់មាន ព្រះរស្មី ១០យោជន៍សព្វកាល។

**ព្រះពុទ្ធកកុសន្ធោ** ទ្រង់សម្តែងធម្មចក្កនៅ**មិគទាយវ័ន** ញ៉ាំងពពួកសត្វឱ្យត្រាស់ដឹង ៣លើកគឺ លើកទី១ចំនួន ៤ម៉ឺនកោដិ លើកទី២ចំនួន ៣ម៉ឺនកោដិ និងលើកទី៣ មិនអាចរាប់ចំនួនបាន។

ទ្រង់ជួបជុំសាវ័កសន្និបាត ១លើកចំនួន ៤ម៉ឺនអង្គ ភិក្ខុជា ឧបដ្ឋាកព្រះអង្គព្រះនាម **ពុទ្ធិជៈ**, អគ្គសាវ័កទាំងពីរគឺ ព្រះនាម**វិធុរៈ១** ព្រះនាម**សញ្ជីវៈ១** និង**អគ្គសាវិកា**ទាំងពីរគឺ ព្រះនាង**សាមា១** ព្រះនាង **ចម្បា១**។

ព្រះអង្គមានឧបាសកជាឧបដ្ឋាក ២រូបគឺ **អច្ចុគ្គតៈឧបាសក១ សុមនៈឧបាសក១** នឹងឧបាសិកាជាឧបដ្ឋាយិកា ២រូបគឺ **នន្ទាឧបាសិកា១ សុនន្ទាឧបាសិកា១**។

**ព្រះពុទ្ធកកុសន្ធោ** មានបល្ល័ង្កកម្ពស់ ២៦ហត្ថ ទ្រង់មានកម្ពស់ ៤០ហត្ថ ព្រះជន្ម៤ម៉ឺនឆ្នាំ ទ្រង់ចូលបរិនិព្វាននៅ ខេមារាម ព្រះធាតុ ចេតិយមានកម្ពស់ ១គាវុត ៕

**២.ព្រះកោនាគមនោ** ទ្រង់ជាព្រាហ្មណ៍ ព្រះនគរ **សោភវតី**

ព្រះបិតា**យញ្ញទត្តព្រាហ្មណ៍** ព្រះមាតា**ឧត្តរា**, ព្រះអង្គទ្រង់គ្រប់គ្រងផ្ទះ ៣ពាន់ឆ្នាំ, អគ្គមហេសីព្រះអង្គ ព្រះនាង**រុចិគត្តា** និងព្រះឱរស**សត្ថវាហៈ**កុមារ ។

ព្រះអង្គទ្រង់យាងទៅបួសដោយ**យានដំរី** ទ្រង់ព្យាយាមអស់ ៦ខែ បានត្រាស់ជាព្រះពុទ្ធ ក្រោមដើម**ឧទុម្ពរព្រឹក្ស**(ល្វា) ទ្រង់មានព្រះរស្មីប្រមាណមិនបាន។

**ព្រះពុទ្ធកោនាគមនោ** ទ្រង់សម្តែងធម្មចក្កនៅ**មិគទាយវ័ន** ញុំាងពពួកសត្វឱ្យ**ត្រាស់ដឹង** ៣លើកគឺ លើកទី១ចំនួន ៣ម៉ឺនកោដិ លើកទី២ចំនួន ២ម៉ឺនកោដិ និងលើកទី៣ចំនួន ១ម៉ឺនកោដិ។

ទ្រង់ជួបជុំសាវ័កសន្និបាត ១លើកចំនួន ៣ម៉ឺនអង្គ ភិក្ខុជា ឧបដ្ឋាកព្រះអង្គព្រះនាម **សោត្ថិជៈ**, អគ្គសាវ័កទាំងពីរគឺ ព្រះនាម **ភិយ្យោសៈ១** ព្រះនាម**ឧត្តរៈ១** និងអគ្គសាវិកាទាំងពីរគឺ ព្រះនាង **សុមុទ្ទា១** ព្រះនាង**ឧត្តរា១**។

ព្រះអង្គមានឧបាសកជាឧបដ្ឋាក ២រូបគឺ **ឧគ្គៈឧបាសក១ សោម-ទេវៈឧបាសក១** និងឧបាសិកាជាឧបដ្ឋាយិកា ២រូបគឺ **សីវលាឧបាសិកា១ សាមាឧបាសិកា១**។

**ព្រះពុទ្ធកោនាគមនោ** មានបល្ល័ង្កកម្ពស់ ២០ហត្ថ ទ្រង់មាន កម្ពស់ ៣០ហត្ថ ព្រះជន្ម៣ម៉ឺនឆ្នាំ ទ្រង់ចូលបរិនិព្វាននៅ **បព្វតារាម** ព្រះធាតុរបស់ព្រះអង្គ**បែកជាចំណែក** ៕

**៣.ព្រះកស្សបោ** ទ្រង់ជាព្រាហ្មណ៍ ព្រះនគរ **ពារាណសី** ព្រះបិតា**ព្រហ្មទត្តព្រាហ្មណ៍** ព្រះមាតា**ធនវតី**, ព្រះអង្គទ្រង់គ្រប់គ្រងផ្ទះ ២ពាន់ឆ្នាំ,

អគ្គមហេសីព្រះអង្គ ព្រះនាង**សុនន្ទា** និងព្រះឱរស **វិជិតសេនៈកុមារ** ។

ព្រះអង្គទ្រង់យាងទៅបួសដោយ **ប្រាសាទ** ទ្រង់ព្យាយាមអស់ ៧ ថ្ងៃ បានត្រាស់ជាព្រះពុទ្ធ ក្រោមដើម**និគ្រោធព្រឹក្ស**(ជ្រៃ) ទ្រង់មាន ព្រះរស្មីប្រមាណមិនបាន។

**ព្រះពុទ្ធកស្សបោ** ទ្រង់សម្តែងធម្មចក្កនៅ**មិគទាយវ័ន** ញ៉ាំង ពពួកសត្វឱ្យត្រាស់ដឹង ៣លើកគឺ លើកទី១ចំនួន ២ម៉ឺនកោដិ លើកទី២ ចំនួន ១ម៉ឺនកោដិ និងលើកទី៣ចំនួន ៥ពាន់កោដិ។

ទ្រង់ជួបជុំសាវ័កសន្និបាត ១លើកចំនួន ២ម៉ឺនអង្គ ភិក្ខុជា ឧបដ្ឋាកព្រះអង្គព្រះនាម **សព្វមិត្ត**, អគ្គសាវ័កទាំងពីរគឺ ព្រះនាម **តិស្សៈ១** ព្រះនាម**ភារទ្វាជៈ១** និងអគ្គសាវិកាទាំងពីរគឺ ព្រះនាង **អនុឡា១** ព្រះនាង**ឧរុវេឡា១** ។

ព្រះអង្គមានឧបាសកជាឧបដ្ឋាក ២រូបគឺ **សុមង្គលៈឧបាសក១ ឃដិការៈឧបាសក១** និងឧបាសិកាជាឧបដ្ឋាយិកា ២រូបគឺ **វិជិតសេនាឧបាសិកា១ កទ្រ្វាឧបាសិកា១**។

**ព្រះពុទ្ធកស្សបោ** មានបល្ល័ង្កកម្ពស់ ១៥ហត្ថ ទ្រង់មាន កម្ពស់ ២០ ហត្ថ ព្រះជន្ម២ម៉ឺនឆ្នាំ ទ្រង់ចូលបរិនិព្វាននៅ **សេតព្យារាម** ព្រះធាតុចេតិយ **មានកម្ពស់មួយយោជន៍** ៕

**៤.ព្រះគោតម** ទ្រង់ជាក្សត្រ នៅព្រះនគរ **កបិលពស្តុ** ព្រះបិតា**សុទ្ធោទនៈ** ព្រះមាតា**មាយាទេវី**, ព្រះអង្គទ្រង់គ្រប់គ្រងផ្ទះ ២៩ឆ្នាំ, អគ្គមហេសីព្រះអង្គ ព្រះនាង**យសោធរា** និងព្រះឱរស**រាហុលកុមារ** ។

ព្រះអង្គទ្រង់យាងទៅបួសដោយ**យានសេះ** ទ្រង់ព្យាយាមអស់ ៦

ឆ្នាំ បានត្រាស់ជាព្រះពុទ្ធ ក្រោមដើម**អស្សត្ថព្រឹក្ស** (ពោធិបាយ) ទ្រង់មានព្រះរស្មី១ព្យាមជានិច្ច។

**ព្រះពុទ្ធសមណគោតម** ទ្រង់សម្តែងធម្មចក្កនៅឥសិបតនៈ ញ៉ាំងពពួកសត្វឱ្យត្រាស់ដឹង ៣លើកគឺ លើកទី១ចំនួន ១៨កោដិ លើកទី២ មិនអាចរាប់ចំនួនបាន និងលើកទី៣ មិនអាចរាប់ចំនួនបាន។

ទ្រង់ជួបជុំសាវ័កសន្និបាត ១លើកចំនួន ១២៥០អង្គ ភិក្ខុជាឧបដ្ឋាកព្រះអង្គព្រះនាម **អានន្ទៈ**, អគ្គសាវ័កទាំងពីរគឺ ព្រះនាម **កោលិតៈ១** ព្រះនាម**ឧបតិស្សៈ១** និងអគ្គសាវិកាទាំងពីរគឺ ព្រះនាង**ខេមា១** ព្រះនាង**ឧប្បលវណ្ណា១**។

ព្រះអង្គមានឧបាសកជាឧបដ្ឋាក ២រូបគឺ **ចិត្តៈឧបាសក១ ហត្ថាឡ-វកៈឧបាសក១** នឹងឧបាសិកាជាឧបដ្ឋាយិកា ២រូបគឺ **នន្ទមាតាឧបាសិកា១ ឧត្តរាឧបាសិកា១**។

**ព្រះពុទ្ធសមណគោតម** មានបល្ល័ង្កកម្ពស់ ១៤ហត្ថ ទ្រង់មានកម្ពស់១៦ហត្ថ ព្រះជន្ម៨០ឆ្នាំ ទ្រង់ចូលបរិនិព្វាននៅ **នគរកុសិនារា** ព្រះធាតុរបស់ព្រះអង្គ**បែកជាចំណែក៕**

**៥.ព្រះមេត្តេយ្យ** ទ្រង់ជាព្រាហ្មណ៍ នៅនគរកេតុមតី ព្រះបិតា**សុព្រហ្មព្រាហ្មណ៍** ព្រះមាតា**ព្រហ្មវតី**, អគ្គមហេសីព្រះអង្គ **ព្រះនាង ចន្ទមុខី** និងព្រះឱរស**ព្រហ្មវឌ្ឍនកុមារ** ។

ព្រះអង្គទ្រង់ទតឃើញនូវនិមិត្ត ៤ប្រការគឺ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងភេទបព្វជិតនេះ ទ្រង់យាងទៅបួសដោយ**ប្រាសាទ** ទ្រង់ព្យាយាមអស់ ៧ថ្ងៃ បានត្រាស់ជាព្រះពុទ្ធ ក្រោមដើម

***នាគព្រឹក្ស*** (ដើមខ្ទឹង) ទ្រង់មានព្រះរស្មីផ្សាយទៅក្នុងម៉ឺន ចក្រវាឡក្តី ទាំងថ្ងៃ ទាំងយប់។

***ព្រះពុទ្ធសិអារ្យមេត្រី*** ទ្រង់សម្តែងធម្មចក្កទេវតាប្រមាណ ៣០ កោដិ បានត្រាស់ដឹងធម៌, ព្រះអង្គសម្តែងព្រះធម៌ញ៉ាំងមនុស្សមួយសែនកោដិ និង ទេវតារាប់ប្រមាណមិនបាន ឱ្យបានដល់អមតរសពោលគឺ ព្រះនិព្វាន ។

*ភិក្ខុជាឧបដ្ឋាកព្រះអង្គព្រះនាម**សីហថេរ**, អគ្គសាវ័កទាំងពីរគឺ ព្រះនាម**អសោកមហាថេរ១**, ព្រះនាម**សុព្រហ្មថេរ១** នឹងអគ្គសាវិកា ទាំងពីរគឺ ព្រះនាង**បទុមាភិក្ខុនី១**, ព្រះនាង **សុមនាភិក្ខុនី១** ។*

*ព្រះអង្គមានឧបាសកជាឧបដ្ឋាក ២រូបគឺ **សុទត្តគហបតីឧបាសក១**, **សង្ឃគហបតីឧបាសក១** និងឧបាសិកាជាឧបដ្ឋាយិកា ២រូបគឺ នាង**យសបវតីឧបាសិកា១**, នាង**សង្ឃឧបាសិកា១**។*

***ព្រះពុទ្ធអរិយមេត្តេយ្យ*** ទ្រង់មានកម្ពស់ ៨៨ហត្ថ ព្រះជន្ម៨ម៉ឺនឆ្នាំ លុះទ្រង់បរិនិព្វានទៅបានប្រតិស្ឋានសាសនាទុក ៨ពាន់ឆ្នាំទៀត ទុកឱ្យសត្វសត្តនិករប្រតិបត្តិ ដើម្បីបានសម្រេច**មគ្គផល**៕

*(ព្រះសិអាមេត្រីពោធិសត្វ ទ្រង់មិនទាន់បានត្រាស់ដឹងទេ សព្វថ្ងៃ ទ្រង់បំពេញបារមីនូវឡើយ សូមអ្នកអានជ្រាបសេចក្តីនេះផង)*

*(បិដក ភាគ៧៧ និងមាគ៌ាជីវិតនៃព្រះពោធិសត្វ)*

**(ចប់ បកិណ្ណកៈ *រឿងព្រះចេតិយក្នុងបិដកភាគ ៧៦-៧៧*)**

## VIII. ថ្ងៃបុណ្យសំខាន់ក្នុងព្រះពុទ្ធសាសនា

❖ *បុណ្យវិសាខបូជាធ្វើឡើងដើម្បីរំឭកដល់ថ្ងៃនក្ខត្តឫក្សទាំង ៧ យ៉ាង:*

*១.ដើម្បីរំឭកដល់ថ្ងៃសុមេធបណ្ឌិតទទួលពុទ្ធព្យាករណ៍*

*២.ដើម្បីរំឭកដល់ថ្ងៃព្រះបរមពោធិសត្វទ្រង់ប្រសូត*

*៣.ដើម្បីរំឭកដល់ថ្ងៃព្រះស្រីមហាពោធិព្រឹក្សដុះឡើងក្នុងលោក*

*៤.ដើម្បីរំឭកដល់ថ្ងៃព្រះបរមពោធិសត្វទ្រង់ត្រាស់ដឹង*

*៥.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាន*

*៦.ដើម្បីរំឭកដល់ថ្ងៃប្រល័យព្រះធាតុ*

*៧.ដើម្បីរំឭកដល់ថ្ងៃព្រះពុទ្ធគ្រប់ៗ ព្រះអង្គត្រាស់ដឹងឡើងក្នុងលោក នាថ្ងៃ១៥កើត ពេញបូណ៌មី ខែវិសាខ ។*

❖ *បុណ្យអាសាឡ្ហបូជាធ្វើឡើងដើម្បីរំឭកដល់ថ្ងៃនក្ខត្តឫក្សទាំង ៧យ៉ាង:*

*១.ដើម្បីរំឭកដល់ថ្ងៃព្រះបរមពោធិសត្វទ្រង់ចុះចាប់បដិសន្ធិ*

*២.ដើម្បីរំឭកដល់ថ្ងៃព្រះបរមពោធិសត្វទ្រង់ចេញសាងផ្នួស*

*៣.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ*

*៤.ដើម្បីរំឭកដល់ថ្ងៃកំណើតព្រះសង្ឃ*

*៥.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធសម្តែងយមកប្បាដិហារិយ៍*

*៦.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុចូលវស្សា*

*៧.ដើម្បីរំឭកដល់ថ្ងៃប្រារព្ធបឋមសង្គាយនា នាថ្ងៃ១៥កើត ពេញបូណ៌មី ខែអាសាឍ ។*

❖ បុណ្យអស្សុជបូជាធ្វើឡើងដើម្បីរំឭកដល់ថ្ងៃនក្ខត្តឫក្សទាំង ៤ យ៉ាង:

១.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធយាងចុះចាកឋានតាវតឹង្ស

២.ដើម្បីរំឭកដល់ថ្ងៃព្រះអង្គទ្រង់ប្រកាសកិត្តិគុណព្រះសារីបុត្រ

៣.ដើម្បីរំឭកដល់ថ្ងៃព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុបវារណាចេញវស្សា

៤.ដើម្បីរំឭកដល់ថ្ងៃព្រះអង្គទ្រង់អនុញ្ញាតកឋិនត្ថារកិច្ច នាថ្ងៃ១៥កើត ពេញបូណ៌មី ខែអស្សុជ ។l

❖ បុណ្យកត្តិកបូជាធ្វើឡើងដើម្បីរំឭកដល់ថ្ងៃនក្ខត្តឫក្សទាំង ៤ យ៉ាង:

១.ដើម្បីរំឭកដល់ថ្ងៃព្រះបរមពោធិសត្វកើតជាទន្សាយបណ្ឌិត

២.ដើម្បីរំឭកដល់ថ្ងៃព្រះអង្គទ្រង់បញ្ជូនភិក្ខុសង្ឃចេញផ្សព្វផ្សាយ សាសនា

៣.ដើម្បីរំឭកដល់ថ្ងៃព្រះធម្មសេនាបតីសារីបុត្របរិនិព្វាន

៤.ដើម្បីរំឭកដល់ថ្ងៃអារាធនាព្រះសារីរិកធាតុទៅប្រតិស្ឋាននៅតម្ពបណ្ណិទ្វីប (កោះលង្កា) នាថ្ងៃ១៥កើត ពេញបូណ៌មីខែកត្តិក ។l

❖ បុណ្យមាឃបូជាធ្វើឡើងដើម្បីរំឭកដល់ថ្ងៃនក្ខត្តឫក្សទាំង ៥ យ៉ាង:

១.ដើម្បីរំឭកដល់ថ្ងៃព្រះធម្មសេនាបតីសារីបុត្រសម្រេចអរហត្តផល

២.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានតំណែងអគ្គសាវកដល់ព្រះធម្មសេនាបតីសារីបុត្រនិងព្រះមហាមោគ្គល្លាន

៣.ដើម្បីរំឭកដល់ថ្ងៃចតុរង្គសន្និបាត

៤.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងឱវាទបាដិមោក្ខ

*៥.ដើម្បីរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធទ្រង់ដាក់ព្រះជន្មាយុសង្ខារ នាថ្ងៃ ១៥កើត ពេញបូណ៌មី ខែមាឃ ៕*

*(សូមលោកអ្នកអានមើលសេចក្តីពិស្តារផង៍ចុះ)*

*(សៀវភៅ ថ្ងៃសំខាន់ក្នុងព្រះពុទ្ធសាសនា)*

## IX. មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធជាម្ចាស់

***ពាក្យមហាបុរិសលក្ខណៈ*** *ន, លក្ខណៈរបស់មហាបុរស គឺបុរស អស្ចារ្យក្នុងលោក មានលក្ខណៈ* ***៣២ប្រការ*** *មានទំនាយថា បើនៅជាគ្រហស្ថនឹងបានជាស្តេចចក្រពត្តិ, បើចេញបួសនឹងបានត្រាស់ ជា****ព្រះសម្មាសម្ពុទ្ធ****ពិតប្រាកដ, (មហាបុរិសលក្ខណៈ ៣២ ប្រការនោះ មាននិយាយក្នុង****លក្ខណសូត្រ*** *នៅក្នុង****គម្ពីរសុត្តន្តបិដក ទីឃនិកាយ បឋមភាគ*** *ព្រះត្រៃបិដក ខ្សែលេខ ១៩ និង****ព្រហ្មាយុសូត្រ*** *នៅក្នុង* ***គម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ*** *ព្រះត្រៃបិដកខ្សែលេខ២៥ ចាប់ពីទំព័រទី ២ ដល់ ៣៤) ។*

- *មហាបុរិសលក្ខណៈមាន៣២ប្រការគឺ:*

***១-សុបតិដ្ឋិតបាទោ*** *មានផ្ទៃព្រះបាទទាំងគូរាបស្មើគ្នា ។*

***២-ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ*** *ត្រង់ផ្ទៃព្រះបាទខាង ក្រោមទាំងគូ មានរូបកង់ចក្រ ប្រកបដោយកណ្តាប់នឹងដុំ ព្រមទាំងកាំ មួយពាន់ មានចន្លោះស្មើគ្នាគ្រប់អន្ទើ។*

***៣-អាយតបណ្ហិ*** *មានព្រះបណ្ហិ គឺកែងព្រះបាទវែង (បើចែក សរីរ*

*ប្បទេសត្រង់នោះជា ៤ភាគ, ២ភាគ ជាចុងព្រះបាទ, ១ ភាគ ជាព្រះបាទ, ១ ភាគទៀត ជាព្រះបណ្ហិ) ។*

***៤-ទីឃង្គុលិ*** *មានព្រះអង្គុលី គឺម្រាមព្រះហស្ត ម្រាមព្រះបាទវែងៗ ចំណែកម្រាមព្រះហស្តទាំង៤ វែងស្មើគ្នា, ម្រាមព្រះបាទទាំង៥វែងស្មើគ្នា, ម្រាមទាំងអស់ មូលត្រសូលរៀវល្អផូរផង់ដូចមនោសិលាដែលគេលាយប្រេងលញ់ ។*

***៥-មុទុតលុនហត្ថបាទោ*** *មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទទន់ល្មើយ (ដូចដុំសំឡីដែលគេថ្លេច១០០ដងហើយ) ។*

***៦-ជាលហត្ថបាទោ*** *មានព្រះហស្ត និងផ្ទៃព្រះបាទាប្រទាក់ដោយក្រឡា ដូចជាក្រឡាសំណាញ់ ។*

***៧-ឧស្សង្ខបាទោ*** *មានព្រះបាទដូចជាអណ្តែតឡើងទៅខាងលើហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ ។*

***៨-ឯណជង្ឃោ*** *មានព្រះជង្ឃា គឺស្មងវែងមូលត្រសូល ស្រដៀងនឹងស្មងសត្វទ្រាយ (ពុំនោះសោតស្រដៀងនឹងដង្ហើមស្រូវ) ។*

***៩-ឋិតកោ ច អនោនមនោ ឧភោហិ បាណិតលេហិ ជណ្ណុកានិ បរាមសតិ*** *កាលបើទ្រង់ឈរមិនឱនព្រះអង្គចុះ អាចស្ទាបព្រះជានុ គឺជង្គង់ដោយព្រះហស្តទាំងពីរបាន ។*

***១០-កោសោហិតវត្ថគុយ្ហោ*** *មានព្រះអង្គាវយវៈដែលគប្បីលាក់កំបាំងដោយ ស្ថិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គជាតនៃសត្វដំរីជាដើម) ។*

***១១-សុវណ្ណវណ្ណោ****មានព្រះឆវីវណ្ណ គឺពណ៌សម្បុរថ្ងៃ (លឿងភ្លឺ*

*អន្ទង់) ដូចជាសម្បុរនៃមាស ។*

***១២-សុខុមច្ឆវី*** *មានព្រះឆវី គឺពណ៌សម្បុរថ្ងៃស្រទន់ល្អិតផូរផង់ រលើងស្រិលរអិលធូលីធ្លាក់ប៉ះមិនជាប់ ។*

***១៣-ឯកេកលោមោ*** *មានព្រះលោមា គឺរោមក្នុងរណ្ដៅមួយៗមានតែមួយសរសៃ១ គ្រប់រណ្ដៅទាំងអស់ ។*

***១៤-ឧទ្ធគ្គលោមោ*** *មានព្រះលោមា ចុងងើងឡើងលើជាទក្ខិណាវដ្ដព័ទ្ធពេនទៅខាងស្ដាំ មានសម្បុរខៀវស្រស់ដូចជាផ្កាអញ្ចាន កួចមូលដូចជាកុណ្ឌល ។*

***១៥-ព្រហ្មុជុគតោ*** *មានកាយត្រង់ដូចជាកាយនៃព្រហ្ម ។*

***១៦-សត្តុស្សទោ*** *មានព្រះមំសៈ គឺសាច់៧អន្លើដោយបរិបូណ៌ (ព្រះមំសៈ៧ អន្លើនោះគឺ ត្រង់ខ្នងព្រះហស្ដទាំងពីរ, ខ្នងព្រះបាទទាំងពីរ, ព្រះមំសកូដ គឺ ចង្កួយស្មាទាំងពីរ និងត្រង់ព្រះខន្ធប្បទេស គឺត្រង់ក, សរីរប្បទេសទាំង៧អន្លើនេះ មានសាច់ឃើញកន្ទួកល្អឥតមានឃើញសរសៃតិចតួចឡើយ ។*

***១៧-សីហបុព្វឌ្ឍកាយោ*** *មានចំណែកខ្វះព្រះកាយខាងដើមស្រដៀងនឹងចំណែក កន្ទះកាយនៃរាជសីហ៍ (ត្រង់កន្លែងដែលគួរវែង គួរខ្លី គួរធាត់ គួរស្គម ឬក៏គួររៀវ គួរមូល ក៏វែង ខ្លី ធាត់ ស្គម ឬរៀវមូលសមឥតមានទ្ទង់)។*

***១៨-បិដ្ឋន្តរំសោ*** *មានព្រះបិដ្ឋិ គឺខ្នងពេញបរិបូណ៌ គឺថាសាច់ជាចន្លោះនៃស្មាបប្រចៀវទាំងពីរ រាបស្មើឥតមានចង្អូរផតខូងត្រង់កណ្ដាលឡើយ ។*

***១៩-និគ្រោធបរិមណ្ឌលោ*** មានទ្រង់ទ្រាយព្រះកាយប្រហែលនឹងបរិវេណមណ្ឌលនៃដើមជ្រៃ គឺមានព្រះកាយ និងព្យាមប្រវែងគ្នា (ដូចជាជ្រៃមានប្រវែងដើមនិងមែកមិនលើស មិនខ្វះហួសគ្នាប៉ុន្មានទេ) ។

***២០-សមវដ្តក្ខន្ធោ*** មានព្រះខន្ធប្បទេស គឺមូលសម ។

***២១-រសគ្គសគ្គី*** មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារក្រៃលែងសម្រាប់ទទួលនាំរសអាហារឱ្យជ្រាបផ្សព្វផ្សាយក្នុងកាយទាំងមូល បានឥតមានទើសទាក់ សូម្បីអាហារយ៉ាងតូចតិចប៉ុននឹងគ្រាប់ល្ង ១ ក៏អាចជ្រួតជ្រាបសព្វសព៌ាង្គកាយបាន ។

***២២-សីហហនុ*** មានព្រះហនុ គឺចង្កាសណ្ឋានស្រដៀងនឹងចង្កពជសីហ៍ (ពេញបរិបូណ៌ ប្រហែលដូចជាព្រះចន្ទត្រង់ថ្ងៃ១២កើត) ។

***២៣-ចត្តាឡីសទន្តោ*** មានព្រះទន្ត ៤០ គត់ គឺខាងលើ ២០ ខាងក្រោម ២០ ។

***២៤-សមទន្តោ*** មានព្រះទន្តរាបស្មើ (មិនប្រជ្រួស ឬច្រពើសខ្ពស់ទាបដូចជាធ្មេញនៃមនុស្សសាមញ្ញពួកខ្លះនោះឡើយ)។

***២៥-អវិរឡទន្តោ*** មានព្រះទន្តជិតស្និទ្ធល្អ ។

***២៦-សុសុក្កទាឋោ*** មានព្រះទាឋា គឺចង្កូម(ទាំង៤)សស្អាតភ្លឺរុងរឿង ដូចជាពន្លឺនៃផ្កាយព្រឹក ។

***២៧-បហូតជិវ្ហោ*** មានព្រះជីវ្ហា គឺអណ្តាតល្មមល្មៃ (ប្លែកជាងអណ្តាតនៃមនុស្ស ទាំងអស់ក្នុងលោក បើទ្រង់លៀនអណ្តាតចេញមកក្រៅអាចយកអណ្តាតគ្របបាំងថ្ងាសបាន) ។

***២៨-ព្រហ្មស្សរោ ករវិកភាណី*** មានព្រះសូរសៀង គឺសូរសព្ទ

*សំឡេងក្រាំងក្រឌី ដូចជាសំឡេងនៃព្រហ្ម, កាលបើបញ្ចេញវាចាលាន់ឮពីរោះដូចជាសំឡេងនៃសត្វករវិក ។*

***២៩-អភិនីលនេត្តោ*** *មានព្រះនេត្រខៀវស្រស់ (ត្រង់កន្លែងដែលត្រូវខៀវ ក៏ខៀវស្រស់ដូចជាផ្កាត្រកៀត ឬផ្កាកណ្ដៀង, ត្រង់កន្លែងដែលគួរលឿង ក៏លឿងដូចជាផ្កាកណ្ណិកា, ត្រង់កន្លែងដែលគួរក្រហម ក៏ក្រហមដូចជាផ្កាចារ, ហើយត្រង់កន្លែងដែលគួរស ក៏សថ្លាត្រចះត្រចង់ដូចផ្កាយព្រឹក, ត្រង់កន្លែងដែលគួរខ្មៅ ក៏ខ្មៅស្រស់ដូចផ្លែផ្តាំ) ។*

***៣០-គោបខុមោ*** *មានដួងព្រះនេត្រ ស្រដៀងនឹងដួងភ្នែកនៃគោ គឺមានដួងនេត្រាទាំងពីរថ្វាយង់ សម្បុររាងក្រហមស្រដៀងនឹងដួងភ្នែកនៃកូនគោដែលទើបនឹងសម្រាលមួយរំពេចនោះ ។*

***៣១-ឧណ្ណា ភមុកន្តរេ ជាតា*** *មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម) មានសម្បុរសក្បុសទន់ល្វន់ដូចជាសំឡី ។*

***៣២- ឧណ្ហិសសីលោ*** *មានព្រះសិរហាក់បីដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ រុងរឿងដូចជាព្រះមហាក្សត្រិយ៍ដែលទ្រង់នៅក្បាំងព្រះភ័ក្ត្រ ។ ន័យមួយទៀត ថាមូលបរិបូណ៌ល្អដូចជាមកុដ ឬមូលហាក់ដូចជាវត្ថុដែលគេក្រឡឹងហើយយកមកតម្កល់ ពុំនោះសោតមូលហាក់ដូចជាពពុះទឹកដែលប៉ោងឡើង ៕*

*(សទ្ទានុក្រមព្រះពុទ្ធសាសនា)*

## X. រូបមង្គល ១០៨ ក្នុងស្នាមព្រះពុទ្ធបាទ

១. *រូបលំពែង*

២. *រូបផ្ទះកំពូល*

៣. *រូបផ្កាចន្ទ*

៤. *រូបសវត្ថិក: គឺរូបស្នាមកាកបាទទាញទៅមុខខាងស្ដាំ*

៥. *រូបផ្កាឈើក្រងលើសីស:*

៦. *រូបថាសដាក់គ្រឿងសំណែន*

៧. *រូបតាំងមាស*

៨. *រូបកង្វេរដំរី*

៩. *រូបប្រាសាទ*

១០. *រូបសសរបង្គោល*

១១. *រូបស្វេតច្ឆត្រ*

១២. *រូបព្រះខ័ន*

១៣. *រូបផ្ចិតស្លឹកត្នោត*

១៤. *រូបផ្ចិតកន្ទុយក្ងោក*

១៥. *រូបក្បាំង*

១៦. *រូបបាត្រ*

១៧. *រូបកែវមណី*

១៨. *រូបក្លងផ្កាម្ទិះ*

១៩. *រូបព្រលឹតខៀវ*

២០. *រូបព្រលឹតក្រហម*

២១. រូបព្រលឹតស

២២. រូបផ្កាឈូកក្រហម

២៣. រូបផ្កាឈូកស

២៤. រូបឆ្នាំងដាក់ទឹកពេញ

២៥. រូបថាសដាក់ទឹកពេញ

២៦. រូបមហាសមុទ្រ

២៧. រូបភ្នំចក្កវាឡ

២៨. រូបភ្នំហិមពាន្ត តាំងនៅក្នុងជម្ពូទ្វីប

២៩. រូបភ្នំសិនេរុ

៣០. រូបព្រះអាទិត្យ

៣១. រូបព្រះចន្ទ

៣២. រូបផ្កាយនក្ខត្តឫក្ស

៣៣. រូបជម្ពូទ្វីប

៣៤. រូបបុព្វវិទេហទ្វីប

៣៥. រូបអបរគោយានទ្វីប

៣៦. រូបឧត្តរកុរុទ្វីប

៣៧. រូបព្រះចៅចក្រពត្តិ និងរូបបរិវារ

៣៨. រូបស័ង្ខសវិលទៅខាងស្តាំ

៣៩. រូបត្រីមាសមួយគូ

៤០. រូបកងចក្រ

៤១. រូបស្ទឹងធំ ទី ១

៤២. រូបស្ទឹងធំ ទី ២

៤៣. រូបស្ទឹងធំ ទី ៣

៤៤. រូបស្ទឹងធំ ទី ៤

៤៥. រូបស្ទឹងធំ ទី ៥

៤៦. រូបស្ទឹងធំ ទី ៦

៤៧. រូបស្ទឹងធំ ទី ៧

៤៨. រូបភ្នំយុគន្ធរ

៤៩. រូបភ្នំឥសិន្ធរ

៥០. រូបភ្នំករវិក

៥១. រូបភ្នំសុទស្សន

៥២. រូបភ្នំនេមិន្ធរ

៥៣. រូបភ្នំវិន្តក

៥៤. រូបភ្នំអស្សកណ្ណ

៥៥. រូបស្រះអនោតត្ត

៥៦. រូបស្រះកណ្ណមុណ្ឌ:

៤៧. រូបស្រះរថការៈ

៥៨. រូបស្រះឆទ្ទន្ត

៥៩. រូបស្រះកុណាលៈ

៦០. រូបស្រះមណ្ឌាកិនី

៦១. រូបស្រះសីហប្បបាតៈ

៦២.រូបស្តេចគ្រុឌ

៦៣. រូបក្រពើ

៦៤. រូបទង់ជ័យ

៦៥. រូបទង់សំពត់

៦៦. រូបវហ៍កែវ (ត្រៃស្នែង)

៦៧. រូបផ្ចិតមាស

៦៨. រូបក្អំកែលាស

៦៩. រូបស្ដេចរាជសីហ៍

៧០. រូបស្ដេចខ្លាធំ

៧១. រូបស្ដេចសេះវលាហកៈ

៧២. រូបស្ដេចដំរីឧបោសថ

៧៣. រូបស្ដេចនាគវាសុកី

៧៤. រូបស្ដេចហង្ស

៧៥. រូបស្ដេចគោឧសភ

៧៦. រូបស្ដេចដំរីឯរាវ័ណ

៧៧. រូបមករមាស (ដូចនាគ តែមានជើង)

៧៨. រូបសំពៅមាសមុខបួន

៧៩. រូបមេគោដោះ

៨០. រូបកិន្នរ

៨១. រូបកិន្នរី

៨២. រូបសត្វករវិក

៨៣. រូបស្ដេចក្ងោក

៨៤. រូបស្តេចក្រៀល
៨៥. រូបស្តេចសត្វចាក្រពាក
៨៦. រូបស្តេចសត្វព្រហីត(សត្វជីវញ្ជីវ)
៨៧. រូបស្ថានសួគ៌ជាន់ចាតុម្មហារាជិកា
៨៨. រូបស្ថានសួគ៌ជាន់តាវត្តិង្ស
៨៩. រូបស្ថានសួគ៌ជាន់យាមា
៩០. រូបស្ថានសួគ៌ជាន់តុសិត
៩១. រូបស្ថានសួគ៌ជាន់និម្មានរតី
៩២. រូបស្ថានសួគ៌ជាន់បរិនិម្មិតវសវតី
៩៣. រូបស្ថានព្រហ្មលោកជាន់បារិសជ្ជា
៩៤. រូបស្ថានព្រហ្មលោកជាន់បុរោហិតា
៩៥. រូបស្ថានព្រហ្មលោកជាន់មហាព្រហ្មា
៩៦. រូបស្ថានព្រហ្មលោកជាន់បរិត្តាភា
៩៧. រូបស្ថានព្រហ្មលោកជាន់អប្បមាណាភា
៩៨. រូបស្ថានព្រហ្មលោកជាន់អាភស្សរា
៩៩. រូបស្ថានព្រហ្មលោកជាន់បរិត្តសុភា
១០០. រូបស្ថានព្រហ្មលោកជាន់អប្បមាណសុភា
១០១. រូបស្ថានព្រហ្មលោកជាន់សុភកិណ្ហា
១០២. រូបស្ថានព្រហ្មលោកជាន់វេហប្ផលា
១០៣. រូបស្ថានព្រហ្មលោកជាន់អសញ្ញីសត្តា
១០៤.រូបស្ថានព្រហ្មលោកជាន់អវិហា

១០៥. រូបស្ថានព្រហ្មលោកជាន់អតប្បា

១០៦.រូបស្ថានព្រហ្មលោកជាន់សុទស្សា

១០៧.រូបស្ថានព្រហ្មលោកជាន់សុទស្សី

១០៨.រូបស្ថានព្រហ្មលោកជាន់អកនិដ្ឋា។

❖ សៀវភៅ ស្នាមព្រះបាទនៃព្រះពុទ្ធ ឯស្ទឹងនទម្មទា និងសច្ចៈ ពន្ធបព័ត និងមង្គល១០៨ ក្នុងស្នាមព្រះពុទ្ធបាទ (សូមមើលសេចក្ដីពិស្ដារក្នុងសៀវភៅនោះទៀតផង)។

## XI. ព្រះសទ្ធម្មជោតិក ធម្មាចរិយពោលសរសើរគម្ពីរផ្សេង ៗ

....កាលនឹងធ្វើការសិក្សាស្រាវជ្រាវស្វែងរកចំណេះដឹងផ្លូវ ធម៌ក្នុងព្រះពុទ្ធសាសនាឱ្យបានទូលំទូលាយ និងត្រឹមត្រូវនោះ បើសិក្សាស្រាវជ្រាវដោយចំពោះតែក្នុងព្រះបាលី គឺព្រះត្រៃបិដកតែម្យ៉ាង មិនអាចបានទទួលនូវចំណេះដឹងឱ្យទូលំទូលាយឡើយ ចាំបាច់ត្រូវសិក្សាទាំង**ព្រះត្រៃបិដក អដ្ឋកថា និងដីកា**ព្រមទាំងស្ដាប់ការអធិប្បាយអំពីអាចារ្យ ដែលមានចំណេះល្អ ទើបជួយឧបការៈឱ្យមានចំណេះដឹងត្រឹមត្រូវទូលំទូលាយបាន ។ ហេតុដែលពោលយ៉ាងនេះ ក៏ព្រោះថា **ព្រះបាលី** គឺព្រះត្រៃបិដកនោះ សម្ដែងទុកតែគោលសំខាន់ៗ មិនបានចង្អុលបង្ហាញ និងអធិប្បាយឱ្យទូលំទូលាយជាក់ច្បាស់ (អាចនឹងមានន័យផ្សេងទៀត បានផង) **ព្រះដីកាចារ្យ** ក៏បានអធិប្បាយសេចក្ដីក្នុង**អដ្ឋកថា**ដែលមិន ទាន់បានអធិប្បាយ ចង្អុលបង្ហាញឱ្យមានសេចក្ដីទូលំទូលាយថែមទៀត និងជាក់ច្បាស់ ។ ម្យ៉ាងទៀត **ព្រះអដ្ឋកថាចារ្យនិងព្រះដីកាចារ្យ** ទាំងពីរពួក

នេះ កាលនឹងពោលក្នុងផ្នែកចំណេះដឹងក្តី ក្នុងផ្នែកនៃការ បដិបត្តិក្តី និង និស្ស័យចិត្តក្តី ក៏ល្អត្រឹមត្រូវទាំងអស់ មិនដូចនឹងពួក យើង ក្នុងកាល បច្ចុប្បន្ននេះទេ ពោលគឺលោកជាអ្នកមានចំណេះដឹង ល្អចាក់ ធ្លុះក្នុងអត្ថ របស់**ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម** បាលី វេយ្យាករណ៍ ការប្រព្រឹត្ត ខាងផ្លូវកាយ ផ្លូវវាចា ក៏តាំងនៅក្នុងសិក្ខាបទ បានយ៉ាងល្អ ត្រឹមត្រូវជា **សុប្បដិបន្នៈ ឧជុបដិបន្នៈ ញាយបដិប្បន្នៈ សាមីចិប្បដិបន្នៈ** ជាទីគោរព ជាទីរាប់អាន ជាទីជ្រះថ្លា ជាទីកើតសទ្ធា ដល់ពុទ្ធសាស និកជនទាំងឡាយ ។ ចិត្តក៏ប្រសើរ មិនតាំងនៅក្នុង អំណាចនៃការ បង្គាប់របស់**តណ្ហា មានៈ ទិដ្ឋិ ឥស្សា និងមច្ឆរិយៈ**ដោយប្រការណា មួយឡើយ ទាំងនេះក៏ព្រោះ ព្រះអាចារ្យរូបខ្លះ ជា **ព្រះអរិយបុគ្គល** ខ្លះទៀតទាំងជា**ព្រះអរិយបុគ្គល និងជាឈានលាភី អភិញ្ញាលាភី ។ ព្រះអាចារ្យរូបខ្លះ** សូម្បីមិនមែនជា ព្រះអរិយបុគ្គល មិនមែនជា**ឈាន លាភី អភិញ្ញាលាភី**ក៏ពិត ប៉ុន្តែចិត្ត នោះវិញ ក៏បានតាំងនៅស៊ុបក្នុង**សីល សមាធិ បញ្ញា**ដែលជាផ្នែកបរិយត្តិ តែម្យ៉ាងបានយ៉ាងបរិបូណ៌ មិនបានហូរចុះក្នុងផ្លូវលោក និងកាមគុណ អារម្មណ៍ដោយប្រការណា មួយឡើយ ។ ដូច្នេះ **អដ្ឋកថាបករណ៍ និង ដីកាបករណ៍** ទាំងនោះ ទើបមានអត្ថដែលប្រកបដោយ ដោយចំណេះ គួរជឿ គួរជ្រះថ្លា ជា ចំណេះដឹងដែលគួរសិក្សាយ៉ាងក្រៃលែង គ្មានអត្ថ ដែលត្រូវ កែប្រែឱ្យ ធូន់ធូរដូចគ្នាដែលនឹងអាចពោលបានថា គ្មានចំណុច ខ្វះខាត ។ កាលបើប្រៀបធៀប ជាមួយសៀវភៅសិក្សាចំណេះដឹងផ្លូវ លោកដែល កំពុងបានជាទីនិយមពេញចិត្ត គួរជឿ គួរទុក ចិត្តបាន ក៏ មាន ការកែ ប្រែថែមថយជារឿយ ៗ មិនឈប់ឈរ អាស្រ័យពួកសាស្ត្រា

ចារឲ្យថ្មី ៗ នឹង ធ្វើការស្រាវជ្រាវឃើញ និងកំណត់ឡើងប៉ុណ្ណោះ ៕
(បរមត្ថជោតិកមហាអភិធម្មត្ថសង្គហដីកា បរិច្ឆេទទី៥ ភាគ២ ទំព័រ ៣០៨-៣០៩)

## XII. បត្តិទានគាថា យាទេវតា

(គាថាផ្សាយកុសល)

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ ត ហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថវោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។
ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ
ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ ច អម្ហេ
រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ
សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ។

ប្រែថា: **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយ មានប្រក្រតីនៅក្នុងទីវត្ត ជាទីនៅនៃសង្ឃ ព្វដ៏ខឿនព្រះស្តូប[១] ព្វដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ

**តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី** ឧបាសិកា ឧបាសកនិងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទានព្រមទាំង អារាមិកជន គឺញោមវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នក និគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា** មួយវិញទៀតសត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែល ជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈ កំណើតក្តី **និយានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជា និយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលដ៏យូរអង្វែងតទៅ) **សង្ឃោ ហោតុ សមគ្គោ វ** សូមព្រះសង្ឃ ព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តី

---

(១).ខ្មែរច្រើនហៅក្លាយជា សថូប។

ចម្រើន ផង ដើម្បីសេចក្ដីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងខ្ញុំទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បា បុណោយ្យាម ធម្មារិយប្បវេទិ តេ** សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្ដីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោក សម្ដែងហើយ៕

(សៀវភៅ គិហិបដិបត្តិ សង្ខេប ទំព័រ ៣៧-៤០)

## XIII.**អនុមោទនារក្ខាយាចនគាថា** (**អាកាសដ្ឋា**)

*អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា*
*បុញ្ញំ នោ(១) អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។*

ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្ដី ដែលឋិតលើផែនដីក្ដី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្ដី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនាឱ្យឋិតថេរ និងឱ្យរុងរឿងយូរអង្វែងទៅ។

*អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា*
*បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។*

ទេវតាទាំងឡាយដែលឋិតឰដ៏អាកាសក្ដី ដែលឋិតលើផែនដីក្ដី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្ដី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះរាជាទាំងឡាយឱ្យឋិតក្នុងរាជ្យ និងឱ្យមានជ័យជាយូរអង្វែងទៅ ។

---

(១).បុញ្ញំ នោ បើសូត្រម្នាក់ឯងត្រូវថា បុញ្ញំ មេ ប្រែថា បុណ្យរបស់ខ្ញុំ។

*អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា*

*បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។*

*ទេវតាទាំងឡាយដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវពួកញាតិទាំងឡាយ (ឱ្យចម្រុងចម្រើន និងឱ្យសុខសាន្ត)ជាអង្វែងទៅ ។*

*អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា*

*បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។*

*ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ(ឱ្យចម្រុងចម្រើននិងឱ្យសុខសាន្ត)ជាអង្វែងទៅ។*

*អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា*

*បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ទោ សទា ។*

*ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យចម្រុងចម្រើន និងឱ្យសុខសាន្ត) យូរយារគ្រប់កាលទាំងពួង៕*

*(ប្រជុំគាណាវារៈ ផ្សាយចេញពីវត្តវិសុទ្ធិមគ្គ បាលី ប្រែ ទំព័រ៤៧-៤៨)*

## XIV. **អវសានកថា**

ខ្ញុំព្រះករុណាអាត្មាភាព ជាអ្នករៀបរៀងសៀវភៅនេះឡើង ដើម្បីប្រយោជន៍ដល់សាធុសប្បុរសប្រុសស្រី ដែលជាអ្នកប្រាថ្នាបុណ្យកុសលទាំងឡាយ ។ ក៏ជាផែនទីសម្រាប់ប្រាប់ផ្លូវ ដើម្បីជាធម្មយាត្រាបំពេញបុណ្យផ្សេង ៗ ផងដែរ ។

លោកអ្នកអានច្បាស់នឹងជួបសេចក្តីសង្ខេបមិនខាន ក្នុងសៀវភៅមួយនេះ ពីព្រោះថា ខ្ញុំករុណាមិនចង់សរសេរសង្ខេបទេ ! ដោយសារតែខ្វះឯសារមិនគ្រប់គ្រាន់ជាដើម, ទោះបីជាយ៉ាងណាក៏លោកអ្នកអានបានចំណេះដឹងខ្វះ ៗសម្រាប់សិក្សាមិនខាន ។

ខ្ញុំព្រះករុណាសូមលើកទឹកចិត្ត ឱ្យព្រះករុណាលោកម្ចាស់ ឱ្យមានការសរសេរប្រវត្តិសង្ខេប ឬពិស្តារ នៅលើថ្មម៉ាបក្តី ឬនៅលើផ្ទាំងសិលាក្តី តម្កល់កន្លែងព្រះចេតិយនោះ ៗ ដើម្បីទុកជាភ័ស្តុតាង ឱ្យកូនខ្មែរជំនាន់នេះ និងជំនាន់ក្រោយ ងាយស្រួលក្នុងការសិក្សា ។

ព្រះចេតិយសព្វថ្ងៃយើងនេះ មិនសូវមានគុណភាពប៉ុន្មានទេ ឆាប់នឹងខូចខាត់ណាស់ ពីព្រោះខ្វះការត្រួតពិនិត្យ ។ រីឯព្រះចេតិយបុរាណវិញ ធ្វើតាមព្រះអរហន្តឱ្យជាពាងដូចពុំទូកស្រូវ ដូចកណ្តឹង ដូចសារដីជាដើម សំណង់ទាំងអស់នេះ ធ្វើតាមក្បួនខ្នាត មានការត្រួតពិនិត្យត្រឹមត្រូវ ទើបឈរនៅមកដល់សត្វថ្ងៃយើងនេះបាន ។

រឿងសំខាន់មួយទៀតនោះ គឺកុំឱ្យញាតិញោមធ្វើចេតិយ ដាក់ធាតុរបស់ខ្លួន ជិតនិងព្រះចេតិយតម្កល់ព្រះសារីរិកធាតុឡើយ (បើធ្វើឱ្យ មានរបៀបរាបរយ) ពីព្រោះខ្វះការគោរព និងគ្មានសណ្តាប់ធ្នាប់ ជាពិសេស

នោះអាក្រក់មើលតែម្តង។

ជាចុងក្រោយ ខ្ញុំព្រះករុណា ក៏សូមខន្តីអភ័យអត់ទោសរាល់កុំហុសទាំងឡាយ ដែលកើតដោយចេតនាក្តី និងអចេតនាក្តី ។ បុណ្យទាំងឡាយដែលកើតពីការធ្វើសៀវភៅនេះទាំងថ្ងៃទាំងយប់ដោយកម្លាំងកាយ វាចា និងចិត្ត សូមប្រគេនករុណាលោកម្ចាស់ និងជូនសាធុសប្បុរសប្រុសស្រីទាំងឡាយ សូមបានជាបច្ច័យរួចចាកទុក្ខកុំបីខានឡើយ ៕

សូមអនុមោទនាបុណ្យ!!!

ថ្ងៃ ពុធ ១២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២៣

# XV.កំណាព្យ វត្តគិរីរម្យចាស់

បទពាក្យ ៨

រុក្ខជាតិលូតលាស់ផ្តល់សម្រស់ល្អ ក្រែមម្លប់ផាត់ពណ៌លម្អកក្រា
ធ្វើបុណ្យដាក់បាត្រសម្អាតចិន្តា ខិតខំសិក្សាប្រាជ្ញាខ្ពង់ខ្ពស់។
អារាមផ្លូវផង់ព្រះសង្ឃថ្លៃថ្លា គណៈកម្មការរក្សាកេរ្តិ៍ឈ្មោះ
មានប្រជាប្រិយសម្តីពីរោះ ខន្តីខ្ពង់ខ្ពស់ព្រោះមានអំណត់។
គិតគូរស្រុះស្រួលសម្រួលចិត្តគ្នា ខិតខំពុះពារការងារហ្មត់ចត់
គិរីរម្យចាស់ផ្លាស់ព្រះនាមវត្ត ឈ្មោះថ្មីប្រាកដជាវត្តមហាវ័ន។
កុដិរៀបជាជួរគួរឱ្យមនោរម្យ សង់តាមជើងភ្នំជាជុំតាមជាន់
ទឹកចិត្តម្ចាស់ទានពុំមានអាក់អន់ បានកសាងទាន់ជំនាន់កុដិថ្មី។
ពេលមានទុក្ខសោកមកគិរីរម្យ ឮសូររៃយំបន្ទុំស្មារតី
ថ្វាយបង្គំព្រះគោតមចេតិយ ទទួលពរជ័យព្រះសង្ឃអប់រំ។
វត្តមហាវ័នគយគន់ចាំញាតិ ក្នុងឧទ្យានជាតិភ្នំគិរីរម្យ
ក្នុងស្រុកភ្នំស្រួចសំបូរដោយភ្នំ កំពង់ស្ពឺម្ដុំក្នុងឃុំចំបក់ ។
ដើមស្រល់តូចធំដុះជុំអមផ្លូវ ស្លឹកស្រល់មើលទៅដូចសរសៃសក់
ទឹកជ្រោះធំតូចថ្លាដូចកញ្ចក់ ស្រល់ត្រូវខ្យល់បក់ដូចសក់សាយទៅ។
ឯអាកាសធាតុខួបប្រាំងវស្សា ពុំមានពេលណាថាជាខែក្តៅ
ត្រជាក់រហូតរៀងរាល់រដូវ អធ្រាត្រយប់ជ្រៅត្រជាក់ស្លឹកដៃ ។
ព្រះសង្ឃច្រើនអង្គគង់ចាំវស្សា បានឃើញពេលណាជ្រះថ្លាពេកក្រៃ
ល្បីល្បាញសាសនាដោយសារស្នាដៃ សង្ឃមានវិន័យគណៈកម្មការល្អ ។
ព្រះសង្ឃជាគ្រូគិតគូរមេរៀន វិន័យដែលមានបង្រៀនបន្ត

មានថ្នាក់មធ្យមឧត្តមបវរ វិន័យមាំល្អទ្រព្រះសាសនា ។
សូមបានសម្រេចដូចក្តីប្រាថ្នា កើតជាតិណាៗ បានសុខសិរី ។
សូមប្រគេនបុណ្យព្រះសង្ឃគ្រប់អង្គ ដែលខំផ្ចិតផ្ចង់អស់ពីហឫទ័យ
រក្សាអារាមតាមធម៌វិន័យ សូមបានជោគជ័យគ្រប់អង្គទាំងអស់ ៕

សូមអនុមោទនា !

ដោយ គុយ សុធន
(សៀវភៅ ជំនួយសតិភាគទី ២០, ទំព័រ ១០៨)

## * ឱគីរីរម្យជំរំចិត្ត *

*ឱគិរីរម្យជំរំចិត្ត រូបខ្ញុំស្នេហ៍ស្និទ្ធនឹងអ្នកណាស់
តាំងពីបានជួបចិត្តស្រឡះ នៅក្នុងឱកាសបុណ្យមួយគ្រា។
*មានខ្យល់ត្រជាក់ប៉ះកាយា ក្រោមដើមរុក្ខាផងនានា
ដុះសងខាងផ្លូវជាប់តគ្នា តាមដងមាគ៌ាចូលអារាម ។
*ព្រះសង្ឃសាវ័កអង្គសមណា ស្ងប់ស្ងាត់សិក្សាសិក្ខាកាម ខំប្រឹង
ប្រព្រឹត្តប្រតិបត្តិតាម ចង់ចេញចាកកាមផុតទុក្ខភ័យ។
*គោតមចេតីយខ្ពស់ត្រដែន ហាក់ដូចអណ្តែតនភាល័យ បរិស័ទ
ទាំងឡាយតែងលកលៃ បង្អោនហទ័យថ្វាយវន្ទា ។
*ហេតុនេះសូមចិត្តអ្នកមេត្តា ចូលអារាមាព្រះសង្ឃា
គោរពកោតក្រែងព្រះភគវា កុំសាងវេរានឹងត្រៃរ័ត្ន ។
*ព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ អ្នកត្រូវឱនអង្គដោយហ្មត់ចត់
ធ្វើអ្វីគ្រប់យ៉ាងឱ្យប្រាកដ ឱ្យមានបែបបទធម៌វិន័យ ។

*កុំឡើយប្រមាទធ្វើបំពាន ដោយមិនខ្មាសអៀនឥតគិតអ្វី
ឃើញតែលាភយសកាមលោកីយ៍ នាំធ្លាក់អវិចីទុក្ខខ្លោចផ្សា ។
*បើអ្នកមិនចង់ធ្លាក់អបាយ ចង់សុខសប្បាយផុតទុក្ខា
ត្រូវសាងសន្សំនូវកុសលា នឹងបានផលាសោយសុខស្ងប់ ៕

*(និពន្ធដោយ លោកម្ចាស់គ្រូ សុវណ្ណជោតោ គួង សុវណ្ណ)*

# XVI.**នាមលោកអ្នកសប្បុរសចូលរួមបោះពុម្ពសៀវភៅមានដូចតទៅ**

*១.ព្រះគ្រូចៅអធិការវត្តក្រូច* ***សើច*** *៣០ម៉ឺនរៀល*

*២.លោកម្ចាស់តា* ***មៀច ម៉ាន*** *២០ម៉ឺនរៀល*

*៣.លោកម្ចាស់* ***ភិក្ខុ សុកក្រ្ត*** *បណ្ឌិតោ ២ម៉ឺនរៀល*

*៤.ញាតិញោមពុទ្ធបរិស័ទ ភូមិ ទ្រា ១២ម៉ឺនរៀល*

*៥.ភន្តេ* ***រតនា*** *១០ម៉ឺនរៀល*

*៦.ពុទ្ធបរិស័ទចំណុះជើងវត្តក្រូច* ***សើច*** *៣៦ ម៉ឺនរៀល*

*៧.ឧបាសក* ***ហង្ស ជួន*** *និងឧបាសិកា* ***ង៉ោ ស៊ឹងីម*** *១០ម៉ឺនរៀល*

*៨.ឧបាសិកា* ***លក្ខិណា កូនខ្មែរ*** *៣ម៉ឺនរៀល*

*៩.ញាតិញោម* ***ផ្សារកំពង់កន្ទួត*** *១៣ ម៉ឺនរៀល*

*១០.ឧបាសក* ***អ៊ូច សារឿន*** *ឧបាសិកា* ***តឹក ចន្ថា*** *២ម៉ឺនរៀល*

*១១.****ម៉ាក់ មីងយ៉ុង*** *និងក្រុមគ្រួសារ ២ម៉ឺនរៀល*

*១២.****ស្រីពៅ*** *ព្រមទាំងក្រុមគ្រួសារ ២ម៉ឺនរៀល*

*១៣.****និត ស៊ីណា*** *និង* ***មាន ស៊ីវថេង*** *៣ម៉ឺរៀល*

# ព្រះចង្កូមកែវទាំង៤ ព្រះអង្គបច្ចុប្បន្នស្ថិតនៅ





**ព្រះចង្កូមកែវ ស្ដាំខាងលើ**
(បច្ចុប្បន្នប្រតិស្ឋាននៅនាឋានតាវត្តឹង្ស)

**ព្រះចង្កូមកែវ ឆ្វេងខាងលើ**
(បច្ចុប្បន្នប្រតិស្ឋាននៅទីក្រុងប៉េកាំងប្រទេសចិន)





**ព្រះចង្កូមកែវ ឆ្វេងខាងក្រោម**
(បច្ចុប្បន្នប្រតិស្ឋាននៅភពនាគ)

**ព្រះចង្កូមកែវ ស្ដាំខាងក្រោម**
(បច្ចុប្បន្នប្រតិស្ឋាននៅទីក្រុងខេនឌីប្រទេសស្រីលង្កា)



# ព្រះគាថា

និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ
ចតុរាសីតិសហស្ស ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។

កាលព្រះសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វាន ទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ម៉ឺន ៤ពាន់ធម្មក្ខន្ធ ដែលព្រះអង្គ ទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វទាំងឡាយ ៕

(សៀវភៅប្រជុំភាណវារ ទំព័រ ៤២១-៤២២)